# គោលជំនឿគ្រីស្ទាន

## មូលដ្ឋានគ្រឹះ២០ចំនុចដែលយើងគួរយល់ដឹង

20

twenty basics every christian should know

# CHRISTIAN BELIEFS

wayne a. GRUDEM

*edited by*
elliot GRUDEM

**Originally published in the U.S.A. under the title: *Christian Beliefs***

**Copyright © 2005 by Wayne Grudem**

**Translation copyright © April 2011 by Wayne A. Grudem; Elliot Grudem**

**Translated by Uch Akphirin and Bill Hale**

**Published by permission of Zondervan, Grand Rapids, Michigan**

កម្មសិទ្ធិរបស់:

**ព្រះវិហារមេត្តាករុណាព្រែកអំបិល**

បកប្រែដោយ:

**លោក អ៊ុច អភិរិន**

**លោក ហេល ប៊ៀល**

ផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធខ្មែរដោយ:

**លោកគ្រូគង្វាល ឈួន ឆេង**

**លោកគ្រូ ឯម វណ្ណាថន**

រក្សាសិទ្ធិគ្រប់យ៉ាង

Copyright 2011

# Contact Information:

www.thechurchofmercy.org
info@thechurchofmercy.org

Cambodia:

Pastor Chheng Nuon
mmcchheng@yahoo.com
(012) 662-710

USA:

Pastor Bill Hale
hale.bill@live.com
(972) 424-4271

**Church of Mercy Books**
Street 21 Prek Talay
Prek Ambel, Saang
Kandal, Cambodia

**With thanks to God for the life and memory of**

**Rachael R. Freeman Grudem**

**Born June 2, 1982**

**Married to Alexander Grudem April 3, 2005**

**Died July 9, 2005**

The Lord gave, and the Lord has taken away; blessed be the name of the Lord.”

(Job 1:21)

And we know that for those who love God all things work together for good, for those who are called according to his purpose.

(Romans 8:28)

‟He will wipe away every tear from their eyes, and death shall be no more, neither shall there be mourning, nor crying, nor pain anymore, for the former things have passed away.”

(Revelation 21:4)

# សារបាន


| | | | |
|---|---|---|---|
| **មុខកថា** | | | ១១ |
| **ជំពូក ១** | ៖ | តើព្រះគម្ពីរជាអ្វី ? | ១៥ |
| **ជំពូក ២** | ៖ | តើព្រះមានលក្ខណៈដូចម្ដេចខ្លះ ? | ៣០ |
| **ជំពូក ៣** | ៖ | តើអ្វីទៅជាព្រះត្រៃឯក ? | ៦២ |
| **ជំពូក ៤** | ៖ | តើអ្វីទៅជាការបង្កើត ? | ៧២ |
| **ជំពូក ៥** | ៖ | តើអ្វីទៅជាសេចក្ដីអធិស្ឋាន ? | ៨១ |
| **ជំពូក ៦** | ៖ | តើអ្វីទៅជាពួកទេវតា អារក្សសាតាំង និង វិញ្ញាណអាក្រក់ ? | ៩២ |
| **ជំពូក ៧** | ៖ | តើមនុស្សជាអ្វី ? | ១០១ |
| **ជំពូក ៨** | ៖ | តើអំពើបាបជាអ្វី ? | ១០៩ |
| **ជំពូក ៩** | ៖ | តើព្រះយេស៊ូវគ្រីស្ទជានរណា ? | ១១៩ |
| **ជំពូក ១០** | ៖ | តើអ្វីជាការប្រោសលោះ ? | ១២៨ |
| **ជំពូក ១១** | ៖ | តើអ្វីជាសេចក្ដីរស់ឡើងវិញ ? | ១៣៧ |
| **ជំពូក ១២** | ៖ | តើអ្វីទៅជាការជ្រើសរើស ? | ១៤៩ |
| **ជំពូក ១៣** | ៖ | តើការក្លាយទៅជាគ្រីស្ទបរិស័ទម្នាក់មាន អត្ថន័យយ៉ាងដូចម្ដេច ? | ១៦៥ |

**ជំពូក ១៤** ៖ តើអ្វីទៅជាការរាប់ជាសុចរិតនិងការយក
មកធ្វើជាកូនចិញ្ចឹម ? ១៧៤

**ជំពូក ១៥** ៖ តើអ្វីទៅជាដំណើរការនៃសេចក្ដីបរិសុទ្ធ
និង សេចក្ដីខ្ជាប់ខ្ជួន ? ១៨៣

**ជំពូក ១៦** ៖ តើអ្វីទៅជាសេចក្ដីស្លាប់ ? ២០១

**ជំពូក ១៧** ៖ តើក្រុមជំនុំជាអ្វី ? ២១២

**ជំពូក ១៨** ៖ តើនឹងមានអ្វីកើតឡើង ពេលព្រះគ្រីស្ទ
យាងត្រឡប់មកវិញ ? ២២៥

**ជំពូក ១៩** ៖ តើអ្វីទៅជាការជំនុំជំរះចុងក្រោយ ? ២៤២

**ជំពូក ២០** ៖ តើស្ថានសួគ៌ជាអ្វី ? ២៥២

# បុព្វកថា

សៀវភៅនេះ គឺជាការសង្ខេបមួយ នៃសេចក្តីបង្រៀនជាមូលដ្ឋានទាំង២០ ដែលគ្រីស្ទបរិស័ទគ្រប់រូបគួរតែយល់ដឹង ។

សៀវភៅនេះ គឺជាការបង្រួមមួយនៃសៀវភៅគោលលទ្ធិព្រះគម្ពីរ (៥២៨ទំព័រ) របស់ខ្ញុំ ហើយសៀវភៅគោលលទ្ធិព្រះគម្ពីរនេះក៏ជាការបង្រួមមួយនៃសៀវភៅវិជ្ជាព្រះជាប្រព័ន្ធ (១២៩០ទំព័រ) កូនប្រុសរបស់ខ្ញុំឈ្មោះអិលលាត ប្រ៊ូដិម បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកវិជ្ជាព្រះពីមហាវិទ្យាល័យព្រះគម្ពីរកែទំរង់ នៅក្នុងទីក្រុង អ័រឡិនដូ រដ្ឋហ្វលរីដា ។ គាត់បានធ្វើការងារល្អក្នុងការបង្រួមការពិភាក្សាដ៏វែងឆ្ងាយ ឲ្យទៅជា ប្រយោគគន្លឹះមួយឬក៏ពីរ ហើយកែសំរួលពាក្យពេចន៍ ឲ្យកាន់តែមានការងាយយល់សំរាប់គ្រីស្ទបរិស័ទថ្មីៗ ។ បន្ទាប់មកខ្ញុំបានធ្វើការកែតំរូវបន្តិចបន្តួច ហើយទំនួលខុសត្រូវ ចំពោះការដាក់ពាក្យពេចន៍ចុងក្រោយ គឺខ្ញុំតែម្នាក់ឯងទេ ។ ខ្ញុំក៏ដឹងគុណសំរាប់ការងាររបស់ស៊្មីរ អ៊ែរិកសាន់ និង រ៉បប៊ើត ផូលេន ដែលគាត់ទាំងពីរនាក់ បានជួយពិនិត្យ ហើយឃ្រីសស៍ ដេវីសស៍ គាត់បានជួយរៀបចំលិបិក្រម ។

ខ្ញុំសង្ឃឹមថា សៀវភៅតូចខ្លីនេះ នឹងមានប្រយោជន៍ សំរាប់គ្រីស្ទបរិស័ទថ្មីៗ ថ្នាក់សិក្សារបស់សមាជិកថ្មីក្នុងក្រុមជំនុំ ហើយនិងសំរាប់ក្រុមសិក្សាព្រះគម្ពីរតាមផ្ទះ ហើយនិង ថ្នាក់សិក្សាថ្ងៃអាទិត្យ និងសំរាប់កុមារមានអាយុលើ ១៣ឆ្នាំ ។ វាក៏គួរមានអត្ថប្រយោជន៍សំរាប់អ្នកមិនជឿ ដែលចង់រៀនពីសេចក្តីបង្រៀនជាមូលដ្ឋានទាំងនេះផងដែរ ។ ជាញឹកញាប់ ខ្ញុំបានឮមតិពីរពីអ្នកដែលបានអាន

សៀវភៅ *វិជ្ជាព្រះជាប្រព័ន្ធ* ឬ *គោលលទ្ធិនៃព្រះគម្ពីរ* គឺទីមួយ "សូមអរគុណសំរាប់ការនិពន្ធសៀវភៅវិជ្ជាព្រះ ដែលបានធ្វើឲ្យខ្ញុំយល់" និងទីពីរ "សៀវភៅនេះបានជួយដល់ ជីវិតជាគ្រីស្ទបរិស័ទរបស់ខ្ញុំ" ។ យើងបានរក្សានូវខ្លឹមសារទាំងអស់នោះនៅក្នុងសៀវភៅតូចនេះដដែល ដូចជា៖ ភាពច្បាស់លាស់ ហើយនិងការប្រើជាប្រយោជន៍នៅក្នុងជីវិតរស់ ។

យើងបានផ្តោតសំខាន់ទៅលើព្រះគម្ពីរ ទុកជាប្រភពដើម សំរាប់អ្វីដែលគ្រីស្ទបរិស័ទជឿ ។ មានកន្លែងជាច្រើននៅក្នុងសៀវភៅនេះយើងបានបង្ហាញឈ្មោះខគម្ពីរ ព្រមទាំងព្រះបន្ទូលដកស្រង់ពីខគម្ពីរទាំងនោះដែរ ពីព្រោះព្រះបន្ទូលរបស់ព្រះគឺ "រស់នៅ ហើយពូកែផង ក៏មុតជាងដាវណាមានមុខពីរ ទាំងធ្លុះចូលទៅទាល់តែកាត់ព្រលឹង និង វិញ្ញាណ ហើយ សន្លាក់ និង ខួរឆ្អឹងដាច់ពីគ្នា ទាំងពិចារណាអស់ទាំងគំនិត ដែលចិត្តគិត ហើយ ដែលសំរេចដែរ" (ហេព្រើរ ៤:១២) ។ ព្រះបន្ទូលនៃព្រះគម្ពីរផ្តល់អាហារខាងព្រលឹងវិញ្ញាណ ដ្បិតសាវ័កប៉ុលបាននិយាយថា "អាចនឹងស្អាងចិត្ត" (កិច្ចការ ២០:៣២) ហើយព្រះយេស៊ូវក៏បានមានបន្ទូលដែរថា "មនុស្សមិនមែនរស់ដោយសារតែនំប៉័ងប៉ុណ្ណោះទេគឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រះមកដែរ" (ម៉ាថាយ ៤:៤) ។ ការយល់ដឹង ពីមូលដ្ឋានគ្រឹះនៃជំនឿគ្រីស្ទបរិស័ទ គឺមានសារៈសំខាន់ណាស់សំរាប់គ្រីស្ទបរិស័ទគ្រប់រូប ។ អស់អ្នកដែលមិនបានយល់ដឹង ពីអ្វីដែលព្រះគម្ពីរបង្រៀន នោះគ្មានសមត្ថភាពដើម្បីនឹងថ្លឹងថ្លែងពីសេចក្តីពិត និងការខុសឆ្គងបានឡើយ ហើយពួកគេនឹងដូចជា "កូនតូចទៀត ទាំងត្រូវគ្រប់អស់ទាំងខ្យល់នៃសេចក្តីបង្រៀន បោកហើយផាត់យើងចុះឡើង" (អេភេសូរ ៤:១៤) ។ គ្រីស្ទបរិស័ទដែល

មានគ្រឹះមាំពីព្រះគម្ពីរ នឹងកាន់តែធំចំរើនឡើង មិនងាយនាំឲ្យវង្វេង ពួកគេនឹងមានសុភវិនិច្ឆ័យល្អ "ដែលបានបង្ហាត់ឥន្ទ្រិយ ដោយធ្លាប់ខ្លួនហើយ ដើម្បីឲ្យបានដឹងខុសត្រូវ" (ហេព្រើរ ៥:១៤) ។

យើងទុកសៀវភៅនេះជា សេចក្តីរំលឹក ដល់លោកស្រី រ៉ាជែល ប្រ្គូដិម ដែលបានទទួលមរណៈភាពភ្លាមៗក្នុងគ្រោះថ្នាក់ចរាចរមួយ នៅក្នុងទីក្រុងសេនថ៍ផល រដ្ឋមិនេសូដា សហរដ្ឋអាមេរិក នៅថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៥ ។

លោកស្រី រ៉ាជែល តែងតែមានសេចក្តីអំណរ និង សេចក្តីជំនឿ នៅក្នុងព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទរបស់គាត់ ហើយនិងសេចក្តីស្រឡាញ់សំរាប់ស្វាមីរបស់គាត់ដែលទើបតែរៀបការហើយបានបីខែ ។ ស្វាមីរបស់នាងឈ្មោះអាឡិកសិនដឺរ ប្រ្គូដិម គឺជាកូនប្រុសរបស់ លោក វ៉េន ប្រ្គូដិម ហើយត្រូវជាបងប្អូនប្រុសរបស់លោក អ៊ិលលាត ប្រ្គូដិម ។ ទោះបីជាយើងមានទុក្ខក្រៀមក្រំយ៉ាងណាក៏ដោយ ប៉ុន្តែព្រះបានធ្វើឲ្យសេចក្តីជំនឿ របស់ពួកយើងកាន់តែជ្រាលជ្រៅឡើងនៅក្នុងគោលលទ្ធិ(សេចក្តីបង្រៀន) ដែលបានពិភាក្សានៅក្នុងសៀវភៅនេះជាពិសេសនៅពេលដែលយើងដឹងថា ព្រះទ្រង់ល្អនិងមានប្រាជ្ញាញាណ ហើយនិងដឹងថាលោកស្រីរ៉ាជែលកំពុងមានសេចក្តីអំណរនៅស្ថានសួគ៌ ហើយ ថ្ងៃណាមួយយើងក៏នឹងនៅក្នុងវត្តមានព្រះជាម្ចាស់ជាមួយលោកស្រីផងដែរ ។

វ៉េន ប្រ្គូដិម
អ៊ិលលាត ប្រ្គូដិម
ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៥

# ជំពូក១
# តើព្រះគម្ពីរជាអ្វី?

ចំលើយនានា ដែលអាចឆ្លើយតបចំពោះសេចក្តីជំនឿគ្រីស្ទបរិស័ទ គួរតែផ្អែកទៅលើអ្វីដែលព្រះមានបន្ទូលពីប្រធានបទនោះ ។ ដូច្នេះ នៅពេលដែលយើងចាប់ផ្តើមមើលទៅលើជំនឿដែលជាមូលដ្ឋានគ្រឹះនានារបស់គ្រីស្ទបរិស័ទ នោះត្រូវពិនិត្យទៅលើព្រះបន្ទូលរបស់ព្រះ ឬក៏ព្រះគម្ពីរជាមុនសិន ។ ប្រធានបទមួយដែលព្រះគម្ពីរនិយាយយ៉ាងម៉ត់ចត់នោះគឺពឹងលើព្រះគម្ពីរខ្លួនវាផ្ទាល់តែម្តង មានន័យថាព្រះគម្ពីរប្រាប់យើងពីអ្វីដែលព្រះបានគិតអំពីព្រះបន្ទូលរបស់ទ្រង់ ។ ការយល់ឃើញរបស់ព្រះ ពីបន្ទូលរបស់ផងទ្រង់ ត្រូវបានចែកជា ៤ផ្នែកធំៗគឺ: អំណាច ភាពច្បាស់លាស់ ភាពចាំបាច់ និងភាពគ្រប់គ្រាន់ ។

## អំណាចនៃព្រះគម្ពីរ

គ្រប់ទាំងព្រះបន្ទូល ដែលនៅក្នុងព្រះគម្ពីរ គឺជាព្រះបន្ទូលរបស់ផងព្រះ ។ ដូច្នេះ ការដែលមិនជឿ ឬក៏មិនស្តាប់បង្គាប់តាមព្រះបន្ទូលទាំងនោះ គឺដូចជាមិនជឿ ឬមិនស្តាប់បង្គាប់ទ្រង់ផ្ទាល់អញ្ចឹងដែរ ។ ជាញឹកញាប់ព្រះបន្ទូល នៅក្នុងសញ្ញាចាស់តែងបានចាប់ផ្តើមដោយឃ្លាថា "ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា" (និក្ខ ៤:២២, យ៉ូស ២៤:២, សាំ ១០:១៨, អេសា ១០:២៤, ចោទិ ១៨:១៨-២០, យេ

១:៩) ។ ឃ្លានេះ ជាការបង្គាប់របស់ស្ដេច ហើយត្រូវតែស្ដាប់បង្គាប់តាម ដោយមិនមានការប្រកែកតវ៉ាឡើយ ។ សូម្បីតែពាក្យនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលមិនបានដកស្រង់ ចេញពីព្រះបន្ទូលទ្រង់ផ្ទាល់ក៏ដោយ ក៏ចាត់ទុកជាព្រះបន្ទូលផ្ទាល់របស់ព្រះផងដែរ ។ នៅក្នុង ២ធី ៣:១៦ សាវ័កប៉ុល បាននិយាយបញ្ជាក់យ៉ាងច្បាស់ ក្នុងការដែលគាត់បានសរសេរថា "គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្ដាលឲ្យតែងទេ" ។ ព្រះគម្ពីរសញ្ញាថ្មី ក៏បានបង្រៀនថា គ្រប់ទាំងពាក្យដែលនៅក្នុងគម្ពីរសញ្ញាថ្មី ក៏ជាព្រះបន្ទូលរបស់ព្រះដែរ ។ នៅក្នុង ២ពេ ៣:១៦ សាវ័កពេត្រុស បាននិយាយសំដៅទៅលើគ្រប់ទាំងសំបុត្ររបស់សាវ័កប៉ុល ថាជាផ្នែកមួយនៃព្រះបន្ទូលរបស់ព្រះ ។ នេះមានន័យថាសាវ័កពេត្រុស និង ក្រុមជំនុំដំបូងបានចាត់ទុកថា ការសរសេររបស់សាវ័កប៉ុល ជាផ្នែកដូចគ្នាទៅនឹងការសរសេរនៅក្នុងគម្ពីរសញ្ញាចាស់ដែរ ។ ដូច្នេះ ពួកគេបានចាត់ទុកថា ការសរសេររបស់សាវ័កប៉ុល ជាព្រះបន្ទូលពិតប្រាកដរបស់ព្រះ ។

លើសពីនោះទៅទៀត នៅក្នុង ១ធី ៥:១៨ សាវ័កប៉ុលបានសរសេរពីរចំនុច ទីមួយ "មិនត្រូវឃ្លុំមាត់គោដែលបញ្ជាន់ស្រូវឡើយ" ទីពីរ "ជើងឈ្នួល គួរឲ្យបានប្រាក់ឈ្នួលខ្លួន" ។ ការដកស្រង់ទីមួយ អំពីគោ គឺចេញពីគម្ពីរសញ្ញាចាស់ (ចោទិ ២៥:៤) ហើយការដកស្រង់ទីពីរ គឺចេញពីគម្ពីរសញ្ញាថ្មី (លូ ១០:៧) ។ សាវ័កប៉ុលមានទំនុកចិត្តក្នុងការដកស្រង់ ពីព្រះគម្ពីរសញ្ញាចាស់ និង ព្រះគម្ពីរសញ្ញាថ្មី ហើយ គាត់បានហៅទាំងពីរថាជាព្រះគម្ពីរ ។ ដូច្នេះ ជា ថ្មីម្ដងទៀត ព្រះបន្ទូលនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ត្រូវបានចាត់ទុកជាព្រះបន្ទូលរបស់ព្រះ ។ ហេតុ

នេះហើយ បានជាសាវ័កប៉ុលអាចសរសេរថា "សេចក្ដីទាំងប៉ុន្មានដែលខ្ញុំសរសេរផ្ញើមកអ្នករាល់គ្នានេះ សុទ្ធតែជាបញ្ញត្តផងព្រះអម្ចាស់ទាំងអស់" (១កូ ១៤:៣៧) ។

ដោយព្រោះទាំងគម្ពីរសញ្ញាចាស់ និងគម្ពីរសញ្ញាថ្មី ត្រូវបានចាត់ទុកជាព្រះគម្ពីរ នោះជាការត្រឹមត្រូវដែលនិយាយថាគម្ពីរទាំងពីរ "គឺព្រះវិញ្ញាណ បណ្ដាលឲ្យតែង" (២ធី ៣:១៦) ។ នេះជាការសមហេតុផល នៅពេលដែលយើងពិចារណាអំពីសេចក្ដីសន្យាមួយរបស់ព្រះយេស៊ូវ ដែលថាព្រះវិញ្ញាណបរិសុទ្ធនឹងនាំមកនូវការ "រំលឹកគ្រប់ទាំងសេចក្ដី" ដល់ពួកសិស្សរបស់ទ្រង់ (យ៉ូន ១៤:២៦) ។ ខណៈពេលដែលពួកសាវកបានសរសេរកណ្ឌគម្ពីរផ្សេងៗដូចជា គម្ពីរម៉ាថាយ គម្ពីរយ៉ូហាន និងគម្ពីរពេត្រុសខ្សែទី១ ឬទី២ គឺជាព្រះវិញ្ញាណបរិសុទ្ធ ដឹកនាំឲ្យពួកគេសរសេរទេ ។

ព្រះគម្ពីរចែងថា "មានរបៀបជាច្រើន" (ហេ ១:១) ដែលព្រះគម្ពីរត្រូវបានសរសេរឡើង ។ ជួនកាលព្រះទ្រង់មានបន្ទូលផ្ទាល់ជាមួយអ្នកសរសេរ រួចហើយអ្នកនោះក៏បានសរសេរឡើងនូវអ្វីដែលគាត់បានឮ (វិវរ ២:១, ៨, ១២) ។ នៅពេលខ្លះ អ្នកសរសេរបានសរសេរដោយផ្អែកទៅលើការសំភាសន៍ ហើយនិងការស្រាវជ្រាវ (លូ១:១-៣) ។ ហើយនៅពេលខ្លះទៀត ព្រះវិញ្ញាណបរិសុទ្ធបានរំលឹកដល់គេ នូវអ្វីដែលព្រះយេស៊ូវបានបង្រៀន (យ៉ូន ១៤:២៦) ។ ហើយពាក្យពេចន៍ដែលពួកគេសរសេរ គឺជាការឆ្លុះបញ្ចាំងពីបុគ្គលិកលក្ខណៈ ជំនាញ ជីវប្រវត្តិ និង ការបណ្ដុះបណ្ដាលរបស់ពួកគេ ។ ប៉ុន្តែពាក្យពេចន៍ដែលពួកគេបានសរសេរ

ពិតជាព្រះបន្ទូលរបស់ព្រះ ដែលទ្រង់សព្វព្រះហឫទ័យឲ្យពួកគេសរសេរមែន ។ ព្រះទ្រង់បានប្រកាសថា ពាក្យពេចន៍ទាំងនេះជាព្រះបន្ទូលរបស់ផងទ្រង់ ។

ប្រសិនបើ ព្រះទ្រង់បានប្រកាសប្រាប់ថាព្រះបន្ទូលនៃព្រះគម្ពីរជាព្រះបន្ទូលរបស់ទ្រង់ហើយ នោះគ្មានអំណាចណាដែលលើសជាងនេះ ដែលអាចយកមកបង្ហាញពីអំណាចនៃព្រះគម្ពីរបានឡើយ ។ តើមានអំណាចអ្វីដែលខ្ពស់លើសជាងព្រះ? ដូច្នេះព្រះគម្ពីរទទួលអំណាចដោយខ្លួនវាផ្ទាល់ ។ ប៉ុន្តែការប្រកាសរបស់ព្រះគម្ពីរ ក្លាយជាសេចក្តីជំនឿផ្ទាល់របស់យើង គឺតាមរយៈព្រះវិញ្ញាណបរិសុទ្ធនៅក្នុងចិត្តយើងប៉ុណ្ណោះ ។ ព្រះវិញ្ញាណបរិសុទ្ធ មិនផ្លាស់ប្តូរព្រះបន្ទូលនៃព្រះគម្ពីរ តាមរបៀបណាមួយសោះឡើយ ។ ព្រះវិញ្ញាណបរិសុទ្ធ ទ្រង់មិនបានធ្វើឲ្យព្រះបន្ទូលទាំងនោះក្លាយទៅជាព្រះបន្ទូលនៃព្រះ ដោយអធិធម្មជាតិទេ ពីព្រោះព្រះគម្ពីរតែងតែជាព្រះបន្ទូលរបស់ព្រះជានិច្ចស្រាប់ទៅហើយ ។ ទោះជាយ៉ាងណាក៏ដោយព្រះវិញ្ញាណបរិសុទ្ធពិតជាអ្នកបំផ្លាស់បំប្រែដល់អ្នកអានវិញ ។ ព្រះវិញ្ញាណបរិសុទ្ធធ្វើឲ្យអ្នកអានបានដឹងថា ព្រះគម្ពីរមិនមែនដូចជាសៀវភៅឯទៀតដែលគេបានអានឡើយ ។ តាមរយៈការអាន ពួកគេជឿថា ព្រះបន្ទូលនៃព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះផ្ទាល់ ។ ដូចជាព្រះយេស៊ូវបានមានបន្ទូលនៅគម្ពីរយ៉ូហាន ១០:២៧ ហើយថា "ចៀមខ្ញុំទាំងប៉ុន្មានវាស្តាប់ខ្ញុំ ហើយមកតាម ខ្ញុំក៏ស្គាល់វាដែរ" ។ មានរបៀបជាច្រើនផ្សេងទៀត ដែលអាចបង្ហាញពី អំណាចនៃព្រះគម្ពីរដែរ ដូចជា ការពឹងផ្អែកលើបុរាណវត្ថុវិទ្យា ការឯកភាពគ្នានៃការបង្រៀន ការសំរេចទំនាយ ព្រះគម្ពីរមានឥទ្ធិពលលើមនុស្ស ព្រមទាំងសោភ័ណភាព និងប្រាជ្ញាដ៏អស្ចារ្យនៃ

ខ្លឹមសាររបស់វា ។ ការទាំងនេះមានប្រយោជន៍ជួយឲ្យយើងឃើញថា ការបង្រៀនរបស់ព្រះគម្ពីរគឺពិតជាសមហេតុផលមែន ។

ព្រះបន្ទូលនៃព្រះគម្ពីរគឺជាបន្ទូលរបស់ព្រះ ហើយព្រះបន្ទូលទាំងនោះមិនគ្រាន់តែពិតត្រង់ប៉ុណ្ណោះទេ វាគឺជាសេចក្ដីពិតដោយខ្លួនឯងផ្ទាល់តែម្ដង (យ៉ូន ១៧:១៧) ។ វាគឺជាវិធានចុងក្រោយសំរាប់ឲ្យដឹងថាគំនិតរបស់នរណាម្នាក់ពិតឬមិនពិត ។ ដូច្នេះ អ្វីៗដែលអនុលោមទៅតាមព្រះគម្ពីរគឺជាសេចក្ដីពិត ប៉ុន្តែអ្វីៗដែលមិនឯកភាពទៅតាមព្រះគម្ពីរ នោះមិនមែនជាសេចក្ដីពិតទេ ។ ព័ត៌មានខាងវិទ្យាសាស្ត្រថ្មីៗ អាចធ្វើឲ្យយើងពិនិត្យឡើងវិញ លើការបកស្រាយព្រះគម្ពីររបស់យើង ប៉ុន្តែបើវាពិតប្រាកដ នោះវានឹងមិនប្រឆាំងជាមួយនឹងព្រះគម្ពីរឡើយ ។

សេចក្ដីពិតនៃព្រះគម្ពីរមិនតំរូវឲ្យ ព្រះគម្ពីរផ្ដល់ព័ត៌មាន គ្រប់ទាំងសេចក្ដីលំអិតនៃព្រឹត្តិការណ៍និមួយៗនោះទេ ប៉ុន្តែអ្វីៗដែលជាសេចក្ដីលំអិតនៅក្នុងព្រះគម្ពីរសុទ្ធតែជាសេចក្ដីពិត ។ សេចក្ដីពិតនៃព្រះគម្ពីរ ក៏មិនតំរូវឲ្យព្រះគម្ពីរប្រាប់យើងពីអ្វីៗគ្រប់យ៉ាងដែលយើងចង់ដឹងលើប្រធានបទមួយនោះដែរ ។ ព្រះគម្ពីរមិនដែលធ្វើការអះអាងយ៉ាងដូច្នេះទេ ។ មួយទៀតសោត ដោយព្រោះព្រះគម្ពីរត្រូវបានសរសេរឡើងដោយមនុស្សធម្មតា ជា ភាសាធម្មតា តាមរបៀបធម្មតា នោះវាមានការដកស្រង់មិនពេញលេញ ឬការដកស្រង់សេរី ហើយទំរង់វេយ្យាករណ៍និងការប្រកបអក្ខរាវិរុទ្ធមិនសូវមានគេប្រើញឹកញាប់ ឬក៏មិនមានសភាពធម្មតា ។ ប៉ុន្តែការទាំងអស់នេះមិនមែនជាបញ្ហានៃសេចក្ដីពិតទេ ។ នៅក្នុងទំរង់ដើមរបស់វា ព្រះគម្ពីរមិនបានអះអាងពីអ្វីមួយដែលផ្ទុយទៅនឹងសេចក្ដីពិតឡើយ ។

ប្រសិនបើ ព្រះគម្ពីរអះអាងពីអ្វីមួយផ្ទុយពីសេចក្ដីពិត នោះវាមិនអាចគួរឲ្យទុកចិត្តបានទេ ។ ហើយប្រសិនបើព្រះគម្ពីរមិនគួរឲ្យទុកចិត្ត នោះព្រះជាម្ចាស់ផ្ទាល់ក៏មិនគួរឲ្យទុកចិត្តដែរ ។ ប្រសិនបើយើងជឿថាព្រះគម្ពីរបានអះអាងពីអ្វីមួយដែលផ្ទុយពីសេចក្ដីពិត នោះមានន័យថា យើងមិនបានជឿដល់ទ្រង់ផ្ទាល់ទេ ។ ប្រសិនបើយើងមិនជឿដល់ទ្រង់ផ្ទាល់ មានន័យថា យើងដាក់ខ្លួនយើងឲ្យមានអំណាចខ្ពស់ជាងព្រះ ហើយយើងគិតថា យើងមានការយល់ដឹងជាងព្រះ ។ ដូច្នេះ ដោយព្រោះព្រះគម្ពីរអះអាងថា វាគឺជាព្រះបន្ទូលរបស់ព្រះ នោះយើងគួរតែធ្វើការស្វែងយល់ពីព្រះបន្ទូលទាំងនោះ ពីព្រោះប្រសិនបើយើងព្យាយាមស្វែងយល់ពីព្រះគម្ពីរ វា មានន័យថា យើងកំពុងតែស្វែងរកទ្រង់ផ្ទាល់ ។ យើងគួរស្វែងរកការទុកចិត្តលើព្រះបន្ទូល ពីព្រោះថាប្រសិនបើយើងកំពុងតែស្វែងរកការទុកចិត្តលើព្រះបន្ទូល នោះមានន័យថា យើងកំពុងតែស្វែងរកការទុកចិត្តដល់ព្រះដែរ ។ ហើយយើងគួរស្វែងរកការស្ដាប់បង្គាប់តាមព្រះបន្ទូល ពីព្រោះពេលណាយើងធ្វើអញ្ចឹង មានន័យថា យើងកំពុងតែស្វែងរកការស្ដាប់បង្គាប់ដល់ព្រះដែរ ។

## ភាពច្បាស់លាស់នៃព្រះគម្ពីរ

នៅពេលយើងអានព្រះគម្ពីរ ហើយព្យាយាមស្វែងយល់វា យើងនឹងឃើញថាព្រះបន្ទូលខ្លះងាយយល់ជាង ព្រះបន្ទូលផ្សេងទៀត ។ ទោះបីជាព្រះបន្ទូលមួយចំនួន ដំបូងហាក់ដូចជាពិបាកយល់ក៏ដោយ តែវាត្រូវបានសរសេរឡើងតាមរបៀប

មួយដែលអាចឲ្យយើងដឹងច្បាស់ អំពីរបៀបឲ្យក្លាយទៅជាគ្រីស្ទាន របៀបរស់នៅជាគ្រីស្ទាន ហើយនិង របៀបឲ្យបានធំចំរើនឡើង ។

មានសេចក្ដីអាថ៌កំបាំងខ្លះនៅក្នុងព្រះគម្ពីរ ប៉ុន្តែសេចក្ដីអាថ៌កំបាំងទាំងនោះ មិនគួរធ្វើឲ្យយើងធ្លាក់ទឹកចិត្តក្នុងការអានព្រះគម្ពីរឡើយ ។ ពីព្រោះ "ឯក្រិត្យវិន័យរបស់ព្រះយេហូវ៉ានោះគ្រប់លក្ខណ៍ ក៏កែព្រលឹងឡើងវិញ សេចក្ដីបន្ទាល់នៃព្រះយេហូវ៉ាជាពិត ក៏ធ្វើឲ្យមនុស្សខ្លៅល្ងង់មានប្រាជ្ញា" (ទំនុក ១៩:៧) ។ ហើយការបើកសំដែងព្រះបន្ទូលទ្រង់ នោះផ្សាយពន្លឺចេញទៅ ក៏ធ្វើឲ្យមនុស្សឆោតល្ងង់មានយោបល់ (ទំនុក ១១៩:១៣០) ។ ព្រះបន្ទូលរបស់ព្រះ ងាយយល់ ហើយច្បាស់លាស់ណាស់ សូម្បីតែមនុស្សឆោតល្ងង់ក៏អាចមានប្រាជ្ញាដោយសារការអានព្រះគម្ពីរដែរ ។ ដ្បិតព្រះបន្ទូលរបស់ព្រះ ជា សេចក្ដីដែលត្រូវពិចារណាយល់ខាងវិញ្ញាណ (១កូ ២:១៤) នោះការយល់ដឹងត្រឹមត្រូវមួយពីបទគម្ពីរ គឺជាលទ្ធផលនៃលក្ខខ័ណ្ឌខាងវិញ្ញាណរបស់បុគ្គលម្នាក់ ជាជាងសមត្ថភាពរបស់គាត់ ។ បើយើងយល់អំពីវា នោះមិនមែនដោយប្រាជ្ញារបស់យើងនោះទេ ប៉ុន្តែសមត្ថភាពយល់របស់យើង វាទាក់ទងទៅនឹងគុណភាពនៃជីវិតខាងព្រលឹងវិញ្ញាណរបស់យើងវិញ ។ ជាញឹកញាប់ អស់អ្នកណាដែលបដិសេធព្រះបន្ទូលព្រះ អ្នកនោះគិតថាព្រះបន្ទូលនៃព្រះជាសេចក្ដីល្ងង់ល្ងើ ។

ប៉ុន្តែនេះមិនមានន័យថា រាល់ពេលនរណាម្នាក់យល់ច្រឡំអំពីព្រះគម្ពីរពីព្រោះជីវិតខាងឯព្រលឹងវិញ្ញាណរបស់គាត់ខ្សោយនោះទេ ។ មានគ្រីស្ទបរិស័ទដែលកោតខ្លាចដល់ព្រះជាច្រើន បានយល់ច្រឡំចំនុចខ្លះនៃព្រះបន្ទូល ។ សាវក

របស់ផងទ្រង់ក៏បានយល់ច្រឡំជាច្រើនដងដែរ (ម៉ាថ ១៥:១៦) ។ ជួនកាល ពួកគេយល់ច្រឡំ ពីព្រោះចិត្តរបស់គេរឹង (លូ ២៤:២៥) ។ ពេលខ្លះ ដោយសារតែ ពួកគេត្រូវការរង់ចាំអ្វីមួយ ដែលនឹងកើតឡើងនៅពេលខាងមុខ (យ៉ូន ១២:១៦) ។ សមាជិកនៃក្រុមជំនុំដំបូង ក៏មិនតែងតែបានយល់ស្របលើអត្ថន័យ នៃព្រះគម្ពីរដែរ (កិច្ច ១៥ , កា ២:១១-១៥) ។

នៅពេលដែលគេមិនបានយល់ស្រប នឹងការបកស្រាយនៃព្រះគម្ពីរបញ្ហានោះមិនមែនដោយសារតែព្រះគម្ពីរទេ ដ្បិតព្រះបណ្ដាលឲ្យសរសេរឡើងដើម្បីឲ្យពួកគេបានយល់ ។ ដូច្នេះដែលជាបញ្ហានោះ គឺជាយើងវិញ ។

ជួនកាល យើងយល់មិនដល់ព្រះគម្ពីរ ពីព្រោះយើងមិនបានផ្ដោតយកចិត្តទុកដាក់លើសេចក្ដីលំអិតនៃចំនុចនោះ ។ ដូច្នេះ យើងគួរអធិស្ឋានសូមព្រះបានបើកសំដែងឲ្យយើងបានយល់ពីសេចក្ដីពិត នៅពេលដែលយើងអានព្រះគម្ពីរ ។

## ភាពចាំបាច់នៃព្រះគម្ពីរ

ជាការពិតណាស់ អ្វីគ្រប់យ៉ាង ដែលយើងត្រូវការដើម្បីឲ្យក្លាយទៅជាគ្រីស្ទបរិស័ទរស់នៅជាគ្រីស្ទបរិស័ទ ធំចំរើនឡើងជាគ្រីស្ទបរិស័ទ គឺត្រូវបានបង្រៀនយ៉ាងច្បាស់លាស់នៅក្នុងព្រះគម្ពីរ ។ វាក៏ជាការពិតផងដែរ បើគ្មានព្រះគម្ពីរ នោះយើងមិនអាចស្គាល់ការទាំងអស់នេះបានឡើយ ។ ភាពចាំបាច់នៃព្រះគម្ពីរ មានន័យថាយើងត្រូវការអានព្រះគម្ពីរ ឬ មាននរណាម្នាក់ប្រាប់យើងពីព្រះគម្ពីរដើម្បីឲ្យបាន

ស្គាល់ព្រះជាម្ចាស់ផ្ទាល់ ហើយដើម្បីឲ្យអំពើបាបរបស់យើងត្រូវបានអត់ទោសឲ្យ ហើយដើម្បីឲ្យបានស្គាល់ព្រះហឫទ័យរបស់ព្រះឲ្យបានច្បាស់ ។

សាវកប៉ុលបង្រៀនអំពីភាពចាំបាច់នៃព្រះគម្ពីរ ពេលដែលគាត់បាននិយាយថា "បើគេមិនបានឮនិយាយ នោះធ្វើដូចម្តេចឲ្យគេជឿដល់ព្រះបាន" (រ៉ូម ១០:១៤) ។ ពីព្រោះ "សេចក្តីជំនឿកើតឡើងដោយឮ ហើយដែលឮនោះ គឺដោយសារព្រះបន្ទូលនៃព្រះ" (រ៉ូម ១០:១៧) ។ ប្រសិន បើគ្មាននរណាម្នាក់ប្រកាសពីព្រះបន្ទូលអំពីព្រះគ្រីស្ទទេ សាវកប៉ុលបាននិយាយថា នោះពួកគេនឹងមិនបានទទួលការសង្គ្រោះឡើយ ហើយព្រះបន្ទូលអំពីព្រះគ្រីស្ទនោះគឺមកពីព្រះគម្ពីរ ។ ដូច្នេះដើម្បីឲ្យក្លាយទៅជាគ្រីស្ទបរិស័ទ យើងត្រូវតែអានព្រះគម្ពីរ ឬក៏មាននរណាម្នាក់ផ្សេងទៀតពន្យល់ដល់យើង ។ សាវកប៉ុលប្រាប់ដល់លោក ធីម៉ូថេថា "តាំងពីក្មេងតូចមក អ្នកបានស្គាល់បទគម្ពីរទាំងប៉ុន្មាន ដែលអាចនឹងនាំឲ្យអ្នកមានប្រាជ្ញាដល់ទីសង្គ្រោះ ដែលបានដោយសារសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទយេស៊ូវផង" (២ធី ៣:១៥) ។

ប៉ុន្តែជីវិតរបស់គ្រីស្ទាន មិនត្រឹមតែចាប់ផ្តើមជាមួយព្រះគម្ពីរប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវការព្រះគម្ពីរដើម្បីឲ្យបានរីកចំរើនផងដែរ ។ ព្រះយេស៊ូវបានមានបន្ទូលថា "មនុស្សមិនមែនរស់ ដោយសារតែនំបុ័ងប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋទ្រង់មកដែរ" (ម៉ាថ ៤:៤) ។ ដូចជារូបកាយរបស់យើងត្រូវការអាហារជាប្រចាំថ្ងៃដើម្បីរស់យ៉ាងដូច្នេះដែរ ។ ជីវិតខាងព្រលឹងវិញ្ញាណរបស់យើង ត្រូវការអាហារមកពីព្រះគម្ពីរ ដើម្បីឲ្យរីកចំរើនឡើង ។

ប្រសិនបើយើងមិនបានអានព្រះគម្ពីរទៀងទាត់ទេ ព្រលឹងរបស់យើងនឹងមិនមានសុខភាពល្អទេ ។

លើសពីនោះទៅទៀត យើងត្រូវការព្រះគម្ពីរ ដើម្បីឲ្យបានស្គាល់ពីបំណងព្រះហឫទ័យរបស់ព្រះ ឲ្យបានច្បាស់ ។ ព្រះទ្រង់មិនបានបើកសំដែង ឲ្យយើងស្គាល់ ពីបំណងព្រះហឫទ័យទ្រង់ទាំងអស់របស់ទ្រង់ទេ ពីព្រោះ“ ឯអស់ទាំងសេចក្តីលាក់កំបាំង នោះស្រេចនៅព្រះយេហូវ៉ាជាព្រះនៃយើងរាល់គ្នាទេ តែសេចក្តីដែលបានបើកសំដែងមកទាំងប៉ុន្មាន នោះស្រេចនៅយើងរាល់គ្នា ហើយនឹងកូនចៅយើង ជារៀងដរាបវិញ ដើម្បីឲ្យយើងបានប្រព្រឹត្តិតាម អស់ទាំងពាក្យក្នុងក្រិត្យវិន័យនេះ” (ចោទិ ២៩:២៨) ។ ប្រសិនបើ យើងស្រឡាញ់ព្រះ យើងត្រូវ “កាន់តាមអស់ទាំងបញ្ញត្តិរបស់ទ្រង់” (១យ៉ូន ៥:៣) ហើយគ្រប់ទាំង បញ្ញត្តិរបស់ទ្រង់ យើងអាចរកឃើញនៅក្នុងព្រះគម្ពីរ ។

ទោះជាយ៉ាងណាក៏ដោយ ព្រះ គម្ពីរមិនត្រូវការចាំបាច់ ដើម្បីឲ្យបានស្គាល់អ្វីៗមួយចំនួន អំពីព្រះនោះទេ ដូចជាចរិតលក្ខណៈ និងអំណាចព្រះចេស្តារបស់ទ្រង់ ពីព្រោះ “ផ្ទៃមេឃសំដែងពីសិរីល្អនៃព្រះ ហើយលំហអាកាសក៏បង្ហាញការដែលព្រះហស្តទ្រង់ធ្វើ” (ទំនុក ១៩:១) ។ សាវកប៉ុលបាននិយាយថា សូម្បីតែមនុស្សអាក្រក់អាចឃើញការទាំងអស់នេះបានដែរ គម្ពីររ៉ូម ១:១៩ “ព្រោះការអ្វីដែលអាចស្គាល់ពីព្រះបាន នោះបានសំដែងមកក្នុងពួកគេហើយ ដោយព្រះទ្រង់សំដែងការនោះឲ្យគេឃើញជាក់” ។ មនុស្សអាក្រក់មិនត្រឹមតែស្គាល់អំពីព្រះប៉ុណ្ណោះទេ ប៉ុន្តែគេស្គាល់នៅក្នុងគំនិត និងបញ្ញាចិត្តរបស់ពួកគេផងដែរ ពីព្រោះពួក

គេបានយល់ខ្លះៗ អំពីក្រមសីលធម៌របស់ទ្រង់ដូចជា កុំសំលាប់មនុស្សឲ្យសោះ, កុំលួច (រ៉ូម ១:៣២ , ២:១៤-១៥) ។ ដូច្នេះយើងអាចដឹងពីការបើកសំដែងទូទៅនេះ ដូចជា អំពីវត្តមានរបស់ព្រះ ចរិតលក្ខណៈរបស់ទ្រង់ ហើយ ក្រមសីលធម៌ ត្រូវបានប្រទានដល់មនុស្សទាំងអស់ ដែលយើងមើលឃើញបានតាមរយៈធម្មជាតិ ហើយនិងកិច្ចការអស្ចារ្យនានាពីអតីតកាលរបស់ព្រះ ហើយនិងបញ្ញាចិត្តរបស់យើង ។ នេះឯងដែលហៅថា ការបើកសំដែងទូទៅ ព្រោះវាត្រូវបានផ្តល់ឲ្យមនុស្សទូទៅទាំងអស់ ។ ការបើកសំដែងទូទៅ ខុសពីព្រះគម្ពីរ ។ ផ្ទុយទៅវិញ ការបើកសំដែងពិសេស មិនបានបើកសំដែងដល់មនុស្សទូទៅទេ ។ ព្រះគម្ពីរទាំងមូល គឺជាការបើកសំដែងពិសេស ហើយការដែលព្រះមានបន្ទូលផ្ទាល់ជាមួយពួកហោរាក៏ជាការបើកសំដែងពិសេសផងដែរ នៅពេលដែលយើងរៀនពីរឿងរ៉ាវនៅក្នុងព្រះគម្ពីរ ។

## ភាពគ្រប់គ្រាន់នៃព្រះគម្ពីរ

អស់អ្នកដែលមានជីវិតរស់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ពួកគេពុំមានការបើកសំដែងពេញលេញរបស់ព្រះទេ ពីព្រោះពួកគេពុំមានព្រះគម្ពីរសញ្ញាថ្មី ។ ប៉ុន្តែ ពួកគេមានការបើកសំដែងទាំងអស់ ដែលព្រះទ្រង់បានសព្វព្រះហឫទ័យបើកសំដែងឲ្យពួកគេត្រូវមាននៅក្នុងជីវិតរបស់ពួកគេ ។ សព្វថ្ងៃនេះព្រះគម្ពីរមានព្រះបន្ទូលនៃព្រះដែលមនុស្សម្នាក់ៗត្រូវការចាំបាច់ ដើម្បីឲ្យក្លាយទៅជាគ្រីស្ទបរិស័ទ ដើម្បីរស់នៅជាគ្រីស្ទបរិស័ទ ហើយនឹងឲ្យបានធំចំរើនឡើងជាគ្រីស្ទបរិស័ទ ។ ដើម្បីឲ្យបាន

គ្រប់លក្ខណ៍នៅចំពោះព្រះ យើងគ្រាន់តែស្តាប់បង្គាប់ព្រះបន្ទូលទ្រង់ប៉ុណ្ណោះ “មានពរហើយ អស់អ្នកដែលផ្លូវប្រព្រឹត្តិខ្លួនបានគ្រប់លក្ខណ៍ គឺជាអ្នកដែលដើរតាមក្រិត្យវិន័យរបស់ព្រះយេហូវ៉ា” (ទំនុក ១១៩:១) ហើយនៅក្នុងព្រះគម្ពីរ ព្រះបានប្រទានការបង្ហាត់បង្រៀន មកយើងនូវអ្វី ដែលយើងត្រូវការសំរាប់ “ធ្វើការល្អគ្រប់មុខ” ដែលទ្រង់សព្វព្រះហឫទ័យឲ្យយើងធ្វើ (២ធី ៣:១៦-១៧) ។ នេះជាអ្វីដែលយើងចង់សំដៅថា ព្រះគម្ពីរមានភាពគ្រប់គ្រាន់ ។

ដូច្នេះយើងគួរមើលនៅក្នុងតែព្រះគម្ពីរប៉ុណ្ណោះ នៅ ពេលណាដែលយើងស្រាវជ្រាវរកព្រះបន្ទូលព្រះ សំរាប់ខ្លួនយើង ។ ហើយគួរមានភាពពេញចិត្តនូវចំលើយដែលយើងបានរកឃើញនៅក្នុងព្រះគម្ពីរ ។ ភាពគ្រប់គ្រាន់នៃព្រះគម្ពីរ គួរលើកទឹកចិត្តដល់យើង ដើម្បីសិក្សាស្វែងយល់តាមរយៈព្រះគម្ពីរ ដើម្បីព្យាយាមរកអ្វីដែលព្រះសព្វព្រះហឫទ័យឲ្យយើងគិត អំពីប្រធានបទជាក់លាក់ណាមួយ ។ អ្វីៗដែលព្រះចង់មានបន្ទូលប្រាប់ដល់រាស្ត្ររបស់ទ្រង់ អំពីស្ថានភាពផ្សេងៗ យើងអាចរកឃើញនៅក្នុងព្រះគម្ពីរ ។ ជួនកាល ព្រះគម្ពីរពុំបានឆ្លើយនឹងសំនួរផ្ទាល់នោះទេ ពីព្រោះ “សេចក្តីលាក់កំបាំងនោះស្រេចនៅព្រះយេហូវ៉ា” (ចោទិ ២៩:២៨) ។ ប៉ុន្តែ វា នឹងផ្តល់នូវការនាំផ្លូវដែលយើងត្រូវការ សំរាប់ការល្អគ្រប់មុខ(២ធី ៣:១៧) ។

ពេលដែលយើងមិនបានរកឃើញចំលើយ ឲ្យចំទៅនឹងសំនួរនៅក្នុងព្រះគម្ពីរយើងពុំមានសេរីភាពដើម្បីបន្ថែមទៅលើព្រះគម្ពីរ ដោយគំនិតផ្ទាល់របស់យើងបានឡើយ ។ វាអាចទៅរួច ដែលព្រះនឹងប្រទានការនាំផ្លូវពិសេសដល់យើង

ក្នុងស្ថានភាពពីមួយថ្ងៃទៅមួយថ្ងៃរបស់យើង ប៉ុន្តែយើងមិនអាចចាត់ទុកការនោះឲ្យស្មើអ្វីដែលនៅក្នុងព្រះគម្ពីរបានឡើយ ។ ហើយយើងមិនត្រូវជំរុញការនាំផ្លូវនោះឲ្យអ្នកដទៃជឿឡើយ ពីព្រោះយើងអាចនឹងមានការខុសឆ្គងពីការនាំផ្លូវនោះ ។

មានស្ថានភាពខ្លះ ព្រះ មិនបានប្រទានបញ្ញត្តច្បាស់លាស់ ដែលយើងចង់បានទេ ពីព្រោះយើងជឿថាព្រះគម្ពីរមានភាពគ្រប់គ្រាន់ យើងមិនអាចបន្ថែមលើសេចក្តីបង្រៀនរបស់ព្រះគម្ពីរឡើយ ។ ឧទាហរណ៍៖ ប្រសិនបើក្រុមជំនុំមួយដែលចាប់ផ្តើមការថ្វាយបង្គំព្រះនៅម៉ោងប្រាំបីគត់នៅព្រឹកថ្ងៃអាទិត្យ វា អាចនឹងជាការល្អ ហើយក្រុមជំនុំមួយផ្សេងទៀត ចាប់ផ្តើមការថ្វាយបង្គំព្រះនៅម៉ោងប្រាំបួនកន្លះនៅព្រឹកថ្ងៃអាទិត្យ វា ក៏អាចជាការល្អផងដែរ ។ ដោយព្រោះតែព្រះគម្ពីរមិនបានប្រាប់យើងថាពេលណាមួយជាពេលដ៏ល្អសំរាប់ការជួបជុំគ្នា នោះយើងអាចជ្រើសរើសពេលវេលាណាក៏បានដែរ ។ ប្រសិនបើ ក្រុមជំនុំដែលថ្វាយបង្គំនៅម៉ោងប្រាំបីគត់ បានប្រាប់ដល់ក្រុមជំនុំដែលថ្វាយបង្គំនៅម៉ោងប្រាំបួនកន្លះថា អ្នកត្រូវថ្វាយបង្គំនៅម៉ោងប្រាំបីគត់ ប្រសិនក្រុមជំនុំនោះបានប្រាប់យ៉ាងដូច្នេះ នោះពួកគេកំពុងធ្វើបាបហើយ ពីព្រោះពួកគេកំពុងតែបន្ថែមលើបញ្ញត្តិរបស់ព្រះ ។

ដូចគ្នាផងដែរ នៅក្នុងជីវិតរស់នៅរបស់គ្រីស្ទបរិស័ទ ភាពគ្រប់គ្រាន់នៃព្រះគម្ពីររំលឹកដល់យើងថា គ្មានអ្វីដែលជាអំពើបាបទេ ប្រសិនព្រះគម្ពីរមិនបានហាមដល់យើង ដោយផ្ទាល់ និងដោយប្រយោល ។ ដូច្នេះយើងមិនអាចបន្ថែមការហាមប្រាម លើ ចំនុចណាមួយ ដែលយើងគិតថាព្រះគម្ពីរមិនមានភាពច្បាស់លាស់គ្រប់គ្រាន់ឡើយ ។ ឧទាហរណ៍៖ អាចមានស្ថានភាពខ្លះ វាមិនសមរម្យ ដែល

គ្រីស្ទបរិស័ទផឹកកាហ្វេអ៊ីន ឬ ទៅមើលកុន ឬ ការបរិភោគសាច់ដែលដាក់ថ្វាយដល់រូបព្រះ (១កូរិន ៨:១០) ។ ដោយសារតែ មិនមានការបង្រៀនចំៗនៅក្នុងព្រះគម្ពីរ ដែលហាមប្រាមការទាំងនេះដល់គ្រីស្ទបរិស័ទគ្រប់រូប គ្រប់ពេល ដូច្នេះយើងមិនអាចនិយាយថា វាតែងតែជាអំពើបាបនោះទេ ។

ដូច្នេះនៅក្នុងគោលលទ្ធិ សីលធម៌ ហើយនិងជំនឿរបស់យើង យើងគួរពេញចិត្តនូវអ្វីដែលព្រះបានមានបន្ទូលប្រាប់យើងនៅក្នុងព្រះគម្ពីរ ។ ព្រះបានបើកសំដែងយ៉ាងច្បាស់នូវអ្វីដែលទ្រង់ជ្រាបថា ជាការត្រឹមត្រូវសំរាប់យើង ។ ក្រុមជំនុំ និង និកាយជាច្រើនមានជំលោះអំពីប្រធានបទ ដែលព្រះគម្ពីរមិនបាននិយាយសង្កត់ធ្ងន់ទៅលើប្រធានបទនោះ ។ មានការសន្និដ្ឋានផ្ទាល់ខ្លួនជាច្រើន ដូចជា ការគ្រប់គ្រងក្រុមជំនុំបែបណាដែលត្រឹមត្រូវ អត្ថន័យត្រឹមត្រូវនៃពិធីលៀងព្រះអម្ចាស់ ឬ ពេលដែលព្រះយេស៊ូវយាងត្រឡប់មកវិញ ជាអ្វីដែលចេញមកពីការប៉ាន់ស្មានរបស់ពួកគេ ច្រើនជាងអ្វីដែលមកពីការបង្រៀនរបស់ព្រះគម្ពីរ ។ យើងគួរបន្ទាបខ្លួន នៅពេលដែលយើងអានព្រះបន្ទូលរបស់ព្រះ កុំឲ្យយើងសង្កត់លើចំនុចអ្វីមួយ ឲ្យធ្ងន់ជាងព្រះគម្ពីរបានផ្តោតឲ្យសោះ ។

# បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១. ហេតុអ្វីបានជាមានសារៈសំខាន់ម្ល៉េះ ដែលព្រះគម្ពីរគឺជាគ្រឹះសំរាប់ជំនឿរបស់យើង?

២. តើព្រះគម្ពីរនឹងមានចំលើយផ្ទាល់ សំរាប់រាល់សំនួរដែលយើងមានឬទេ? ហេតុអ្វីមាន ឬ ហេតុអ្វីមិនមាន?

៣. តើអ្វី ដែលព្រះគម្ពីរបានបង្រៀនយើងយ៉ាងច្បាស់ ? ហើយតើអ្វី ដែលព្រះគម្ពីរមិនបានបង្រៀនយើងយ៉ាងច្បាស់ ? តើមួយណាដែលយើងគួរផ្តោតយកចិត្តទុកដាក់ទៅលើជាង ?

# ជំពូក ២

# តើព្រះមានលក្ខណៈយ៉ាងដូចម្តេច?

ព្រះគម្ពីរគឺជាប្រភពដ៏សំខាន់បំផុតនៃព័ត៌មានអំពីខ្លួនវាផ្ទាល់ ហើយព្រះក៏ជាប្រភពដ៏សំខាន់បំផុតសំរាប់អង្គទ្រង់ផ្ទាល់ដែរ ។ ប្រសិនបើមានប្រភពសំខាន់ជាងនេះនៅទីណាផ្សេងទៀតនោះ មានន័យថាព្រះនឹងមិនមែនជាព្រះទេ ។ ដូច្នេះ វាមានសារៈសំខាន់ណាស់ ប្រសិនយើងចង់សិក្សាអំពីព្រះ យើងត្រូវសិក្សាពីអ្វីដែលព្រះបានបង្រៀនដល់យើងអំពីទ្រង់ផ្ទាល់នៅលើទំព័រព្រះគម្ពីរ ។ ព្រះបង្រៀនអំពីទ្រង់ផ្ទាល់នៅក្នុងព្រះគម្ពីរ ។

## ព្រះមានព្រះជន្មគង់នៅ

ព្រះគម្ពីរសន្និដ្ឋានថា ព្រះ ទ្រង់មានព្រះជន្មគង់នៅ ។ ខគម្ពីរដំបូងនៃព្រះគម្ពីរបង្រៀនយើងថា "កាលដើមដំបូងឡើយព្រះបានបង្កើតផ្ទៃមេឃ និងផែនដី" (លោក ១:១) ។ ដូច្នេះយើងដឹងថា ព្រះមានព្រះជន្មគង់នៅ ។

ព្រះគម្ពីរក៏បានប្រាប់យើងផងដែរថាមនុស្សទាំងអស់គ្រប់ទីកន្លែង គេដឹងថាព្រះមានព្រះជន្មគង់នៅ ហើយពួកគេជាសភាវៈ ដែលព្រះបានបង្កើតមក ។ នៅក្នុងគម្ពីររ៉ូម ១:១៩ សាវ័ក ប៉ុល និយាយថា សូម្បីតែមនុស្សអាក្រក់ដឹងថា ព្រះមានព្រះជន្មគង់នៅ "ពីព្រោះការអ្វីដែលអាចនឹងស្គាល់ពីព្រះបាន នោះបានសំដែង

មកក្នុងពួកគេហើយ ដោយព្រះទ្រង់សំដែងការនោះឲ្យគេឃើញជាក់" ។ មនុស្សជាច្រើនមិនទទួលស្គាល់ថាព្រះមានព្រះជន្មគង់នៅ តែសាវ័កប៉ុលនិយាយថា គេ មិនទទួលស្គាល់ការនេះពីព្រោះ "គេបានផ្លាស់សេចក្តីពិតនៃព្រះ ឲ្យទៅជាសេចក្តីភូតភរវិញ ក៏កោតខ្លាច ហើយគោរពប្តូជាដល់របស់ដែលកើតមក ជាជាងដល់ព្រះដែលបង្កើតរបស់ទាំងនោះមក" (រ៉ូម ១:២៥) ។ ជាទូទៅ ពួកគេធ្វើឲ្យខ្លួនឯងជឿជាក់ថា "មនុស្សអាក្រក់ពោលដោយឫកអំនួតរបស់ខ្លួនគេថា ព្រះទ្រង់នឹងមិនធ្វើទោសទេ ឯអស់ទាំងគំនិតរបស់គេ នោះតែងគិតថាគ្មានព្រះណាសោះ" (ទំនុក ១០:៤) ។

ព្រះតំរិះរបស់ព្រះដែលសាវ័កប៉ុលបាននិយាយ អាចនឹងឃើញច្បាស់វិញ "ដ្បិតអ្វីៗរបស់ទ្រង់ ដែលរកមើលមិនឃើញ តាំងពីកំណើតលោកីយ៍មក ទោះទាំងព្រះចេស្តាដ៏នៅអស់កល្បជានិច្ច និង និស្ស័យជាព្រះរបស់ទ្រង់ នោះឃើញច្បាស់វិញ ដោយពិចារណាយល់របស់ទាំងប៉ុន្មាន ដែលទ្រង់បានបង្កើតមក" (រ៉ូម ១:២០) ។ គ្រប់ទាំងរបស់ដែលព្រះបានបង្កើតមក ផ្តល់ភស្តុតាងពីព្រះនិង ចរិតលក្ខណៈរបស់ទ្រង់ ។ មនុស្សត្រូវបានបង្កើតឲ្យដូចរូបអង្គទ្រង់ ហើយ បានផ្តល់នូវភស្តុតាងដ៏ច្រើនបំផុត ថាព្រះមានព្រះជន្មគង់នៅ ។ ដូច្នេះ សេចក្តីជំនឿរបស់យើងមិនមែនជាជំនឿដែលងងឹតងងល់នោះទេ ពីព្រោះ វាមានមូលដ្ឋានទៅលើភស្តុតាងដែលបានរកឃើញនៅក្នុងព្រះគម្ពីរ ហើយនៅក្នុងពិភពធម្មជាតិទាំងមូល ។

## យើងអាចស្គាល់ព្រះបាន

ព្រះមិនត្រឹមតែមានព្រះជន្មគង់នៅប៉ុណ្ណោះទេ ប៉ុន្តែទ្រង់មានព្រះជន្មគង់នៅ តាមរបៀបមួយដែលយើងអាចស្គាល់អ្វីៗអំពីទ្រង់ ហើយនិង ស្គាល់ទ្រង់ផ្ទាល់បាន ។ ទោះជាយ៉ាងណាក៏ដោយ យើងមិនអាចស្គាល់ព្រះមួយរយភាគរយបានទេ ។ ទ្រង់គ្មានព្រំខណ្ឌ ហើយយើងមានព្រំខណ្ឌ ។ “ឯសណ្ឋានធំប្រសើររបស់ទ្រង់ នោះនឹងរកយល់មិនបាន” ទ្រង់ធំប្រសើរពេកក្រៃ មិនអាចយល់អស់ឡើយ (ទំនុក ១៤៥:៣) ។ “ឯប្រាជ្ញាញាណរបស់ទ្រង់ ក៏យល់គ្រប់ទាំងអស់”(ទំនុក ១៤៧:៥) ។ “ការដឹងច្បាស់យ៉ាងនេះ ក៏អស្ចារ្យហួសល្បត់ទូលបង្គំ ហើយខ្ពស់ដល់ម្ល៉េះ បានជាទូលបង្គំឈោងមិនដល់សោះ” (ទំនុក ១៣៩:៦) ។ ហើយប្រសិនបើយើងអាចរាប់គំនិតរបស់ព្រះបាន គំនិតនេះនឹងច្រើនជាងដីខ្សាច់នៅផែនដីនេះផង (ទំនុក ១៣៩:១៧-១៨) ។

ជាការពិតណាស់ យើងមិនអាចស្គាល់ព្រះមួយរយភាគរយបានទេ ប៉ុន្តែយើងអាចស្គាល់ទ្រង់ដោយផ្ទាល់បាន ។ ព្រះយេស៊ូវមានបន្ទូលនៅក្នុងព្រះគម្ពីរយ៉ូហាន ១៧:៣ “នេះជាជីវិតដ៏នៅអស់កល្បជានិច្ច គឺឲ្យគេបានស្គាល់ដល់ទ្រង់ដ៏ជាព្រះពិតតែ១ និងព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានចាត់ឲ្យមកផង” ។ ការនេះប្រសើរជាងការដែលគ្រាន់តែដឹងអំពីព្រះ ។ ពិតមែនហើយ នៅក្នុងព្រះគម្ពីរយេរេមា ៩:២៤ ព្រះអង្គមានបន្ទូលថា “ឯអ្នកដែលអួត នោះត្រូវឲ្យគេអួតតែពីសេចក្តីនេះវិញ គឺថាខ្លួនមានយោបល់ ហើយក៏ស្គាល់ដល់អញ” ។

ក្រៅពីយើងអាចស្គាល់ទ្រង់ដោយផ្ទាល់បាន យើងក៏អាចស្គាល់អំពីលក្ខណៈរបស់ទ្រង់ តាមរយៈការនានាដែលទ្រង់បានបង្រៀនយើងនៅក្នុងទំព័រព្រះគម្ពីរផងដែរ ។ ឧទាហរណ៍៖ ព្រះគម្ពីរប្រាប់យើងថា ព្រះជាសេចក្ដីស្រលាញ់ (១យ៉ូន ៤:៨) ព្រះជាពន្លឺ (១យ៉ូន ១:៥) ព្រះជាវិញ្ញាណ (យ៉ូន ៤:២៤) ហើយព្រះសុចរិត (រ៉ូម ៣:២៦) ។ លក្ខណៈខ្លះរបស់ព្រះ ងាយស្រួលយល់ជាងលក្ខណៈផ្សេងទៀត ពីព្រោះយើងក៏មានលក្ខណៈខ្លះទាំងនោះដែរ ។ ប៉ុន្តែ លក្ខណៈផ្សេងទៀតរបស់ទ្រង់ មានការពិបាកយល់ជាង ពីព្រោះយើងពុំមានលក្ខណៈទាំងនោះដូចទ្រង់ ។ ដោយព្រោះយើងជាមនុស្សមានព្រំខណ្ឌ តែ ព្រះអាទិករវិញគ្មានព្រំខណ្ឌទេ ដូច្នេះយើងមិនអាចយល់អំពីលក្ខណៈទាំងអស់របស់ទ្រង់បានឡើយ ។ ទោះជាយ៉ាងណាក៏ដោយ វា គឺជាតំលៃដ៏ធំធេងក្រៃលែងក្នុងការដែលយើងរៀនអំពីលក្ខណៈរបស់ទ្រង់ ពីព្រោះនៅក្នុងលក្ខណៈទាំងអស់នោះ យើងបានរៀនអំពីសេចក្ដីពិតរបស់ទ្រង់ ដែលទ្រង់សព្វព្រះហឫទ័យឲ្យយើងស្គាល់ ។ ព្រះបានបង្កើតយើងមកសំរាប់សិរីល្អរបស់ទ្រង់ (អេសា ៤៣:៧) ហើយយើងអាចថ្វាយសិរីល្អដល់ទ្រង់ ដោយយកគំរូតាមលក្ខណៈរបស់ទ្រង់ ។

## ព្រះទ្រង់ឯករាជ្យ

ព្រះទ្រង់ឯករាជ្យ មានន័យថា ទ្រង់មិនត្រូវការយើង ឬអ្វីផ្សេងទៀតនៅក្នុងការបង្កើត សំរាប់អ្វីណាមួយឡើយ ។ ទ្រង់មិនមែនបង្កើតយើងមក ដោយសារទ្រង់ឯកោ ឬក៏ដើម្បីឲ្យមានការប្រកបជាមួយនឹងមនុស្សផ្សេងៗទៀតនោះទេ ។ ព្រះតែង

តែសប្បាយព្រះហឫទ័យពេញលេញជាបរិបូរជានិច្ច ។ សាវ័កប៉ុលបាននិយាយនៅក្នុងព្រះគម្ពីរ កិច្ចការ ១៧:២៤-២៥ ថា “ដ្បិតព្រះដែលបង្កើតលោកិយ និងរបស់សព្វសារពើ ព្រះអង្គនោះ ទ្រង់ជាព្រះអម្ចាស់នៃស្ថានសួគ៌ និងផែនដី ទ្រង់មិនគង់នៅក្នុងវិហារ ដែលដៃមនុស្សធ្វើទេ ក៏មិនបាច់មានដៃមនុស្សបំរើទ្រង់ ដូចជាទ្រង់ត្រូវការអ្វីនោះដែរ ដ្បិតគឺទ្រង់ដែលផ្គត់ផ្គង់ដោយព្រះអង្គទ្រង់ ឲ្យគ្រប់ទាំងអស់មានជីវិត មានដង្ហើមគ្រប់ជំពូក” ។

ព្រះមិនត្រូវបានគេបង្កើតមកទេ ទ្រង់តែងតែមានវត្តមានជាដរាបមក ។ ទំនុកដំកើង ៩០:២ “គឺមុនដែលអស់ទាំងភ្នំបានកើតឡើង ក្នុងកាលដែលទ្រង់មិនទាន់បង្កើតផែនដី និងមនុស្សលោកនៅឡើយ ចាប់តាំងពីអស់កល្បរៀងទៅដល់អស់កល្បជានិច្ច នោះ គឺទ្រង់ហើយជាព្រះ” ។ ពិតមែនហើយព្រះមិនពឹងដល់នរណាសំរាប់ការអ្វីមួយនោះទេ តែការបង្កើតទាំងអស់របស់ទ្រង់គួរអាស្រ័យលើទ្រង់វិញ ។ “ដ្បិតរបស់សព្វសារពើ បានកើតមកពីទ្រង់ ដោយសារទ្រង់ ហើយសំរាប់ទ្រង់ សូមឲ្យទ្រង់បានសិរីល្អនៅអស់កល្បជានិច្ច” (រ៉ូម ១១:៣៦) ។

ទោះបីជាទ្រង់ឯករាជ្យមួយរយភាគរយក៏ដោយ ប៉ុន្តែទ្រង់ក៏ជ្រើសរើសដើម្បីប្រទានតំលៃ និងអត្ថន័យដល់យើងរាល់គ្នាផងដែរ ។ ទ្រង់ឲ្យយើងរាល់គ្នាក្លាយជាអ្នកដែលសំខាន់ចំពោះទ្រង់ ! ជាការពិតណាស់ គ្រប់ទាំងរបស់សព្វសារពើថ្វាយសិរីល្អដល់ទ្រង់ ហើយនាំសេចក្តីអំណរដល់ទ្រង់ ។ នៅក្នុងព្រះគម្ពីរ អេសាយ ៤៣:៧ “គឺគ្រប់មនុស្សដែលបានហៅតាមនាមឈ្មោះអញជាអ្នកដែលអញបានបង្កើតមកសំរាប់សិរីល្អនៃអញ គឺជាអ្នកដែលអញបានជប់សូន អើជាអ្នក

ដែលអញបានតែងតាំងឡើង” ។ ហើយនៅក្នុងព្រះគម្ពីរសេផានាចែងថា “ព្រះយេហូវ៉ាដ៏ជាព្រះនៃឯង ទ្រង់គង់នៅកណ្តាលឯង ទ្រង់ជាព្រះដ៏មានឥទ្ធិឫទ្ធិ ដើម្បីជួយសង្គ្រោះ ទ្រង់នឹងមានសេចក្តីរីករាយអរសប្បាយចំពោះឯង ទ្រង់នឹងសំរាកក្នុងសេចក្តីស្រឡាញ់របស់ទ្រង់ ក៏នឹងអរសប្បាយនឹងឯងដោយសំលេងច្រៀង” (សេផា ៣:១៧) ។ ទោះបីជាព្រះមិនត្រូវការយើងក៏ដោយ ទ្រង់នៅតែអនុញ្ញាតឲ្យយើងនាំសេចក្តីអំណរដល់ព្រះហឫទ័យទ្រង់ ជា សេចក្តីអំណរដែលនាំឲ្យមានសំលេងច្រៀង ! នោះហើយគឺជាសញ្ញានៃអត្ថន័យពិត ។

## ព្រះទ្រង់មិនចេះប្រែប្រួល

ព្រះមិនចេះប្រែប្រួលទេ ប៉ុន្តែ មិនមែនតាមរបៀបផ្សេងៗដែលយើងចេះតែគិតនោះទេ ។ ផ្ទុយទៅវិញ ទ្រង់មិនចេះប្រែប្រួលតែនៅក្នុងរបៀបនានា ដែលព្រះគម្ពីរបានបង្រៀនប៉ុណ្ណោះ ដូចជា សភាព លក្ខណៈ គោលបំណង និងសេចក្តីសន្យារបស់ទ្រង់ ។ អ្នកច្រៀងបទទំនុកដំកើង ក៏បានសរសើរដល់ព្រះតាមរបៀបដូចគ្នានេះដែរ (ទំនុក ១០២:២៧) ។ ព្រះបញ្ជាក់ការនេះ ពេលដែលទ្រង់មានបន្ទូលថា ទ្រង់មិនប្រែប្រួល “ដ្បិតអញ គឺយេហូវ៉ា គឺអញមិនប្រែប្រួលឡើយ ហេតុនោះ ឱពួកកូនចៅយ៉ាកុបអើយ ឯងរាល់គ្នាមិនបានត្រូវវិនាសទេ” (ម៉ាឡ ៣:៦) ។ ព្រះទ្រង់ខុសពីយើង ទ្រង់មិនចេះប្រែប្រួលទេ តែយើងតែងតែប្រែប្រួលគ្រប់ពេលវេលា ម្យ៉ាងវិញទៀតលក្ខណៈរបស់ទ្រង់នៅតែដដែលជារៀងរហូត ។

លើសពីនោះទៅទៀត ទ្រង់មិនចេះប្រែប្រួលគោលបំណងរបស់ទ្រង់ឡើយ ។ ពេលណាដែលទ្រង់បានសំរេចព្រះហឫទ័យធ្វើអ្វីមួយ នោះនឹងសំរេចជាមិនខាន ។ "ឯដំបូន្មានផងព្រះយេហូវ៉ាវិញ នោះនៅជាប់ជានិច្ច ហើយគំនិតក្នុងព្រះហឫទ័យទ្រង់ ក៏នៅជាដរាបដល់អស់ទាំងដំណតទៅ" (ទំនុក ៣៣:១១) ។ ផែនការនិមួយៗ សំរាប់ភាពអស់កល្បរបស់ទ្រង់នឹងបានសំរេច ដូចជាមាននៅក្នុង (ម៉ាថាយ ២៥:៣៤, អេ ១:៤, ១១) ។

ព្រះទ្រង់ក៏មិនចេះប្រែប្រួលសេចក្តីសន្យារបស់ទ្រង់ដែរ ។ នៅក្នុងព្រះគម្ពីរជនគណនា ២៣:១៩ បានចែងថា "ព្រះទ្រង់មិនមែនជាមនុស្ស ទ្រង់មិនចេះកុហកឡើយ ក៏មិនមែនជាកូនមនុស្សដែរ ទ្រង់មិនត្រូវការនឹងប្រែគំនិតទេ សេចក្តីដែលទ្រង់មានវាចាហើយ តើទ្រង់មិនធ្វើតាមឬអី ឬសេចក្តីដែលទ្រង់មានបន្ទូលតើមិនសំរេចតាមទេឬអី" ។

មានកន្លែងមួយចំនួននៅក្នុងព្រះគម្ពីរ ហាក់ដូចជាបង្ហាញថាព្រះទ្រង់ប្រែប្រួល ជា ពិសេស ទាក់ទងទៅនឹងគោលបំណង ហើយនិងសេចក្តីសន្យារបស់ទ្រង់ ។ ឧទាហរណ៍៖ ព្រះមិនបានដាក់ទោសដល់ទីក្រុងនីនីវេ ដូចដែលទ្រង់បានសន្យាទេ នៅពេលដែលពួកគេបានប្រែចិត្ត (យ៉ូណា ៣:៤, ១០) ហើយនៅក្នុង និក្ខ ៣២:៩-១៤ និងអេសា ៣៨:១-៦ ក៏ស្រដៀងគ្នានេះដែរ ។ ប៉ុន្តែយើងគួរយល់ពីចំនុចទាំងអស់នេះថា ជាព្រះទ័យភ្លាមរបស់ព្រះ ដែលទាក់ទងទៅនឹងស្ថានភាពជាក់ស្តែងទាំងនោះប៉ុណ្ណោះ គឺថា នៅ ពេលដែលស្ថានភាពប្រែប្រួល អាកប្បកិរិយារបស់ព្រះក៏ប្រែប្រួលដែរ ។

ភាពមិនប្រែប្រួលរបស់ព្រះមិនមានន័យថា ទ្រង់នឹងមិនធ្វើ ឬ មិនមានអារម្មណ៍ផ្សេង ទៅនឹងស្ថានភាពផ្សេងៗនោះទេ ។ នេះជាមូលហេតុ ដែលទ្រង់យុត្តិធម៌ ពីព្រោះទ្រង់ឆ្លើយតបផ្សេងៗគ្នាចំពោះអំពើបាប ហើយនិងការប្រែចិត្តនិងសេចក្តីសុចរិត ។ ភាពមិនប្រែប្រួលរបស់ព្រះក៏មិនមានន័យថា ព្រះមិនដឹងពីអារម្មណ៍នោះដែរ ។ ជាការពិតណាស់ របៀបមួយដែលទ្រង់បង្ហាញថា "ព្រះមិនមែនជាមនុស្ស ទេ" គឺដោយមិនសំរេចតាមសេចក្តីកំហឹងដ៏សហ័សរបស់ទ្រង់ ហើយបំផ្លាញរាស្ត្ររបស់ទ្រង់ឡើយ ។ ប៉ុន្តែ ចិត្តរបស់ទ្រង់ "នឹង ប្រែប្រួលនៅក្នុងខ្លួន" ហើយ "សេចក្តីអាណិតអាសូរ" របស់ទ្រង់ "បានរំជួលឡើងជាមួយគ្នា" វិញ (ហូ ១១:៨-៩) ។

## ព្រះគង់នៅអស់កល្បជានិច្ច

ព្រះគង់នៅអស់កល្បជានិច្ច ទ្រង់គ្មានដើមដំបូង និងចុងបញ្ចប់ទេ ។ ហើយទ្រង់ក៏មិនគង់នៅក្នុងពេលវេលានៃព្រឹត្តិការណ៍នានាដែរ ។ យើងរៀនពីចំនុចនេះនៅក្នុងព្រះគម្ពីរទំនុកដំកើង ៩០:២ "គឺមុនដែលអស់ទាំងភ្នំបានកើតឡើង ក្នុងកាលដែលទ្រង់មិនទាន់បង្កើតផែនដី និងមនុស្សលោកនៅឡើយ ចាប់តាំងពីអស់កល្បរៀងទៅដ៏អស់កល្បជានិច្ច នោះ គឺទ្រង់ហើយជាព្រះ" ។ ទ្រង់ធ្វើការតាំងពីមុនកំណើតផែនដីម្ល៉េះ (អេ ១:៤) ។ ទ្រង់តែងតែគង់នៅជានិច្ច ទ្រង់ជាដើម ហើយជាចុង "អញជាអាល់ផា និងជាអូមេកា គឺជាដើមហើយជាចុង" (វិវ ១:៨) ។ ព្រះគម្ពីរយូដាស ១:២៥ "គឺជាព្រះអង្គដ៏ជាព្រះតែមួយ ជាព្រះអង្គសង្គ្រោះនៃយើងរាល់គ្នា

ដោយសារព្រះយេស៊ូវគ្រីស្ទ ជា ព្រះអម្ចាស់នៃយើង នោះសូមឲ្យទ្រង់បានសិរីល្អ ឫទ្ធានុភាព ព្រះចេស្តា និង អំណាច តាំងពីមុននៅជាន់ឥឡូវនេះ ហើយទៅដល់អស់កល្បជានិច្ចទៅ ។ អាម៉ែន" ។

ដោយព្រោះព្រះគង់នៅអស់កល្ប ដូចនេះការគិតពីពេលវេលារបស់ទ្រង់មានការខុសគ្នាពីយើង ។ ឧទាហរណ៍៖ "ដ្បិតនៅព្រះនេត្រទ្រង់ នោះមួយពាន់ឆ្នាំរាប់ដូចជាថ្ងៃម្សិលដែលកន្លងហួសទៅ ហើយក៏ដូចជាយាមមួយក្នុងវេលាយប់ប៉ុណ្ណោះ" (ទំនុក ៩០:៤) ។ ដូច្នេះគ្រប់ទាំងប្រវត្តិសាស្ត្រនៅអតីតកាល សំរាប់ព្រះគឺជារឿងដែលទើបតែបានកើតឡើងប៉ុណ្ណោះ ។ សាវកពេត្រុស បង្រៀនពីការនេះផងដែរ នៅពេលដែលគាត់បានសរសេរថា "តែពួកស្ងួនភ្ងាអើយ កុំឲ្យភ្លេចសេចក្តីមួយនេះឡើយ គឺថា នៅចំពោះព្រះអម្ចាស់ មួយថ្ងៃទុកដូចជាមួយពាន់ឆ្នាំ" ។ ប៉ុន្តែលោកក៏បានបង្រៀនយើងថា មួយថ្ងៃហាក់ដូចជារយៈពេលជារៀងរហូត "ហើយមួយពាន់ឆ្នាំក៏ទុកដូចជាមួយថ្ងៃដែរ" (២ពេ ៣:៨) ។

ពេលដែលយើងដាក់គំនិតទាំងពីរជាមួយគ្នា ធ្វើឲ្យយើងឃើញថា គ្រប់ទាំងប្រវត្តិសាស្ត្រ ព្រះ ទ្រង់អាចទតឃើញយ៉ាងច្បាស់ ដូចជារឿងដែលទើបនឹងកើតឡើងកាលពីម្សិលមិញអញ្ចឹង ។ ហើយទ្រង់ក៏ប្រើពេលមួយរំពេច ដែលមានរយៈពេលជារៀងរហូត ។ ព្រះទ្រង់ទតឃើញ ហើយជ្រាបគ្រប់ទាំងព្រឹត្តិការណ៍អតីតកាល បច្ចុប្បន្ន និងអនាគត យ៉ាងជាក់ច្បាស់ដូចៗគ្នា ។ ទោះបីជាគ្រប់ពេលវេលា សុទ្ធតែដូចគ្នាទាំងអស់នៅចំពោះទ្រង់ក៏ដោយ ក៏ទ្រង់អាចនឹងទតឃើញពេលវេលាក្នុងរបៀបដូចជាយើងបានដែរ ។ ទ្រង់បានបង្កើតពេលវេលា ហើយ

ទ្រង់គ្រប់គ្រងលើពេលវេលានោះ ហើយទ្រង់ប្រើពេលវេលានោះតាមរបៀបដែលទ្រង់សព្វព្រះហឫទ័យ ។

## ព្រះទ្រង់គង់នៅគ្រប់ទីកន្លែង

ទ្រង់គ្មានព្រំខណ្ឌក្នុងពេលវេលា ទ្រង់ក៏គ្មានព្រំខណ្ឌក្នុងលំហដែរ ។ ទ្រង់គង់នៅគ្រប់ទីកន្លែងក្នុងពេលតែមួយ ទ្រង់សព្វឧត្តភាព ។ ទ្រង់ពុំមានទំហំ ឬក៏ទ្រង់ទ្រាយទេ ។ ទ្រង់មិនអាចកំណត់ដោយលំហបានឡើយ ពីព្រោះទ្រង់បានបង្កើតលំហ (លោក ១:១) ។

ព្រះទ្រង់ក៏មានវត្តមានគ្រប់ទីកន្លែង ពាសពេញស្ថានសួគ៌ ហើយផែនដីផង (យេ ២៣:២៣-២៤) ។ ស្តេចដាវីឌបានសរសេរថា “តើទូលបង្គំនឹងទៅឯណាឲ្យរួចពីព្រះវិញ្ញាណទ្រង់ តើ នឹងរត់ទៅឯណាឲ្យរួចពីព្រះភ័ក្ត្រទ្រង់ ទោះ បើទូលបង្គំនឹងឡើងទៅឯស្ថានសួគ៌ ក៏មានទ្រង់សណ្ឋិតនៅទីនោះ ទោះបើទូលបង្គំនឹងរៀបដំណេកនៅស្ថានឃុំព្រលឹងមនុស្សស្លាប់នោះ ក៏ឃើញមានទ្រង់សណ្ឋិតនៅដែរ ទោះបើទូលបង្គំនឹងយកស្លាបនៃបច្ចូសកាលហោះទៅនៅឯទីបំផុតនៃសមុទ្រ គង់តែព្រះហស្តទ្រង់នឹងនាំទូលបង្គំនៅទីនោះ ហើយព្រះហស្តស្តាំទ្រង់នឹងក្តាប់ទូលបង្គំដែរ” (ទំនុក ១៣៩:៧-១០) ។ ព្រះមានវត្តមាននៅគ្រប់ទីកន្លែងទាំងអស់នៃលំហ “ផ្ទៃមេឃ និងអស់ទាំងជាន់នៃផ្ទៃមេឃ នោះមិនល្មមឲ្យទ្រង់គង់ចុះទៅហើយ”(១ពង្សា ៨:២៧) ។

ទោះបីជាទ្រង់មានវត្តមានគ្រប់ទីកន្លែង ប៉ុន្តែ វត្តមាន និងសកម្មភាពរបស់ទ្រង់មានភាពផ្សេងគ្នានៅកន្លែងផ្សេងគ្នា ។ ជាញឹកញាប់ ព្រះមានវត្តមាន គឺដើម្បីប្រទានពរ ដូចជានៅក្នុងព្រះគម្ពីរទំនុកដំកើង ១៦:១១ “នៅចំពោះទ្រង់មានសេចក្តីអំណរដ៏ពោរពេញ នៅព្រះហស្តស្តាំទ្រង់មានសេចក្តីអរសប្បាយជាដរាបតទៅ” ។ ហើយជួនកាល នៅកន្លែងផ្សេងទៀត ទ្រង់មានវត្តមាន មិនដើម្បីបង្ហាញការប្រទានពរទេ ប៉ុន្តែដើម្បីដាក់ទណ្ឌកម្ម ហើយបង្ហាញពីសេចក្តីយុត្តិធម៌របស់ទ្រង់វិញ ដូចជានៅស្ថាននរក (អេម ៩:១-៤) ។

ហើយជួនកាល ទ្រង់មានវត្តមាន គឺមិនដើម្បីប្រទានពរ ឬដាក់ទណ្ឌកម្មទេ តែផ្ទុយទៅវិញ ទ្រង់មានវត្តមាន គឺដើម្បីទ្រទ្រង់ចក្រវាឡ និង រក្សាមុខនាទីរបស់វាតាមរបៀបដែលទ្រង់សព្វព្រះហឫទ័យ ។ ក្នុងព្រះគ្រីស្ទ “ដ្បិតព្រះបានសព្វព្រះហឫទ័យ ឲ្យគ្រប់ទាំងសេចក្តីពោរពេញបានស្ថិតនៅក្នុងទ្រង់” (កូល ១:១៧) ។ ព្រះគ្រីស្ទនៅតែបន្តទ្រទ្រង់ “គ្រប់របស់ទាំងអស់ ដោយសារព្រះបន្ទូល” (ហេ ១:៣) ។

## ព្រះជាវិញ្ញាណ

ព្រះយេស៊ូវ បានបញ្ជាក់ថា ព្រះ មិនមានកំរិតនៅកន្លែងណាមួយទេ ពេលដែលព្រះយេស៊ូវមានបន្ទូលថា “ឯព្រះទ្រង់ជាវិញ្ញាណ” (យ៉ូន ៤:២៤) ។ ព្រះមានវត្តមាននៅក្នុងរបៀបមួយដែលមិនកើតឡើង ដោយសារធាតុណាមួយឡើយ ។ ទ្រង់គ្មានអវយវៈ គ្មានទំហំ ហើយទ្រង់ទ្រាយទេ ។ យើងមិនអាចដឹងទ្រង់ ដោយឥន្ទ្រិយ

វិញ្ញាណរបស់យើងបានឡើយ ។ ប្រសិនបើយើងប្រៀបធៀបទ្រង់នឹងអ្វីៗផ្សេងទៀត នៅក្នុងការបង្កើតរបស់ទ្រង់ យើងនឹងបកស្រាយខុស ពីព្រោះទ្រង់ល្អលើសជាជាងរបស់ទាំងនោះ ។

ប៉ុន្តែ ទ្រង់បានជ្រើសរើស បង្កើតយើងឲ្យមាននិស្ស័យខាងព្រលឹងវិញ្ញាណដូចទ្រង់ ហើយការនេះគ្រាន់តែដូចបន្តិចបន្តួចប៉ុណ្ណោះ ។ ទ្រង់បានប្រទានឲ្យយើងមានព្រលឹងវិញ្ញាណ ដើម្បីឲ្យយើងថ្វាយបង្គំទ្រង់ (យ៉ូន ៤:២៤) ។ សាវ័កប៉ុលបានសរសេរថា "ឯអ្នកដែលនៅជាប់នឹងព្រះអម្ចាស់ នោះក៏ជាវិញ្ញាណតែមួយជាមួយនឹងទ្រង់ដែរ" (១ កូរិន ៦:១៧) ។ ជាវិញ្ញាណតែមួយជាមួយនឹងព្រះ ព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់នៅក្នុងយើង ធ្វើទីបន្ទាល់ថា យើងជាកូនចិញ្ចឹមរបស់ទ្រង់ (រ៉ូម ៨:១៦) ។ នៅពេលដែលយើងស្លាប់ ប្រសិនបើយើងជាប់ជាមួយទ្រង់ព្រលឹងវិញ្ញាណរបស់យើងនឹងត្រឡប់ទៅឯព្រះ "ដែលទ្រង់បានប្រទានមក" (សាស្តា ១២:៧) ។

## យើងមិនអាចមើលឃើញព្រះបានទេ

ដោយព្រោះទ្រង់ជាវិញ្ញាណ យើងមិនអាចមើលឃើញទ្រង់បានឡើយ ។ "គ្មានអ្នកណាដែលឃើញព្រះឡើយ" (យ៉ូន ១:១៨) ។ ហើយក៏គ្មានអ្នកណានឹងដែលឃើញភាពជាវិញ្ញាណទាំងស្រុងរបស់ព្រះបានដែរ ។

ប៉ុន្តែ ព្រះគម្ពីរមានបទគម្ពីរខ្លះ ដែលបង្ហាញថា មានមនុស្សខ្លះបានឃើញរបស់ខ្លះនៃព្រះ ។ អេសាយបានប្រាប់យើងថា "ខ្ញុំឃើញព្រះអម្ចាស់ទ្រង់គង់លើ

បល្ល័ង្កនៅទីខ្ពស់ ហើយបានដំកើងឡើង" (អេសា ៦:១) ។ "រួចព្រះយេហូវ៉ាទ្រង់លេចមកឯគាត់ នៅត្រង់ដើមម៉ៃសាក់របស់ម៉ាមរេ" (លោក ១៨:១) ។ ហើយយ៉ាកុបបាននិយាយថា "អញបានឃើញព្រះនៅប្រទល់មុខ" (លោក ៣២:៣០) ។ នៅក្នុងឧទាហរណ៍នេះ និង ឧទាហរណ៍ផ្សេងទៀតដែលស្រដៀងគ្នានេះ ព្រះបានយកជាទំរង់នានាដើម្បីបង្ហាញអង្គទ្រង់ ដល់មនុស្ស ។ មានការលេចឡើងមួយដែលកាន់តែអស្ចារ្យជាងនោះ ដែលយើងបានឃើញនៅក្នុងតួអង្គព្រះយេស៊ូវគ្រីស្ទ ។ ដូចជាព្រះយេស៊ូវបានមានបន្ទូលហើយថា "អ្នកណាដែលឃើញខ្ញុំ នោះក៏បានឃើញព្រះវរបិតាដែរ" (យ៉ូន ១៤:៩) ។

ដោយព្រោះទ្រង់ជាវិញ្ញាណ គ្មាននរណាម្នាក់អាចឃើញព្រះទាំងស្រុងបានឡើយ ប៉ុន្តែ ជួនកាលទ្រង់បានបង្ហាញរបស់ខ្លះនៃព្រះដល់មនុស្សដែរ ។ ទ្រង់បានបើកសំដែងអង្គទ្រង់ដល់យើង តាមរយៈរបស់មើលឃើញដែលទ្រង់បានបង្កើតមក ជាពិសេស តាមរយៈអង្គព្រះយេស៊ូវគ្រីស្ទ ។

## ទ្រង់ជ្រាបគ្រប់ការទាំងអស់

ទ្រង់ "ជ្រាបគ្រប់ទាំងអស់" (១ យ៉ូន ៣:២០) ។ ព្រះទ្រង់ជ្រាបពីអង្គទ្រង់ទាំងស្រុង ហើយនិងអ្វីៗដែលកើតឡើង និងអ្វីៗដែលអាចនឹងកើតឡើងដែរ ។ ទ្រង់ជ្រាបអ្វីៗទាំងអស់ "គ្មានអ្វីកើតមកដែលទ្រង់ទតមិនឃើញនោះឡើយ គឺគ្រប់ទាំងអស់នៅជាអាក្រាត ហើយចំហនៅចំពោះព្រះនេត្រនៃព្រះ" (ហេ ៤:១៣) ។ ដ្បិតទ្រង់ជ្រាបទាំងអស់ពីអង្គទ្រង់ (១ កូ ២:១០-១១) ទ្រង់ជ្រាបគ្រប់ការទាំងអស់ដែល

ទ្រង់អាចនឹងបង្កើតបាន តែ ទ្រង់មិនបង្កើតវាមកទេ ។ ទ្រង់ក៏ជ្រាបផងដែរពីព្រឹត្តិការណ៍ដែលអាចនឹងមិនកើតឡើង និងព្រឹត្តិការណ៍ដែលអាចនឹងកើតឡើងប្រសិនបើព្រឹត្តិការណ៍ផ្សេងទៀតមិនបានកើតឡើងនៅក្នុងប្រវត្តិសាស្រ្ត (ម៉ាថ ១១:២១) ។

ព្រះតែងតែជ្រាបពីអ្វីៗទាំងអស់គ្រប់ពេលវេលា ។ ចំណេះដឹងរបស់ទ្រង់មិនដែលផ្លាស់ប្តូរ ឬរីកចំរើនលូតលាស់ឡើយ ។ គ្មានអ្វីមួយដែលអាចធ្វើឲ្យទ្រង់ភ្ញាក់ផ្អើលឡើយ ។ គ្មានអ្វីមួយដែលលាក់កំបាំងពីទ្រង់ឡើយ ។ តាំងពីអស់កល្បរៀងមក ព្រះបានជ្រាបពីការដែលនឹងត្រូវកើតឡើងរួចទៅហើយ ហើយនិងគ្រប់ទាំងការដែលទ្រង់នឹងធ្វើ ។

## ព្រះទ្រង់មានប្រាជ្ញាញាណ

ក្រៅពីជ្រាបគ្រប់ការទាំងអស់ ព្រះក៏មានប្រាជ្ញាញាណគ្រប់ការទាំងអស់ដែរ ។ ការនេះមានន័យថា ទ្រង់តែងតែជ្រើសរើសគោលដៅដែលប្រសើរបំផុត និងមធ្យោបាយដែលប្រសើរបំផុត ដើម្បីនឹងសំរេចគោលដៅនោះ ។ ព្រះ “ជាព្រះដ៏មានប្រាជ្ញាតែមួយព្រះអង្គ” (រ៉ូម ១៦:២៧) ។ ព្រះ “មានព្រះហឫទ័យប្រកបដោយប្រាជ្ញា” (យ៉ូប ៩:៤) ហើយទ្រង់ “មានទាំងប្រាជ្ញា និងឥទ្ធិឫទ្ធិផង ទ្រង់ក៏មានព្រះដំរិះ និងយោបល់ដែរ” (យ៉ូប ១២:១៣) ។

ប្រាជ្ញារបស់ទ្រង់ បានបង្ហាញនៅក្នុងវិស័យជាច្រើន ។ ឧទាហរណ៍៖ ដោយប្រាជ្ញារបស់ទ្រង់ ទ្រង់បានបង្កើតអ្វីៗគ្រប់ទាំងអស់ (ទំនុក ១០៤:២៤) ។

ប្រាជ្ញារបស់ទ្រង់ក៏បង្ហាញតាមរយៈអស់អ្នកដែលស្រឡាញ់ទ្រង់ ហើយនិងអស់អ្នកដែលបានត្រាស់ហៅមកតាមបំណងព្រះហឫទ័យទ្រង់ (រ៉ូម ៨:២៨) ។ គ្រប់ការទាំងអស់បានធ្វើការរួមគ្នាសំរាប់ការល្អដល់ពួកអ្នកជឿ ដោយសារប្រាជ្ញារបស់ទ្រង់ (រ៉ូម ៨:២៨) ។

ព្រះបានប្រទានប្រាជ្ញានេះដល់កូនរបស់ទ្រង់ ។ លោក យ៉ាកុបបានលើកទឹកចិត្តអ្នកអានថា "បើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញាមានតែសូមដល់ព្រះ ដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ដោយសទ្ធា ឥតបន្ទោសផង នោះទ្រង់នឹងប្រទានឲ្យ" (យ៉ា ១:៥) ។ ប្រាជ្ញានៃព្រះត្រូវបានរកឃើញ តាមរយៈការអាន និងស្តាប់បង្គាប់ព្រះបន្ទូលរបស់ទ្រង់ ហើយប្រាជ្ញានៃព្រះនេះ ធ្វើឲ្យទ្រង់ពេញព្រះហឫទ័យណាស់ ។ "សេចក្តីបន្ទាល់នៃព្រះយេហូវ៉ាជាពិត ក៏ធ្វើឲ្យមនុស្សខ្លៅល្ងង់មានប្រាជ្ញា" (ទំនុក ១៩:៧) ។

ទោះជាយ៉ាងណាក៏ដោយ យើងមិនអាចទទួលបានប្រាជ្ញាពីព្រះទាំងស្រុងនោះទេ ។ ពីព្រោះ "អើហ្ន៎ ប្រាជ្ញា និងចំណេះដឹងបរិបូររបស់ព្រះជ្រៅណាស់តើ ឯព្រះដំរិះរបស់ទ្រង់តើមានអ្នកណានឹងស្ទង់បាន ហើយផ្លូវទ្រង់ តើមានអ្នកណានឹងរកតាមបាន" (រ៉ូម ១១:៣៣) ។ ជួនកាល ទ្រង់នឹងអាចឲ្យយើងយល់ពីការដែលត្រូវកើតឡើង ប៉ុន្តែ នៅពេលផ្សេងទៀត យើងមិនអាចយល់ទាំងស្រុងពីមូលហេតុដែលការអ្វីមួយកើតឡើងទេ ។ កំឡុងគ្រាលំបាក យើងត្រូវតែ "ពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ" (សុ ៣:៥) ។

## ព្រះទ្រង់ពិតត្រង់

“ព្រះយេហូវ៉ាជាព្រះដ៏ពិត” (យេ ១០:១០)។ គ្រប់ទាំងចំណេះ និងគ្រប់ទាំងព្រះបន្ទូលរបស់ទ្រង់សុទ្ធតែពិតត្រង់ ហើយជាខ្នាតនៃសេចក្តីពិត ។ នៅពេលដែលព្រះមានបន្ទូលអ្វីមួយ យើងអាចទុកចិត្តថាទ្រង់នឹងធ្វើវា ទៅតាមអ្វីដែលទ្រង់បានមានបន្ទូល ។ យើងអាចទុកចិត្តថា ទ្រង់នឹងពិតត្រង់ចំពោះសេចក្តីសន្យារបស់ទ្រង់ (ជន ២៣:១៩) ។ ជាការពិតណាស់ សេចក្តីជំនឿពិតប្រាកដ គឺជាសេចក្តីជំនឿដែលទទួលព្រះបន្ទូលទ្រង់ និងពឹងលើទ្រង់ថា ទ្រង់នឹងធ្វើតាមការដែលទ្រង់បានសន្យា ។

យើងអាចយកតំរាប់តាមភាពពិតត្រង់របស់ព្រះ ដោយការព្យាយាម ឲ្យបានចំណេះដឹងពិតអំពីទ្រង់ និងព្រះបន្ទូលរបស់ទ្រង់ ។ យើងក៏អាចយកតំរាប់តាមភាពពិតត្រង់របស់ព្រះ ដោយភាពពិតត្រង់នូវអ្វីដែលយើងនិយាយ និងអ្វីដែលយើងធ្វើ (កូល ៣:៩-១០) ។

## ព្រះទ្រង់ល្អ

ព្រះយេស៊ូវមានបន្ទូលថា “គ្មានអ្នកណាល្អឡើយ មានតែមួយប៉ុណ្ណោះគឺជាព្រះ” (លូ ១៨:១៩) ។ ដូច្នេះ ព្រះជាខ្នាតនៃសេចក្តីពិត ។ ទ្រង់ល្អ ហើយ អ្វីដែលទ្រង់ធ្វើសុទ្ធតែល្អ ហើយគួរសរសើរ ។ គ្មានខ្នាតនៃសេចក្តីល្អណាខ្ពស់ជាងចរិតលក្ខណៈរបស់ព្រះឡើយ ហើយទ្រង់គាំទ្រនូវអ្វីដែលមានចរិតលក្ខណៈដូចទ្រង់ ។ ឧទាហរណ៍៖ សេចក្តីល្អ និងការគាំទ្រនៃសេចក្តីល្អរបស់ទ្រង់ បានបង្ហាញឲ្យឃើញ

នៅក្នុងការបង្កើតរបស់ទ្រង់ "ព្រះទ្រង់ទតគ្រប់ទាំងរបស់ដែលទ្រង់បានធ្វើនោះ ក៏ឃើញថា ទាំងអស់ជាការល្អប្រពៃ" (លោក ១:៣១) ។

ដោយព្រោះព្រះជាខ្លួនឯងនៃសេចក្តីល្អ ទ្រង់ក៏ជាប្រភពនៃសេចក្តីល្អទាំងអស់ដែរ ។ លោក យ៉ាកុប បានប្រាប់យើងថា "គ្រប់ទាំងរបស់ដ៏ល្អ ដែលព្រះប្រទានមក និងអស់ទាំងអំណោយទានដ៏គ្រប់លក្ខណ៍ នោះសុទ្ធតែមកពីស្ថានលើ គឺមកពីព្រះវរបិតានៃពន្លឺ" (យ៉ា ១:១៧) ។ ព្រះតែមួយប៉ុណ្ណោះ ដែលទ្រង់ប្រទានអំណោយទានល្អដល់កូនរបស់ទ្រង់ ។ ព្រះបានសន្យាថា "ទ្រង់នឹងមិនសំចៃទុករបស់ល្អអ្វីដល់ពួកអ្នកដែលដើរដោយទៀងត្រង់ឡើយ" (ទំនុក ៨៤:១១) ។ ព្រះយេស៊ូវបានបញ្ជាក់ការនេះ នៅពេលដែលទ្រង់បានមានបន្ទូលថា "ទ្រង់នឹងប្រទានរបស់ល្អ មកអស់អ្នកដែលសូម" (ម៉ាថ ៧:១១) ។ ដូច្នេះគ្រប់ទាំងសេចក្តីល្អដែលយើងស្វែងរក តាមពិតទៅ យើងរកបាននៅក្នុងព្រះផ្ទាល់ ។ អ្នកសរសេរកណ្ឌទំនុកដំកើងបានដឹងថា "នៅផែនដីទូលបង្គំប្រាថ្នាចង់បានតែទ្រង់ទេ" (ទំនុក ៧៣:២៥) ។

ជាញឹកញាប់ សេចក្តីល្អរបស់ព្រះអាចបង្ហាញឲ្យឃើញតាមរយៈសេចក្តីមេត្តាករុណា និងព្រះគុណរបស់ទ្រង់ ។ សេចក្តីមេត្តាករុណារបស់ទ្រង់ គឺជាសេចក្តីល្អចំពោះអស់អ្នកដែលកំសត់ និងមានទុក្ខលំបាក ។ ព្រះគុណរបស់ទ្រង់ គឺជាសេចក្តីល្អ ចំពោះអស់អ្នកដែលត្រូវទទួលទោសប៉ុណ្ណោះ ។ អស់អ្នកដែលទទួលសេចក្តីល្អរបស់ព្រះដែលមកតាមរយៈសេចក្តីមេត្តា និងព្រះគុណរបស់ទ្រង់ គួរបង្ហាញការល្អនេះដល់អ្នកឯទៀត ។ ដូចដែលសាវកប៉ុលបាននិយាយនៅក្នុង

គម្ពីរកាឡាទី ៦:១០ ថា “ដូច្នេះកាលណាយើងមានឱកាស នោះត្រូវធ្វើល្អដល់មនុស្សទាំងអស់ ហើយគឺដល់ពួកអ្នកជឿជាដើម” ។

## ព្រះជាសេចក្តីស្រឡាញ់

“ព្រះទ្រង់ជាសេចក្តីស្រឡាញ់” (១ យ៉ូន ៤:៨) ។ ព្រះតែងតែប្រទានអង្គទ្រង់ទុកជាសេចក្តីល្អសំរាប់អ្នកដទៃជាដរាប ។ ព្រះយេស៊ូវបានមានបន្ទូលថា និស្ស័យដែលប្រទានមិនចេះសំចៃនេះមានសកម្មភាព “តាំងតែពីមុនកំណើតលោកិយរៀងមក” (យ៉ូន ១៧:២៤) ។ ភស្តុតាងនៅក្នុងសេចក្តីស្រឡាញ់នោះ គឺជាសេចក្តីស្រឡាញ់ដែលព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធមានចំពោះគ្នា (យ៉ូន ១៤:៣១; ១៧:២៤) ។

យើងអាចឃើញសេចក្តីស្រឡាញ់ដ៏អស់កល្បនេះ នៅក្នុងសេចក្តីស្រឡាញ់ដែលប្រទានមិនចេះសំចៃ ដល់កូនរបស់ទ្រង់ ។ លោក យ៉ូហាន បានប្រាប់យើងថា “នេះហើយជាសេចក្តីស្រឡាញ់ មិនមែនថាយើងបានស្រឡាញ់ព្រះនោះទេ គឺទ្រង់បានស្រឡាញ់យើងវិញទេតើ ហើយបានចាត់ព្រះរាជបុត្រាទ្រង់ឲ្យមក ទុកជាដង្វាយឲ្យធួននឹងបាបយើងរាល់គ្នា” (១ យ៉ូន ៤:១០) ។ ហើយសាវក ប៉ុលបានសរសេរថា “ទ្រង់សំដែងសេចក្តីស្រឡាញ់របស់ទ្រង់ ដល់យើងរាល់គ្នាឲ្យឃើញច្បាស់ ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា នោះ គឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង” (រ៉ូម ៥:៨) ។

ដោយព្រោះព្រះទ្រង់បានស្រឡាញ់យើង ហើយទ្រង់នឹងស្រឡាញ់យើងជាដរាបតទៅ ដូច្នេះយើងអាចផ្តល់សេចក្តីស្រឡាញ់នោះដល់អ្នកដទៃទៀតដែរ ។ ជាការពិតណាស់ ព្រះយេស៊ូវបានសរុបទំនួលខុសត្រូវរបស់យើងចំពោះព្រះ ដោយមានបន្ទូលថា "ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ ជាព្រះនៃឯងឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង ហើយអស់អំពីគំនិតផង" ហើយ "ត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនផង" (ម៉ាថ ២២:៣៧-៣៩) ។ ត្រូវឲ្យសេចក្តីស្រឡាញ់របស់យើង ជាសេចក្តីស្រឡាញ់ដែលឲ្យមិនចេះសំចៃ ដូចជាសេចក្តីស្រឡាញ់របស់ព្រះយ៉ាងដូច្នេះដែរ (១ យ៉ូន ៣:១៦-១៧) ។ "យើងមិនត្រូវស្រឡាញ់ដោយពាក្យសំដីឬដោយបបូរមាត់ប៉ុណ្ណោះឡើយ គឺដោយការប្រព្រឹត្ត និងសេចក្តីពិតវិញ" (១ យ៉ូន ៣:១៨) ។

## ព្រះទ្រង់បរិសុទ្ធ

"ព្រះយេហូវ៉ា ជាព្រះនៃយើងខ្ញុំ ទ្រង់បរិសុទ្ធ" (ទំនុក ៩៩:៩) ។ នោះមានន័យថា ទ្រង់គង់នៅដាច់ពីអំពើបាប ហើយទ្រង់ផ្តោតលើការស្វែងរកកិត្តិយសទ្រង់ផ្ទាល់ ។ ជាញឹកញាប់ គេហៅព្រះថា "ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល" (ឧ៖ ទំនុក ៧១:២២) ។ ពួកសេរភីមដែលនៅជុំវិញបល្ល័ង្កទ្រង់ នៅ តែបន្លឺស្រែកឡើងថា "បរិសុទ្ធ បរិសុទ្ធ គឺជាព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់បរិសុទ្ធ" (អេសាយ ៦:៣) ។

សេចក្តីបរិសុទ្ធរបស់ព្រះត្រូវបានផ្តល់មកទុកជាគំរូ ដើម្បីឲ្យកូនរបស់ទ្រង់យកតំរាប់តាម ។ ទ្រង់មានបន្ទូលនៅក្នុងកណ្ឌលេវីវិន័យ ១៩:២ ថា "ត្រូវឲ្យឯងរាល់គ្នាបានបរិសុទ្ធ ដ្បិតអញនេះដែលជាព្រះយេហូវ៉ាជាព្រះនៃឯងរាល់គ្នា អញ

បរិសុទ្ធ” ។ តាមរយៈអំណាចព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ “ឲ្យបានញែកជាបរិសុទ្ធដែរ បើអ្នកណាគ្មានសេចក្ដីបរិសុទ្ធ នោះមិនដែលឃើញព្រះអម្ចាស់ឡើយ” (ហេ ១២:១៤) ។ អ្នកសរសេរកណ្ឌគម្ពីរហេព្រើរបានប្រាប់យើងថា ព្រះវាយផ្ចាលកូនរបស់ទ្រង់ “ដើម្បីឲ្យយើងបានសេចក្ដីបរិសុទ្ធរបស់ទ្រង់” (ហេ ១២:១០) ។ នៅពេលដែលទ្រង់កំពុងធ្វើឲ្យយើងម្នាក់ៗ និងពួកជំនុំបានបរិសុទ្ធ (អេ ៥:២៦-២៧) នោះយើងទទឹងរង់ចាំថ្ងៃដែលអ្វីៗទាំងអស់នៅស្ថានសួគ៌ និងផែនដី បានញែកចេញពីសេចក្ដីអាក្រក់ សំអាតពីអំពើបាប ហើយផ្ដោតទៅលើការស្វែងរកតែកិត្តិយសរបស់ព្រះ ដោយភាពបរិសុទ្ធប៉ុណ្ណោះ (សាក ១៤:២០-២១) ។

## ព្រះទ្រង់សុចរិត និងយុត្តិធម៌

លោក ម៉ូសេ បាននិយាយអំពីព្រះថា “អស់ទាំងផ្លូវទ្រង់សុទ្ធតែប្រកបដោយយុត្តិធម៌ ទ្រង់ជាព្រះដ៏ស្មោះត្រង់ ឥតមានសេចក្ដីទុច្ចរិតណាឡើយ ទ្រង់ក៏ត្រឹមត្រូវហើយទៀងត្រង់” (ចោទិ ៣២:៤) ។ ដូចជាលោក ម៉ូសេ បាននិយាយអញ្ចឹង ព្រះតែងតែធ្វើអ្វីៗដែលត្រឹមត្រូវ ពីព្រោះទ្រង់ផ្ទាល់ជាខ្នាតនៃអ្វីៗដែលត្រឹមត្រូវ ។ ជាចៅក្រមនៃលោកិយទាំងមូល ទ្រង់នឹងធ្វើអ្វីៗដែលត្រឹមត្រូវ (លោក ១៨:២៥) ។ ទ្រង់មានបន្ទូលពីសេចក្ដីពិត ហើយ “និយាយតាមសុចរិត អញថ្លែងប្រាប់សេចក្ដីដែលត្រឹមត្រូវ” (អេសា ៤៥:១៩) ។ ដូច្នេះ នៅពេលដែលយើងស្វែងរកអ្វីមួយដែលសុចរិត ហើយអ្វីមួយដែលយើងគួរធ្វើ យើងត្រូវតែព្យាយាមធ្វើការនោះទៅ

តាមចរិតលក្ខណៈដែលប្រកបដោយសីលធម៌របស់ព្រះ ពីព្រោះវាជាខ្លាតនៃសេចក្តីសុចរិត ។

ដោយព្រោះព្រះសុចរិត និងយុត្តិធម៌ ទ្រង់ត្រូវតែធ្វើចំពោះមនុស្សតាមការដែលពួកគេគួរទទួល ។ ដូច្នេះ ទ្រង់ត្រូវតែដាក់ទណ្ឌកម្មចំពោះអ្វីៗដែលប្រឆាំងនឹងទ្រង់ ដែលហៅថាអំពើបាប ។ ប៉ុន្តែ ជួនកាល ព្រះអត់ទោសចំពោះអំពើបាបរបស់ពួកគេ ហើយទ្រង់ក៏មិនដាក់ទណ្ឌកម្មចំពោះអំពើបាបរបស់ពួកគេដែរ ។ តើទ្រង់ធ្វើយ៉ាងដូច្នេះម្តេចបាន បើសិនជាទ្រង់សុចរិត ? ព្រះអាចអត់ទោសដល់មនុស្សបានដោយព្រោះព្រះគ្រីស្ទបានសុគត ដើម្បីទទួលការដាក់ទណ្ឌកម្មរបស់ព្រះចេញពីពួកគេ មកដាក់លើអង្គទ្រង់វិញ “ដែលព្រះបានតាំងទ្រង់ ទុកជាទីសន្តោសប្រោសដោយសារសេចក្តីជំនឿដល់ព្រះលោហិតទ្រង់ សំរាប់នឹងសំដែងឲ្យឃើញសេចក្តីសុចរិតរបស់ព្រះ ចំពោះការដែលទ្រង់មិនប្រកាន់អំពើបាប ដែលគេប្រព្រឹត្តិពីដើមដោយទ្រង់មានព្រះហប្ញទ័យអត់ធ្មត់ ដើម្បីនឹងសំដែងឲ្យឃើញសេចក្តីសុចរិតរបស់ព្រះនៅជាន់ឥឡូវនេះ ប្រយោជន៏ឲ្យទ្រង់បានសុចរិត ព្រមទាំងរាប់ពួកអ្នកដែលមានសេចក្តីជំនឿជឿដល់ព្រះយេស៊ូវ ថាជាសុចរិតដែរ” (រ៉ូម ៣:២៥-២៦) ។

ដោយព្រោះព្រះមានអំណាចព្រះចេស្តា គ្រប់ការទាំងអស់ទ្រង់បានធ្វើឲ្យបានសុចរិតនៅទីបំផុត ។ ទ្រង់នឹងនាំមកនូវសេចក្តីយុត្តិធម៌ ។ យើងបានទទួលអត្ថប្រយោជន៍ពីសេចក្តីសុចរិត និងសេចក្តីយុត្តិធម៌របស់ទ្រង់ ដូច្នេះយើងគួរចូលរួមជាមួយទ្រង់ ដែលទ្រង់ជាចៅក្រមនៃលោកិយទាំងមូល ដោយយើងធ្វើអ្វីៗដែលសុចរិត ។ យើងគួរព្យាយាមធ្វើអ្វីដែលសុចរិតជានិច្ច ហើយយើងគួរនាំយក

សេចក្ដីសុចរិតនេះមក សំរាប់អស់អ្នកណាដែលមិនទាន់មានបទពិសោធន៍ខាងសេចក្ដីសុចរិតនេះនៅឡើយ ។ ដូចជា គម្ពីរសុភាសិត ២១:៣ ចែងថា “ការដែលប្រព្រឹត្តិតាមសេចក្ដីសុចរិត និងសេចក្ដីយុត្តិធម៌ នោះជាទីគាប់ព្រះហឫទ័យដល់ព្រះយេហូវ៉ា ជាជាងយញ្ញបូជាទៅទៀត” ។

## ព្រះទ្រង់មានសេចក្ដីប្រចណ្ឌ

នៅពេលកំពុងតែពន្យល់ពីក្រិត្យវិន័យទីមួយ ព្រះមានបន្ទូលថា “ដ្បិតអញដែលជាយេហូវ៉ា ជា ព្រះនៃឯង អញមានសេចក្ដីប្រចណ្ឌ” (និក្ខមនំ ២០:៥) ។ នៅក្នុងសេចក្ដីប្រចណ្ឌរបស់ទ្រង់ ទ្រង់នៅតែបន្តការការពារសិរីរុងរឿងផ្ទាល់របស់ទ្រង់ ។ ទ្រង់សព្វព្រះហឫទ័យចង់ឲ្យការថ្វាយបង្គំ បានថ្វាយតែចំពោះទ្រង់ប៉ុណ្ណោះ ហើយមិនត្រូវថ្វាយដល់អ្នកណាមួយ ឬអ្វីមួយផ្សេងទៀតបានឡើយ ។ ការដែលទ្រង់តែងតែស្វែងរកសិរីរុងរឿងផ្ទាល់របស់ទ្រង់ នោះមិនមែនជារឿងខុសឡើយពីព្រោះ នេះគឺជាសិរីរុងរឿងដែលទ្រង់សមទទួល ដ្បិតទ្រង់ជាព្រះ ។ មូលហេតុនេះហើយ បានជាទ្រង់អាចនិយាយដោយត្រឹមត្រូវថា “ឯសិរីល្អរបស់អញៗមិនព្រមលើកឲ្យទៅអ្នកដទៃឡើយ” (អេសា ៤៨:១១) ។

## ព្រះទ្រង់មានសេចក្ដីក្រោធចំពោះអំពើបាប

ព្រះស្អប់អំពើបាបខ្លាំងណាស់ ។ សេចក្ដីខ្ញាល់របស់ព្រះ ទាស់ប្រឆាំងដ៏សហ័សនឹងអំពើបាប ហើយសេចក្ដីខ្ញាល់នេះ នឹងបំផ្លាញអ្នកដែលបដិសេធព្រះយេស៊ូវ និង

អ្នកដែលនៅតែបន្តប្រព្រឹត្តអំពើបាប ឲ្យវិនាសបង់ ។ ដូចជាព្រះយេស៊ូវមានបន្ទូលថា "តែអ្នកណាដែលមិនព្រមជឿដល់ព្រះរាជបុត្រាវិញ នោះនឹងមិនឃើញជីវិតសោះឡើយ គឺសេចក្តីក្រោធរបស់ព្រះតែងនៅជាប់លើអ្នកនោះឯង" (យ៉ូន ៣:៣៦) ។ ហើយសាវក ប៉ុលបាននិយាយថា "ពីព្រោះសេចក្តីក្រោធរបស់ព្រះបានសំដែងពីស្ថានសួគ៌ទាស់នឹងគ្រប់ទាំងសេចក្តីទមិឡល្មើស និងសេចក្តីទុច្ចរិតរបស់មនុស្សដែលគេបង្ខាំងសេចក្តីពិតដោយសេចក្តីទុច្ចរិត" (រ៉ូម ១:១៨) ។

ដូច្នេះសេចក្តីក្រោធជាលក្ខណៈមួយរបស់ទ្រង់ ដែលយើងគួរអរព្រះគុណ និងសរសើរដល់ទ្រង់ ។ ប្រសិនបើ ទ្រង់សប្បាយរីករាយចំពោះអំពើបាប ឬក៏មិនអើពើចំពោះអំពើបាប នោះទ្រង់មិនស័ក្តិសមឲ្យយើងថ្វាយបង្គំទេ ។ អំពើបាបជាអ្វីដែលយើងគួរស្អប់ខ្ពើម ។ ជាការពិតណាស់ យើងបានទទួលការលើកទឹកចិត្តពីគំរូរបស់ព្រះគ្រីស្ទដែលទ្រង់ស្អប់ចំពោះអំពើបាប និងការអាក្រក់ "ទ្រង់បានស្រឡាញ់សេចក្តីសុចរិត ហើយស្អប់ការទទឹងច្បាប់" (ហេព្រើរ ១:៩) ។ យើងមិនគួររីករាយចំពោះអ្នកដែលកំពុងតែវិនាសទេ តែយើងគួរតែស្រឡាញ់ និងអធិស្ឋានឲ្យវិញ ដើម្បីឲ្យពួកគេប្រែចិត្តពីការអាក្រក់ ។ ប៉ុន្តែ យើងក៏គួរតែរីករាយចំពោះការដាក់ទណ្ឌកម្មនៃការអាក្រក់ផងដែរ ។ យើងគួរអធិស្ឋានសំរាប់អ្នកដែលធ្វើបាប ដើម្បីឲ្យពួកគេបានទុកចិត្តដល់ទ្រង់ សំរាប់ការអត់ទោស ។ អស់អ្នកណាដែលទុកចិត្តដល់ព្រះគ្រីស្ទ នោះនឹងបានរួចចេញពីសេចក្តីក្រោធរបស់ព្រះ ពីព្រោះការដាក់ទណ្ឌកម្មដ៏យុត្តិធមិ៌របស់ព្រះ បានធ្លាក់មកលើព្រះគ្រីស្ទនៅលើឈើឆ្កាងហើយ(រ៉ូម ៣:២៥; ៥:៨-៩) ។ ដូច្នេះ អស់អ្នកដែលជឿដល់ព្រះគ្រីស្ទ មិនគួរខ្លាចសេចក្តី

ក្រោធរបស់ព្រះឡើយ ។ សេចក្តីក្រោធដែលយើងសមទទួលនោះ បានធ្លាក់លើព្រះយេស៊ូវទាំងស្រុងហើយ ។ តាមរយៈការសុគត និងការរស់ឡើងវិញ ព្រះយេស៊ូវ “ប្រោសឲ្យយើងរួចពីសេចក្តីខ្ញាល់ទៅមុខ” (១ ថែស ១:១០) ។ ប៉ុន្តែផ្ទុយទៅវិញ អស់អ្នកដែលបដិសេធព្រះយេស៊ូវវិញ គួរខ្លាចសេចក្តីក្រោធរបស់ព្រះ ព្រោះសេចក្តីក្រោធនោះជាប់នៅទាំងស្រុងលើពួកគេ (យ៉ូន ៣:៣៦) ។

## ព្រះធ្វើអ្វីដែលទ្រង់សព្វព្រះហឫទ័យ

ព្រះតែងតែ “ធ្វើគ្រប់ការទាំងអស់តាមដែលគាប់ព្រះហឫទ័យទ្រង់” (អេ ១:១១) ។ ព្រះហឫទ័យរបស់ព្រះ ជា មូលហេតុដ៏ចំបងបំផុតដែលអ្វីគ្រប់យ៉ាងកើតឡើង ។ ព្រះហឫទ័យរបស់ព្រះ ជាអ្វីដែលព្រះបានអនុម័ត និងកំណត់ ថានឹងធ្វើនូវអ្វីៗគ្រប់យ៉ាងដែលចាំបាច់ សំរាប់ការគង់នៅរបស់ទ្រង់ និងគ្រប់ទាំងអ្វីៗដែលទ្រង់បានបង្កើតមក ។ ព្រះហឫទ័យរបស់ព្រះ ជារបៀបដែលទ្រង់ជ្រើសរើស ដើម្បីធ្វើ ឬមិនធ្វើអ្វីមួយ ។

ឧទាហរណ៍៖ អ្វីៗគ្រប់យ៉ាងបានកើតមកតាមព្រះហឫទ័យរបស់ព្រះ (វិវរ ៤:១១); រដ្ឋាភិបាលមានអំណាចតាមព្រះហឫទ័យទ្រង់ (រ៉ូម ១៣:១); ហើយជួនកាល ជាព្រះហឫទ័យរបស់ព្រះដែរ ដែលកូនរបស់ទ្រង់រងទុក្ខ (១ ពេ ៣:១៧) ។ គ្រប់ទាំងព្រឹត្តិការណ៍នៅក្នុងជីវិតរបស់យើង កើតឡើងទៅតាមព្រះហឫទ័យរបស់ព្រះ ។ មូលហេតុនេះហើយ ដែលលោក យ៉ាកុប បានលើកទឹកចិត្តយើងថា មិនត្រូវនិយាយថា យើងនឹងធ្វើនេះ ឬធ្វើនោះឡើយ ប៉ុន្តែ យើងគួរនិយាយ “ដូច្នេះ

វិញថា បើយើងរស់នៅ ហើយព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យ នោះយើងនឹងធ្វើការនេះ ឬការនោះ” (យ៉ាកុប ៤:១៥) ។

សូម្បីតែការសុគតរបស់ព្រះគ្រីស្ទ និងព្រឹត្តិការណ៍នានាជុំវិញវា បានកើតឡើងទៅតាមបំណងព្រះហឫទ័យនៃព្រះ ។ លោក លូកា បានប្រាប់យើងនៅគម្ពីរកិច្ចការ ៤:២៧-២៨ ថាអស់អ្នកណាដែលចូលរួមជាមួយការសុគតរបស់ព្រះគ្រីស្ទបាន “ធ្វើអស់ទាំងការដែលព្រះហស្តទ្រង់ និងព្រះតំរិះទ្រង់បានគិតសំរេចជាមុន” ។ ជួនកាល ព្រះហឫទ័យរបស់ព្រះបានសំដែងឲ្យឃើញយ៉ាងច្បាស់ ដូចជា នៅពេលដែលព្រះគម្ពីរបានប្រាប់យើងពីអ្វីមួយដែលយើងត្រូវធ្វើ ឬក៏អ្វីមួយដែលព្រះបានបង្គាប់ចំៗយើងឲ្យធ្វើ ។ នេះជាអ្វីដែលព្រះយេស៊ូវបានមានបន្ទូលប្រាប់យើងឲ្យអធិស្ឋាន “សូមឲ្យព្រះហឫទ័យទ្រង់បានសំរេចនៅផែនដី ដូចនៅស្ថានសួគ៌ដែរ (ម៉ាថាយ ៦:១០) ។

នៅពេលផ្សេងទៀត បទគម្ពីរពុំបានផ្តល់ឲ្យយើងនូវការណែនាំច្បាស់លាស់ ថា យើងត្រូវធ្វើអ្វីមួយ ឬរបៀបណាមួយដែលយើងត្រូវធ្វើទេ ។ នៅពេលនោះ យើងគួរបន្ទាបអរកប្បកិរិយា និងពឹងលើការគ្រប់គ្រងលើព្រឹត្តិការណ៍របស់ព្រះ នៅក្នុងជីវិតរបស់យើង ។ យើងគួរធ្វើគំរោងជំហានរបស់យើង ដូចជាលោកយ៉ាកុប បានលើកទឹកចិត្តយើង “ដូច្នេះវិញថា បើយើងរស់នៅ ហើយព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យ នោះយើងនឹងធ្វើការនេះ ឬការនោះ” (យ៉ាកុប ៤:១៥) ។

ដូច្នេះនៅក្នុងស្ថានភាពពិបាកៗ ប្រសិនបើព្រះគម្ពីរមិនបានចែងយ៉ាងច្បាស់ទេ យើងត្រូវតែប្រុងប្រយ័ត្នក្នុងការដែលនិយាយថា ការនោះជាបំណង

ព្រះហឫទ័យរបស់ព្រះ ។ ឧទាហរណ៍៖ ជាការគ្រោះថ្នាក់ណាស់ នៅពេលដែលយើងនិយាយថា ព្រឹត្តិការណ៍អាក្រក់នានាបានកើតឡើងតាមព្រះហឫទ័យរបស់ព្រះ ទោះបីជា យើងអាចនឹងរកកន្លែងណាមួយនៅក្នុងព្រះគម្ពីរដែលនិយាយរបៀបនេះក៏ដោយ ។ ប្រសិនបើយើងពន្យល់អំពីការអាក្រក់ថា វាជាលទ្ធផលមួយដែលកើតឡើងដោយបំណងព្រះហឫទ័យរបស់ព្រះ នោះអាចនឹងស្តាប់ទៅហាក់ដូចជាយើងបន្ទោសដល់ព្រះពីអំពើបាប ឬ ការអាក្រក់នោះ ឬក៏ ហាក់ដូចជាព្រះទ្រង់សព្វព្រះទ័យនឹងការអាក្រក់អញ្ចឹង ។ ប៉ុន្តែ នេះមិនមែនជាករណីឡើយ ។ នៅក្នុងព្រះគម្ពីរតែងតែបន្ទោសដល់មនុស្ស និង ទេវតាអាក្រក់ (អារក្ស) ប៉ុណ្ណោះសំរាប់ការអាក្រក់ ។ តែព្រះមិនត្រូវបានបន្ទោសឡើយ ។ សូម្បីតែការសុគតរបស់ព្រះគ្រីស្ទព្រះគម្ពីរបានចែងថា គឺជាការដែលកើតឡើងតាមគំរោងការរបស់ព្រះ ប៉ុន្តែការនោះបានសំរេចដោយ “សារដៃមនុស្សទទឹងច្បាប់ ព្រមទាំងឆ្កាងសំលាប់ទ្រង់ផង” (កិច្ច ២:២៣) ។

យើងមិនគួរបន្ទោសព្រះ ក្នុងការដែលការអាក្រក់កើតឡើងឡើយ ឬក៏កុំឲ្យគិតថាទ្រង់ត្រូវទទួលខុសត្រូវចំពោះអំពើបាបនោះដែរ ។ ទំនាក់ទំនងពិតប្រាដកវវាងបំណងព្រះហឫទ័យរបស់ព្រះ និងការអាក្រក់ មិនត្រូវបានបើកសំដែងមកឲ្យច្បាស់លាស់ទាំងស្រុងនោះទេ ។ ដូច្នេះយើងត្រូវតែទទួលការកំសាន្តចិត្តនៅក្នុងព្រះគម្ពីរ “ឯអស់ទាំងសេចក្តីលាក់កំបាំងនោះស្រេចនៅព្រះយេហូវ៉ាជាព្រះនៃយើងរាល់គ្នាទេ” (ចោទិ ២៩:២៨) ។

## ព្រះជាម្ចាស់មានសេរីភាព

ព្រះគម្ពីរទំនុកដំកើង ១១៥:៣ ចែងថា “ចំណែកព្រះនៃយើងខ្ញុំ ទ្រង់គង់នៅស្ថានសួគ៌ ទ្រង់បានធ្វើការដែលគាប់ដល់ព្រះហឫទ័យទ្រង់ហើយ” ។ គ្មានអ្វីអាចរារាំងទ្រង់ មិនឲ្យធ្វើតាមបំណងព្រះហឫទ័យទ្រង់ឡើយ ។ ក្រៅពីអង្គទ្រង់ផ្ទាល់ គ្មានអ្វីណាមួយដាក់កំរិតដល់ទ្រង់ឡើយ ហើយទ្រង់មានសេរីភាពពេញលេញដើម្បីធ្វើអ្វីៗដែលទ្រង់សព្វព្រះហឫទ័យចង់ធ្វើ ។ ទ្រង់មិននៅក្រោមអំណាច ឬ ទទួលការដាក់កំរិតដោយអ្នកណាម្នាក់ឡើយ ហើយក៏គ្មានអ្នកណាម្នាក់ ឬ អំណាចណាមួយអាចប្រាប់ឲ្យទ្រង់ធ្វើអ្វីមួយនោះដែរ ។

នៅពេលដែលយើងមានបំណងធ្វើអ្វីមួយ និងធ្វើការសំរេចចិត្តពីអ្វីមួយ យើងអាចធ្វើត្រាប់តាមព្រះនៅក្នុងសេរីភាពរបស់ទ្រង់ ប៉ុន្តែគ្រប់ទាំងការសំរេចចិត្តនោះ ត្រូវទៅតាមបំណងព្រះហឫទ័យព្រះ ។ ព្រះគម្ពីរសុភាសិត ១៦:៩ ប្រាប់យើងថា “ចិត្តរបស់មនុស្សរមែងគិតសំរេចផ្លូវរបស់ខ្លួន តែគឺព្រះយេហូវ៉ាដែលទ្រង់តំរង់ជំហានគេវិញ” ។ ព្រះគម្ពីរចែងថា សូម្បីតែស្តេច “ព្រះទ័យនៃស្តេច នោះនៅក្នុងព្រះហស្តព្រះយេហូវ៉ា ដូចជាផ្លូវនៃទឹកហូរទាំងឡាយ ទ្រង់ឲ្យបែរហូរទៅខាងណាក៏តាមតែព្រះហឫទ័យ” (សុ ២១:១) ។

## ព្រះជាម្ចាស់មានគ្រប់អំណាចព្រះចេស្តា

នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ១៨:១៤ មានសំនួរមួយសួរថា “តើមានការអ្វីដែលព្រះយេហូវ៉ាធ្វើមិនកើតដែរឬទេ ?” ។ មានចំលើយជាច្រើនកន្លែងនៅក្នុងព្រះគម្ពីរ

សំរាប់សំនួរនេះ ។ លោកយេរេមាបាននិយាយទៅកាន់ព្រះថា "គ្មានអ្វីដែលពិបាកពេកដល់ទ្រង់ទេ" (យេ ៣២:១៧) ។

ទ្រង់មានគ្រប់អំណាចព្រះចេស្តាទ្រង់អាចធ្វើគ្រប់ការទាំងអស់បាន តាមបំណងព្រះហឫទ័យដ៏បរិសុទ្ធរបស់ទ្រង់ ។ គ្មានអ្វីណាមួយអាចដាក់កំរិតលើអ្វីៗដែលទ្រង់បានសំរេចព្រះហឫទ័យធ្វើបានឡើយ ។ សាវកប៉ុលប្រាប់យើងថា "ឯព្រះដែលទ្រង់អាចនឹងធ្វើអ្វីហួសសន្ធឹកលើសជាងអស់ទាំងសេចក្តី ដែលយើងសូម ឬគិតក្តី តាមព្រះចេស្តាដែលបណ្តាលក្នុងយើងរាល់គ្នា" (អេ ៣:២០) ។ ព្រះយេស៊ូវមានបន្ទូលថា "ការនោះមនុស្សលោកធ្វើមិនកើតទេ តែព្រះទ្រង់អាចនឹងធ្វើការទាំងអស់" (ម៉ាថ ១៩:២៦) ។ ព្រះចេស្តារបស់ព្រះគ្មានដែនកំនត់ទេ ។

ប៉ុន្តែព្រះមានអ្វីៗមួយចំនួន ដែលទ្រង់ធ្វើមិនបាន ។ ទ្រង់ មិនអាចធ្វើអ្វីមួយដែលផ្ទុយពីចរិតលក្ខណៈរបស់ទ្រង់ផ្ទាល់បានឡើយ ។ ឧទាហរណ៍៖ ទ្រង់មិនអាចកុហក (ទីត ១:២) ។ ទ្រង់មិនអាចត្រូវសេចក្តីល្បួងបានទេ (យ៉ា ១:១៣) ។ ហើយទ្រង់ក៏មិនអាចបដិសេធខ្លួនឯងដែរ (២ ធី ២:១៣) ។ ដូច្នេះការប្រើប្រាស់នៃអំណាចដ៏គ្មានព្រំដែនរបស់ទ្រង់ ត្រូវបានគ្រប់គ្រងដោយលក្ខណៈដ៏មានអំណាចព្រះចេស្តាដទៃទៀតរបស់ទ្រង់ ។

យើងធ្វើត្រាប់តាមព្រះ នូវអំណាចដែលទ្រង់បានប្រទានមកយើង នៅពេលដែលយើងបានសំរេចជោគជ័យនូវអ្វីមួយ ដែលទ្រង់សព្វព្រះទ័យឲ្យយើងធ្វើ ។ នៅក្នុងរបៀបនេះ យើងបានបង្ហាញការឆ្លុះបញ្ចាំងព្រាលៗនៃអំណាចដ៏គ្មានព្រំដែនរបស់ទ្រង់ ហើយនិងថ្វាយសេរីល្អដល់ទ្រង់ ។

## ព្រះជាម្ចាស់គ្រប់លក្ខណ៍

ព្រះយេស៊ូវមានបន្ទូលប្រាប់ដល់យើងនៅក្នុងព្រះគម្ពីរម៉ាថាយ ៥:៤៨ ថា “ដូច្នេះ ចូរឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ ដូចជាព្រះវរបិតានៃអ្នកដែលគង់នៅស្ថានសួគ៌ ទ្រង់គ្រប់លក្ខណ៍ដែរ” ។ មានន័យថា ព្រះទ្រង់មានគ្រប់ទាំងគុណលក្ខណៈដ៏ល្អបំផុត ហើយមិនខ្វះផ្នែកណាមួយនៃគុណលក្ខណៈទាំងនោះឡើយ ។ យើងអាចធ្វើត្រាប់តាមភាពគ្រប់លក្ខណ៍របស់ទ្រង់ ដោយការខិតខំព្យាយាម ដើម្បីឲ្យបានគ្រប់លក្ខណ៍ ដូចជាព្រះយេស៊ូវបានបង្គាប់យើងឲ្យធ្វើ (ម៉ាថ ៥:៤៨) ។ ទោះបីជា យើងមិនបានទទួលសេចក្តីគ្រប់លក្ខណ៍ ដូចដែលយើងចង់បាននៅនាលោកិយនេះក៏ដោយ ប៉ុន្តែ តាមរយៈកិច្ចការនៃព្រះគ្រីស្ទក្នុងនាមយើងរាល់គ្នា នោះ យើងរាល់គ្នានឹងបានរីកចំរើនបន្តិចម្តងៗ ឆ្ពោះទៅកាន់សេចក្តីគ្រប់លក្ខណ៍ក្នុងជីវិតរបស់យើង ។

## ព្រះជាម្ចាស់ទ្រង់ប្រកបដោយព្រះពរ

នេះមានន័យថា ព្រះសព្វព្រះហឫទ័យអង្គទ្រង់ផ្ទាល់ និងអ្វីៗដែលឆ្លុះបញ្ចាំងពីលក្ខណៈរបស់ទ្រង់ ។ ទ្រង់គឺជាប្រភពនៃសុភមង្គល និងសេចក្តីសប្បាយរីករាយ ដូច្នេះទ្រង់មានសេចក្តីរីករាយដ៏ពេញបរិបូរនៅក្នុងអង្គទ្រង់ ។

ប៉ុន្តែ ព្រះក៏បានរីករាយនៅក្នុងការបង្កើតរបស់ទ្រង់ដែរ ។ នៅពេលដែលទ្រង់បានទតឃើញអ្វីៗដែលទ្រង់បានបង្កើត ទ្រង់មានបន្ទូលថា “ទាំងអស់ជាការល្អប្រពៃ” (លោក ១:៣១) មានន័យថា ទ្រង់សប្បាយព្រះហឫទ័យចំពោះអ្វីៗដែល

ទ្រង់បានបង្កើត ។ ព្រះចង់ទទួលនូវសេចក្តីរីករាយចំពោះកូនរបស់ទ្រង់ខ្លាំងណាស់ “ដ្បិតដែលមនុស្សកំលោះយកស្រីក្រមុំធ្វើជាប្រពន្ធយ៉ាងណា នោះពួកកូនប្រុសៗរបស់ឯងនឹងមករួមនឹងឯងយ៉ាងនោះដែរ ហើយដែលប្តីថ្មោងថ្មីមានចិត្តរីករាយចំពោះប្រពន្ធយ៉ាងណា នោះព្រះនៃឯងនឹងមានសេចក្តីរីករាយចំពោះឯងយ៉ាងនោះដែរ” (អេសា ៦២:៥) ។

នៅពេលដែលយើងរកបានសុភមង្គល ដែលគាប់ព្រះហឫទ័យដល់ទ្រង់នោះ គឺយើងបានបង្ហាញពីរបៀបផ្សេងៗដែលព្រះបានប្រទានពរដល់យើងហើយដូចជា ការប្រព្រឹត្តិរបស់មនុស្ស, អ្វីៗនៃការបង្កើត ឬក៏ផ្នែកមួយចំនួននៃជីវិតរបស់យើង ។ ដូច្នេះយើងត្រូវថ្វាយកិត្តិយស និងធ្វើត្រាប់តាមនៅក្នុងការទទួលព្រះពររបស់ទ្រង់ ។ ព្រះគឺជាព្រះពរដ៏ធំរបស់យើង ហើយជាប្រភពនៃគ្រប់ទាំងការល្អ ។

## ព្រះទ្រង់មានសេចក្តីលំអ

នៅក្នុងព្រះគម្ពីរទំនុកដំកើង ២៧:៤ ស្តេចដាវីឌនិយាយថា “ខ្ញុំបានសុំសេចក្តីតែមួយពីព្រះយេហូវ៉ា ហើយនឹងស្វែងរកសេចក្តីនោះឯង គឺឲ្យខ្ញុំបាននៅក្នុងដំណាក់នៃព្រះយេហូវ៉ារាល់តែថ្ងៃអស់មួយជីវិតខ្ញុំ ដើម្បីនឹងរំពឹងមើលសេចក្តីលំអរនៃព្រះយេហូវ៉ា” ។ ព្រះគឺជាការសរុបចូលគ្នានៃគុណភាពគួរចង់បាន ហើយទ្រង់មានគ្រប់ទាំងគុណលក្ខណ:គួរចង់បានទាំងនោះ ។ ដូច្នេះស្តេចដាវីឌបានរកឃើញថាយើងអាចសំរេចបំណងរបស់យើងបាននៅក្នុងព្រះប៉ុណ្ណោះ គឺជាព្រះតែមួយដែលមានសេចក្តីលំអពិតប្រាកដនោះ ។

## ព្រះជាម្ចាស់មានភាពតែមួយ

ទោះបីជាលក្ខណៈមួយចំនួនរបស់ព្រះ ហាក់ដូចជាផ្តោតសំខាន់ជាង លក្ខណៈផ្សេងទៀតក៏ដោយ ប៉ុន្តែវាមានសារៈសំខាន់ដែលយើងត្រូវដឹងថាទ្រង់មានភាពតែមួយនៅក្នុងលក្ខណៈរបស់ទ្រង់ ។ ទ្រង់មិនមានលក្ខណៈណាមួយលើសជាជាងលក្ខណៈណាមួយផ្សេងទៀតឡើយ ។ ទ្រង់មិនបែងចែកជាផ្នែកៗនោះទេ ។ ទ្រង់មិនមានលក្ខណៈមួយនៅថ្ងៃនេះ ហើយមានលក្ខណៈផ្សេងទៀតនៅថ្ងៃស្អែកទេ ។ ទ្រង់មានគ្រប់លក្ខណៈពេញលេញគ្រប់ពេលវេលា ។

ព្រះគម្ពីរមិនដែលប្រាប់យើងថា មានលក្ខណៈណាមួយរបស់ព្រះមានសារៈសំខាន់ជាងលក្ខណៈផ្សេងទៀតរបស់ទ្រង់ទេ ។ ឧទាហរណ៍៖ “ព្រះទ្រង់ជាពន្លឺភ្លឺ” (១យ៉ូន ១:៥) ហើយ “ ព្រះទ្រង់ជាសេចក្តីស្រឡាញ់” (១យ៉ូន ៤:៨) ។ ទ្រង់មិនមែនជាផ្នែកពន្លឺ ហើយជាផ្នែកសេចក្តីស្រឡាញ់ទេ ។ ទ្រង់មិនមែនជាសេចក្តីស្រឡាញ់នៅពេលថ្ងៃ ហើយជាពន្លឺនៅពេលយប់នោះទេ ទ្រង់ជាពន្លឺ និងសេចក្តីស្រឡាញ់គ្រប់ពេល គ្រប់របៀប ។ លក្ខណៈនិមួយៗរបស់ព្រះបញ្ជាក់ពីលក្ខណៈដទៃទៀតរបស់ទ្រង់ ។

លក្ខណៈនិមួយៗរបស់ទ្រង់ តំណាងឲ្យជ្រុងមួយនៃចរិតលក្ខណៈរបស់ទ្រង់ ហើយនៅពេលដែលយើងមើលទៅជ្រុងផ្សេងៗទៀត យើងនឹងដឹងថាទ្រង់ជានរណា ។ ហើយនៅពេលដែលយើងដឹងថា ទ្រង់ជានរណាហើយ នោះយើងនឹងដឹងថែមទៀតថា ទ្រង់បានបង្កើតយើងមកឲ្យធ្វើជានរណា ។

# បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១. តើលក្ខណៈអ្វីខ្លះដែលព្រះមាន ហើយយើងក៏មានដែរ ? តើលក្ខណៈអ្វីខ្លះដែលព្រះមាន ហើយយើងមិនមាន ? ចូរប្រាប់ពីលក្ខណៈមួយរបស់ព្រះ ដែលយើងចង់ធ្វើត្រាប់តាមជាងគេបំផុតក្នុងជីវិតរបស់អ្នក ?

២. ប្រសិនបើយើងគិតថាលក្ខណៈមួយរបស់ព្រះ មានសារៈសំខាន់ជាងលក្ខណៈផ្សេងទៀតរបស់ទ្រង់ នោះតើមានការគ្រោះថ្នាក់អ្វីខ្លះនឹងកើតឡើង ?

៣. តើលក្ខណៈណាខ្លះរបស់ព្រះ ដែលអ្នកគិតថាអស្ចារ្យជាងគេ ? តាមរយៈលក្ខណៈនេះ តើយើងបានរៀនអ្វីខ្លះអំពីព្រះ?

# ជំពូក ៣

# តើព្រះត្រៃឯកជាអ្វី ?

ជួនកាលគេប្រើព្រះនាមបីផ្សេងៗគ្នា នៅពេលដែលគេនិយាយអំពីព្រះ ដូចជាព្រះជាម្ចាស់ ឬ ព្រះវរបិតា ព្រះយេស៊ូវគ្រីស្ទ និងព្រះវិញ្ញាណបរិសុទ្ធ ។ ប៉ុន្តែ ព្រះនាមទាំងនេះមិនមែនជាព្រះនាមសំដៅលើអង្គតែមួយនោះទេ តែសំដៅទៅលើអង្គបីផ្សេងៗគ្នាវិញ ។ ប៉ុន្តែ ព្រះវរបិតា ព្រះរាជបុត្រា (ព្រះយេស៊ូវ) និងព្រះវិញ្ញាណបរិសុទ្ធ ជាបុគ្គលបីអង្គដែលគង់នៅអស់កល្ប តែជាព្រះតែមួយប៉ុណ្ណោះ ។ សេចក្ដីបង្រៀននេះ គេហៅថាព្រះត្រៃឯក ។ គំនិតអំពីបុគ្គលបីអង្គ តែ ជាព្រះតែមួយនេះពិតជាពិបាកយល់ឲ្យពេញលេញណាស់ ។ ប៉ុន្តែ វា នៅតែជាផ្នែកដ៏សំខាន់មួយនៃផ្នែកផ្សេងៗទៀតនៃសេចក្ដីជំនឿរបស់គ្រីស្ទបរិស័ទ ។

## ព្រះត្រៃឯកក្នុងព្រះគម្ពីរ

ពាក្យថា “ព្រះត្រៃឯក” មិនមានឃើញនៅក្នុងព្រះគម្ពីរទេ ប៉ុន្តែគំនិតតំណាងឲ្យពាក្យថា “ព្រះត្រៃឯក” មាននៅកន្លែងជាច្រើនក្នុងព្រះគម្ពីរ ។ ឧទាហរណ៍៖ នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ១:២៦ ព្រះបានមានបន្ទូលថា “ចូរយើងធ្វើមនុស្សឲ្យដូចជារូបយើង” ។ ព្រះប្រើពាក្យថា “យើង” ជាសញ្ញាមួយដែលបង្ហាញថា មានលើសពីមួយបុគ្គលដែលបានចូលរួមនៅក្នុងការបង្កើតនេះ ។ បុគ្គលផ្សេងទៀតដែលព្រះ

កំពុងតែមានបន្ទូលជាមួយ យើងអាចនឹងគិតថាជាពួកទេវតា ប៉ុន្តែ យើងមិនត្រូវបានបង្កើតមក ឲ្យដូចជារូបរបស់ទេវតាទេ "ទ្រង់ក៏បង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់" វិញ (លោក ១:២៧)។ ដូច្នេះ ៩២៦ ត្រូវតែមានន័យថា មានព្រះលើសពីមួយអង្គ ។

នៅពេលដែលព្រះយេស៊ូវបានទទួលបុណ្យជ្រមុជទឹក "នោះទ្រង់យាងឡើងពីទឹកភ្លាម ស្រាប់តែមេឃក៏របើកឡើង ឲ្យទ្រង់ឃើញព្រះវិញ្ញាណនៃព្រះយាងចុះមកដូចជាសត្វព្រាប ក៏សណ្ឋិតលើទ្រង់ នោះមានឮសំលេងចេញពីមេឃថា នេះជាកូនស្ងួនភ្ងារបស់អញ ជាទីពេញចិត្តអញណាស់" (ម៉ាថ ៣:១៦-១៧)។ នៅពេលនេះយើងឃើញថា សមាជិកទាំងបីនៃព្រះត្រៃឯក បានសំដែងជាសកម្មភាពបីផ្សេងគ្នា ព្រះវរបិតាបានកំពុងមានបន្ទូល ព្រះរាជបុត្រាបានកំពុងទទួលបុណ្យជ្រមុជទឹក ហើយព្រះវិញ្ញាណបរិសុទ្ធបានកំពុងមកសណ្ឋិតលើព្រះរាជបុត្រា ។

ស្រដៀងគ្នានេះដែរ នៅពេលដែលព្រះយេស៊ូវបានចាត់ពួកសិស្សរបស់ទ្រង់ឲ្យចេញទៅធ្វើការរបស់ពួកគេ ទ្រង់បានបង្គាប់ដល់ពួកគេថា "ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ" (ម៉ាថ ២៨:១៩)។ តាមរយៈព្រះបន្ទូលត្រង់នេះ ព្រះយេស៊ូវបានកំពុងបញ្ជាក់ថា សមាជិកទាំងបីនៃព្រះត្រៃឯកដាច់ដោយឡែកពីគ្នា ។ (ឧ៖ ព្រះវរបិតាមិនអាចជាព្រះរាជបុត្រាបានឡើយ)។ នៅក្នុងព្រះគម្ពីរយូដាស ១:២០-២១ បញ្ជាក់ដល់យើងម្តងទៀតពីអង្គ

ទាំងបីនៃព្រះត្រៃឯក “ប៉ុន្តែ ឯអ្នករាល់គ្នាជាពួកស្ងួនភ្ងាអើយ ចូររក្សាខ្លួនក្នុងសេចក្តីស្រឡាញ់របស់ព្រះចុះ ព្រមទាំងរង់ចាំសេចក្តីមេត្តាករុណារបស់ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើង ឲ្យបានជីវិតអស់កល្បជានិច្ចវិញ ដោយស្អាងចិត្តឡើងដោយសេចក្តីជំនឿដ៏បរិសុទ្ធបំផុតរបស់អ្នករាល់គ្នា ហើយទាំងអធិស្ឋានដោយនូវព្រះវិញ្ញាណបរិសុទ្ធផង” ។

## អត្ថន័យនៃព្រះត្រៃឯក

ព្រះជាបុគ្គលបីអង្គផ្សេងគ្នា ដូច្នេះព្រះវរបិតាមិនមែនជាព្រះរាជបុត្រា ឬក៏ជាព្រះវិញ្ញាណបរិសុទ្ធទេ ហើយព្រះរាជបុត្រាមិនមែនជាព្រះវរបិតា ឬក៏ជាព្រះវិញ្ញាណបរិសុទ្ធ រីឯព្រះវិញ្ញាណបរិសុទ្ធក៏មិនមែនជាព្រះវរបិតា ឬក៏ជាព្រះរាជបុត្រាដែរ ។ ខគម្ពីរដែលបានដកស្រង់ពីមុនមកនេះ សុទ្ធតែបានបង្ហាញថាព្រះជាបុគ្គលបីអង្គ ។

អង្គនិមួយៗនៃព្រះត្រៃឯក ជាព្រះពេញលេញមួយរយភាគរយ ។ ព្រះវរបិតាគឺជាព្រះ ហើយយើងដឹងពីការនេះតាំងពីខគម្ពីរដំបូងនៃព្រះគម្ពីរ “កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃ និងផែនដី” (លោក ១:១) និងកន្លែងជាច្រើនផ្សេងទៀតនៅក្នុងព្រះគម្ពីរ ។ នៅពេលព្រះគម្ពីរប្រើពាក្យថា “ព្រះ” ជាធម្មតាគឺសំដៅលើព្រះវរបិតា ។

ប៉ុន្តែ ព្រះរាជបុត្រាដែលយាងមកផែនដី ជាព្រះយេស៊ូវគ្រីស្ទក៏ជាព្រះពេញលេញមួយរយភាគរយដែរ ។ សាវកប៉ុលបានសរសេរនៅក្នុងព្រះគម្ពីរកូឡុស

២:៩ ថា “ដ្បិតមានគ្រប់ទាំងសេចក្តីពោរពេញរបស់ព្រះសណ្ឋិតនៅក្នុងទ្រង់ទាំងមានរូបអង្គផង” ។ ដូច្នេះលោកថូម៉ាសដែលជាសាវករបស់ព្រះយេស៊ូវ គាត់ត្រឹមត្រូវដែលគាត់បានទូលព្រះយេស៊ូវថា “ព្រះអម្ចាស់ទូលបង្គំ ឱព្រះនៃទូលបង្គំអើយ” (យ៉ូន ២០:២៨) ។ សាវកយ៉ូហានបាននិយាយថា ដែលគាត់បានសរសេរគឺ “ដើម្បីឲ្យអ្នករាល់គ្នាបានជឿថាព្រះយេស៊ូវជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះពិត” (យ៉ូន ២០:៣១) ។

រីឯព្រះវិញ្ញាណបរិសុទ្ធក៏ជាព្រះពេញលេញមួយរយភាគរយដែរ ។ ដោយព្រះវរបិតា និងព្រះរាជបុត្រាជាព្រះ ដូច្នេះវាសមហេតុផល ដែលអង្គទាំងបីត្រូវបានថែងពីសារៈសំខាន់ស្មើៗគ្នា ដូចជានៅក្នុងព្រះគម្ពីរម៉ាថាយ ២៨:១៩ (“ធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ”) ។ ការនេះបង្ហាញយើងថា ព្រះគម្ពីរបានបង្រៀនអំពីអង្គទាំងបីថាជាព្រះពេញលេញ ។ សាវកពេត្រុសបានបញ្ជាក់ពីការបង្រៀននេះ នៅពេលដែលគាត់បានចោទប្រកាន់នរណាម្នាក់ថាកុហក “ហេតុអ្វីបានជាអារក្សសាតាំងមកនៅពេញក្នុងចិត្តអ្នកឲ្យអ្នកហ៊ានកុហកដល់ព្រះវិញ្ញាណបរិសុទ្ធ ដោយគែទុកតំលៃដីមួយចំនែកដូច្នេះ” (កិច្ច ៥:៣) ។ ហើយបន្ទាប់មកគាត់បានពន្យល់ដល់បុរសនេះថា “នេះមិនមែនកុហកដល់មនុស្សទេ គឺឈ្មោះថាកុហកដល់ព្រះវិញ” (កិច្ច ៥:៤) ។ សាវកប៉ុលនិយាយថា ព្រះវិញ្ញាណជ្រាបគ្រប់ការទាំងអស់ដូចជាព្រះវរបិតាដែរ “ហើយបើមិនមែនជាព្រះវិញ្ញាណនៃព្រះ នោះក៏គ្មានអ្នកណាស្គាល់សណ្ឋានព្រះបានដែរ” (១កូ ២:១១) ។

ប៉ុន្តែ ព្រះគម្ពីរបានប្រាប់យ៉ាងច្បាស់ផងដែរថា មានព្រះតែមួយគត់ប៉ុណ្ណោះ មិនមែនមានព្រះបីទេ ។ ព្រះគម្ពីរចែងថា ព្រះគឺមានតែមួយប៉ុណ្ណោះ ។ ព្រះគម្ពីរចោទិយកថា ៦:៤ "ព្រះយេហូវ៉ាជាព្រះនៃយើង គឺព្រះយេហូវ៉ាតែមួយអង្គទ្រង់" ។ ជាញឹកញាប់ព្រះបានមានបន្ទូលដដែលៗអំពីបទនេះ ពីព្រោះទ្រង់ចង់ឲ្យយល់ច្បាស់ថា គ្មានព្រះឯណាទៀតឡើយក្រៅពីទ្រង់ឡើយ ។ ឧទាហរណ៍៖ ព្រះគម្ពីរអេសាយ ៤៥: ៥ ចែងថា "អញនេះជាយេហូវ៉ា គ្មានព្រះណាឯទៀតឡើយក្រៅពីអញឥតមានព្រះណាទៀតសោះ" ។

សាវកប៉ុលបានបញ្ជាក់ការនេះនៅក្នុងព្រះគម្ពីររ៉ូម ៣:៣០ ដែលគាត់សរសេរថា "ដ្បិតគឺជាព្រះតែមួយព្រះអង្គ" ហើយម្តងទៀតនៅព្រះគម្ពីរ ១ធីម៉ូថេ ២:៥ សរសេរថា "ពីព្រោះមានព្រះតែមួយ" ។ ក្នុងព្រះគម្ពីរយ៉ាកុប ២:១៩ យើងឃើញថា សូម្បីតែអារក្សក៏ទទួលស្គាល់ថាមានព្រះតែមួយដែរ "អ្នកជឿថា មានព្រះតែមួយនោះត្រូវហើយ ទោះទាំងពួកអារក្សក៏ជឿដូច្នេះ ព្រមទាំងព្រឺខ្លាចដែរ" ។

ដូនកាលវាហាក់ដូចជាពិបាកយល់ថា មានអង្គបីផ្សេងគ្នានៃព្រះត្រៃឯក ហើយអង្គនិមួយៗជាព្រះពេញលេញ ប៉ុន្តែជាព្រះតែមួយ ហើយទ្រង់មិនមានការបែងចែកជាផ្នែកទៅវិញ ។ វាពិបាកយល់មែន ។ អំពីព្រះត្រៃឯកគឺជាសេចក្តីអាថ៌កំបាំងមួយ ដែលយើងអាចយល់បានខ្លះៗប៉ុណ្ណោះ ។ ដូនកាលការស្រដៀងគ្នាផ្សេងៗពីរបស់ដែលព្រះបានបង្កើត អាចជួយឲ្យបានយល់អំពីព្រះត្រៃឯកបន្តិចបន្តួចដែរ ប៉ុន្តែនៅទីបំផុតការស្រដៀងគ្នាទាំងអស់នោះ មិនអាចពន្យល់ពីសេចក្តីអាថ៌កំបាំងនោះបានឡើយ ពីព្រោះវាព្យាយាមពន្យល់ថា ព្រះប្រៀបដូចអ្វីមួយនៃ

ការបង្កើតទៅវិញ ។ គ្មានអ្វីមួយនៃការបង្កើតអាចប្រៀបប្រដូចទៅនឹងទ្រង់បានឡើយ ។ គ្រប់ទាំងការព្យាយាមដើម្បីពន្យល់ពីសេចក្តីអាថ៌កំបាំងនេះឲ្យបានពេញលេញ មិនអាចទទួលបានជោគជ័យទេ ជាញឹកញាប់វាបែរជាធ្វើឲ្យយើងជឿអ្វីមួយដែលប្រឆាំងនឹងសេចក្តីបង្រៀននៃព្រះគម្ពីរវិញ ។ ជាសង្ខេប ការបង្រៀនអំពីព្រះត្រៃឯក គឺជាអ្វីមួយដែលយើងមិនអាចយល់មួយរយភាគរយបានទេ ពីព្រោះផ្នែករបស់វាលើសពីការយល់ដឹងរបស់យើង ។ វាគឺជាសេចក្តីលាក់កំបាំងមួយរបស់ព្រះ (ចោទិ ២៩:២៨) ។

ទោះបីជាយើងមិនអាចយល់ទាំងអស់ក៏ដោយ តែវាពិតជាមានសារៈសំខាន់ខ្លាំងណាស់ថា ការបង្រៀននេះជាសេចក្តីពិត ។ ឧទាហរណ៍៖ ប្រសិនបើព្រះយេស៊ូវមិនមែនជាព្រះ ហើយជាអង្គផ្សេងទៀតក្រៅពីព្រះជាម្ចាស់ ដូច្នេះទ្រង់មិនអាចនឹងទទួលនូវសេចក្តីក្រោធទាំងស្រុងរបស់ព្រះជាម្ចាស់ ការសុគត និងការមានព្រះជន្មរស់ឡើងវិញបានទេ ។ ហើយប្រសិនបើព្រះយេស៊ូវមិនបានមានព្រះជន្មរស់ឡើងវិញទេ នោះអស់អ្នកណាដែលជឿដល់ទ្រង់គឺជាអ្នកដែលល្ងីល្ងើដូចជាសំដីរបស់សាវកប៉ុលថា ហើយអស់អ្នកណាដែលប្រកាសខ្លួនថាជាគ្រីស្ទបរិស័ទ “នោះយើងវេទនា លើសជាងមនុស្សទាំងអស់ទៅទៀត” (១កូ ១៥:១៩) ។

## តួនាទីផ្សេងៗនៃព្រះត្រៃឯក

សមាជិកទាំងបីនៃព្រះត្រៃឯក មានតួនាទីផ្សេងៗគ្នា ។ ឧទាហរណ៍៖ នៅក្នុងការបង្កើត ព្រះមានបន្ទូល ហើយផែនដីក៏បានកើតឡើង (លោក ១:៩-១០) ។ ប៉ុន្តែព្រះគម្ពីរយ៉ូហាន ១:៣ ចែងថា ព្រះរាជបុត្រាបានធ្វើវិញ "គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្ដារបស់ដែលបានបង្កើតមកទាំងប៉ុន្មាននោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ" ហើយព្រះគម្ពីរលោកុប្បត្តិ ១:២ ប្រាប់យើងនៅពេលព្រះកំពុងតែបង្កើត ថា "ឯផែនដីបានខូច ហើយនៅទទេ មានសុទ្ធតែងងឹតគ្របលើជំរៅទឹក ហើយព្រះវិញ្ញាណនៃព្រះក៏រេរានៅពីលើទឹក" ។ នេះមានន័យថាព្រះវិញ្ញាណកំពុងតែសំដែងឲ្យឃើញពីវត្តមានរបស់ទ្រង់នៅក្នុងការបង្កើតនោះដែរ ។

យើងអាចឃើញតួនាទីផ្សេងៗនៃព្រះត្រៃឯក នៅក្នុងសេចក្ដីសង្គ្រោះរបស់យើង ។ ព្រះវរបិតា "ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ" "ទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងលោកិយ ដើម្បីនឹងជំនុំជំរះលោកិយនោះទេ គឺឲ្យលោកិយបានសង្គ្រោះដោយសារទ្រង់វិញ" (យ៉ូន ៣:១៦ , ១៧) ។ ព្រះយេស៊ូវបានមានបន្ទូលអំពីតួនាទីរបស់ទ្រង់ "ពីព្រោះខ្ញុំបានចុះពីស្ថានសួគ៌មក មិនមែននឹងធ្វើតាមចិត្តខ្ញុំទេ គឺតាមបំណងព្រះហឫទ័យនៃព្រះវិញ ដែលទ្រង់ចាត់ឲ្យខ្ញុំមក" (យ៉ូន ៦:៣៨) ។ ហើយបំណងព្រះហឫទ័យរបស់ព្រះ គឺឲ្យព្រះយេស៊ូវសុគតសំរាប់អំពើបាបរបស់យើង ដើម្បីមិនឲ្យយើងត្រូវស្លាប់ (ហេ ១០:១០) ។ ពេលដែលព្រះយេស៊ូវបានមានព្រះជន្ម

រស់ឡើងវិញ ហើយបានយាងទៅស្ថានសួគ៌ ទ្រង់និងព្រះវរបិតាបានចាត់ព្រះវិញ្ញាណបរិសុទ្ធ ដើម្បីបំពេញកិច្ចការដែលព្រះវរបិតា និងព្រះរាជបុត្រាបានចាប់ផ្តើម (យ៉ូន ១៤:១៦ , ១៦:៧) ។

ទាំងនៅក្នុងការបង្កើត និងទាំងនៅក្នុងការប្រោសលោះ ព្រះ វរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ មានតួនាទីផ្សេងៗគ្នា ។ ព្រះវរបិតាតំរង់ទិសដៅ ហើយចាត់ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធមក ។ ព្រះរាជបុត្រា និងព្រះវរបិតាក៏ចាត់ព្រះវិញ្ញាណបរិសុទ្ធមកដែរ ។ ព្រះរាជបុត្រាស្តាប់បង្គាប់ដល់ព្រះវរបិតា ហើយព្រះវិញ្ញាណបរិសុទ្ធស្តាប់បង្គាប់ដល់ព្រះរាជបុត្រា និងព្រះវរបិតា ។ ទាំងព្រះរាជបុត្រា និងទាំងព្រះវិញ្ញាណបរិសុទ្ធ បានអនុវត្តតួនាទីស្មើៗគ្នាដូចព្រះវរបិតាដែរ ។ ប៉ុន្តែ អង្គទាំងពីរចុះចូលចំពោះព្រះវរបិតា ។

តួនាទីផ្សេងៗគ្នាទាំងអស់នេះ បានបង្ហាញយើងអំពីទំនាក់ទំនងអស់កល្បរវាង ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ។ តួនាទីផ្សេងៗគ្នាទាំងអស់នេះ មិនបង្កើនភាពជាព្រះ លក្ខណៈ ឬក៏និស្ស័យនៃព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធឡើយ ។ អង្គទាំងបីមានការខុសគ្នាគឺគ្រាន់តែ ការទំនាក់ទំនង និងការបង្កើតប៉ុណ្ណោះ ។ នេះជាផ្នែកខុសគ្នាទៅនឹងបទពិសោធន៍របស់យើង មនុស្សទាំងអស់គឺខុសគ្នា ។ ប៉ុន្តែព្រះខុសគ្នាទៅនឹងបទពិសោធន៍របស់យើងឆ្ងាយណាស់ ដូចជាទ្រង់មិនអាចមានការបែងចែកជាផ្នែក តែមានទំនាក់ទំនងជាមួយអង្គបីផ្សេងគ្នា ។ នេះគឺជាអ្វីដែលខុសគ្នាស្រឡះទៅនឹងអ្វីៗដែលជាបទពិសោធន៍របស់យើង ដែលការនេះ ធ្វើឲ្យយើងមិនអាចយល់ឲ្យពេញលេញអំពីវាបាន ។

ប៉ុន្តែភាពតែមួយ និង ភាពផ្សេងៗគ្នា នៅ ក្នុងព្រះត្រៃឯកផ្ដល់នូវមូលដ្ឋានគ្រឹះដ៏អស្ចារ្យមួយ សំរាប់ភាពតែមួយ ភាពផ្សេងៗគ្នា ដែលយើងមានបទពិសោធន៍នៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង ។ ឧទាហរណ៍៖ នៅក្នុងអាពាហ៍ពិពាហ៍ មនុស្សពីរនាក់ដោយឡែកផ្សេងគ្នា បានមកជាមួយគ្នា ហើយតាមរយៈអាពាហ៍ពិពាហ៍នេះពួកគេក្លាយមកជាសាច់ឈាមតែមួយ (អេ ៥:៣១) ។ ប្ដីប្រពន្ធមានតំលៃ ហើយមានភាពជាមនុស្សស្មើៗគ្នា នៅចំពោះព្រះ ប៉ុន្តែពួកគេក៏មានតួនាទីផ្សេងៗគ្នា ។ ដូចគ្នាដែលព្រះវរបិតាមានអំណាចលើព្រះរាជបុត្រា ដូចជាប្ដីមានអំណាចលើប្រពន្ធយ៉ាងដូច្នេះដែរ ។ សាវកប៉ុលបានបង្រៀននៅ ១ កូរិនថូស ១១:៣ ថា “តែខ្ញុំចង់ឲ្យអ្នករាល់គ្នាដឹងថា ព្រះគ្រីស្ទជាសិរសានៃបុរសទាំងអស់ ឯបុរសវិញ នោះជាក្បាលនៃស្ត្រី ហើយសិរសានៃព្រះគ្រីស្ទ គឺជាព្រះ” ។ ទោះបីជា ជួនកាលវាអាចនឹងពិបាកដឹងអំពីតួនាទីរបស់ប្ដីនិងប្រពន្ធក៏ដោយ ប៉ុន្តែព្រះគម្ពីរបានបង្ហាញយ៉ាងច្បាស់ពីទំនាក់ទំនងក្នុងព្រះត្រៃឯក ទុកជាគំរូសំរាប់ទំនាក់ទំនងប្ដីប្រពន្ធនៅក្នុងជីវិតអាពាហ៍ពិពាហ៍ ។

គំរូមួយទៀតពីភាពតែមួយ និងភាពផ្សេងគ្នា ត្រូវបានឃើញនៅក្នុងពួកជំនុំដែលមានសមាជិកច្រើន ហើយពួកគេមានជំនាញផ្សេងៗគ្នា ប៉ុន្តែ ពួកគេជារូបកាយតែមួយនៅក្នុងព្រះគ្រីស្ទ ហើយមានគោលបំណងតែមួយដូចគ្នា (១ កូរិន ១២:១២) ។ យើងក៏អាចឃើញពីការនេះផងដែរ នៅក្នុងពួកជំនុំចំរុះជាតិសាសន៍ “គេមកពីគ្រប់ទាំងសាសន៍ គ្រប់ទាំងពូជមនុស្ស គ្រប់ទាំងគ្រួសារ គ្រប់ទាំងភាសា” (វិវរ ៧:៩) ។ ភាពផ្សេងគ្នានេះ បានបន្ថែមភាពសាំញ៉ាំ ដែលបង្ហាញឲ្យឃើញពី

ប្រាជ្ញាញាណនៃព្រះ ដោយព្រះបានអនុញ្ញាតឲ្យមានភាពតែមួយ និងភាពផ្សេងគ្នានេះ នៅក្នុងលោកិយរបស់ទ្រង់ ។ នេះគឺជាការឆ្លុះបញ្ចាំងមួយនៃភាពតែមួយ និងភាពផ្សេងគ្នា ដែលមាននៅក្នុងព្រះត្រៃឯក ។

## បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១. ចូរប្រាប់ខគម្ពីរឲ្យបានបី ឬបួន ដែលបង្រៀនពីព្រះត្រៃឯក ។ តើខគម្ពីរទាំងនេះបានប្រាប់យើងអ្វីខ្លះ អំពីព្រះត្រៃឯក ?

២. ហេតុអ្វីបានជាគំនិតប្រៀបប្រដូចពីព្រះត្រៃឯកទាំងអស់ មិនអាចពន្យល់អំពីព្រះត្រៃឯកឲ្យពេញលេញបាន ? តើមានន័យថា យើងត្រូវតែបង្កើតគំនិតប្រៀបប្រដូចថ្មីមួយទៀតឬ ? ហេតុអ្វីបានជាត្រូវបង្កើត ឬ ហេតុអ្វីបានជាមិនត្រូវបង្កើត ?

៣. តើទំនាក់ទំនាក់រវាង ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ បានផ្តល់គំរូដល់យើង ពីរបៀបដែលយើងគួរមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេចខ្លះ ?

# ជំពូក ៩

# តើអ្វីទៅជាការបង្កើត ?

តើសកលលោកនេះ កើតឡើងមកពីណា ? ហើយអ្វីទៅជាគោលបំណងរបស់វា ? តើយើងគួរគិតថា ការបង្កើតជាការល្អ ឬក៏ការអាក្រក់ ? នៅក្នុងជំពូកនេះ យើងនឹងព្យាយាមយល់ថា តើព្រះបានបង្កើតសកលលោកនេះមកយ៉ាងដូចម្ដេច ? តើទ្រង់បានបង្កើតសកលលោកនេះមក ឲ្យមានលក្ខណៈយ៉ាងដូចម្ដេច ? បច្ចុប្បន្ននេះ តើយើងគួរគិតយ៉ាងដូចម្ដេច ពីការបង្កើតនេះ ?

## ការបង្កើតដែលបានបង្កើតមក

ព្រះបានបង្កើតសកលលោកនេះពីគ្មានអ្វីទាំងអស់ ។ មុនពេលដែលសកលលោកត្រូវបានបង្កើតមក គ្មានអ្វីទាំងអស់ក្រៅពីព្រះ ។ គ្រប់របស់ទាំងអស់ត្រូវបានបង្កើតឡើងដោយសារព្រះ “កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃ និងផែនដី” (លោក ១:១) ។ លោកយ៉ូហាន បានបញ្ជាក់ការនេះថា “គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់” (យ៉ូន ១:៣) ។ នៅក្នុងបទគម្ពីរកូលុ៉ស ១:១៦ ចែងថា “ដ្បិតគឺទ្រង់ហើយដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌ និងនៅផែនដី ទាំងរបស់ដែលមើលឃើញ ហើយដែលមើលមិនឃើញផង” ។ ហើយដូចជា

យើងបានឃើញនៅជំពូក៣ ស្រាប់ហើយថា សមាជិកទាំងអស់នៃព្រះត្រៃឯកសុទ្ធតែបានចូលរួមក្នុងការបង្កើត ។

ព្រះបានមានបន្ទូលឲ្យការបង្កើតទាំងអស់បានកើតមានឡើង ដូចជា ទឹក ដី រុក្ខជាតិ សត្វ (លោក ១:៣-២៥) -អ្វីគ្រប់យ៉ាងទាំងអស់ លើកលែងតែមនុស្ស ។ មនុស្សប្រុស និងមនុស្សស្រី ត្រូវបានបង្កើតមក ដោយព្រះហស្តរបស់ទ្រង់ ហើយបានទទួលជីវិត ដោយសារខ្យល់ដង្ហើមរបស់ទ្រង់ (លោក ២:៧, ២២) ។ ដោយព្រោះយើងត្រូវបានបង្កើតមកដោយព្រះហស្តរបស់ទ្រង់ ជាសញ្ញាមួយដែលបង្ហាញថា មនុស្សពិតជាមានតួនាទីពិសេសណាស់ នៅក្នុងការបង្កើតរបស់ទ្រង់ ។ លើសពីនេះទៅទៀត មានតែមនុស្សប៉ុណ្ណោះ ដែលព្រះបានបង្កើតមក "ដូចរូបអង្គទ្រង់" (លោក ១:២៧) ។ ដូចរូបអង្គទ្រង់ មានន័យថា យើងដូចជាព្រះ ហើយជាតំណាងរបស់ព្រះ ។ មនុស្សជាផ្នែកដ៏ខ្ពស់បំផុតនៃការបង្កើតរបស់ព្រះ ។ មនុស្សដូចព្រះជាងគេនៅក្នុងចំណោមការបង្កើតទាំងអស់ ។ មនុស្សជាអ្នកដែលត្រូវបានតាំងឡើង ឲ្យគ្រប់គ្រងលើការបង្កើតទាំងអស់ ហើយជាអ្នកតំណាងរបស់ព្រះ (លោក ១:២៨-៣១) ។

មានទ្រឹស្តីវិទ្យាសាស្ត្រជាច្រើន ដែលប្រឆាំងនឹងការបង្រៀននៃព្រះគម្ពីរអំពីការបង្កើត ដូចជា ទ្រឹស្តីដែលនិយាយថា របស់មានជីវិតទាំងអស់កើតឡើងពីការវិវឌ្ឍន៍កំឡុងរយៈពេលច្រើនឆ្នាំ ។ ព្រះគម្ពីរបានបង្រៀនថា របស់មានជីវិតទាំងអស់ កើតឡើងពីផែនការ និងអំណាចព្រះចេស្តាដ៏គ្មានព្រំខណ្ឌរបស់ទ្រង់ ។ គ្រប់ទ្រឹស្តីវិទ្យាសាស្ត្រទាំងឡាយណា ដែលមិនបង្រៀនពីព្រះអាទិករ នោះពួកគេមិន

បានធ្វើឲ្យយើងមានសេចក្ដីថ្លៃថ្នូរ ដូចជាមាននៅក្នុងព្រះគម្ពីរទេ ។ ព្រះគម្ពីរបានបង្រៀនថា តាមពិតទៅ ព្រះមិនបាច់ត្រូវការបង្កើតអ្វីណាសោះ តែទ្រង់បានជ្រើសរើសដើម្បីបង្កើតយើង ហើយឲ្យដូចរូបអង្គទ្រង់ផង ។

ម្យ៉ាងវិញទៀត ជួនកាលការពិនិត្យសង្កេតខាងវិទ្យាសាស្ត្រ អំពីផែនដីនេះអាចនឹងកែតំរូវមនុស្សដែលយល់ច្រឡំបានដែរ ។ មានពេលមួយ គ្រីស្ទបរិស័ទជាច្រើនបានគិតថា ព្រះអាទិត្យវិលជុំវិញផែនដី ។ ពួកគេបានប្រឆាំងនឹងទ្រឹស្ដីរបស់លោក*ហ្គាលីឡេអូ* ដែលជាការពិនិត្យសង្កេតលើផ្កាយ ហើយវាធ្វើឲ្យគាត់ជឿថា ផែនដីវិលខ្លួនឯង (២៤ ម៉ោងក្នុងមួយជុំ) ហើយវិលជុំវិញព្រះអាទិត្យ (៣៦៥ ថ្ងៃក្នុងមួយជុំ) ។ នៅទីបំផុត ពួកជំនុំទាំងមូល បានសំគាល់ឃើញថា ព្រះគម្ពីរមិនដែលបានបង្រៀនថា ព្រះអាទិត្យវិលជុំវិញផែនដីទេ ដូច្នេះ ពួកគេអាចទទួលយកទ្រឹស្ដីរបស់លោក*ហ្គាលីឡេអូ*បាន ។ យើងគួរតែប្រយ័ត្នប្រយែង នៅ ពេលដែលយើងនិយាយអំពីបញ្ហានានា ដែលព្រះគម្ពីរមិនបាននិយាយច្បាស់លាស់ ។ ហើយនៅពេលដែលយើងគិតថា ការពិនិត្យសង្កេតពីធម្មជាតិនៃផែនដី ហាក់ដូចជាមិនស្របគ្នានឹងការយល់ដឹងពីបទគម្ពីរ នោះយើងគួរពិនិត្យមើលទាំងពីរនេះម្ដងទៀត ហើយព្យាយាម រកឲ្យឃើញថា ការយល់ដឹងដែលខុសឆ្គងរបស់យើងនៅត្រង់កន្លែងណា ។ នៅទីបំផុត ការយល់ដឹងត្រឹមត្រូវរបស់យើងពីវិទ្យាសាស្ត្រ ហើយនិងការយល់ដឹងត្រឹមត្រូវរបស់យើងពីបទគម្ពីរ នឹងមិនប្រឆាំងគ្នាទេ ។

ព្រះគម្ពីរបានចែងយ៉ាងច្បាស់ថា ព្រះ បានបង្កើតរបស់សព្វសារពើ ពីគ្មានអ្វីទាំងអស់ ។ ទ្រង់បានបង្កើតមនុស្សពីធូលីដីនៃផែនដីដែលទ្រង់បានបង្កើតមក ។

មុនពេលការបង្កើត គ្មានអ្វីទាំងអស់ក្រៅពីព្រះ ។ ដូច្នេះ គ្មានអ្វីណាមួយក្រៅពីព្រះដែលនៅរស់កល្បទេ ។ ហើយគ្មានអ្វីណាមួយក្រៅពីព្រះដែលគ្រប់គ្រងលើរបស់ទាំងអស់ដែរ ។ ដូច្នេះ គ្មានអ្វីណាមួយក្រៅពីព្រះដែលស័ក្ដិសមឲ្យយើងថ្វាយបង្គំទេ ។ ដោយព្រោះ យើងជាផលិតផលពិសេសនៃការបង្កើតរបស់ទ្រង់ នោះការនេះគួរបង្កើតឲ្យមានការបន្ទាបខ្លួននៅក្នុងយើងម្នាក់ៗ ។ លើសពីនេះទៀត ដោយព្រោះទ្រង់បានបង្កើតសកលលោកនេះពីគ្មានអ្វីទាំងអស់ ហើយទ្រង់មិនបានត្រូវការចាំបាច់ដើម្បីបង្កើតរបស់ទាំងនោះ អញ្ចឹងមានន័យថា ទ្រង់បានបង្កើតរបស់ទាំងអស់នោះមក ដោយមានបំណង ។ ជាចុងក្រោយ ដោយព្រោះយើងជាផលិតផលពិសេសនៃការបង្កើតរបស់ទ្រង់ នោះការនេះបានផ្ដល់ឲ្យយើងមានសេចក្ដីថ្លៃថ្នូរ ។

## ការបង្កើតដែលខុសគ្នា ប៉ុន្តែមិនឯករាជ្យ

ជាព្រះអាទិករ ព្រះខុសពីការបង្កើតរបស់ទ្រង់ ទ្រង់មិនមែនជាផ្នែកនៃការបង្កើតទេ ។ ជាលក្ខណៈច្រើនយ៉ាង ទ្រង់ខុសពីការបង្កើតរបស់ទ្រង់ ទ្រង់បានបង្កើតគ្រប់ទាំងអស់ ហើយគ្រប់គ្រងលើទាំងអស់ ។ ទ្រង់អស្ចារ្យលើសអស់ទាំងការបង្កើតរបស់ទ្រង់ឆ្ងាយណាស់ ហើយទ្រង់ក៏មិនពឹងលើរបស់ទាំងអស់នោះផង ។ ទ្រង់មិនត្រូវការការបង្កើតរបស់ទ្រង់ណាមួយទាល់តែសោះ ។

ប៉ុន្តែ ព្រះបានចូលរួមយ៉ាងជិតស្និតជាមួយការបង្កើតរបស់ទ្រង់ ។ ដោយខ្យល់ដង្ហើមរបស់ទ្រង់ ទ្រង់បានប្រទានជីវិតដល់អ្នកដែលមានរូបដូចអង្គទ្រង់ ។

“ជីវិតនៃសត្វទាំងឡាយ សុទ្ធតែនៅក្នុងព្រះហស្តទ្រង់ ព្រមទាំងខ្យល់ដង្ហើមរបស់មនុស្សផង” (យ៉ូប ១២:១០) ។ ព្រះផ្ទាល់ “ឲ្យគ្រប់ទាំងអស់មានជីវិត មានដង្ហើមគ្រប់ជំពូក” ពីព្រោះ “ដ្បិតគឺដោយសារទ្រង់ហើយ ដែលយើងរាល់គ្នាបានរស់កំរើក ហើយមាននៅផង” (កិច្ច ១៧:២៥, ២៨) ។ សាវក ប៉ុល បាននិយាយថា យើងជា “ពូជព្រះ” (កិច្ច ១៧:២៩) ។

ព្រះចូលរួមជាមួយការបង្កើតរបស់ទ្រង់ ប៉ុន្តែ ទ្រង់ខុសពីរបស់ទាំងនោះ ។ ទ្រង់មិនពឹងលើការបង្កើតរបស់ទ្រង់ទេ តែការបង្កើតរបស់ទ្រង់វិញទេតើ ដែលត្រូវពឹងផ្អែកលើទ្រង់នោះ ។ ដូច្នេះ គ្មានអ្វីណាមួយនៅក្នុងការបង្កើតរបស់ទ្រង់ ដែលស័ក្តិសមនឹងសេចក្តីស្រឡាញ់ដែលទ្រង់សមទទួលនោះទេ ។ ទោះបីជា ព្រះទ្រង់ឯករាជ្យក៏ដោយ ប៉ុន្តែទ្រង់មិនបានជ្រើសរើសឲ្យពួកវាធ្វើតួនាទីដោយខ្លួនពួកវាផ្ទាល់នោះទេ ។ ទ្រង់បានជ្រើសរើសដើម្បីចូលរួមជាមួយការបង្កើតរបស់ទ្រង់ទាំងនោះវិញ ជាពិសេសជាមួយនឹងអ្នកដែលទ្រង់បានបង្កើតឲ្យដូចជារូបអង្គទ្រង់ ។ ដូច្នេះ ទ្រង់មិនគង់នៅឆ្ងាយពីយើងពេក ដែលទ្រង់មិនអាច ឬនឹងមិនចូលរួមយ៉ាងជិតស្និតជាមួយជីវិត និងការតស៊ូរបស់យើងនោះទេ ។ ទ្រង់គង់នៅជិត “ព្រះទ្រង់ជាទីពឹងជ្រក ក៏ជាកំលាំងនៃយើងខ្ញុំ ជាជំនួយដែលនៅជាប់ជាមួយក្នុងគ្រាអាសន្ន” (ទំនុក ៤៦:១) ។ ដោយព្រោះ ទ្រង់អស្ចារ្យជាងការបង្កើត ហើយចូលរួមជាមួយការបង្កើតទាំងអស់ អញ្ចឹងប្រសិនបើ យើងមានសង្ឃឹមលើទ្រង់ នោះយើងនឹងមិនខ្លាចអ្វីឡើយ ។

## ការបង្កើតដែលថ្វាយសិរីល្អដល់ទ្រង់

គ្រប់ទាំងការបង្កើត គឺត្រូវបានបង្កើតឡើងដើម្បីថ្វាយសិរីល្អដល់ព្រះ ។ “ផ្ទៃមេឃសំដែងពីសិរីល្អនៃព្រះ ហើយលំហអាកាសក៏បង្ហាញការដែលព្រះហស្តទ្រង់ធ្វើ” (ទំនុក ១៩:១) ។ ព្រះមានបន្ទូលថា យើងក៏ត្រូវបានបង្កើតឡើងសំរាប់សិរីល្អរបស់ទ្រង់ផងដែរ (អេសា ៤៣:៧) ។ ជាការពិតណាស់ តួនាទីរបស់ព្រះក្នុងនាមជាព្រះអាទិករ ធ្វើឲ្យទ្រង់ស័ក្តិសមទទួលការថ្វាយសិរីល្អរបស់យើង៖ “ឱព្រះអម្ចាស់ជាព្រះនៃយើងរាល់គ្នាអើយ ទ្រង់គួរនឹងទទួលសិរីល្អ កិត្តិនាម និងព្រះចេស្តា ដ្បិតទ្រង់បានបង្កើតរបស់សព្វសារពើមក ហើយគឺដោយបំណងព្រះហឫទ័យទ្រង់ហើយ ដែលរបស់ទាំងនោះបានកើតមក ហើយមាននៅផង” (វិវរ ៤:១១) ។

ការបង្កើតរបស់ព្រះបង្ហាញពីអំណាច និងប្រាជ្ញាញាណដ៏ធំរបស់ទ្រង់ ។ “ព្រះទ្រង់បានបង្កើតផែនដី ដោយឫទ្ធិតេជះរបស់ទ្រង់ ទ្រង់បានតាំងលោកិយឡើង ដោយសារប្រាជ្ញារបស់ទ្រង់ ហើយបានលាតផ្ទៃមេឃ ដោយសារយោបល់” (យេរេ ១០:១២) ។ សូម្បីតែមានការឆ្លុះបញ្ចាំងបន្តិចបន្តួចមួយពីភាពស្មុគស្មាញសាំញ៉ាំ ភាពសំបូរបែប និងសោភ័ណភាពនៅក្នុងការបង្កើតក៏ដោយ ការនោះគួរធ្វើឲ្យយើងសរសើរដល់ព្រះ ពីអំណាច ប្រាជ្ញាញាណ និងយោបល់របស់ទ្រង់ ។

ព្រះមិនត្រូវការសិរីល្អណាបន្ថែមទៀតពីការបង្កើតរបស់ទ្រង់ឡើយ ។ សិរីល្អដែលទ្រង់ត្រូវការនោះ គឺមាននៅក្នុងព្រះត្រៃឯកជាដរាបមកហើយ ។ ផ្ទុយទៅវិញ ព្រះគម្ពីរបានបង្ហាញយ៉ាងច្បាស់ថា ព្រះ “ទ្រង់បានបង្កើតរបស់សព្វសារពើមក” ហើយដោយបំណងព្រះហឫទ័យទ្រង់ “របស់ទាំងនោះបានកើតមក ហើយ

មាននៅផង” (វិវរ ៤:១១) ។ ការបង្កើតគឺជាកិច្ចការដ៏មានសេរីភាពពេញទីរបស់ព្រះ ។ ទ្រង់បានបង្កើតសកលលោក ដើម្បីបង្ហាញឲ្យឃើញពីភាពអស្ចារ្យរបស់ទ្រង់ ដើម្បីបង្ហាញពីការដ៏ប្រសើរឥតខ្ចោះ និងដើម្បីសប្បាយរីករាយនៅក្នុងការបង្កើតរបស់ទ្រង់ ។ ដូច្នេះ នៅពេលដែលយើងមានភាពសប្បាយរីករាយនៅក្នុងសកម្មភាពដ៏ប៉ិនប្រសប់របស់ព្រះ នៅក្នុងសកម្មភាពដ៏ប៉ិនប្រសប់របស់យើង ហើយនិងនៅក្នុងសកម្មភាពដ៏ប៉ិនប្រសប់របស់អ្នកដទៃទៀត នោះយើងកំពុងតែថ្វាយសិរីល្អដល់ព្រះ ដោយការធ្វើត្រាប់តាមសេចក្តីរីករាយដែលទ្រង់មាននៅក្នុងការបង្កើតរបស់ទ្រង់ហើយ ។

## ការបង្កើតដ៏ល្អ

ព្រះអាចមានភាពសប្បាយរីករាយនៅក្នុងការបង្កើតរបស់ទ្រង់ ពីព្រោះវាថ្វាយសិរីល្អដល់ទ្រង់ ។ ទ្រង់ក៏សប្បាយរីករាយនៅក្នុងវា ពីព្រោះ ដូចជា នៅក្នុងគម្ពីរលោកុប្បត្តិ ១:៣១ បានប្រាប់យើងហើយថា នៅពេលដែលទ្រង់ទតមើល “គ្រប់ទាំងរបស់ដែលទ្រង់បានធ្វើនោះ” ទ្រង់បានចាត់ទុកថា “ល្អប្រពៃ” ។ ទោះបីជា ការបង្កើតមិនតែងតែធ្វើតួនាទីតាមអ្វីដែលវាគួរធ្វើដោយព្រោះអំពើបាបក៏ដោយ យើងក៏គួរចាត់ទុកថា ការបង្កើតគឺជាការល្អផងដែរ ។ “ដ្បិតសត្វទាំងអស់ដែលព្រះទ្រង់បានបង្កើតមក នោះសុទ្ធតែល្អ ហើយមិនត្រូវចោលមួយឡើយ ឲ្យគ្រាន់តែទទួលដោយអរព្រះគុណប៉ុណ្ណោះ” (១ ធី ៤:៤) ។

ដូច្នេះ យើងត្រូវសប្បាយរីករាយនឹងការល្អដែលព្រះបានបង្កើតមកសំរាប់យើង ។ ទោះបីជា ការខ្លះនៅក្នុងការបង្កើត អាចត្រូវបានប្រើប្រាស់សំរាប់បំណងអំពើបាបក៏ដោយ ក៏ការប្រើប្រាស់ដ៏មានគ្រោះថ្នាក់របស់ពួកវានោះ មិនធ្វើឲ្យពួកវាអាក្រក់គ្រប់ស្ថានភាពនោះទេ ។ ឧទាហរណ៍៖ ទោះបីជា សាវ៉ក ប៉ុលនិយាយថា "ដ្បិតការដែលស្រឡាញ់ប្រាក់ នោះ ហើយជាមេឫសនៃសេចក្តីអាក្រក់គ្រប់យ៉ាង" (១ ធី ៦:១០) ក៏ដោយ គាត់ក៏បាននិយាយថាព្រះទ្រង់ផ្ទាល់ "ប្រទានគ្រប់ទាំងអស់មកយើងរាល់គ្នាជាបរិបូរ ឲ្យយើងបានអរសប្បាយ" (១ ធី ៦:១៧) ។ ដូច្នេះ យើងគួរតែប្រើប្រាស់ផែនដីដ៏ពោរពេញដែលព្រះបានប្រទានមកយើងនេះ ដោយអំណារ ហើយនិងស្វែងរកការអភិវឌ្ឍន៍វា នៅ ក្នុងរបៀបមួយដែលនាំសិរីល្អ និងកិត្តិយសដល់ព្រះនាមរបស់ព្រះ ។

# បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១. តើនៅក្នុងរបៀបណាខ្លះ ដែលសកម្មភាពនៃការបង្កើតរបស់ព្រះ ផ្តល់ឲ្យយើងនូវការបន្ទាបខ្លួន ? តើសកម្មភាពទាំងនោះផ្តល់ឲ្យយើងនូវសេចក្តីថ្លៃថ្នូដោយរបៀបណា ?

២. ចូររៀបរាប់ពីរបៀបនានាដែលផែនដី សត្វ ហើយនិងអ្នកផ្ទាល់ អាចថ្វាយសិរីល្អដល់ព្រះដ៏ជាព្រះអាទិករបាន ?

៣. តើព្រះគិតយ៉ាងដូចម្តេច អំពីអ្វីៗទាំងអស់នៃការបង្កើតរបស់ទ្រង់ ? តើគំនិតនេះផ្លាស់ប្តូរយ៉ាងដូចម្តេច បន្ទាប់ពីលោក អ័ដាម និងនាងអេវ៉ា បានធ្វើបាប ? តើគំនិតរបស់ព្រះអំពីការបង្កើតរបស់ទ្រង់ ខុសគ្នាពីគំនិតរបស់អ្នកដោយរបៀបណា ?

# ជំពូក ៥
# តើអ្វីជាសេចក្តីអធិស្ឋាន ?

របៀបមួយដែលព្រះអនុញ្ញាតឲ្យការបង្កើតរបស់ទ្រង់ មានទំនាក់ទំនងជាមួយទ្រង់ គឺតាមរយៈសេចក្តីអធិស្ឋាន ។ សេចក្តីអធិស្ឋានគឺជាទំនាក់ទំនងផ្ទាល់ខ្លួនរបស់យើងទៅនឹងព្រះ ។ សេចក្តីអធិស្ឋានមិនត្រឹមតែជួយយើងឲ្យស្គាល់*អំពី*ព្រះប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជួយយើងឲ្យ*ស្គាល់*ព្រះពិតប្រាកដដែរ ។ តាមរយៈសេចក្តីអធិស្ឋាន យើងអាចទំនាក់ទំនងការទូលសូមរបស់យើងទៅចំពោះព្រះ យើងអាចលន់តួបាបរបស់យើងទៅចំពោះព្រះ ហើយយើងអាចថ្វាយសេចក្តីស្រឡាញ់ ការសរសើរ និងការអរព្រះគុណទៅចំពោះព្រះបានផងដែរ ។

## ហេតុផលសំរាប់សេចក្តីអធិស្ឋាន

ព្រះមិនសព្វព្រះហឫទ័យឲ្យយើងអធិស្ឋាន សូមឲ្យទ្រង់បានជ្រាបពីអ្វីដែលយើងត្រូវការនោះទេ ដ្បិតព្រះយេស៊ូវបានមានបន្ទូលថា “ព្រះវរបិតានៃអ្នក ទ្រង់ជ្រាបនូវរបស់អ្វីដែលអ្នកត្រូវការ មុនដែលអ្នកសូមផង” (ម៉ាថាយ ៦:៨) ។ តែព្រះជាម្ចាស់សព្វព្រះហឫទ័យចង់ឲ្យយើងអធិស្ឋាន សូមឲ្យការពឹងដល់ទ្រង់កាន់តែកើនឡើងជំនួសវិញ ។ នៅពេលដែលយើងមកឯទ្រង់ដោយសេចក្តីអធិស្ឋានអំពីអ្វីមួយ យើងត្រូវបង្ហាញពីការទុកចិត្តមួយនៅក្នុងទ្រង់ គឺជាការដែលយើងទុកចិត្តថា ព្រះ

នឹងឮ ហើយឆ្លើយតបនឹងសេចក្តីអធិស្ឋានរបស់យើង ។ មូលហេតុនេះហើយបាន ជាព្រះយេស៊ូវប្រៀបធៀបសេចក្តីអធិស្ឋានរបស់យើងទៅនឹងក្មេងម្នាក់សុំត្រី ឬ ស៊ុតពីឪពុកគាត់ (លូក ១១:៩-១២) ។ ខណៈដែលក្មេងម្នាក់ទុកចិត្ត ហើយរំពឹងថា ឪពុកគាត់នឹងផ្តល់ឲ្យគាត់ នោះយើងគួរតែរំពឹងដោយជំនឿថា ព្រះនឹងផ្តល់មក សំរាប់យើងដែរ ។ មូលហេតុដែលព្រះយេស៊ូវបានមានបន្ទូលថា “គ្រប់ទាំង សេចក្តីអ្វី ដែលអ្នករាល់គ្នានឹងអធិស្ឋានសូម ដោយមានចិត្តជឿ នោះនឹងបាន សំរេចទាំងអស់” (ម៉ាថាយ ២១:២២) ។

ព្រះមិនគ្រាន់តែចង់ឲ្យការទុកចិត្តរបស់យើង ធំចំរើនឡើងតាមរយៈ សេចក្តីអធិស្ឋានប៉ុណ្ណោះទេ ទ្រង់ក៏ចង់ឲ្យយើងមានសេចក្តីស្រឡាញ់ចំពោះទ្រង់ ហើយមានទំនាក់ទំនងជាមួយនឹងទ្រង់កាន់តែស៊ីជំរៅ ហើយចំរើនឡើងផងដែរ ។ នៅពេលយើងអធិស្ឋានដោយពិតត្រង់ យើងអធិស្ឋានដោយគ្រប់ផ្នែកនៃចរិត លក្ខណៈរបស់យើង ទាក់ទងនឹងគ្រប់ផ្នែកនៃចរិតលក្ខណៈរបស់ទ្រង់ ។ ដូច្នេះ អ្វី ដែលយើងគិតហើយមានអារម្មណ៍អំពីព្រះ នឹងមកតាមរយៈសេចក្តីអធិស្ឋានរបស់ យើង ។ ការនេះនឹងធ្វើឲ្យសេចក្តីស្រឡាញ់ និងការយល់ដឹងរបស់យើងអំពីព្រះ កាន់តែស៊ីជំរៅឡើង ហើយនៅទីបញ្ចប់ វាធ្វើឲ្យយើងមានទំនាក់ទំនងជ្រាលជ្រៅ ជាមួយនឹងទ្រង់ ។ នេះគឺជាអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ ។ វាក៏ជាអ្វីមួយ ដែលនាំសិរីរុងរឿងមកថ្វាយទ្រង់ផងដែរ ។

សរុបសេចក្តីមក ព្រះសព្វព្រះហឫទ័យចង់ឲ្យយើងអធិស្ឋាន ពីព្រោះវាធ្វើ ឲ្យយើងក្លាយជាផ្នែកមួយនៃសាច់រឿង ដែលធំជាងរឿងរ៉ាវផ្ទាល់របស់យើង ។ វា

ធ្វើឲ្យយើងមានការទាក់ទងនឹងសកម្មភាពដែលពោរពេញ ដោយអត្ថន័យដ៏អស់កល្បនានា ។ នៅពេលយើងអធិស្ឋាន រាជ្យរបស់ទ្រង់នឹងមក ដូចជាព្រះហឫទ័យទ្រង់បានសំរេច “នៅផែនដីដូចនៅស្ថានសួគ៌ដែរ” (ម៉ាថាយ ៦:១០) ។

## ប្រសិទ្ធិភាពនៃសេចក្តីអធិស្ឋាន

ពេលយើងសូមអ្វីៗនៅក្នុងសេចក្តីអធិស្ឋាន ជា ញឹកញាប់ព្រះឆ្លើយតបនឹងសេចក្តីអធិស្ឋានទាំងនោះ ។ ព្រះយេស៊ូវធ្វើឲ្យការនេះមានភាពជាក់ច្បាស់ នៅ ពេលដែលទ្រង់មានបន្ទូលថា “ចូរសូម នោះតែងនឹងឲ្យមកអ្នក ចូររក នោះតែងនឹងឃើញ ចូរគោះ នោះតែងនឹងបើកឲ្យអ្នក ។ ដ្បិតអស់អ្នកដែលសូម នោះរមែងបាន អ្នកណាដែលរក នោះរមែងឃើញ ក៏បើកឲ្យអ្នកណាដែលគោះដែរ” (លូ ១១:៩-១០) ។ ជាញឹកញាប់ ការខកខានមិនបានសូមដល់ព្រះ គឺជាហេតុផលដែលយើងមិនបានទទួលនូវអ្វីដែលព្រះសព្វហឫទ័យប្រទានមកយើង ។ លោក យ៉ាកុប បាននិយាយថា “មិនបានអ្វីសោះ ពីព្រោះមិនសូម” (យ៉ា ៤:២) ។

បទគម្ពីរផ្តល់នូវគំរូជាច្រើនអំពីការឆ្លើយតបរបស់ព្រះ សូម្បីតែទ្រង់ផ្លាស់ប្តូររបៀបដែលទ្រង់ធ្វើ ក៏ទ្រង់នៅតែឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់ពួកគេដែរ ។ ឧទាហរណ៍៖ នៅពេលដែលព្រះយេហូវ៉ាបានមានបន្ទូលប្រាប់លោក ម៉ូសេថា ទ្រង់នឹងបំផ្លាញប្រជាជនអ៊ីស្រាអែល ដោយព្រោះអំពើបាបរបស់ពួកគេ លោកម៉ូសេបានទូលតបដោយសេចក្តីអធិស្ឋានយ៉ាងដូច្នេះថា “សូមទ្រង់បង្វែរសេចក្តីក្រោធដ៏សហ័សរបស់ទ្រង់ ហើយប្រែព្រះហឫទ័យ ដែលទ្រង់បានគិតធ្វើឲ្យរាស្រ្ត

ទ្រង់អន្តរាយនោះចេញ" (និក្ខ ៣២:១២) ។ នៅក្នុងការឆ្លើយតប "ព្រះយេហូវ៉ាទ្រង់ក៏ប្រែព្រះហឫទ័យ លែងគិតធ្វើឲ្យរាស្ត្ររបស់ទ្រង់អន្តរាយចេញទៅ" (និក្ខ ៣២:១៤) ។ លើសពីនោះទៀត សាវក យ៉ូហានប្រាប់យើងថា "បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឲ្យយើង ហើយនិងសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង" (១ យ៉ូន ១:៩) ។ គំរូទាំងពីរនេះ និងគំរូឯទៃជាច្រើនផ្សេងទៀតនៅក្នុងព្រះគម្ពីរ គួរលើកទឹកចិត្តយើង ឲ្យអធិស្ឋានកាន់តែច្រើនឡើងថែមទៀត គឺសូមដល់ព្រះដោយចិត្តក្លាហាន ដើម្បីឲ្យទ្រង់ធ្វើការតាមរបៀបនានាដែលទ្រង់អាចធ្វើបាន ។ ដោយខ្លួនរបស់យើងផ្ទាល់ យើងពុំមានសិទ្ធិសូមអ្វីមួយពីព្រះ ដោយចិត្តក្លាហានបានទេ ។ អំពើបាបរបស់យើងគួរតែបំបិទសិទ្ធិយើងពីការស្នើសុំអ្វីមួយពីព្រះដ៏បរិសុទ្ធ ។ ប៉ុន្តែ ប្រសិនបើសេចក្តីជំនឿរបស់យើងនៅក្នុងព្រះយេស៊ូវ នោះព្រះគម្ពីរបានប្រាប់យើងថា ទ្រង់គឺជាហេតុផល ដែលសេចក្តីអធិស្ឋានរបស់យើងមានប្រសិទ្ធភាព ។ ទ្រង់ឈរក្នុងនាមជា "អ្នកសម្រុះសម្រួលតែ១ នៅកណ្តាលព្រះនិងមនុស្ស " (១ធី ២:៥) ។ ឬក៏ដូចដែលព្រះយេស៊ូវបានមានបន្ទូលថា "បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណា ទៅឯព្រះវរបិតាបានឡើយ" (យ៉ូន ១៤:៦) ។ ដូច្នេះ ព្រះមិនស្ថិតនៅក្រោមកាតព្វកិច្ច ក្នុងការឆ្លើយតបសេចក្តីអធិស្ឋាននៃពួកអស់អ្នកដែលបដិសេធព្រះរាជបុត្រារបស់ ទ្រង់ទេ ។ ទោះបីទ្រង់ជ្រាបពីសេចក្តីអធិស្ឋាននោះ ហើយពេលខ្លះដោយសេចក្តីមេត្តារបស់ទ្រង់ ទ្រង់បានឆ្លើយតបក៏ដោយ ប៉ុន្តែ មិនបានសន្យាថា នឹងសណ្តាប់ ហើយឆ្លើយតបនឹងសេចក្តីអធិស្ឋានរបស់ពួកអ្នកមិន

ជឿ ដូចជាទ្រង់សណ្ដាប់ និងឆ្លើយតបសេចក្ដីអធិស្ឋានរបស់ពួកអ្នកជឿ ទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់នោះឡើយ ។

ដោយព្រោះព្រះយេស៊ូវជាអ្នកសម្រុះសម្រួលតែមួយ រវាងព្រះដ៏បរិសុទ្ធ និងមនុស្សមានបាប បានជាទ្រង់អាចមានបន្ទូលប្រាប់ដល់ពួកសិស្សទ្រង់ថា “អ្វីៗដែលអ្នករាល់គ្នានឹងសូមដល់ព្រះវរបិតា ដោយនូវឈ្មោះខ្ញុំ នោះទ្រង់នឹងប្រទានឲ្យ” (យ៉ូន ១៦:២៣) ។ ពេលទ្រង់មានបន្ទូលដូច្នេះ នោះព្រះយេស៊ូវមិនបានសំដៅថា យើងត្រូវតែភ្ជាប់ឃ្លា “ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ” នៅក្នុងគ្រប់ទាំងសេចក្ដីអធិស្ឋានរបស់យើងនោះទេ ។ ត្រង់នេះ ទ្រង់បានសំដៅថា សេចក្ដីអធិស្ឋានរបស់យើង គួរត្រូវបានអធិស្ឋានឡើង ដោយមានមូលដ្ឋានលើអំណាចរបស់ទ្រង់ ក្នុងនាមជាអ្នកសម្រុះសម្រួលរបស់យើង ហើយទៅតាមចរិតលក្ខណៈរបស់ទ្រង់វិញ ។ នេះគឺក៏ជាអ្វីដែលសាវក យ៉ូហាន ចង់និយាយ នៅពេលដែលគាត់បានសរសេរថា “អ្នករាល់គ្នាដែលជឿដល់ព្រះនាមព្រះរាជបុត្រានៃព្រះ” ហើយ “បើយើងនឹងសូមអ្វី ដែលត្រូវតាមព្រះហឫទ័យទ្រង់ នោះទ្រង់នឹងទទួលព្រម” (យ៉ូន ៥:១៣-១៤) ។

## អាកប្បកិរិយារបស់យើងក្នុងសេចក្ដីអធិស្ឋាន

ទ្រង់មិនត្រឹមតែទទួលព្រមតាមយើងប៉ុណ្ណោះទេ តែលោក យ៉ូហាននិយាយថា “បើយើងដឹងថា ទ្រង់ទទួលព្រមតាមយើង ក្នុងការអ្វីដែលយើងសូមដូច្នេះ នោះយើងក៏ត្រូវដឹងថា យើងបានអ្វីដែលយើងសូមពីទ្រង់ហើយដែរ” (១ យ៉ូន ៥:១៥) ។ សេចក្ដីអធិស្ឋានដ៏មានប្រសិទ្ធភាព ដែលព្រះយេស៊ូវឆ្លើយតបទាំងនេះ “ត្រូវតាម

ព្រះហឫទ័យទ្រង់” ហើយយើងត្រូវមានចិត្តចង់អធិស្ឋានឲ្យ “ត្រូវតាមព្រះហឫទ័យទ្រង់”ដែរ (១ យ៉ូន ៥:១៤) ។ ជាញឹកញាប់ ការអធិស្ឋានដែលត្រូវតាមព្រះហឫទ័យ គឺតំរូវឲ្យយើងបន្ទាបខ្លួន ដ្បិតវាតំរូវឲ្យយើងអធិស្ឋាន មិនសំរាប់អ្វីដែលយើងប្រាថ្នាចង់បាននោះឡើយ តែសំរាប់អ្វីដែលព្រះសព្វព្រះហឫទ័យវិញ ។ ជួនកាល វាងាយស្រួលក្នុងការស្គាល់ពីអ្វីដែលជាបំណងព្រះហឫទ័យរបស់ព្រះ ដូច្នេះ យើងត្រូវអធិស្ឋានឲ្យត្រូវតាមបំណងព្រះហឫទ័យរបស់ទ្រង់ ។ ឧទាហរណ៍៖ ប្រសិនបើយើងអធិស្ឋានឲ្យត្រូវតាមការបង្គាប់ផ្ទាល់ ឬការប្រកាសមួយអំពីព្រះហឫទ័យរបស់ទ្រង់នៅក្នុងបទគម្ពីរ នោះយើងនឹងសូមព្រះ ឲ្យទ្រង់ធ្វើអ្វីដែលទ្រង់សព្វព្រះហឫទ័យចង់ធ្វើ ហើយសូមអ្វីៗដែលផ្គាប់ដល់ព្រះហឫទ័យទ្រង់ ។ ជាការពិតណាស់ ព្រះយេស៊ូវលើកទឹកចិត្តយើងថា ត្រូវមានព្រះបន្ទូលរបស់ព្រះនៅក្នុងយើង នៅពេលដែលយើងអធិស្ឋាន “បើអ្នករាល់គ្នានៅជាប់នឹងខ្ញុំ ហើយពាក្យខ្ញុំនៅជាប់ក្នុងអ្នករាល់គ្នា នោះ ចូរសូមអ្វីតាមតែប្រាថ្នាចុះ សេចក្តីនោះនឹងបានសំរេចដល់អ្នករាល់គ្នាជាមិនខាន” (យ៉ូន ១៥:៧) ។

ទោះជាយ៉ាងណាក៏ដោយ មានស្ថានភាពជាច្រើនដែលយើងមិនសូវច្បាស់ថា អ្វីជាបំណងព្រះហឫទ័យរបស់ព្រះ ។ នៅពេលនោះ យើងគួរអធិស្ឋានទៅតាមការបង្រៀនទូទៅនៃបទគម្ពីរ ដោយសូមព្រះឲ្យទ្រង់ធ្វើការក្នុងនាមយើង ហើយទូលទ្រង់ពីសំណូមពរនានាដែលហាក់ដូចជាល្អបំផុតចំពោះយើង រហូតយើងយល់អំពីការទាំងអស់នោះ ។ យើងគួរធ្វើដូច្នេះ ដោយមានអាកប្បកិរិយាបន្ទាបខ្លួន ដែលគួរដឹងថា យើងកំពុងតែសូមព្រះឲ្យធ្វើការណាដែលតាម

ព្រះហឫទ័យទ្រង់ប៉ុណ្ណោះ ។ ជួនកាល ព្រះមិនបានប្រទាននូវអ្វីដែលយើងសូមទេ ។ ជួនកាល យើងយល់កាន់តែជ្រៅពីស្ថានភាពនោះ យ៉ាងនេះ ចិត្តរបស់យើងប្តូរទៅអធិស្ឋានសូមអ្វីមួយផ្សេងទៀត ។ ជួនកាល ទ្រង់ហាក់ដូចជានៅស្ងៀម ។ ក្នុងស្ថានភាពពិបាកៗនោះ យើងគួរស្គាល់ថា បំណងព្រះហឫទ័យរបស់ព្រះនៅក្នុងស្ថានភាពនេះ គឺប្រសើរជាងអ្វីដែលយើងបានសូម ។

ដូច្នេះ ព្រះយេស៊ូវលើកទឹកចិត្តយើងឲ្យអធិស្ឋានតាមរបៀបមួយដែលយើងជឿថា យើងបានទទួលនូវអ្វីដែលយើងបានសូម (ម៉ាក ១១:២៤) (មានន័យថា ព្រះបានសំរេចព្រះហឫទ័យប្រទានមកយើងរួចទៅហើយ) ។ សេចក្តីជំនឿបែបនេះ គឺមិនមែនជាអ្វីមួយដែលយើងអាចបង្កើតឡើង ឬបង្ខំបានទេ ប្រសិនបើយើងមិនជឿពិតប្រាកដ ដ្បិតវាជាអំណោយទានមួយដែលទ្រង់ប្រទានមកនៅក្នុងសេចក្តីអធិស្ឋាន ។ “រីឯសេចក្តីជំនឿ នោះគឺជាចិត្តដែលដឹងជាក់ថា នឹងបានដូចសង្ឃឹម ជា សំគាល់ពីការដែលមើលមិនឃើញ” (ហេ ១១:១) គឺមកពីជំនឿមួយដែលយើងជឿថា ព្រះមានព្រះជន្មគង់នៅ ហើយ “ថាទ្រង់ប្រទានរង្វាន់ដល់អស់អ្នកដែលស្វែងរកទ្រង់” (ហេ ១១:៦) ។

អ្វីៗនៅក្នុងជីវិតយើងដែលមិនគាប់ព្រះហឫទ័យដល់ព្រះ នឹងបាំងសេចក្តីអធិស្ឋានរបស់យើង ។ ដូចដែលអ្នកនិពន្ធទំនុកដំកើងពន្យល់ថា “ប្រសិនបើជាខ្ញុំឃើញមានសេចក្តីទុច្ចរិតនៅក្នុងចិត្ត នោះព្រះអម្ចាស់ទ្រង់មិនព្រមស្តាប់ខ្ញុំទេ” (ទំនុក ៦៦:១៨) ។ ស្រដៀងគ្នានេះ “ព្រះយេហូវ៉ាទ្រង់គង់នៅឆ្ងាយពីមនុស្សអាក្រក់ តែ ទ្រង់ស្តាប់សេចក្តីអធិស្ឋានរបស់មនុស្សសុចរិតវិញ” (សុ ១៥:២៩) ។

ហើយ "ព្រះនេត្រនៃព្រះអម្ចាស់ តែងទតមកលើមនុស្សសុចរិត ឯព្រះកាណ៌ទ្រង់ក៏ផ្ទៀងស្តាប់ពាក្យទូលអង្វររបស់គេ តែព្រះភក្រ្តព្រះអម្ចាស់ តែងទាស់ទទឹងនឹងពួកអ្នកដែលប្រព្រឹត្តិអាក្រក់វិញ" (១ ពេ ៣:១២) ។ ទោះជាយ៉ាងណាក៏ដោយ យើងមិនត្រូវតែរួចពីអំពើបាបទាំងស្រុង ទើបព្រះព្រមស្តាប់សេចក្តីអធិស្ឋានរបស់យើងនោះទេ ។ ប្រសិនបើព្រះព្រមស្តាប់តែសេចក្តីអធិស្ឋានរបស់មនុស្សគ្រប់លក្ខណ៍គ្មានបាប នោះ ប្រហែលជាព្រះឆ្លើយតបតែសេចក្តីអធិស្ឋានរបស់ព្រះយេស៊ូវប៉ុណ្ណោះ ។ ហើយដូចជាយើងបាននិយាយខាងដើមអញ្ចឹង គឺដោយព្រោះតែកិច្ចការរបស់ព្រះយេស៊ូវក្នុងនាមយើង បានជាព្រះជាម្ចាស់ព្រមស្តាប់សេចក្តីអធិស្ឋានរបស់យើង ។ ទោះជាយ៉ាងណាក៏ដោយ យើងត្រូវតែស្វែងរកភាពបរិសុទ្ធនៅក្នុងជីវិតរបស់យើង ដ្បិតជាញឹកញាប់ នេះគឺជាផ្លូវទៅកាន់ព្រះពរកាន់តែធំ ។

នៅពេលដែលយើងធ្វើបាប ព្រះទូន្មានយើងឲ្យប្រើអំណោយទាននៃសេចក្តីអធិស្ឋាន ដើម្បីស្វែងរកការអត់ទោស ។ នៅពេលដែលយើងលន់តួអំពើបាបរបស់យើងទៅព្រះ នោះជាការស្តារឡើងវិញនូវទំនាក់ទំនងពីមួយថ្ងៃទៅមួយថ្ងៃរបស់យើងជាមួយនឹងព្រះ ។ ពេលយើងលន់តួអំពើបាបរបស់យើង ព្រះមាន "ព្រះហឫទ័យស្មោះត្រង់ និងសុចរិត" នឹងអត់ទោសបាបទាំងនោះ ហើយមិនដាក់ទណ្ឌកម្មយើងទេ (១ យ៉ូន ១:៩) ពីព្រោះព្រះគ្រីស្ទបានទទួលទណ្ឌកម្មសំរាប់អំពើបាបទាំងនោះ នៅលើឈើឆ្កាងហើយ ។ ដោយសារការលើកទឹកចិត្តនេះ យើងមិនគួរស្វែងរកតែសេចក្តីអត់ទោសរបស់ព្រះសំរាប់អំពើខុសឆ្គងដែលយើងដឹង ថាបានធ្វើប៉ុណ្ណោះទេ ប៉ុន្តែយើងគួរសូមឲ្យទ្រង់ប្រកាសយើងថា "ជ្រះស្អាតពីអំពើ

លាក់កំបាំងផង”ដែរ (ទំនុក ១៩:១២)។ លើសពីនោះទៅទៀត លោក យ៉ាកុប បានលើកទឹកចិត្តយើងឲ្យលន់តួអំពើបាបរបស់យើង “នឹងគ្នា” ហើយ “អធិស្ឋានឲ្យគ្នាទៅវិញទៅមក” ដើម្បីឲ្យបានជា (យ៉ា ៥:១៦)។

ជាទីបញ្ចប់ ដោយកិច្ចការរបស់ព្រះក្នុងនាមយើង យើងគួរសូមអ្វីៗដោយឥរិយាបទបន្ទាបខ្លួន ដ្បិត “ព្រះទ្រង់ទាស់ទទឹងនឹងពួកមានឫកធំ តែផ្តល់ព្រះគុណមកពួករាបសារវិញ” (យ៉ា ៤:៦)។ នេះមានន័យថា យើងដឹងថាយើងមិនតែងតែសូមអ្វីដែលត្រឹមត្រូវ ដូចដែលយើងគួរសូម ឬក៏ទៅតាមបំណងព្រះហឫទ័យទ្រង់នោះទេ ។ ដូច្នេះ ជួនកាលព្រះនឹងមិនឆ្លើយតបនឹងសេចក្តីអធិស្ឋានរបស់យើង ដូចជាយើងចង់បាននោះទេ ។

នៅពេលទ្រង់មិនបានឆ្លើយតបនឹងសេចក្តីអធិស្ឋានរបស់យើង ។ យើងបានដូចជាព្រះយេស៊ូវ និងសាវក ប៉ុលដែរ គឺព្រះមិនបានឆ្លើយតបនឹងសេចក្តីអធិស្ឋានរបស់ទ្រង់ និងរបស់គាត់។ សូម្បីតែព្រះយេស៊ូវ មុនពេលដែលគេឆ្កាងទ្រង់ ទ្រង់បានសូមដល់ព្រះវរបិតាថា “សូមយកពែងនេះចេញ”ពីទ្រង់។ ប៉ុន្តែការបន្ទាបខ្លួន និងការចុះចូលរបស់ទ្រង់ចំពោះបំណងព្រះហឫទ័យរបស់ព្រះ បានបង្ហាញនៅក្នុងផ្នែកទីពីរនៃសេចក្តីអធិស្ឋានរបស់ទ្រង់យ៉ាងដូចនេះថា “ប៉ុន្តែ កុំតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់វិញ” (លូ ២២:៤២)។

សាវក ប៉ុល “សូមអង្វរដល់ព្រះអម្ចាស់៣ដង” ដើម្បីសូមឲ្យទ្រង់ដកសេចក្តីវេទនារបស់គាត់។ ព្រះអម្ចាស់មិនបានដកចេញទេ ប៉ុន្តែទ្រង់បានមានបន្ទូលប្រាប់ដល់ប៉ុលវិញថា “គុណរបស់អញល្មមដល់ឯងហើយ ដ្បិតកំលាំងអញ

បានពេញខ្នាត ដោយសេចក្ដីកំសោយ ដូច្នេះ ខ្ញុំនឹងស៊ូអួតពីសេចក្ដីកំសោយរបស់ខ្ញុំ ដោយអំណរជាខ្លាំង ដើម្បីឲ្យព្រះចេស្ដានៃព្រះគ្រីស្ទបានសណ្ឋិតនៅនឹងខ្ញុំ” (២ កូរិន ១២:៨-៩)។ សេចក្ដីអធិស្ឋានដែលគ្មានចំលើយទាំងនេះ មិនបានធ្វើឲ្យព្រះយេស៊ូវ ឬសាវក ប៉ុល ឈប់ទុកចិត្តដល់ព្រះមួយអង្គដែលធ្វើកិច្ចការ “ទាំងអស់ផ្សំគ្នា សំរាប់សេចក្ដីល្អ” ទេ (រ៉ូម ៨:២៨)។ ព្រះនៅតែសន្យានឹងយើងដល់សព្វថ្ងៃនេះថា “អញនឹងមិនចាកចេញពីឯង ក៏មិនបោះបង់ចោលឯងឡើយ” (ហេ ១៣:៥)។ ដូច្នេះ យើងអាចនិយាយយ៉ាងក្លាហាន ដោយមិនគិតពីស្ថានភាពនោះថា “ខ្ញុំមិនព្រមខ្លាចឡើយ ព្រោះព្រះអម្ចាស់ទ្រង់ជាជំនួយខ្ញុំ តើមនុស្សនឹងធ្វើដល់ខ្ញុំជាយ៉ាងណាបាន” (ហេ ១៣:៦)។

# បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១. ហេតុអ្វីបានជាព្រះចង់ឲ្យយើងអធិស្ឋាន ? តើថ្មីៗនេះអ្នកមានបទពិសោធន៍ទទួលបានអត្ថប្រយោជន៍ពីសេចក្តីអធិស្ឋានដែរឬទេ ? សូមចំណាយពេលអធិស្ឋានបន្តិច ដើម្បីអរព្រះគុណដល់ព្រះសំរាប់ការដែលព្រះបានប្រទានពរដល់អ្នក តាមរយៈសេចក្តីអធិស្ឋាន ។

២. តើព្រះត្រូវតែប្រទានដល់យើង នូវអ្វីៗដែលយើងបានសូមនៅក្នុងសេចក្តីអធិស្ឋានរបស់យើងឬទេ ? ហេតុអ្វីបានជាត្រូវតែប្រទាន ឬ ហេតុអ្វីបានជាមិនត្រូវតែប្រទាន ?

៣. តើមានអ្វីមួយនៅក្នុងជីវិតអ្នកនៅពេលសព្វថ្ងៃនេះ អាចរារាំងដល់សេចក្តីអធិស្ឋានរបស់អ្នកដែរឬទេ ? ប្រសិនបើមាន សូមចំណាយពេលបន្តិចដើម្បីអធិស្ឋានសូមឲ្យព្រះអត់ទោសដល់អ្នកពីការទាំងឡាយណាដែលរារាំងដល់សេចក្តីអធិស្ឋានរបស់អ្នក ។

# ជំពូក ៦

# តើពួកទេវតា សាតាំង និងពួកអារក្សជាអ្វី ?

របូតមកដល់ចំនុចនេះ នៅពេលដែលពិភាក្សាពីការបង្កើតរបស់ព្រះ យើងបានពិភាក្សាត្រឹមតែផ្នែកទូទៅនៃរូបធាតុប៉ុណ្ណោះ ។ ប៉ុន្តែក៏មាន ស្នាព្រះហស្តរបស់ព្រះខាងឯវិញ្ញាណ ដែលព្រះបានបង្កើតមកផងដែរ នោះហៅថា ពួកទេវតា ពួកអារក្ស ។ សាតាំង គឺជាអារក្សមួយ ដែលគេចាត់ទុកថា ជាមេដឹកនាំពួកអារក្ស ។

## ពួកទេវតា

ទេវតាត្រូវបានបង្កើតមកឲ្យមានជីវិតខាងឯវិញ្ញាណ ដែលមានការចេះដឹងខុសត្រូវ និងមានបញ្ញាខ្ពស់ ប៉ុន្តែគ្មានរូបកាយទេ ។ ពួកគេជាអ្នកចំបាំងរបស់ព្រះ ហើយជាក្រុមមួយដែលជាញឹកញាប់ គេសំដៅថា ជា ពួកពលបរិវារ (ឬកងទ័ព)នៅលើមេឃ ។ ពួកគេមានដើមកំណើត ។ ពួកគេជាផ្នែកនៃចក្រវាឡដែលព្រះបានបង្កើតមក ។ លោក អែសរ៉ា បានបញ្ជាក់ការនេះ នៅពេលដែលគាត់បាននិយាយអំពីព្រះថា "ទ្រង់បានបង្កើតផ្ទៃមេឃ និងអស់ទាំងជាន់នៃផ្ទៃមេឃ ព្រមទាំងពួកពលបរិវារ" (នេហេមា ៩:៦) ។

ដោយព្រោះពួកទេវតាជា "វិញ្ញាណ" (ហេ ១:១៤) នោះពួកគេមិនមានរូបកាយទេ ។ ព្រះយេស៊ូវមានបន្ទូលថា "ដ្បិតខ្មោចគ្មានសាច់ ឬឆ្អឹង ដូចជាឃើញ

ខ្ញុំនេះទេ” (លូ ២៤:៣៩) ។ ដូច្នេះយើងមិនអាចមើលឃើញទេវតាបានទេ លុះត្រាតែព្រះបើកភ្នែករបស់យើង (ដូចជាទ្រង់បានធ្វើជាមួយបាឡាម នៅ ក្នុងព្រះគម្ពីរជនគណនា ២២:៣១) ឬក៏ ពួកគេយកទំរង់ជាមនុស្ស ដើម្បីលេចមកឲ្យយើងឃើញ (ដូចជាបានកើតឡើងនៅឯផ្នូររបស់ព្រះយេស៊ូវនៅក្នុងកណ្ឌម៉ាថាយ ២៨:៥) ។ ទោះជាយ៉ាងណាក៏ដោយ ជា ធម្មតា យើងមិនអាចមើលឃើញពួកទេវតា នៅពេលដែលពួកគេធ្វើសកម្មភាពការងារនៃការថែរក្សាយើង ក្នុងគ្រប់ទាំងផ្លូវបានទេ (ទំនុក ៩១:១១) ។ ហើយក៏មិនអាចមើលឃើញ នៅពេលពួកគេចូលរួមថ្វាយបង្គំព្រះជាមួយយើងបានដែរ (ហេ ១២:២២) ។ ពួកទេវតាបានបង្ហាញពីការចេះដឹងខុសត្រូវ នៅពេលដែលពួកគេ “បានធ្វើអំពើបាប” ហើយព្រះបានទំលាក់ពួកគេចេញពីស្ថានសួគ៌ (២ពេ ២:៤) ។ ពួកគេបង្ហាញពីបញ្ញារបស់ពួកគេតាមរយៈការនិយាយជាមួយមនុស្ស (ឧ៖ សូមមើលម៉ាថាយ ២៨:៥) និងការច្រៀងសរសើរដំកើងដល់ព្រះ (ឧ៖ សូមមើលវិវរណៈ ៤:១១) ។

ពួកទេវតាមានអំណាចខ្លាំងណាស់ ។ គេហៅពួកទេវតាថា “អ្នកមានឥទ្ធិឫទ្ធិខ្លាំង” (ទំនុក ១០៣:២០) ហើយជាពួកអ្នក “ដ៏មានកំលាំង មានឫទ្ធិលើសជាងគេ” (២ ពេ ២:១១) ។ ទោះជាយ៉ាងនេះក៏ដោយ ព្រះបានបង្ហាញសេចក្តីស្រឡាញ់ដ៏អស្ចារ្យមួយសំរាប់មនុស្ស លើសជាងសំរាប់ពួកទេវតា ដ្បិត “ព្រះមិនបានប្រណីដល់ពួកទេវតាដែលបានធ្វើបាប គឺទ្រង់បោះទំលាក់ទៅក្នុងជង្ហុកជ្រៅបំផុត ឲ្យជាប់ច្រវាក់នៃសេចក្តីងងឹត” (២ ពេ ២:៤) ។ ផ្ទុយទៅវិញ ទោះបីជា លោកអ័ដាម និងនាងអេវ៉ា ត្រូវបានបណ្តេញចេញពីសួនដ៏ស្រស់ត្រកាល នៅពេលពួកគេបានធ្វើ

បាបក៏ដោយ ប៉ុន្តែ ពួកគេមិនត្រូវបានបោះចោលទៅក្នុងស្ថាននរកទេ ។ ជំនួសការដាក់ច្រវាក់ ព្រះជាម្ចាស់បានធ្វើសំលៀកបំពាក់សំរាប់ពួកគេ បិទបាំងកេរ្តិ៍ខ្មាសវិញ (លោក ៣:២១-២៣) ។

នៅពេលដែលពួកទេវតាប្រតិបត្តិផែនការតាមបង្គាប់របស់ព្រះ ដោយធ្វើតាម "ព្រះបន្ទូលទ្រង់" (ទំនុក ១០៣:២០) មានន័យថា ពួកគេកំពុងបំរើព្រះ ទុកជាគំរូមួយសំរាប់យើងរាល់គ្នា ។ ពួកគេក៏បំរើព្រះ ទុកជាគំរូសំរាប់យើងរាល់គ្នាផងដែរ នៅពេលដែលពួកគេថ្វាយបង្គំ និងថ្វាយសិរីល្អដល់ព្រះឥតឈប់ឈរ (សូមមើល អេសាយ ៦:២-៣) ។ ដូច្នេះ យើងគួរតែដឹងពីវត្តមានដ៏មើលមិនឃើញរបស់ពួកទេវតា នៅពេលដែលពួកគេធ្វើការនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង ។ ពួកគេអាចនឹងចូលរួមជាមួយពួកយើងក្នុងការថ្វាយបង្គំព្រះ ការការពារ និងរក្សាសុវត្ថិភាពយើង ឬក៏ មកលេងយើងក្នុងនាមជាអ្នកចំងាយមកសុំសំណាក់នៅ (ហេ ១៣:២) ។ ប៉ុន្តែ យើងមិនត្រូវអធិស្ឋាន ឬថ្វាយបង្គំពួកទេវតាទេ ។ នៅពេលដែលសាវក យ៉ូហាន បានព្យាយាមថ្វាយបង្គំទេវតាម្នាក់ ទេវតានោះបាននិយាយភ្លាមថា "កុំឲ្យធ្វើដូច្នេះឡើយ ដ្បិតខ្ញុំជាបាវបំរើជាមួយនឹងអ្នក ហើយនិងបងប្អូនអ្នក ដែលមានសេចក្តីបន្ទាល់ពីព្រះយេស៊ូវដែរ" (វិវរ ១៩:១០) ។ យើងត្រូវថ្វាយបង្គំ និងអធិស្ឋានដល់ព្រះវិញ យើងមិនត្រូវធ្វើចំពោះទេវតាដែលជាផ្នែកនៃការបង្កើតរបស់ព្រះ ដូចជាយើងធ្វើចំពោះព្រះបានទេ ។

## ពួកអារក្ស

ពួកអារក្សជាពួកទេវតាអាក្រក់ ដែលបានធ្វើបាបប្រឆាំងនឹងព្រះ ហើយជាអ្នកដែលបន្តធ្វើការអាក្រក់ឥតឈប់ឈរក្នុងលោកិយសព្វថ្ងៃនេះ ។ ពួកវា ជា ពួកទេវតាដែលព្រះ “មិនបានប្រណី...ដែលបានធ្វើអំពើបាប គឺទ្រង់បោះទំលាក់ទៅក្នុងជង្ហុកជ្រៅបំផុត ឲ្យជាប់ច្រវាក់នៃសេចក្តីងងឹត” (២ ពេ ២:៤) ។ ប៉ុន្តែ ពួកអារក្សមិនបានចាប់ផ្តើម ជា ទេវតាអាក្រក់ទេ ។ ពួកគេជាផ្នែកនៃការបង្កើតដើមដំបូង គឺជាផ្នែកនៃអ្វីៗទាំងអស់ដែលព្រះបានបង្កើតមក ហើយទ្រង់គិតថា “ល្អប្រពៃ” (លោក ១:៣១) ។ ទោះបីជា ព្រះគម្ពីរមិនបានប្រាប់យើងចំៗ នៅពេលដែលពួកគេធ្លាក់ចុះក៏ដោយ ប៉ុន្តែ នៅចន្លោះពេលរវាងការបង្កើតរបស់ពួកគេ និងការល្បួងរបស់សាតាំងដែលនាំនាងអេវ៉ាឲ្យធ្វើបាប ពួកអារក្សទាំងនេះ “មិនបានរក្សាសណ្ឋានដើមរបស់ខ្លួន គឺជាទេវតាដែលបោះបង់ចោលទីលំនៅចេញ” (យូ ៦) ហើយត្រូវបានបោះចោលទៅក្នុងស្ថាននរក ។

សាតាំងគឺជាឈ្មោះផ្ទាល់ខ្លួនរបស់មេដឹកនាំពួកអារក្ស ។ គេនិយាយអំពីឈ្មោះវា នៅក្នុងបទគម្ពីរជាច្រើនដូចជា ១ របាក្សត្រ ២១:១ និយាយថា “សាតាំងក៏ឈរឡើង ទាស់នឹងពួកអ៊ីស្រាអែល បណ្តាលឲ្យដាវីឌរាប់ចំនួនបណ្តារាស្ត្រទាំងឡាយ” ។ ព្រះយេស៊ូវបានមានបន្ទូលផ្ទាល់ទៅកាន់វា នៅ ពេលដែលវាបានល្បួងទ្រង់នៅក្នុងទីរហោស្ថានថា “នែ សាតាំង ចូរឯងថយចេញពីអញទៅ” (ម៉ាថ ៤:១០)។ នៅពេលដែលពួកសិស្សប្រាប់ព្រះយេស៊ូវថា ពួកអារក្សក៏ចុះចូលនឹងពួកគេដោយព្រះនាមទ្រង់ដែរ ព្រះយេស៊ូវបានតបថា “ខ្ញុំបានឃើញអារក្សសាតាំង

ធ្លាក់ពីលើមេឃមក ដូចជាផ្លេកបន្ទោរ” (លូ ១០:១៨) ។ ព្រះគម្ពីរក៏ប្រើឈ្មោះខាងក្រោមសំដៅលើសាតាំងដែរ ដូចជា “អារក្ស” (ម៉ាថ ៤:១), “ពស់” (លោក ៣:១), “បេលសេប៊ូល” (ម៉ាថ ១០:២៥), “ចៅហ្វាយរបស់លោកិយនេះ” (យ៉ូន ១២:៣១), “មេគ្រប់គ្រងរាជ្យលើអាកាស” (អេ ២:២), “អាកំណាច” (ម៉ាថ ១៣:១៩) ។

សាតាំងគឺជា “អ្នកសំឡាប់គេតាំងពីដើមមក” ហើយជា “ឪពុកនៃសេចក្ដីកុហក” (យ៉ូន ៨:៤៤) ។ កណ្ឌ ១ យ៉ូហាន ៣:៨ បានប្រាប់យើងថា “អារក្សបានធ្វើបាប ចាប់តាំងពីដើមរៀងមក” ។ វាជាមេបង្កើតបាប ដែលបានធ្វើបាបមុនពេលដែលវា “បានបញ្ឆោតនាងអេវ៉ាដោយឧបាយកលយ៉ាងនោះដែរ” (២ កូរិន ១១:៣) ។ វាក៏ព្យាយាមល្បួងព្រះគ្រីស្ទឲ្យធ្វើបាប (ម៉ាថ ៤:១-១១) ដើម្បីឲ្យទ្រង់បរាជ័យក្នុងព័ន្ធកិច្ច ក្នុងការ “បំផ្លាញការរបស់អារក្សចេញ” របស់ទ្រង់ (១ យ៉ូន ៣:៨) ។ សាតាំង និងពួកអារក្សរបស់វា នឹងព្យាយាមប្រើល្បិចបំផ្លិញបំផ្លាញគ្រប់ប្រភេទ ដើម្បីធ្វើឲ្យមនុស្សខ្វាក់ “ក្រែងរស្មីពន្លឺនៃដំណឹងល្អ ដែលសំដែងពីសិរីល្អនៃព្រះគ្រីស្ទដ៏ជារូបអង្គព្រះ បានភ្លឺមកដល់គេ” (២ កូរិន ៤:៤) ។ ពួកគេនឹងប្រើល្បិចបំផ្លិចបំផ្លាញតាមរបៀបស្រដៀងគ្នា ដូចជា សេចក្ដីល្បួង ការសង្ស័យ កុហក កាប់សំលាប់ កំហុស សេចក្ដីភ័យខ្លាច សេចក្ដីវឹកវរ ជំងឺ ច្រណែនឈ្នានីស អំនួត ហើយការមួលបង្កាស ដើម្បីរាំងខ្ទប់ទីបន្ទាល់ និងភាពដ៏មានប្រយោជន៍របស់គ្រីស្ទបរិស័ទ ។

អំណាចរបស់សាតាំង និងពួកអារក្សរបស់វា មានកំណត់ ហើយអំណាចនោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះ ដែលទ្រង់បានកំណត់នូវអ្វីដែលវាអាចធ្វើបាន និងអ្វីដែលវាមិនអាចធ្វើបាន ។ ព្រះដាក់ពួកវា "ក្នុងសេចក្តីងងឹត ទាំងជាប់ចំណងអស់កល្បជានិច្ច" (យូ ៦) ។ យើងអាចតតាំងនឹងសាតាំងខ្លួនវាផ្ទាល់បានដោយជោគជ័យ តាមរយៈអំណាចព្រះគ្រីស្ទ "តស៊ូនឹងអារក្សវិញចុះ នោះវានឹងរត់ចេញពីអ្នករាល់គ្នាទៅ" (យ៉ា ៤:៧) ។ សាតាំង និងអារក្សរបស់វា មិនអាចដឹងពីអនាគតបានទេ ដ្បិតមានតែព្រះប៉ុណ្ណោះដែលអាចសំដែងប្រាប់ថា "ការដែលត្រូវមកខាងចុងបំផុត ហើយតាំងពីចាស់បុរាណ ដ៏ប្រាប់ពីការដែលមិនទាន់មានមកដែរ" (អេសា ៤៦:១០) ។ ទោះបីជា ពួកវាអាចនឹងសង្កេតឃើញនូវអ្វីដែលយើងធ្វើសព្វថ្ងៃនេះក៏ដោយ (ពីចំនុចនេះ អាចទាញការសន្និដ្ឋានមួយអំពីគំនិតរបស់យើង ឬអនាគតរបស់យើង) តែពួកវាមិនអាចដឹងប្រាកដពីអ្វីដែលយើងកំពុងគិត ឬអនាគតរបស់យើងជាយ៉ាងណានោះទេ (សូមមើលបទគម្ពីរ ដានីយ៉ែល ២:២៧-២៨ - គ្មាននរណាមួយអាចកាត់ស្រាយដោយអំណាចណាផ្សេងទៀតបានទេ មានតែព្រះនៃស្ថានសួគ៌ប៉ុណ្ណោះ ដែលទ្រង់អាចជ្រាបពីសប្តិរបស់ស្តេចបាន) ។

## សកម្មភាពរបស់ពួកអារក្ស

ដូចជាទេវតានៃព្រះ សាតាំង និងពួកអារក្សរបស់វាមមាញឹកក្នុងលោកិយសព្វថ្ងៃនេះ ហើយពួកវាធ្វើការដ៏អាក្រក់ជាច្រើន ។ ប៉ុន្តែ ពួកវាមិនទទួលខុសត្រូវចំពោះការអាក្រក់ទាំងអស់ដែលនៅក្នុងលោកិយនេះទេ ។ អំពើបាបជាច្រើនដែលបានចែង

នៅក្នុងព្រះគម្ពីរ គឺមិនមែនជាលទ្ធផលរបស់សាតាំង ឬពួកអារក្សរបស់វាទេ ប៉ុន្តែជាលទ្ធផលនៃសកម្មភាពផ្ទាល់របស់មនុស្សម្នាក់ៗវិញ (យ៉ា ១:១៤)។ ប៉ុន្តែព្រះគម្ពីរលើកទឹកចិត្តយើងថា "ចូរដឹងខ្លួន" ហើយ "ចាំយាមចុះ" ដ្បិត "វាតែងដើរក្រវែលទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណា ដែលវានឹងត្របាក់លេបបាន (១ ពេ ៥:៨)។ ដូច្នេះ យើងត្រូវបានលើកទឹកចិត្តឲ្យ "តស៊ូនឹងវា" (១ ពេ ៥:៩) ហើយ "កុំឲ្យអារក្សមានឱកាសឲ្យសោះ" (អេ ៤:២៧)។

នៅពេលសាតាំង និងពួកអារក្សរបស់វា វាយប្រហារតាមរបៀបផ្សេងៗ និងកំរិតផ្សេងៗ អ្នកដែលជឿដល់ព្រះគ្រីស្ទគួរដឹងថា តាមរយៈការសុគត ព្រះគ្រីស្ទបានបំផ្លាញអំណាចរបស់ "អានោះ ដែលមានអំណាចលើសេចក្តីស្លាប់ គឺជាអារក្ស" (ហេ ២:១៤)។ ហើយនៅឯឈើឆ្កាងព្រះបាន "ទំលាក់ងារពីពួកគ្រប់គ្រង និងពួកមានអំណាច ទាំងដាក់ពួកទាំងនោះនៅកណ្តាលជំនុំឲ្យគេឃើញ ហើយដឹកនាំគេទៅដោយមានជ័យជំនះ" នៅក្នុងព្រះគ្រីស្ទ (កូល ២:១៥)។ ដូច្នេះ ប្រសិនបើសាតាំង និងពួកអារក្សលើកគ្នាមកច្បាំងនឹងយើង យើងគួរទុកចិត្តនៅក្នុងជ័យជំនះរបស់ព្រះគ្រីស្ទ ហើយប្រើ "គ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់យើង" ដែល "ជាឥទ្ធិឫទ្ធិដែលមកពីព្រះ សំរាប់នឹងរំលំទីមាំមួនវិញ" (២ កូរិន ១០:៤)។ ជួនកាល យើងក៏សំរេចចិត្តនិយាយដោយផ្ទាល់ទៅកាន់វិញ្ញាណអាក្រក់ផងដែរ ដោយបង្គាប់ឲ្យវាថយចេញទៅ នៅក្នុងព្រះនាមព្រះយេស៊ូវ (សូមមើល លូ ៩:១; ១០:១៧; កិច្ច ៨:៧; ១៦:១៨; យ៉ា ៤:៧)។ យើងមិនគួរខ្លាចអារក្សទេ ដ្បិត "ព្រះដែលគង់នៅក្នុងអ្នករាល់គ្នា នោះ ទ្រង់ធំជាងអានោះ ដែលនៅក្នុងលោកិយផង"

(១ យ៉ូន ៩:៩) ។ គ្រប់ពេលវេលា យើងគួរតែ "កុំឲ្យអរសប្បាយ ដោយព្រោះអារក្សចុះចូលអ្នករាល់គ្នានោះឡើយ ត្រូវឲ្យរីករាយដោយព្រោះឈ្មោះអ្នករាល់គ្នាបានកត់ទុកនៅស្ថានសួគ៌វិញ" (លូ ១០:២០) ។

នៅក្នុងកណ្ឌគម្ពីររ៉ូម ១៦:២០ សាវក ប៉ុល បានប្រាប់ពួកគ្រីស្ទានថា "ព្រះនៃសេចក្តីសុខសាន្ត នៅ បន្តិចទៀតទ្រង់នឹងកិនអារក្សសាតាំងនៅក្រោមជើងអ្នករាល់គ្នាហើយ" ។ នៅខណៈពេលដែលដំណឹងល្អត្រូវបានគេប្រកាស ហើយមនុស្សបានមកជឿព្រះយេស៊ូវ មានន័យថា យើងឈ្នះចំបាំងខាងវិញ្ញាណមួយទៀតហើយ ។ ហើយថ្ងៃមួយព្រះគ្រីស្ទនឹងយាងមក ហើយនឹងដកឥទ្ធិពលរបស់អារក្សសាតាំងឲ្យអស់ពីលោកិយនេះចេញ (សូមមើល ២ ថែស ២:៨; វិវរ ២០:១-៣) ។

# បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១. តើពួកទេវតាមានលក្ខណៈដូចយើងយ៉ាងដូចម្តេច ? តើពួកគេមានលក្ខណៈខុសពីយើងដោយរបៀបណា ?

២. តើអ្វីទៅជាតួនាទីដ៏សំខាន់បំផុតរបស់ពួកទេវតា នៅក្នុងលោកិយសព្វថ្ងៃនេះ ?

៣. តើមានអ្វីខ្លះដែលព្រះគម្ពីរបានប្រាប់យើងអំពីសាតាំង ? តើការទាំងអស់នេះ ធ្វើឲ្យអ្នកចេះទប់ទល់នឹងសាតាំងដោយរបៀបណា ? តើការទាំងអស់នេះ ដកការភ័យខ្លាចដល់សាតាំង ចេញពីយើងរាល់គ្នាដោយរបៀបណា ?

# ជំពូក ៧

# តើមនុស្សជាអ្វី ?

បន្ទាប់ពីព្រះបានបង្កើតរុក្ខជាតិ និងសត្វនៅលើផែនដីរួចមក ទ្រង់មានការមួយផ្សេងទៀតដែលទ្រង់ត្រូវបង្កើត គឺជាការបង្កើតដ៏កំពូលរបស់ទ្រង់ ។ ដូច្នេះព្រះបានបង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់ ឲ្យចំនឹងរូបអង្គព្រះ ក៏បង្កើតគេមកជាប្រុសជាស្រី ។ ហើយព្រះប្រទានពរដល់គេ ។ “ចូរបង្កើតកូនឲ្យចំរើនជាច្រើនឡើង ឲ្យមានពេញពាសលើផែនដីចុះ ត្រូវបង្ក្រាបផែនដី ហើយមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស និងជីវិតផងទាំងឡាយដែលកំរើកនៅផែនដីផង” (លោក ១:២៧-២៨) ។

ព្រះជាម្ចាស់មិនបានបង្កើតយើងមក ដោយព្រោះទ្រង់ខ្វះ ឬក៏ត្រូវការអ្វីម្យ៉ាងនោះទេ ។ ទ្រង់មិនបាននៅឯកោទេ ហើយទ្រង់ក៏មិនត្រូវការឲ្យអ្នកណាម្នាក់ ឬអ្វីមួយ សរសើរ ហើយថ្វាយសិរីល្អដល់ទ្រង់ដែរ ។ ប៉ុន្តែ ទ្រង់នៅតែជ្រើសរើសដើម្បីបង្កើតយើងមក ហើយយើងត្រូវថ្វាយសិរីល្អដល់ទ្រង់ ។ នៅក្នុងអេសាយ ៤៣:៧ ព្រះមានបន្ទូលថា “គ្រប់មនុស្សដែលបានហៅតាមនាមឈ្មោះអញ ជាអ្នកដែលអញបានបង្កើតមកសំរាប់សិរីល្អនៃអញ” ។ ទោះបីជាសេចក្តីពិតនេះ ផ្តល់នូវអត្ថន័យដល់ជីវិតរបស់យើងក៏ដោយ ប៉ុន្តែ វា អាចហាក់ដូចជាទទេ និងគ្មានន័យវិញ ប្រសិនបើយើងមិនយល់ពីអត្ថន័យរបស់វា ។ ការថ្វាយសិរីល្អដល់ព្រះ គឺជា

ការគោរពប្រតិបត្តិ និងសរសើរដល់ទ្រង់ ហើយយើងអាចធ្វើយ៉ាងនោះតាមរបៀបផ្សេងៗ ។

## មនុស្សត្រូវបានបង្កើតមក សំរាប់សិរីល្អរបស់ព្រះ

ដោយព្រោះយើងត្រូវបានបង្កើតមកសំរាប់សិរីល្អរបស់ព្រះ នោះគោលបំណងដ៏សំខាន់បំផុតនៅក្នុងជីវិតរបស់យើង គួរតែរស់នៅសំរាប់សិរីល្អរបស់ទ្រង់ ។ ការថ្វាយសិរីល្អដល់ព្រះ នឹងធ្វើឲ្យជីវិតរបស់យើងមានបំណង និងមានន័យ ហើយវានឹងធ្វើឲ្យយើងមានសេចក្ដីអំណរនៅក្នុងជីវិតរបស់យើង ដែលយើងប្រាថ្នាចង់បាន ។ ព្រះយេស៊ូវបានមានបន្ទូលអំពីការថ្វាយសិរីល្អដល់ព្រះ គឺជាផ្នែកនៃជីវិតនៅពេលដែលទ្រង់បានមានបន្ទូលថា “ខ្ញុំបានមក ដើម្បីឲ្យវារាល់គ្នាមានជីវិតហើយឲ្យមានជីវិតនោះពេញបរិបូរផង” (យ៉ូន ១០:១០) ។

របៀបមួយដែលយើងថ្វាយសិរីល្អដល់ព្រះ គឺដោយមានអំណរចំពោះទ្រង់ ។ នៅពេលស្ដេចដាវីឌ និយាយថា “នៅចំពោះទ្រង់មានសេចក្ដីអំណរដ៏ពោរពេញ នៅព្រះហស្ដស្ដាំទ្រង់មានសេចក្ដីអរសប្បាយជាដរាបតទៅ” (ទំនុក ១៦:១១) ។ សេចក្ដីអំណរដ៏ពោរពេញ គឺត្រូវបានរកឃើញ ក្នុងការដែលស្គាល់ដល់ព្រះ និងរីករាយក្នុងទ្រង់ ។ នៅពេលដែលយើងធ្វើយ៉ាងដូច្នេះ មានន័យថាយើងថ្វាយសិរីល្អដែលទ្រង់ចង់បាន ហើយនោះជាអ្វីដែលយើងចង់ថ្វាយដល់ទ្រង់ ។ នៅក្នុងការនេះ យើងដឹងថា ព្រះកំពុងតែអរសប្បាយនឹងយើង ដោយ

“សេចក្ដីរីករាយ” និង “អរសប្បាយ” ចំពោះយើង “ដោយសំលេងច្រៀង” (សេ ៣:១៧) ។

## មនុស្សត្រូវបានបង្កើតមកឲ្យដូចជារូបអង្គព្រះ

ប្រសិនបើព្រះគម្ពីរគ្រាន់តែប្រាប់យើងថា យើងត្រូវបានបង្កើតមកសំរាប់សិរីល្អរបស់ព្រះ ការនោះជារឿងដ៏អស្ចារ្យ ប៉ុន្តែវានឹងមិនបង្ហាញពីភាពខុសគ្នារវាងយើង និងការបង្កើតផ្សេងដទៃទៀតទេ ។ ដ្បិត “ផ្ទៃមេឃសំដែងពីសិរីល្អនៃព្រះ ហើយលំហអាកាសក៏បង្ហាញការដែលព្រះហស្តទ្រង់ធ្វើ” (ទំនុក ១៩:១) ។ ប៉ុន្តែ ផ្នែកនៃការខុសប្លែកពីការបង្កើតដទៃទៀតរបស់យើង គឺមកពីសេចក្ដីពិតដែលថា យើងជាផ្នែកតែមួយគត់នៃការបង្កើតរបស់ព្រះ ដែលបង្កើតមក “ដូចរូបអង្គទ្រង់” (លោក ១:២៧) ។

ជាអ្នកដែលព្រះបានបង្កើតមកឲ្យដូចរូបអង្គទ្រង់ យើងបានបង្កើតមកឲ្យដូចជាទ្រង់ ។ ដូច្នេះ កាលណាយើងយល់ពីព្រះកាន់តែច្រើន នោះយើងយល់អំពីខ្លួនយើងកាន់តែច្រើនដែរ ។ ហើយកាលណាយើងយល់អំពីខ្លួនយើងកាន់តែច្រើន នោះយើងក៏យល់អំពីព្រះកាន់តែច្រើនដែរ ។ ឧទាហរណ៍៖ យើងជាការបង្កើតដែលដឹងខុសត្រូវ ដែលបានបង្កើតមកឲ្យមានវិចារណញ្ញាណដឹងខុសត្រូវតាំងពីកំណើត ។ នេះគឺជាការឆ្លុះបញ្ចាំងមួយនៃវិចារណញ្ញាណដឹងខុសត្រូវដ៏គ្រប់លក្ខណ៍របស់ព្រះ ។ មិនតែប៉ុណ្ណោះ យើងមិនគ្រាន់តែជាការបង្កើតខាងរូបកាយប៉ុណ្ណោះទេ យើងក៏ជាការបង្កើតខាងវិញ្ញាណផងដែរ មានន័យថា យើងមានលក្ខណៈជា

វិញ្ញាណដូចជាទ្រង់។ វិញ្ញាណរបស់យើង គឺជាការឆ្លុះបញ្ចាំងមួយពីនិស្ស័យរបស់ព្រះ ហើយធ្វើឲ្យយើងទាក់ទងជាមួយទ្រង់ដោយផ្ទាល់បាន ។ ឧទាហរណ៍៖ មួយទៀតដូចជា សមត្ថភាពក្នុងការគិតពិចារណា និងដំណើរការព័ត៌មានរបស់យើង គឺជាការឆ្លុះបញ្ចាំងមួយពីចំណេះដឹងរបស់ព្រះ ។ សមត្ថភាពក្នុងការទំនាក់ទំនងគ្នា និងក្តីប្រាថ្នារបស់យើងសំរាប់សហគមន៍ គឺជាការឆ្លុះបញ្ចាំងមួយនៃសហគមន៍ដ៏គ្រប់លក្ខណ៍នៅក្នុងព្រះត្រៃឯករបស់ទ្រង់ ។ ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ទាក់ទងគ្នាទៅវិញទៅមក យ៉ាងល្អគ្រប់លក្ខណ៍ ជារៀងរហូត ។

ដោយព្រោះអំពើបាប រូបអង្គព្រះនៅក្នុងយើងមានផ្នែកខ្លះមិនត្រឹមត្រូវ ។ លក្ខណៈរបស់ទ្រង់ មិនបានបង្ហាញឲ្យឃើញច្បាស់ដូចលើកមុនទេ ។ ទោះបីជាព្រះគម្ពីរបានបង្ហាញច្បាស់ថា មនុស្សនៅតែ “កើតមកតាមរូបអង្គព្រះ” (យ៉ា ៣:៩) ក៏ដោយ តែលក្ខណៈដូចរូបអង្គទ្រង់នោះ ត្រូវបានបង្ខូចដោយអំពើបាបហើយមើលទៅមិនដូចជាសណ្ឋានកាលពីដើមទេ ។ ឧទាហរណ៍៖ អំពើបាបធ្វើឲ្យខូចការវិនិច្ឆ័យដឹងខុសត្រូវរបស់យើង ធ្វើឲ្យការគិតរបស់យើងទៅជាងងឹត ហើយរាំងខ្ទប់យើង មិនឲ្យមានការប្រកបគ្នាជាមួយនឹងអ្នកដទៃទៀត ។

ដំណឹងល្អគឺមានន័យថា រូបអង្គរបស់ព្រះកំពុងតែត្រូវបានស្តារឡើងវិញនៅក្នុងយើង ។ ព្រះប្រោសលោះកូនៗរបស់ទ្រង់ តាមរយៈ ព្រះជន្ម ការសុគត និងការរស់ឡើងវិញ របស់ព្រះយេស៊ូវ យ៉ាងនោះបានជាពួកគេអាច “ត្រឡប់ដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់” (រ៉ូម ៨:២៩) ដែលទ្រង់ជា “រូបអង្គនៃព្រះដ៏មើលមិនឃើញ” (កូល ១:១៥) ។ សាវក ប៉ុល និយាយថា បងប្អូនគ្រីស្ទានមាននិស្ស័យថ្មី

“ដែលកំពុងតែកែឡើងខាងឯសេចក្តីចេះដឹង ឲ្យបានត្រូវនឹងរូបអង្គព្រះ ដែលបង្កើតមនុស្សថ្មីនោះមក” (កូល ៣:១០) ។ ហើយកាលកំពុងនៅលើផែនដីនេះនៅឡើយ យើង “កំពុងតែផ្លាស់ប្រែទៅ” ជារូបអង្គព្រះគ្រីស្ទ “ពីសិរីល្អទៅឯសិរីល្អ” (២ កូរិន ៣:១៨) ។

នៅទីបញ្ចប់នោះ កូនៗទាំងអស់របស់ព្រះ នឹងបានត្រឡប់ដូចជាព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ ។ ដ្បិត “យើងក៏នឹងមានរូបរាងរបស់ព្រះអម្ចាស់ពីស្ថានសួគ៌ ដូចជាយើងមានរូបរាងរបស់មនុស្ស ដែលធ្វើពីធូលីដីមកដែរ” (១ កូរិន ១៥:៤៩) ។ ព្រះគ្រីស្ទគឺ “ជារូបអង្គព្រះ” (២ កូរិន ៤:៤) នៅក្នុងភាពគ្រប់លក្ខណ៍មួយ ។ នៅក្នុងព្រះយេស៊ូវ យើងឃើញលក្ខណៈរបស់ផងព្រះ ដូចដែលព្រះមានបំណងចង់ឲ្យបានយ៉ាងដូច្នោះ ។ ដោយព្រោះព្រះយេស៊ូវ នៅទីបំផុតយើងនឹងបានផ្លាស់ប្រែ ដើម្បីឆ្លុះបញ្ចាំងឲ្យឃើញរូបអង្គព្រះ ដូចដែលព្រះមានបំណងចង់ធ្វើឲ្យយើងបានយ៉ាងដូច្នោះដែរ ។

## ទំនួលខុសត្រូវ ក្នុងនាមជាមនុស្សក្នុងរូបអង្គព្រះ

ជាមនុស្សដែលបានបង្កើតមកក្នុងរូបអង្គព្រះ យើងក៏ត្រូវបានបង្កើតមក ឲ្យធ្វើជាអ្នកតំណាងរបស់ទ្រង់នៅលើផែនដីនេះ ។ ប្រៀបដូចជាស្តេចមួយអង្គ ដែលដាក់រូបអង្គទ្រង់ផ្ទាល់ (ឧ៖ រូបចម្លាក់ និងរូបភាព) ជុំវិញនគររបស់ទ្រង់ ដើម្បីបង្ហាញពីទីកន្លែងដែលទ្រង់គ្រប់គ្រង ។ តាមរយៈយើង ព្រះបានដាក់រូបអង្គទ្រង់ពាសពេញពិភពលោកនេះ ។ នេះជាមូលហេតុដែលទ្រង់បានបង្គាប់ដល់អ័ដាម និងអេវ៉ា

“បង្កើតកូនឲ្យចំរើនជាច្រើនឡើង ឲ្យមានពាសពេញលើផែនដី” (លោក ១:២៨) ។ នៅពេលដែលពួកគេបានបង្កើតរូបអង្គព្រះឲ្យមាននៅពាសពេញផែនដី ពួកគេបានបង្ហាញថា ព្រះគ្រប់គ្រង និងសោយរាជ្យគ្រប់ទីកន្លែង ។ ហើយដោយព្រោះ “ផែនដី និងសារពើនៅផែនដី ជារបស់ព្រះយេហូវ៉ា” (ទំនុក ២៤:១) ព្រះសព្វព្រះហឫទ័យឲ្យរូបអង្គទ្រង់ “មានពាសពេញផែនដី” (លោក ១:២៨) ។ នៅពេលដែលយើងបំពេញផែនដីនេះដោយរូបអង្គព្រះ នោះយើងបង្ហាញថា ទ្រង់សោយរាជ្យ និងគ្រប់គ្រងនៅគ្រប់ទីកន្លែង ហើយថ្វាយសិរីល្អដែលទ្រង់សព្វព្រះហឫទ័យ និងសមទទួល ដល់ទ្រង់ ។

ក្នុងនាមអ្នកតំណាងរបស់ព្រះនៅលើផែនដីនេះ យើងក៏ត្រូវថែរក្សាទឹកដីរបស់ទ្រង់ដែរ ។ នៅពេលព្រះបានបង្គាប់ដល់អ័ដាម និងនាងអេវ៉ា “បង្ក្រាប” ផែនដីហើយ “មានអំណាចលើ...ជីវិតផងទាំងឡាយដែលកំរើកនៅផែនដី” (លោក ១:២៨) ទ្រង់បានធ្វើដូច្នេះ ប្រៀបដូចជាស្តេចមួយអង្គ កំពុងតែប្រាប់ដល់អ្នកតំណាងរបស់ទ្រង់ ឲ្យថែរក្សានគររបស់ទ្រង់ ក្នុងរបៀបមួយដែលលើកដំកើងដល់ទ្រង់ ។ ដូច្នេះ ទោះបីជាយើងមានសេរីភាពក្នុងការយកអ្វីៗ ពីភាពដ៏លើសលប់នៃផែនដីរបស់ព្រះក៏ដោយ ប៉ុន្តែ យើងត្រូវធ្វើតាមរបៀបមួយដែលបង្ហាញថា យើងថែរក្សាវា និងគោរពដល់អ្នកដែលបង្កើតវាមក ។ ហើយនៅពេលដែលយើងប្រើឱកាស ក្នុងការធ្វើឲ្យមានការរីកចំរើននៅក្នុងពិភពលោកដែលយើងរស់នៅនេះ មានន័យថា យើងកំពុងតែថ្វាយសិរីល្អដែលស័ក្តិសមដល់ព្រះ

ដោយធ្វើឲ្យពិភពលោកនេះមើលទៅកាន់តែដូចលក្ខណៈ ដែលទ្រង់បានរចនាឡើង ។

ពួកអ្នកផ្ទុករូបអង្គព្រះ គឺជាពួកអ្នកតំណាងនៃចក្រវាឡនេះ ដូច្នេះយើងមានទំនួលខុសត្រូវដ៏អស្ចារ្យ ក្នុងការជួយស្តាររាស្ត្រ និងទឹកដីរបស់ទ្រង់ឡើងវិញ ទៅកាន់ផ្លូវដែលគេគួរទៅ ។ យើងមានឱកាសធ្វើការជាមួយស្តេចដែល “ធ្វើទាំងអស់ឡើងជាថ្មី” (វិវរ ២១:៥) ។

ដូច្នេះយើងមានសេចក្តីសង្ឃឹម និងការគោរពដ៏ធំធេង ចំពោះមនុស្សទាំងអស់ ដោយមិនគិតពីសណ្ឋានរបស់ពួកគេឡើយ ។ ពួកគេជាកំពូលនៃការបង្កើតដ៏ប្រកបដោយប្រាជ្ញាញាណគ្មានព្រំខណ្ឌ និងដ៏ជំនាញរបស់ព្រះ ដូចពួកយើងដែរ ។ ពួកគេមានសក្តានុពល ក្នុងការត្រឡប់មកឯភាពលំអនៃព្រះយេស៊ូវគ្រីស្ទ “រូបអង្គនៃព្រះដ៏មើលមិនឃើញ” (កូល ១:១៥) ដោយការចេញពីអំពើបាប ហើយបែរទៅរកព្រះដែលបង្កើតពួកគេមក ។

យើងក៏មានសេចក្តីសង្ឃឹម និងការគោរពដ៏ធំធេង ដែលព្រះឲ្យយើងធ្វើចំពោះលោកិយនេះដែរ ។ យើងចង់ឃើញលោកិយនេះ ត្រឡប់ទៅរកសណ្ឋានដើមរបស់វាវិញ គឺជាលោកិយដែលដុះជា “បន្លា ហើយនឹងអញ្ចាញ” (លោក ៣:១៨) ។ ហើយខណៈពេលដែលយើងធ្វើការយ៉ាងអរសប្បាយចំពោះគោលបំណងនេះ នោះយើងថ្វាយសិរីល្អដល់ព្រះដែលបានបង្កើតយើងមកឲ្យថ្វាយសិរីល្អដល់ទ្រង់ ។

# បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១. ហេតុអ្វីបានជាព្រះបង្កើតយើងមក ? តើអ្វីខ្លះដែលជាឧទាហរណ៍ចំៗពីរបៀបដែលយើងអាចសំរេចគោលបំណង ដែលព្រះបានបង្កើតយើងមក ?

២. តើការបង្កើតឲ្យដូចរូបអង្គទ្រង់ មានន័យយ៉ាងដូចម្តេច ? តើការនោះមានឥទ្ធិពលលើទស្សនៈផ្ទាល់ខ្លួនរបស់អ្នកយ៉ាងដូចម្តេច ?

៣. តើអ្នកផ្ទុករូបអង្គព្រះ មានទំនួលខុសត្រូវអ្វីខ្លះ ? តើរបៀបណាខ្លះ ដែលអ្នក និងពួកជំនុំរបស់អ្នក អាចបំពេញទំនួលខុសត្រូវទាំងនោះបាន ?

# ជំពូក ៨

# តើអំពើបាបជាអ្វី ?

បាបធ្វើឲ្យអ្វីៗទាំងអស់មានបញ្ហា ។ យើងមិនបានរស់នៅតាមបែបជីវិតមួយដែលព្រះបានតាក់តែងឲ្យរស់នៅកាលពីដើមដំបូងនោះទេ ហើយយើងក៏មិនបានរស់នៅក្នុងលោកិយនេះ ដូចដែលព្រះបានតាក់តែងឲ្យរស់នៅ កាលពីដើមដំបូងដែរ ។ អំពើបាប ធ្វើឲ្យខូចរូបអង្គព្រះដែលនៅក្នុងយើង ។ ព្រះបានបង្កើតយើងមកឲ្យឆ្លុះបញ្ចាំងពីភាពគ្រប់លក្ខណ៍ តែ យើងមិនអាចធ្វើជាការឆ្លុះបញ្ចាំងពីភាពគ្រប់លក្ខណ៍នោះទៀតទេ ។ ដោយព្រោះអំពើបាប អ្វីៗមិនបានដើរតាមលំអានដើមរបស់ពួកវាទេ ។ រឿងរ៉ាវមនុស្សជាតិ ដែលបានបង្ហាញនៅក្នុងព្រះគម្ពីរ គឺជារឿងរ៉ាវនៃការដែលព្រះកំពុងតែជួសជុលមនុស្សបាក់បែក នៅក្នុងលោកិយដែលបាក់បែកមួយ ។ វាគឺជារឿងរ៉ាវនៃជ័យជំនះរបស់ព្រះលើអំពើបាបក្នុងលោកិយនេះ ។

## តើអំពើបាបជាអ្វី ?

អំពើបាបគឺជាការខកខានទាំងឡាយណា ដែលផ្ទុយពីក្រិត្យវិន័យខាងសីលធម៌របស់ព្រះក្នុងការប្រព្រឹត្តិ អាកប្បកិរិយា ឬនិស្ស័យ ។ ព្រះបានប្រទានឲ្យមានក្រិត្យវិន័យខាងសីលធម៌ ជា ច្រើនកន្លែងនៅក្នុងព្រះគម្ពីរទាំងមូល ។ កន្លែងមួយក្នុងចំណោមនោះ គឺក្រិត្យវិន័យទាំងដប់ប្រការ នៅក្នុងកណ្ឌគម្ពីរនិក្ខមនំ ២០:១-១៧ ។

ប្រសិន អំពើបាបជាសកម្មភាពទាំងឡាយណាដែលផ្ទុយពីច្បាប់សីលធម៌របស់ព្រះ នោះវាសមហេតុផលដែលគម្ពីរនិក្ខមនំ ២០:១៣ និយាយថា "កុំឲ្យសំឡាប់មនុស្សឲ្យសោះ" ហើយនិក្ខមនំ ២០:១៥ និយាយថា "កុំឲ្យលួចប្លន់ឲ្យសោះ" ។ ប៉ុន្តែ អំពើបាបក៏បានរកឃើញនៅក្នុងអាកប្បកិរិយាដែលផ្ទុយពីច្បាប់សីលធម៌របស់ព្រះដែរ ។ នេះជាមូលហេតុដែលគម្ពីរនិក្ខមនំ ២០:១៧ និយាយថា "កុំឲ្យលោភចង់បានផ្ទះអ្នកជិតខាងខ្លួនឲ្យសោះ" ក៏កុំឲ្យលោភចង់បានប្រពន្ធគេ" ។ អំពើបាបក៏បានរកឃើញនៅក្នុងនិស្ស័យរបស់យើង គឺចរិតខាងក្នុងដែលជាលក្ខណៈដ៏សំខាន់របស់យើង ។ នេះជាមូលហេតុដែលសាវក ប៉ុល បាននិយាយថា អស់អ្នកដែលបដិសេធព្រះយេស៊ូវជា "មនុស្សជាប់ក្នុងសេចក្តីខ្ញាល់" (អេ ២:៣) ។

ព្រះមានចរិតល្អជារៀងរហូត ដោយទ្រង់ធ្វើតាមច្បាប់សីលធម៌របស់ទ្រង់បាន យ៉ាងគ្រប់លក្ខណ៍ ។ ដូច្នេះអ្វីណាមួយដែលប្រឆាំងនឹងច្បាប់សីលធម៌របស់ទ្រង់ គឺប្រឆាំងនឹងចរិតរបស់ទ្រង់ មានន័យថាវាប្រឆាំងនឹងទ្រង់ផ្ទាល់តែម្តង ។ ព្រះស្អប់អំពើបាប ពីព្រោះបាបប្រឆាំងផ្ទាល់នឹងអ្វីៗគ្រប់យ៉ាងដែលជាចរិតរបស់ទ្រង់ ។

## តើអំពើបាបមកពីណា ?

ដោយព្រោះអំពើបាបទាស់ប្រឆាំងនឹងព្រះទាំងស្រុង នោះទ្រង់មិនអាចនឹងធ្វើបាបទេ ហើយយើងមិនគួរបន្ទោសព្រះពីអំពើបាប ឬគិតថាទ្រង់មានទំនួលខុសត្រូវចំពោះអំពើបាបដែរ ។ "ការរបស់ទ្រង់សុទ្ធតែគ្រប់លក្ខណ៍" ហើយ "អស់ទាំងផ្លូវ

ទ្រង់ សុទ្ធតែប្រកបដោយយុត្តិធម៌ ។ ទ្រង់ជាព្រះដ៏ស្មោះត្រង់ ឥតមានសេចក្តីទុច្ចរិតណាឡើយ ទ្រង់ក៏ត្រឹមត្រូវ ហើយទៀងត្រង់" (ចោទិ ៣២:៤) ។ មិនអាចទៅរួចទេ ដែលព្រះចង់ធ្វើខុសនោះ "ដ្បិតសេចក្តីអាក្រក់ពុំអាចនឹងល្បួងនាំព្រះហឫទ័យព្រះបានឡើយ ហើយព្រះក៏មិនល្បួងអ្នកណាដែរ" (យ៉ា ១:១៣) ។ ប៉ុន្តែព្រះគម្ពីរបានចែងផងដែរថា ព្រះ "ធ្វើគ្រប់ទាំងអស់ តាមដែលគាប់ព្រះហឫទ័យទ្រង់" (អេ ១:១១) ដូច្នេះ ហាក់ដូចជាព្រះបានតាំង ឲ្យអំពើបាបបានចូលមកក្នុងលោកិយនេះដោយរបៀបណាមួយ ។ ព្រះមិនបានភ្ញាក់ផ្អើលនឹងអំពើបាបដែលចូលមកក្នុងលោកិយនេះទេ ហើយវាក៏មិនមានអំណាចលើទ្រង់ដែរ ។ តែ ព្រះបានសំរេចព្រះហឫទ័យថា ទ្រង់នឹងអនុញ្ញាតឲ្យការបង្កើតដែលដឹងខុសត្រូវ ជ្រើសរើសធ្វើបាបតាមចិត្តដែលគេចង់ធ្វើ និងដោយស្ម័គ្រចិត្ត វិញ ។ របៀបដែលយើងដាក់សេចក្តីពិតទាំងពីរនេះចូលគ្នា គឺជាចម្ងល់មួយដ៏ពិបាកបំផុតនៅក្នុងការសិក្សាវិជ្ជាព្រះគម្ពីរ ហើយវាជាការដែលប្រសើរសំរាប់យើង ក្នុងការដែលយើងទទួលយកសមាសធាតុមួយនៃសេចក្តីអាថ៌កំបាំង ដោយទទួលស្គាល់ថា ការយល់ដឹងពេញលេញពីសេចក្តីអាថ៌កំបាំងនោះ គឺលើសពីសមត្ថភាពរបស់មនុស្សនៅសម័យនេះ ។ (ការទទួលស្គាល់សេចក្តីអាថ៌កំបាំងនេះ គួរការពារយើងមិនឲ្យធ្លាក់ចូលទៅក្នុងការវែកញែកដោយកំហឹង លើប្រធានបទនេះ) ។

បាបមាននៅក្នុងសាតាំង និងពួកអារក្សរបស់វា តាំងពីមុនការមិនស្តាប់បង្គាប់របស់លោក អ័ដាម និងនាងអេវ៉ា មកម៉្លេះ ហើយបន្ទាប់មកវាបានចូលមកក្នុងលោកិយនៃមនុស្សជាតិនេះ ដោយការសំរេចចិត្តរបស់ពួកគេ ។ ព្រះបានមាន

បន្ទូលប្រាប់អ័ដាមថា "តែឯត្រង់ដើមដឹងខុសត្រូវ នោះមិនត្រូវឲ្យឯងស៊ីផល ឡើយ" (លោក ២:១៧) ។ ដូច្នេះ នៅពេលដែលលោក អ័ដាម និងនាងអេវ៉ា បាន បរិភោគពីដើមឈើនោះ (លោក ៣:៦) ពួកគេបានធ្វើខុសដោយផ្ទាល់ចំពោះការ បង្គាប់របស់ព្រះ ។ ព្រះ និង អារក្ស មិនបានបង្ខំឲ្យពួកគេបរិភោគពីដើមនោះទេ គឺ ពួកគេធ្វើដោយស្ម័គ្រពីចិត្ត ហើយពួកគេក៏បានធ្វើបាបចំពោះព្រះដោយស្ម័គ្រពីចិត្ត ដែរ ។

ជាលទ្ធផល និស្ស័យរបស់អ័ដាម បានក្លាយជានិស្ស័យដែលមានពោរ ពេញទៅដោយបាប ។ បាបបានក្លាយជាអ្វីមួយ ដែលអ័ដាមបានធ្វើជាធម្មតាទៅ វិញ ។ បាបរបស់អ័ដាមក៏បណ្តាលឲ្យយើងទទួលបាននូវនិស្ស័យដ៏ពោរពេញ ដោយអំពើបាបនោះ ហើយជាធម្មតា និស្ស័យនេះប្រឆាំងចំពោះព្រះ និងច្បាប់ សីលធម៌របស់ទ្រង់ ។ មូលហេតុនេះហើយបានជាសាវក ប៉ុល បាននិយាយថា "ខ្ញុំ ដឹងថា នៅក្នុងខ្លួនខ្ញុំ គឺក្នុងសាច់ឈាមខ្ញុំ គ្មានអ្វីល្អទេ" (រ៉ូម ៧:១៨) ។ ហោរា យេរេមាក៏បាននិយាយដែរថា "ចិត្តជាគ្រឿងបញ្ឆោតលើសជាងទាំងអស់ ហើយក៏ អាក្រក់ហួសល្បត់ផង តើអ្នកណានឹងអាចស្គាល់បាន" (យេ ១៧:៩) ។ ហើយវាក៏ ជាមូលហេតុដែលស្តេច ដា វីឌ បានមានបន្ទូលថា "ទូលបង្គំបានកើតមកក្នុង សេចក្តីទុច្ចរិត ហើយម្តាយទូលបង្គំបានមានទំងន់" (ទំនុក ៥១:៥) ។ ហើយ "ពួក មនុស្សអាក្រក់ គេជាអ្នកដទៃ តាំងតែពីកំណើតមក គេវង្វេង" (ទំនុក ៥៨:៣) ។

ទោះបីជា យើងបានទទួលមរតកអំពើបាបក៏ដោយ ប៉ុន្តែយើងមិនមែន អាក្រក់ដូចជាសារធាតុពិតដែលយើងមាននោះទេ ។ ប៉ុន្តែមានន័យថា យើងគឺដូច

ជាលោក អ័ដាម ក្រោយពេលគាត់បានធ្វើបាបយ៉ាងដូច្នេះដែរ គឺមិនអាចពឹងខ្លួនឯងដើម្បីធ្វើអ្វីមួយឲ្យគាប់ព្រះហឫទ័យដល់ព្រះបានទេ ។ យើងខ្វះសេចក្ដីល្អខាងឯវិញ្ញាណនៅក្នុងខ្លួនយើង ដូច្នេះហើយយើងមិនអាចធ្វើសេចក្ដីល្អខាងឯវិញ្ញាណណាមួយចំពោះព្រះបានឡើយ ។ ទោះបីជា យើងអាចនឹងធ្វើអ្វីៗដែលហាក់ដូចជាការល្អ តាមគំនិតមនុស្សក៏ដោយ តែ នៅចំពោះព្រះ "អស់ទាំងអំពើសុចរិតរបស់យើងខ្ញុំ ក៏ដូចជាអាវកខ្វក់ហើយ" (អេសា ៦៤:៦) ។

គ្រប់ផ្នែកនៃសណ្ឋានរបស់យើងត្រូវបានប៉ះពាល់ដោយអំពើបាប ដូចជាសមត្ថភាពយល់ដឹងរបស់យើង អារម្មណ៍របស់យើង សេចក្ដីប្រាថ្នារបស់យើង ចិត្តរបស់យើង គោលដៅរបស់យើង ការជំរុញទឹកចិត្តរបស់យើង ហើយសូម្បីតែរូបកាយរបស់យើង ។ ទាំងអស់នេះធ្វើឲ្យមានសេចក្ដីពុករលួយ និងសេចក្ដីវិនាសដែលបណ្ដាលមកពីអំពើបាប ។ សកម្មភាពរបស់យើង អាកប្បកិរិយារបស់យើង ហើយនិងនិស្ស័យរបស់យើង សុទ្ធតែធ្វើឲ្យយើងមានទោសនៃអំពើបាប ។

យើងបានទទួល មិនត្រឹមតែនិស្ស័យបាបរបស់អ័ដាមប៉ុណ្ណោះទេ ប៉ុន្តែយើង ក៏បានទទួលបាបដែលបង្កើតឲ្យមានទោសរបស់គាត់ផងដែរ ។ សកម្មភាពរបស់អ័ដាម មានលទ្ធផលមិនត្រឹមតែនៅក្នុងទោសផ្ទាល់ខ្លួនរបស់គាត់ប៉ុណ្ណោះទេ តែនៅក្នុងទោសនៃមនុស្សគ្រប់គ្នាផងដែរ ។ ដូចជាសាវក ប៉ុល បានពន្យល់ថា "បាបបានចូលមកក្នុងលោកិយ ដោយសារមនុស្សតែម្នាក់ ហើយក៏មានសេចក្ដីស្លាប់ចូលមកដែរ ដោយសារអំពើបាបនោះជាយ៉ាងណា នោះសេចក្ដីស្លាប់បានឆ្លងរាលដាល ដល់មនុស្សគ្រប់គ្នាយ៉ាងនោះដែរ" (រ៉ូម ៥:១២) ។ ហើយ "ដូចជា

មនុស្សជាច្រើន បានត្រឡប់ជាមានបាបដោយសារមនុស្សតែម្នាក់ មិនបានស្តាប់បង្គាប់” (រ៉ូម ៥:១៩)។ ព្រះចាត់ទុកមនុស្សជាតិជាសមូហភាពរួមមួយ ដែលតំណាងដោយលោក អ័ដាម ជាក្បាលដឹកនាំរបស់សមូហភាពនោះ ។ ដូចដែលមានចែងយ៉ាងច្បាស់នៅក្នុងគម្ពីររ៉ូម ៥:១៩ ទ្រង់ក៏ចាត់ទុកប្រជាជាតិថ្មីនៃពួកគ្រីស្ទានជាសមូហភាពរួមមួយដែរ ដែលតំណាងដោយព្រះគ្រីស្ទ ជា ព្រះសិរសាររបស់សមូហភាពនោះ ។ យើងមិនអាចទទួលយកចំនុចទីពីរ ដោយមិនទទួលយកចំនុចទីមួយបានទេ ។

ប្រសិនបើយើងមិនជឿថា យើងត្រូវបានចាត់ទុកជាអ្នកមានទោសដោយព្រោះអំពើបាបរបស់អ័ដាមទេ នោះមានន័យថា យើងប្រឆាំងនឹងច្បាប់សីលធម៌របស់ព្រះ ក្នុងអាកប្បកិរិយា និងក្នុងសកម្មភាពហើយ ។ ដូច្នេះ យើងមានទោសនៃអំពើបាប ហើយត្រូវការរបៀបមួយជាចាំបាច់ ដើម្បីធ្វើឲ្យខ្លួនរបស់យើងបានត្រឹមត្រូវជាមួយនឹងព្រះ ។ ដំណឹងល្អគឺថា ព្រះបានរៀបចំលោកិយនេះនៅក្នុងរបៀបមួយ ដែលទោសរបស់យើងម្នាក់ៗ អាចត្រូវបានលោះមកតាមរយៈកិច្ចការនៃបុគ្គលម្នាក់ទៀត។ ការមិនស្តាប់បង្គាប់របស់យើងម្នាក់ៗ អាចត្រូវបានធ្វើឲ្យត្រឹមត្រូវ ដោយការស្តាប់បង្គាប់របស់បុគ្គលម្នាក់ទៀត ។ អំពើបាបរបស់យើងម្នាក់ៗ អាចយកចេញដោយភាពគ្មានបាបរបស់បុគ្គលម្នាក់ទៀត ។

## តើអំពើបាបមានឥទ្ធិពលលើយើងរាល់គ្នាដោយរបៀបណា ?

បទគម្ពីរបង្ហាញយ៉ាងច្បាស់ថា "ដ្បិតគ្មានមនុស្សណាមួយដែលមិនធ្វើបាបឡើយ" (១ ពង្សា ៨:៤៦), "គ្មានអ្នកណាមួយដែលប្រព្រឹត្តិល្អឡើយ"(ទំនុក ១៤:៣), "គ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ" (រ៉ូម ៣:២៣), ហើយសាវក យ៉ូហាន បានប្រាប់យើងថា "ប្រសិនជាយើងថា យើងគ្មានបាបសោះ នោះឈ្មោះថាយើងបញ្ឆោតដល់ខ្លួន ហើយសេចក្តីពិតមិនស្ថិតនៅក្នុងយើងទេ" (១ យ៉ូន ១:៨) ។ ដូច្នេះ មនុស្សទាំងអស់មានទោសនៅចំពោះព្រះ ។

ព្រះបានមានបន្ទូលថា ទោសនៃការបរិភោគពីដើមឈើដឹងខុសត្រូវ គឺជាសេចក្តីស្លាប់ (លោក ២:១៧) ។ សាវក ប៉ុល បានប្រាប់យើងថា តាមពិតទៅសេចក្តីស្លាប់គឺជាទោសសំរាប់គ្រប់ទាំងអំពើបាប "ឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់" (រ៉ូម ៦:២៣) ។ ប៉ុន្តែ ព្រះមិនបាននាំទោសស្លាប់មកលើអ័ដាម និងនាងអេវ៉ា ភ្លាមទេ ដូច្នេះទ្រង់ក៏មិននាំទោសស្លាប់មកលើយើងភ្លាមដែរ ។ ជាការពិតណាស់ តាមរយៈព្រះជន្ម ការសុគត ហើយនិងការរស់ឡើងវិញរបស់ព្រះយេស៊ូវ ព្រះផ្តល់ឲ្យយើងមានសេរីភាពពីការផ្តន្ទាទោសដែលអំពើបាបនាំមក ។ សាវក ពេត្រុស បាននិយាយអំពីព្រះយេស៊ូវថា "ទ្រង់បានផ្ទុកអំពើបាបយើងរាល់គ្នា នៅលើរូបអង្គទ្រង់ ជាប់លើឈើឆ្កាង ដើម្បីឲ្យយើងបានរស់ខាងឯសេចក្តីសុចរិត ដោយបានស្លាប់ខាងឯអំពើបាបហើយ" (១ ពេ ២:២៤) ។ អស់អ្នកណាដែលសំឡឹងមើលទៅព្រះយេស៊ូវ សំរាប់ការអត់ទោសនៃអំពើបាបរបស់គេ "នោះគ្មានទោសសោះ" (រ៉ូម ៨:១) ។

ដូច្នេះ នៅពេលដែលយើងធ្វើបាប ក្នុងកាលដែលយើងជាគ្រីស្ទានដែលបានទទួលការអត់ទោសហើយនោះ ការឈរដោយស្របច្បាប់នៅចំពោះព្រះ គឺមិនមានការប៉ះពាល់ទេ ។ យើងនៅតែទទួលការអត់ទោសដដែល ពីព្រោះការសុគតរបស់ព្រះគ្រីស្ទបានសងសំរាប់អំពើបាបទាំងអស់របស់យើងរួចហើយ ។ សាវ៉កប៉ុល បានប្រាប់យើងថា "ព្រះគ្រីស្ទបានសុគតដោយព្រោះបាបរបស់យើងរាល់គ្នា" (១ កូរិន ១៥:៣) គឺដោយគ្មានការបែងចែកបាបនៅអតីតកាល បច្ចុប្បន្ន និងអនាគតទេ ។ ទោះបីជា សាវ៉ក យ៉ូហាន ប្រាប់យើងថា យើងរាល់គ្នាធ្វើបាបក៏ដោយ ប៉ុន្តែគាត់ក៏បញ្ជាក់ថា សូម្បីតែនៅក្នុងអំពើបាបរបស់យើង "ឥឡូវនេះ យើងរាល់គ្នាជាកូនព្រះហើយ" (១ យ៉ូន ៣:២) ។

ទោះជាអំពើបាបមិនធ្វើឲ្យប៉ះពាល់ដល់សណ្ឋាន ឬការឈរជាមួយព្រះក៏ដោយ ប៉ុន្តែវាប៉ះពាល់ដល់ការប្រកបរបស់យើងជាមួយនឹងព្រះ ដ្បិតព្រះទ្រង់ព្រួយព្រះហឫទ័យដោយព្រោះបាបយើង ។ ជាញឹកញាប់ ការនេះអាចជាលទ្ធផលក្នុងការវាយប្រដៅរបស់ព្រះនៅក្នុងជីវិតរបស់យើង ព្រោះ "ទ្រង់ផ្ចាញ់ផ្ចាលចំពោះអស់អ្នកណាដែលទ្រង់ស្រឡាញ់" (ហេ ១២:៦) ។ ការផ្ចាញ់ផ្ចាលដ៏មានសេចក្តីស្រឡាញ់នេះគឺ "សំរាប់ជាប្រយោជន៍ដល់យើងវិញ ដើម្បីឲ្យយើងបានសេចក្តីបរិសុទ្ធរបស់ទ្រង់" (ហេ ១២:១០) ។ អំពើបាបក៏អាចប៉ះពាល់ដល់ទំនាក់ទំនងរបស់យើងជាមួយនឹងអ្នកដទៃទៀតដែរ ។ ពាក្យសំដី ឬសកម្មភាពដែលមានបាបក៏អាចជាលទ្ធផលនៅក្នុងការបាក់បែកទំនាក់ទំនងរវាងគ្រីស្ទាន និងគ្រីស្ទានដែរ ។

ទោះបីជាគ្រីស្ទានទាំងអស់នៅតែធ្វើបាបក៏ដោយ តែ ពួកគេមិនគួរធ្វើនៅក្នុងរយៈពេលដ៏យូរមួយនៃការមិនស្តាប់បង្គាប់ដែលកាន់តែខ្លាំងឡើងៗ ចំពោះច្បាប់សីលធម៌របស់ព្រះនោះទេ ដ្បិត “អស់អ្នកណាដែលកើតពីព្រះ នោះមិនដែលប្រព្រឹត្តិអំពើបាបទេ” (១ យ៉ូន ៣:៩)។ ប្រសិនបើមនុស្សម្នាក់ប្រព្រឹត្តិអំពើបាប ហើយអ្នកនោះ នៅតែបន្តធ្វើរហូតក្នុងការមិនស្តាប់បង្គាប់ដោយគ្មានការប្រែចិត្ត ប្រហែលជាគាត់ អាចនឹងមិនដែលទុកចិត្តដល់ព្រះយេស៊ូវសំរាប់សេចក្តីសង្គ្រោះដោយពិតប្រាកដទេ ។ ការនេះមានន័យថា គំរូដ៏ពោរពេញដោយអំពើបាបនៃជីវិតរបស់គាត់ បង្ហាញថាគាត់មិនដែលជាគ្រីស្ទានម្នាក់ពិតប្រាកដនោះទេ ។

ផ្ទុយទៅវិញ នៅពេលដែលគ្រីស្ទានធ្វើបាប ពួកគេគួរ “លន់តួ” អំពើបាបរបស់គេចំពោះព្រះដោយស្មោះត្រង់ និងភ្លាមៗ។ ពេលយើងធ្វើដូច្នេះ យើងនឹងដឹងថាព្រះ “មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឲ្យយើង ហើយនិងសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង” (១ យ៉ូន ១:៩) ។

# បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១. តើបាបជាអ្វី ? តើវាប៉ះពាល់ជីវិតរបស់យើង និងលោកិយដែលយើងរស់នៅ ដោយរបៀបណា ?

២. តើគ្រីស្ទាននឹងនៅតែបន្តធ្វើបាបទៀតឬ ? ហេតុអ្វីនឹងបន្ត ឬហេតុអ្វីនឹងមិនបន្ត ?

៣. តើអ្វីខ្លះជាលទ្ធផលអវិជ្ជមាននៃ អំពើបាបក្នុងជីវិតជាគ្រីស្ទានរបស់យើង ? តើគ្រីស្ទានគួរធ្វើយ៉ាងដូចម្តេច ប្រសិនបើពួកគេធ្វើបាប ?

៤. តើគេយកឈ្នះអំពើបាបដោយរបៀបណា ? តើការនេះធ្វើឲ្យយើងមានអារម្មណ៍យ៉ាងដូចម្តេច ? សូមចំណាយពេលបន្តិចបន្តួចដើម្បីអធិស្ឋាន ដោយទូលដល់ព្រះថា ជ័យជំនះលើអំពើបាបរបស់ទ្រង់ធ្វើឲ្យយើងមានអារម្មណ៍យ៉ាងណា ។

# ជំពូក ៩

# តើព្រះគ្រីស្ទជានរណា ?

នៅក្នុងអង្គបុគ្គលនៃព្រះយេស៊ូវ ព្រះបានចូលមកក្នុងលោកិយរបស់យើងដោយមានរូបកាយ ។ ទ្រង់ជាព្រះគ្មានព្រំខណ្ឌ បានចូលមកគង់នៅក្នុងលោកិយដែលមានព្រំខ័ណ្ឌ ។ ទ្រង់ជាព្រះដែលជ្រាបយ៉ាងច្បាស់ពីអ្វីដែលត្រូវកើតឡើង ហើយអ្វីដែលមិនត្រូវកើតឡើង ។ នៅក្នុងព្រះគ្រីស្ទ ព្រះ និងមនុស្ស ក្លាយជាបុគ្គលតែមួយជាបុគ្គលមួយដែលខុសពីបុគ្គលដទៃទៀត ដែលលោកិយធ្លាប់បានឃើញ ។ ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះពេញលេញ ហើយជាមនុស្សពេញលេញ ក្នុងអង្គបុគ្គលតែមួយអស់កល្ប ។ ហើយបុគ្គលអង្គនោះ បានផ្លាស់ប្តូរដំណើរការនៃប្រវត្តិសាស្រ្តជារៀងរហូតទៅ ។

## ព្រះយេស៊ូវ ជាមនុស្សដ៏ពេញលេញ

ព្រះយេស៊ូវជាមនុស្សមួយរយភាគរយ ។ ទ្រង់បានចាប់កំណើតនឹងផ្ទៃមាតារបស់ទ្រង់ ដោយកិច្ចការដ៏អស្ចារ្យនៃព្រះវិញ្ញាណបរិសុទ្ធ ។ ការនេះបានបង្ហាញយ៉ាងច្បាស់នៅក្នុងបទគម្ពីរម៉ាថាយ ១:១៨ “រីឯកំណើតព្រះយេស៊ូវគ្រីស្ទ នោះបានកើតមកយ៉ាងដូច្នេះ គឺនាងម៉ារា មាតា ទ្រង់ កាលដែលយ៉ូសែបបានដណ្តឹងនាងហើយ នោះនាងមានគភ៌ដោយព្រះវិញ្ញាណបរិសុទ្ធ” ។ នៅក្នុងសេចក្តីដែលបាន

ជាច្រើននៅត្រង់នេះ មានចំនុចមួយបានបញ្ជាក់យ៉ាងច្បាស់ថា "ព្រះយេស៊ូវបានចាប់កំណើតពីមាតាដែលជាមនុស្សម្នាក់ ។ ការចាប់កំណើតតាមបែបមនុស្សធម្មតារបស់ទ្រង់ បញ្ជាក់ថា ទ្រង់ជាមនុស្សជាតិ ។

ព្រះយេស៊ូវមានរូបកាយមនុស្សដូចជាយើងរាល់គ្នាដែរ ។ នៅវ័យជាកុមារម្នាក់ ទ្រង់ "មានវ័យចំរើនធំឡើង មានកំលាំងខាងវិញ្ញាណរឹតតែច្រើនឡើង" (លូ ២:៤០) ហើយនៅពេលដែលទ្រង់កាន់តែធំឡើង ទ្រង់ "ប្រកបដោយប្រាជ្ញារឹតតែច្រើនឡើង ហើយជាទីគាប់ព្រះហឫទ័យដល់ព្រះ និងចិត្តមនុស្សផង" (លូ ២:៥២) ។ ទ្រង់ "អស់កំលាំង" ពីការធ្វើដំណើរ (យ៉ូន ៤:៦) ។ បន្ទាប់ពីទ្រង់តមអាហារ "ទ្រង់ឃ្លាន" (ម៉ាថ ៤:២) ហើយពេលទ្រង់ជាប់នៅលើឈើឆ្កាង ទ្រង់បានមានបន្ទូលថា "ខ្ញុំស្រេកទឹកណាស់" (យ៉ូន ១៩:២៨) ។ គ្រប់ផ្នែកនៃរូបកាយរបស់ទ្រង់ ដូចជារូបកាយរបស់យើងដែរ ។

ព្រះយេស៊ូវបានរស់ពីការសុគតឡើងវិញ នៅក្នុងរូបកាយមនុស្សមួយដែលមិនមានសេចក្តីកំសោយ ជំងឺ ឬសេចក្តីស្លាប់ទេ ។ ទ្រង់បានមានបន្ទូលប្រាប់ពួកសិស្សរបស់ទ្រង់ ដែលមានសេចក្តីអស្ចារ្យនឹងការដែលព្រះគ្រីស្ទរស់ឡើងវិញថា "ចូរមើលមកដៃ និងជើងខ្ញុំ ឲ្យបានដឹងថា នេះគឺខ្ញុំពិតមែន ចូរពាល់ខ្ញុំមើល ដ្បិតខ្មោចគ្មានសាច់ឬឆ្អឹង ដូចជាឃើញខ្ញុំនេះទេ" (លូ ២៤:៣៩) ។ ព្រះនៅតែបន្តរស់នៅក្នុងរូបកាយជាមនុស្សគ្រប់លក្ខណ៍នេះនៅឯនគរស្ថានសួគ៌ ។

ចិត្តគំនិតរបស់ព្រះយេស៊ូវដូចជាគំនិតរបស់យើងដែរ ។ ទ្រង់បានឆ្លងកាត់ការរៀនសូត្រដូចជា រៀននិយាយ អាន សរសេរ និងបរិភោគ ដូចក្មេងដទៃទៀត

ដែរ ។ នៅក្នុងនិស្ស័យជាមនុស្សរបស់ទ្រង់ ទ្រង់មិនបានជ្រាបពីថ្ងៃដែលទ្រង់ត្រូវយាងត្រឡប់មកផែនដីវិញទេ “ឯត្រង់ថ្ងៃ និងពេលកំណត់ នោះគ្មានអ្នកណាដឹងបានទេ ទោះទាំងពួកទេវតាដែលនៅស្ថានសួគ៌ ឬព្រះរាជបុត្រាក៏មិនជ្រាបដែរ ជ្រាបតែព្រះវរបិតាប៉ុណ្ណោះ” (ម៉ាក ១៣:៣២) ។

លើសពីនោះទៀត ព្រះយេស៊ូវក៏មានអារម្មណ៍ពេញលេញដែរ ដូចជាទ្រង់ “មានសេចក្ដីអស្ចារ្យក្នុងព្រះហឫទ័យ” ពីសេចក្ដីជំនឿរបស់មេទ័ពម្នាក់ (ម៉ាថ ៨:១០) ហើយទ្រង់ “ព្រះកន្សែង” នឹងការស្លាប់របស់ឡាសារដែលជាសំឡាញ់របស់ទ្រង់ (យ៉ូន ១១:៣៥) ។ ទ្រង់បានអធិស្ឋានទៅឯព្រះ “ដោយសំលេងជាខ្លាំងទាំងទឹកភ្នែក” (ហេ ៥:៧) ។ មុនពេលគេឆ្កាង ទ្រង់បានមានបន្ទូលថា “ចិត្តខ្ញុំព្រួយពន់ពេក ស្ទើរតែនឹងស្លាប់” (ម៉ាថ ២៦:៣៨) ហើយថា “ឥឡូវនេះ ខ្ញុំមានចិត្តតប់ប្រមល់” (យ៉ូន ១២:២៧) ។

ព្រះយេស៊ូវមានលក្ខណៈគ្រប់ផ្នែកដូចជាយើងរាល់គ្នាដែរ តែលើកលែងតែមួយប៉ុណ្ណោះ គឺទ្រង់គ្មានបាប ។ មូលហេតុនេះហើយបានជានៅចុងបញ្ចប់នៃព្រះជន្មរបស់ទ្រង់ ទ្រង់អាចមានបន្ទូលថា “ខ្ញុំបានកាន់តាមបញ្ញត្តនៃព្រះវរបិតាខ្ញុំ ហើយក៏នៅជាប់ក្នុងសេចក្ដីស្រឡាញ់របស់ទ្រង់ដែរ” (យ៉ូន ១៥:១០) ។ សាវក ប៉ុល និយាយសំដៅទៅព្រះយេស៊ូវថា “ដ្បិតឯព្រះអង្គមិនដែលបានស្គាល់បាបសោះ” (២ កូរិន ៥:២១) ។ សាវក ពេត្រុស បានប្រាប់យើងថា ព្រះយេស៊ូវ “មិនបានធ្វើបាបអ្វីសោះ ក៏មិនឃើញមានកិច្ចកលអ្វីនៅព្រះឱស្ឋទ្រង់ឡើយ” (១ ពេ ២:២២) ។ សាវក យ៉ូហាន បានប្រាប់យើងថា “នៅក្នុងទ្រង់ នោះគ្មានបាបសោះ”

(១ យ៉ូន ៣:៥) ។ ជាការពិតណាស់ថា ព្រះយេស៊ូវ "បានត្រូវសេចក្ដីល្បួងគ្រប់យ៉ាង ដូចជាយើងរាល់គ្នាដែរ តែឥតធ្វើបាបឡើយ" (ហេ ៤:១៥) ។

ព្រះយេស៊ូវត្រូវតែជាមនុស្សមួយរយភាគរយ ដើម្បីធ្វើជាអ្នកតំណាងនៃការស្លាប់បង្គាប់យ៉ាងគ្រប់លក្ខណ៍របស់យើងរាល់គ្នា ។ ទ្រង់ជាអ្នកតំណាងនៃការស្លាប់បង្គាប់ម្នាក់ ដែលផ្ទុយពីលោក អ័ដាម ។ សាវក ប៉ុល បាននិយាយថា "ដ្បិតដូចជាមនុស្សជាច្រើន បានត្រឡប់ជាមានបាប ដោយសារមនុស្សតែម្នាក់ មិនបានស្ដាប់បង្គាប់ជាយ៉ាងណា នោះមនុស្សជាច្រើន ក៏បានត្រឡប់ជាសុចរិត ដោយសារម្នាក់បានស្ដាប់បង្គាប់វិញយ៉ាងនោះដែរ" (រ៉ូម ៥:១៩) ។ ប្រសិនព្រះយេស៊ូវមិនមែនជាមនុស្សពេញលេញនោះទេ ការស្ដាប់បង្គាប់របស់ទ្រង់ជំនួសយើង នឹងគ្មានន័យ ។

ព្រះយេស៊ូវត្រូវតែជាមនុស្ស ដើម្បីរស់នៅជំនួសយើង ហើយក៏ត្រូវតែជាមនុស្ស ដើម្បីសុគតជំនួសយើងផងដែរ ។ នេះគឺជាការចាំបាច់ណាស់ ព្រោះយើងជាមនុស្ស ។ ដូចជាបទគម្ពីរហេព្រើរ ២:១៧ បានប្រាប់យើងថា "ហេតុនោះបានជាគួរឲ្យទ្រង់ បានដូចបងប្អូនទ្រង់គ្រប់ជំពូកដែរ ដើម្បីឲ្យបានធ្វើជាសម្ដេចសង្ឃដែលមានព្រះទ័យមេត្តាករុណា ហើយក៏ស្មោះត្រង់ក្នុងការទាំងប៉ុន្មានខាងឯព្រះប្រយោជន៍នឹងថ្វាយដង្វាយឲ្យធួននឹងបាបរបស់ប្រជាជនទាំងឡាយ" ។ ប្រសិនបើព្រះយេស៊ូវមិនមែនជាមនុស្សពេញលេញទេ ការសុគតរបស់ទ្រង់ជំនួសយើងនឹងទៅជាគ្មានន័យ ។

លើសពីនោះទៅទៀត ភាពជាមនុស្សរបស់ព្រះយេស៊ូវ (ក៏ដូចជាភាពជាព្រះរបស់ទ្រង់) អនុញ្ញាតឲ្យទ្រង់បំរើជាអ្នក "សម្រុះសម្រួលតែមួយ នៅកណ្តាលព្រះនិងមនុស្ស" (១ ធី ២:៥) ។ វាក៏មានន័យថា ទ្រង់ជាមនុស្សម្នាក់ "ទ្រង់បានត្រូវសេចក្តីល្បួងគ្រប់យ៉ាង ដូចជាយើងរាល់គ្នាដែរ" ដូច្នេះហើយទ្រង់អាចនឹង "អាណិតអាសូរ ដល់សេចក្តីកំសោយរបស់យើងរាល់គ្នា" (ហេ ៤:១៥) ។ "ដ្បិតដែលទ្រង់រងទុក្ខលំបាក ទាំងត្រូវសេចក្តីល្បួង នោះទ្រង់ក៏អាចនឹងជួយដល់អស់អ្នក ដែលត្រូវសេចក្តីល្បួងដែរ" (ហេ ២:១៨) ។

## ព្រះយេស៊ូវ ជាព្រះដ៏ពេញលេញ

ដូចជាយើងបាននិយាយខាងដើមហើយថា ព្រះយេស៊ូវបានចាប់ទំផ្ទៃម្តាយរបស់ទ្រង់ ដោយកិច្ចការដ៏អស្ចារ្យនៃព្រះវិញ្ញាណបរិសុទ្ធ ។ ការនេះបង្ហាញយ៉ាងច្បាស់ម្តងទៀតនៅក្នុងបទគម្ពីរម៉ាថាយ ១:១៨ ។ កំណើតពីស្ត្រីព្រហ្មចារីរបស់ព្រះយេស៊ូវ គឺជាកិច្ចការអធិធម្មជាតិនៃព្រះ ។ តាមរយៈកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងនាងម៉ារាដែលជាមាតារបស់ព្រះយេស៊ូវ ភាពជាមនុស្ស និងភាពជាព្រះ បានរួមសហភាពជាមួយគ្នា តាមរបៀបមួយ ដែលភាពទាំងពីរនោះ មិនដែលនៅក្នុងបុគ្គលផ្សេងទៀត ។

ដូចជាយើងបានឃើញ នៅពេលដែលយើងពិភាក្សាពីភាពជាព្រះពេញលេញនៃព្រះត្រៃឯករួចមកហើយ (សូមមើលជំពូក ៣) ព្រះគម្ពីរបានថែងយ៉ាងច្បាស់ថា ព្រះយេស៊ូវជាព្រះពេញលេញ ។ ឧទាហរណ៍៖ សាវក ប៉ុល បានសរសេរ

អំពីព្រះយេស៊ូវនៅក្នុងបទគម្ពីរកូល៉ុស ២:៩ ថា "មានគ្រប់ទាំងសេចក្ដីពោរពេញរបស់ព្រះ សណ្ឋិតនៅក្នុងទ្រង់ ទាំងមានរូបអង្គផង" ។ នៅពេលដែលអ្នករស់នៅជំនាន់ព្រះយេស៊ូវ បានហៅទ្រង់ថា "ព្រះអម្ចាស់" ពួកគេបានកំពុងតែប្រើប្រាស់ពាក្យនេះ រហូតដល់៦០០០ដង នៅក្នុងការបកប្រែភាសាក្រិកនៃព្រះគម្ពីរសញ្ញាចាស់ ដែលសំដៅលើព្រះ ឬ "ព្រះយេហូវ៉ា" ។ ដូច្នេះ នៅពេលទេវតាប្រកាសពីការប្រសូតរបស់ព្រះយេស៊ូវ ដោយនិយាយថា "ដ្បិតនៅថ្ងៃនេះ មានព្រះអង្គសង្គ្រោះមួយអង្គ ប្រសូតដល់អ្នករាល់គ្នា នៅ ក្រុងហ្លួងដាវីឌ គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់" (លូ ២:១១) នោះពួកគេកំពុងតែនិយាយថា ព្រះអម្ចាស់ផ្ទាល់បានប្រសូតមក ។

នៅពេលដែលគេសួរថា ទ្រង់បានឃើញលោក អ័ប្រាហាំ ព្រះយេស៊ូវបានតបដោយមានបន្ទូលថា "មុនដែលលោក អ័ប្រាហាំកើតមក នោះមានខ្ញុំហើយ" (យ៉ូន ៨:៥៨) ។ ពួកអ្នកដែលបានឮទ្រង់មានបន្ទូលដូច្នេះ បាននិយាយថា ចូររើសថ្ម ហើយចោលវាទៅ (យ៉ូន ៨:៥៩) ។ នេះគឺជាអ្វី ដែលពួកមេដឹកនាំសាសនាដែលចង់ឲ្យគេផ្ដាប់ផ្គុន នឹងធ្វើប្រសិនបើមានអ្នកណាម្នាក់ប្រកាសខ្លួនថាជាព្រះ ។ ពួកបានយល់ថា ព្រះយេស៊ូវកំពុងប្រកាសងារ ដូចដែលព្រះបានប្រកាសនៅបទគម្ពីរ និក្ខមនំ ៣:១៤ ថា "អញជាព្រះដ៏ជាព្រះ" ។

នៅក្នុងបទគម្ពីរវិវរណៈ ២២:១៣ ព្រះយេស៊ូវមានបន្ទូលថា "អញជាអាលផា និងអូមេកា គឺជាមុនគេ ហើយក្រោយគេ ជាដើម ហើយជាចុង" ។ នេះគឺស្រដៀងគ្នាណាស់ទៅនឹងអ្វីដែលព្រះវរបិតាមានបន្ទូល នៅ ដើមដំបូងនៃកណ្ឌ

ដដែលនេះ ថា “ព្រះអម្ចាស់ដ៏ជាព្រះ ដែលទ្រង់គង់នៅ ក៏គង់នៅតាំងពីដើម ហើយត្រូវយាងមកទៀត គឺជាព្រះដ៏មានព្រះចេស្តាបំផុត ទ្រង់មានបន្ទូលថា អញជាអាលផា និងជាអូមេកា គឺជាដើម ហើយជាចុង” (វិវរ ១:៨) ។

ហោរា អេសាយ បានបញ្ជាក់ថា ព្រះយេស៊ូវជាស្តេចដែលត្រូវសោយរាជ្យជារៀងរហូត ។ ទ្រង់មានតួនាទីមួយ ដែលមានតែព្រះប៉ុណ្ណោះ ដែលអាចធ្វើបាន “សេចក្តីចំរើននៃរដ្ឋាភិបាលទ្រង់ និងសេចក្តីសុខសាន្តរបស់ទ្រង់ នោះនឹងមិនចេះផុត” (អេសា ៩:៧) ។ មូលហេតុនេះហើយបានជាសាវក ប៉ុល បាននិយាយថា ព្រះយេស៊ូវស័ក្តិសមឲ្យយើងថ្វាយបង្គំ “ព្រះបានលើកទ្រង់យ៉ាងខ្ពស់ ហើយបានប្រទានឲ្យមាននាមដ៏ប្រសើរលើសជាងអស់ទាំងនាមផង ដើម្បីកាលណាឮព្រះនាមព្រះយេស៊ូវ នោះឲ្យគ្រប់ទាំងជង្គង់នៅស្ថានសួគ៌ នៅផែនដី ហើយនៅក្រោមផែនដីត្រូវលុតចុះ ហើយឲ្យគ្រប់ទាំងអណ្តាតបានថ្លែងប្រាប់ថា ព្រះយេស៊ូវគ្រីស្ទ ទ្រង់ជាព្រះអម្ចាស់ សំរាប់ជាសិរីល្អដល់ព្រះដ៏ជាព្រះវរបិតា” (ភី ២:៩-១១) ។ ភាពជាព្រះរបស់ព្រះយេស៊ូវ គឺជាហេតុផលដែលព្រះវរបិតាមានបន្ទូលថា “ចូរឲ្យអស់ទាំងទេវតានៃព្រះថ្វាយបង្គំចុះ” (ហេ ១:៦) ។

ព្រះយេស៊ូវជាព្រះពេញលេញ ។ “ព្រះបានសព្វព្រះហឫទ័យ ឲ្យគ្រប់ទាំងសេចក្តីពោរពេញបានស្ថិតនៅក្នុងទ្រង់” (កូល ១:១៩) ។ ប្រសិនបើព្រះយេស៊ូវមិនមែនជាព្រះពេញលេញទេ ទ្រង់មិនអាចផ្ទុកទោសនៃអំពើបាបទាំងអស់ សំរាប់លោកិយទាំងមូលបានឡើយ ។ ហើយប្រសិនបើទ្រង់មិនផ្ទុកទោសនៃអំពើបាបទាំងអស់ សំរាប់លោកិយទាំងមូលក្នុងនាមជាមនុស្សគ្មានបាបម្នាក់ទេ នោះនឹងមិន

មានការសងថ្លៃសំរាប់អំពើបាបរបស់យើងទេ ហើយក៏គ្មាននរណាម្នាក់អាចនឹងទទួលសេចក្តីសង្គ្រោះបានដែរ ។

## ព្រះយេស៊ូវ ជាព្រះដ៏ពេញលេញ និងជាមនុស្សដ៏ពេញលេញ

ព្រះយេស៊ូវជាព្រះមួយរយភាគរយ ហើយទ្រង់ក៏ជាមនុស្សមួយរយភាគរយដែរ ។ ព្រះរាជបុត្រាដ៏អស់កល្បរបស់ព្រះ បានយកនិស្ស័យជាមនុស្សដ៏ពិតប្រាកដម្នាក់ ។ និស្ស័យជាព្រះ និងនិស្ស័យជាមនុស្សរបស់ទ្រង់ ជា និស្ស័យពីរផ្សេងដាច់ដោយឡែកពីគ្នាជារៀងរហូត ហើយនៅតែមានសភាពផ្សេងគ្នា ទោះ បីជានិស្ស័យទាំងពីរនេះ បានរួមសហភាពជាមួយគ្នានៅក្នុងបុគ្គលតែមួយក៏ដោយ ។

ការនេះ ប្រហែលជាអព្ភូតហេតុដ៏អស្ចារ្យបំផុតនៃព្រះគម្ពីរបរិសុទ្ធទាំងមូល គឺថា ទ្រង់ជាព្រះរាជបុត្រាដ៏អស់កល្បរបស់ព្រះ, ទ្រង់ជាព្រះពេញលេញ, ហើយទ្រង់បានក្លាយជាមនុស្សពេញលេញ ហើយដោយធ្វើយ៉ាងដូច្នោះ អង្គទ្រង់បានចូលរួមនឹងនិស្ស័យមនុស្សជារៀងរហូតទៅ ។ ព្រះយេស៊ូវជាមនុស្សម្នាក់ដែលមិនដូចជាមនុស្សដទៃទៀតទេ ។ លោកិយនឹងមិនដែលឃើញមនុស្សបែបនោះម្តងទៀតទេ ។ ទ្រង់នាំភាពមានព្រំខ័ណ្ឌ និងភាពគ្មានព្រំខ័ណ្ឌមករួមគ្នា នៅ អស់កល្បជានិច្ច ។ ទ្រង់បានផ្លាស់ប្តូរដំណើរនៃប្រវត្តិសាស្ត្រ ជារៀងរហូតទៅ ។

# បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១. ដែលព្រះយេស៊ូវជាព្រះដ៏ពេញលេញ តើការនេះលើកទឹកចិត្តយើងតាមរបៀបណាខ្លះ ?

២. ដែលព្រះយេស៊ូវជាមនុស្សដ៏ពេញលេញ តើការនេះលើកទឹកចិត្តយើងតាមរបៀបណាខ្លះ ?

៣. សូមចំណាយពេលបន្តិចបន្តួច ហើយនិយាយដោយផ្ទាល់ទៅកាន់ព្រះយេស៊ូវ ដើម្បីអរព្រះគុណទ្រង់សំរាប់ការយាងមកផែនដី និងការដែលទ្រង់បានក្លាយជាមនុស្សដ៏ពេញលេញដោយយល់ដល់យើង ។

# ជំពូក ១០

# តើឯង្វាយធួននឹងបាបជាអ្វី ?

មុនពេលព្រះយេស៊ូវបានប្រសូត ទេវតាម្នាក់បានប្រាប់លោក យ៉ូសែប ដែលជាឪពុកខាងលោកិយរបស់ទ្រង់ ឲ្យដាក់ឈ្មោះឲ្យទ្រង់ថា “យេស៊ូវ” “បុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ឲ្យរួចពីបាប” (ម៉ាថ ១:២១)។ ព្រះយេស៊ូវពិតជាបានសង្គ្រោះរាស្ត្រទ្រង់ឲ្យរួចពីបាបរបស់ពួកគេមែន តាមរយៈព្រះជន្មដែលទ្រង់បានរស់នៅ ហើយនិងការសុគតដែលទ្រង់បានសុគត ។ ព្រះយេស៊ូវបានធ្វើកិច្ចការនេះនៅក្នុងការរស់នៅ និងការសុគតរបស់ទ្រង់ ដើម្បីរកឲ្យបានសេចក្តីសង្គ្រោះរបស់យើង ។ សេចក្តីសង្គ្រោះនេះ ជួនកាល គេសំដៅថា ជាឯង្វាយឲ្យធួននឹងបាប ។

## បុព្វហេតុនៃឯង្វាយធួននឹងបាប

បទគម្ពីរបានបញ្ជាក់យ៉ាងច្បាស់ថា ព្រះគ្រីស្ទបានយាងមក ដើម្បីរកឲ្យបានសេចក្តីសង្គ្រោះរបស់យើង ដោយព្រោះសេចក្តីស្រឡាញ់ដ៏ស្មោះត្រង់របស់ព្រះ (ឬសេចក្តីមេត្តាករុណា) និងសេចក្តីយុត្តិធម៌ ។ សេចក្តីស្រឡាញ់របស់ព្រះ ត្រូវបានបញ្ជាក់នៅក្នុងបទគម្ពីរយ៉ូហាន ៣:១៦ “ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម្ល៉េះបានជាទ្រង់បានប្រទានព្រះរាជ្យបុត្រាទ្រង់តែមួយ ដើម្បីឲ្យអស់អ្នកណាដែលជឿដល់ព្រះរាជបុត្រានោះមិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ច

វិញ” ។ សេចក្តីយុត្តិធម៌របស់ព្រះ ត្រូវបានបញ្ជាក់យ៉ាងច្បាស់ នៅ ពេលដែល សាវ័ក ប៉ុល សរសេរថា ព្រះបានតាំងព្រះយេស៊ូវ “ទុកជាទីសន្តោសប្រោស” (រ៉ូម ៣:២៥) មានន័យថា ទ្រង់ជាយញ្ញបូជាមួយដែលផ្ទុកសេចក្តីក្រោធរបស់ព្រះ ដើម្បីឲ្យព្រះបានទតមើលមកយើងដោយគាប់ព្រះហឫទ័យ ។ សាវ័ក ប៉ុល បាននិយាយថា ការនេះបានសំរេចឡើង “សំរាប់នឹងសំដែងឲ្យឃើញសេចក្តីសុចរិតរបស់ព្រះ” ហើយ “ប្រយោជន៍ឲ្យទ្រង់បានសុចរិត” ផងដែរ (រ៉ូម ៣:២៥-២៦) ។ និយាយឲ្យងាយស្តាប់ទៅ អំពើបាបដែលព្រះ “បានរំលង” ឬមិនបានដាក់ទណ្ឌកម្មមុនពេលព្រះគ្រីស្ទយាងមកផែនដី នៅទីបំផុតត្រូវតែទទួលទណ្ឌកម្ម ប្រសិនបើព្រះពិតជា “យុត្តិធម៌” មែន ។ ដូច្នេះ ត្រូវតែមានអ្នកណាម្នាក់ ទទួលទណ្ឌកម្មសំរាប់អំពើបាបទាំងនោះ ហើយអ្នកនោះគឺជាព្រះយេស៊ូវ ។ នៅក្នុងព្រះជន្ម និងការសុគតរបស់ព្រះយេស៊ូវ យើងបានរកឃើញការបង្ហាញដ៏ពេញលេញមួយនៃសេចក្តីយុត្តិធម៌របស់ព្រះ (បាបដែលត្រូវទទួលទណ្ឌកម្ម) និងសេចក្តីស្រឡាញ់ដ៏ស្មោះត្រង់ (ព្រះបានប្រទានព្រះរាជបុត្រារបស់ទ្រង់ ឲ្យមកទទួលទណ្ឌកម្មនោះ) ។

## ភាពចាំបាច់នៃដង្វាយធួននឹងបាប

ទោះបីជាវាមិនចាំបាច់ ដែលព្រះយេស៊ូវត្រូវសង្គ្រោះមនុស្សណាម្នាក់ក៏ដោយ តែដោយសេចក្តីស្រឡាញ់របស់ទ្រង់ ទ្រង់បានជ្រើសរើស ដើម្បីសង្គ្រោះមនុស្សខ្លះ ។ នៅពេលមួយដែលទ្រង់បានសំរេចព្រះហឫទ័យធ្វើយ៉ាងដូច្នោះ នោះសេចក្តី

យុត្តិធម៌របស់ព្រះ បានធ្វើឲ្យវាមានភាពចាំបាច់សំរាប់ព្រះគ្រីស្ទ ដែលទ្រង់ត្រូវរស់នៅជីវិតដែលទ្រង់បានរស់នៅ ហើយសុគតសេចក្តីសុគតដែលទ្រង់បានសុគត ។

បន្ទាប់ពីព្រះយេស៊ូវបានរស់ពីសុគតឡើងវិញ ទ្រង់បានសួរសំនួរពិសេសមួយថា "តើមិនគួរឲ្យព្រះគ្រីស្ទរងទុក្ខទាំងនោះ ហើយចូលទៅក្នុងសិរីល្អនៃទ្រង់វិញទេឬអី ?" (លូ ២៤:២៦) ។ ព្រះយេស៊ូវបានជ្រាបថា គ្មានផ្លូវឯណាទៀត ដើម្បីឲ្យព្រះបានសង្គ្រោះយើង ក្រៅពីទ្រង់ត្រូវសុគតជំនួសយើងនោះទេ ។ ព្រះយេស៊ូវត្រូវតែរងទុក្ខសុគត ហើយសុគតសំរាប់អំពើបាបរបស់យើង ។ ផ្លូវផ្សេងទៀត ដូចជាយញ្ញបូជា ដែលបានថ្វាយសំរាប់អំពើបាបនៅក្នុងសម័យសញ្ញាចាស់ មិនមានតំលៃជាអចិន្ត្រៃយ៍ទេ ដ្បិត "ឈាមគោឈ្មោល និងពពែឈ្មោល នោះពុំអាចនឹងដោះបាបបានឡើយ" (ហេ ១០:៤) ។ ព្រះយេស៊ូវ "យកព្រះលោហិតនៃអង្គទ្រង់" ទទួល "បានសេចក្តីប្រោសលោះអស់កល្បជានិច្ច" ជាអចិន្ត្រៃយ៍ (ហេ ៩:១២) ដើម្បីនឹងលើកអំពើបាបចោល "ដោយថ្វាយព្រះអង្គទ្រង់" (ហេ ៩:២៦) ។

## និស្ស័យនៃដង្វាយធួននឹងបាប

ប្រសិនបើព្រះគ្រីស្ទបានគ្រាន់តែថ្វាយអង្គទ្រង់ជាដង្វាយមួយ ដើម្បីឲ្យយើងបានទទួលការអត់ទោសនៃអំពើបាប នោះយើងមានផ្លូវចូលទៅកាន់តែផ្នែកមួយនៃសេចក្តីសង្គ្រោះប៉ុណ្ណោះ ។ ទោះបីជាទោសរបស់យើងបានយកចេញក៏ដោយ ប៉ុន្តែយើងនឹងបានដូចជាលោកអ័ដាម និងនាងអេវ៉ា នៅ ពេលដែលពួកគេត្រូវបាន

បង្កើតមកនៅពេលដំបូងជាមិនខាន គឺមិនមានទោសមែន តែអាចធ្វើបាបបាន ហើយមិនមានការស្តាប់បង្គាប់ពេញមួយជីវិតទេ ។ ហើយដើម្បីចូលទៅក្នុងការប្រកបជាមួយព្រះ យើងនឹងត្រូវរស់នៅក្នុងជីវិតដែលស្តាប់បង្គាប់ព្រះដ៏គ្រប់លក្ខណ៍មួយ ។

ដូច្នេះ ព្រះគ្រីស្ទត្រូវតែរស់នៅក្នុងជីវិតដែលស្តាប់បង្គាប់ព្រះដ៏គ្រប់លក្ខណ៍មួយ យ៉ាងនេះ សេចក្តីល្អនៃការស្តាប់បង្គាប់នោះ អាចនឹងចាត់ទុកថា ជាការស្តាប់បង្គាប់សំរាប់យើងដែរ ។ នេះជាអ្វីដែលសាវក ប៉ុល ចង់និយាយថា "មនុស្សជាច្រើន ក៏បានត្រឡប់ជាសុចរិត ដោយសារមនុស្សម្នាក់បានស្តាប់បង្គាប់វិញ" (រ៉ូម ៥:១៩) ។ មូលហេតុនេះហើយ បានជាសាវក ប៉ុល មិនបានទុកចិត្តលើសេចក្តីសុចរិតរបស់គាត់ទេ ប៉ុន្តែគាត់បានទុកចិត្តលើ "សេចក្តីសុចរិតដែលមកពីសេចក្តីជំនឿដល់ព្រះគ្រីស្ទ" វិញ (ភី ៣:៩) ។ តាមរយៈជីវិតដ៏ឥតមានបាប ដែលព្រះគ្រីស្ទបានរស់នៅ នោះបានត្រឡប់ជា "សេចក្តីសុចរិត...ដល់យើង" (១ កូរិន ១:៣០) ។

ព្រះយេស៊ូវក៏បានរស់នៅក្នុងជីវិតមួយដ៏ឈឺចាប់ដែរ ។ នៅក្នុងសំដីរបស់លោក អេសាយ ទ្រង់ត្រូវ "គេមើលងាយ ហើយត្រូវមនុស្សបោះបង់ចោល ទ្រង់ជាមនុស្សទូទុក្ខ ហើយក៏ធ្លាប់ស្គាល់សេចក្តីឈឺចាប់" (អេសា ៥៣:៣) ។ ទ្រង់បានរងទុក្ខ នៅពេលដែលទ្រង់ត្រូវបានវាយដំ ដោយការវាយប្រហារ និងសេចក្តីល្បួងរបស់សាតាំង នៅក្នុងទីរហោស្ថាន (ម៉ាថ ៤:១-១១) ។ ទ្រង់ "បានទ្រាំទ្រនឹងពួកមនុស្សមានបាប ដែលធ្វើទទឹងទទែងនឹងទ្រង់ជាខ្លាំងម្ល៉េះ" (ហេ ១២:៣) ។ ទ្រង់បានឈឺចាប់យ៉ាងខ្លាំង ចំពោះការស្លាប់របស់ឡាសារ ដែលជាមិត្តសំឡាញ់របស់

ទ្រង់ (យ៉ូន ១១:៣៥) ។ តាមរយៈការទាំងនេះ ហើយនិងការឈឺចាប់ផ្សេងៗទៀត ទ្រង់ "បានរៀនស្តាប់បង្គាប់" (ទោះបីទ្រង់មិនដែលមិនបានស្តាប់បង្គាប់ក៏ដោយ) ហើយ "ទ្រង់បានត្រឡប់ជាមេបង្កើតនៃសេចក្តីសង្គ្រោះដ៏នៅអស់កល្បជានិច្ច" (ហេ ៥:៨-៩) ។

នៅពេលដែលការសុគតរបស់ទ្រង់ជិតមកដល់ ការរងទុក្ខរបស់ទ្រង់កាន់តែកើនឡើង ។ ទ្រង់បានប្រាប់សិស្សរបស់ទ្រង់ពីការឈឺចាប់ដែលទ្រង់កំពុងតែរំពឹងគិតថា "ចិត្តខ្ញុំព្រួយពន់ពេក ស្ទើរតែនឹងស្លាប់" (ម៉ាថ ២៦:៣៨) ។ នៅពេលព្រះយេស៊ូវត្រូវគេឆ្កាង ទ្រង់បានឈឺចាប់ នៅក្នុងទំរង់ដ៏អាក្រក់បំផុតមួយនៃសេចក្តីស្លាប់ ដែលត្រូវបានបង្កើតឡើងដោយមនុស្ស ។ ទោះបីជាយើងមិនបានដឹងច្បាស់ថា ទ្រង់កំពុងទទួលការឈឺចាប់ខ្លាំងលើសពីការឈឺចាប់របស់មនុស្សក៏ដោយ ប៉ុន្តែយើងដឹងថា សេចក្តីឈឺចាប់ដែលទ្រង់បានឆ្លងកាត់គឺធំធេងណាស់ ។

នៅពេលគេឆ្កាង ព្រះគ្រីស្ទត្រូវបានបង្ខំឲ្យទ្រាំទ្រការស្លាប់ដ៏យឺតៗមួយ ដោយគេធ្វើឲ្យទ្រង់ដកដង្ហើមមិនរួច ដែលបណ្តាលមកពីទម្ងន់នៃរូបកាយរបស់ទ្រង់ផ្ទាល់ ។ ទ្រង់ត្រូវបានគេដាក់សន្ទឹង ហើយដាក់ជាប់នៅលើឈើឆ្កាង ដោយដំដែកគោល ។ ព្រះហស្តទ្រង់បានទ្រទម្ងន់ភាគច្រើននៃរូបអង្គទ្រង់ ។ ប្រអប់ទ្រូងរបស់ទ្រង់ត្រូវបានគេដាក់ឲ្យពើងទៅលើ និងទៅខាង ដើម្បីធ្វើឲ្យពិបាកបញ្ចេញខ្យល់ដង្ហើម ហើយបន្ទាប់មកព្យាយាមដកដង្ហើមចូល ។ ដើម្បីឲ្យដកដង្ហើមបាន ទ្រង់ត្រូវតែរុញខ្លួនឡើងដោយជើងរបស់ទ្រង់ ដោយដាក់ទម្ងន់ទាំងអស់លើដែកគោលដែលទម្លុះជើងរបស់ទ្រង់ និងទាញខ្លួនឡើងដោយដែកគោលដែលទម្លុះព្រះ

ហស្តរបស់ទ្រង់ ការទាំងអស់នេះធ្វើឲ្យមានការឈឺចាប់យ៉ាងក្រៃលែងតាមរយៈប្រព័ន្ធប្រសាទនៃព្រះហស្ត និងព្រះបាទរបស់ទ្រង់ ។ ខ្នងរបស់ទ្រង់ដែលត្រូវបានគេវាយឲ្យមានរបួសហើយនោះ បានកកិតនឹងភាពគ្រើមនៃឈើឆ្កាងនោះ នៅពេលដែលទ្រង់ដង្ហើមម្តងៗ ។

ប៉ុន្តែការឈឺចាប់ខាងរូបកាយ មិនអាចប្រៀបធៀបនឹងការឈឺចាប់ខាងព្រលឹងវិញ្ញាណ ទេ ។ ព្រះយេស៊ូវមិនដែលធ្វើបាបសោះ ទ្រង់ស្អប់អំពើបាប ។ ប៉ុន្តែទ្រង់ទទួលអំពើបាបទាំងអស់ របស់ពួកអ្នកដែលនឹងបានទទួលសេចក្តីសង្គ្រោះ មកលើអង្គទ្រង់ ។ “ទ្រង់បានទទួលរងទោសនៃអំពើបាបរបស់មនុស្សជាច្រើន” (អេសា ៥៣:១២) ។ អំពើបាបដែលទ្រង់បានស្អប់បំផុត ត្រូវបានច្រូចចេញមកលើអង្គទ្រង់ ។ ដូចជាលោក ពេត្រុសបានប្រាប់យើងថា “ទ្រង់បានផ្ទុកអំពើបាបរបស់យើងរាល់គ្នា លើ រូបអង្គទ្រង់ ជាប់លើឈើឆ្កាង ដើម្បីឲ្យយើងបានរស់ខាងឯសេចក្តីសុចរិត ដោយបានស្លាប់ខាងអំពើបាបហើយ គឺដោយស្នាមជាំរបស់ទ្រង់ ដែលអ្នករាល់គ្នាបានជា” (១ ពេ ២:២៤) ។ ដោយព្រោះយើង ព្រះគ្រីស្ទ “ត្រឡប់ជាតួបាប” (២ កូរិន ៥:២១) ។ ព្រះយេស៊ូវក្លាយជា “បណ្តាសាជំនួសយើង” ដើម្បីប្រោសលោះយើង “ឲ្យរួចពីសេចក្តីបណ្តាសារបស់ក្រិត្យវិន័យ” (កា ៣:១៣) ។

ព្រះយេស៊ូវប្រឈមមុខនឹងការទាំងអស់នេះតែម្នាក់ឯង ។ “ពួកសិស្សទាំងអស់ក៏រត់ចោលទ្រង់ទៅ” (ម៉ាថ ២៦:៥៦) ។ ព្រះវរបិតាបានបោះបង់ទ្រង់ចោល ។ ព្រះយេស៊ូវបានស្រែកឡើងថា “ឱព្រះអង្គៗនៃទូលបង្គំអើយ ហេតុអ្វី

បានជាទ្រង់ចោលទូលបង្គំ ?” (ម៉ាថ ២៧:៤៦) ពីព្រោះនៅពេលនោះ ទ្រង់ត្រូវបាន កាត់ផ្តាច់ចេញពីការប្រកបគ្នាដ៏ផ្អែមល្ហែម ជា មួយនឹងព្រះវរបិតាទ្រង់គង់នៅស្ថានសួគ៌ ដែលទ្រង់ជាប្រភពដ៏មិនចេះសាបសូន្យនៃកំលាំងខាងក្នុង និងសេចក្តីអំណរដ៏អស្ចារ្យបំផុត នៅ ក្នុងជីវិតមួយដែលពោរពេញដោយសេចក្តីទុក្ខព្រួយ ។ ទ្រង់បាននៅតែម្នាក់ឯង នៅពេលដែលទ្រង់កំពុងឈឺចាប់បំផុត ។

ការឈឺចាប់ដែលលើសពី ការឈឺចាប់ខាងផ្លូវកាយ ផ្លូវចិត្ត និងការបោះបង់ចោល ទៅទៀតនោះគឺ ការឈឺចាប់នៃការទទួលសេចក្តីក្រោធទាំងស្រុងរបស់ព្រះមកលើអង្គទ្រង់ ។ នៅពេលដែលព្រះយេស៊ូវបានទទួលទោសនៃអំពើបាបរបស់យើង ព្រះបានធ្វើឲ្យសេចក្តីក្រោធ និង ទណ្ឌកម្មសំរាប់អំពើបាបទាំងអស់របស់យើង ធ្លាក់មកលើព្រះរាជបុត្រារបស់ទ្រង់ ។ ព្រះយេស៊ូវបានត្រឡប់ទៅជាកម្មបទនៃសេចក្តីសំអប់អំពើបាប ហើយកម្មបទនៃការដាក់ទោសចំពោះអំពើបាបដែលព្រះបានប្រមូលទុក ដោយអត់ធ្មត់ តាំងពីដើមដំបូងនៃលោកិយនេះមក ។ ព្រះគ្រីស្ទបានផ្ទុកទណ្ឌកម្មទាំងអស់នៃអំពើបាបរបស់យើង នៅលើឈើឆ្កាង ដោយចាំបាច់ និងស្ម័គ្រព្រះហឫទ័យ ។ ហើយតាមរយៈការសុគតរបស់ទ្រង់ សេចក្តីយុត្តិធម៌របស់ព្រះត្រូវបានស្កប់ស្កល់ ។ ព្រះគ្រីស្ទ “លើកអំពើបាបចោល ដោយថ្វាយព្រះអង្គទ្រង់...ទុកជាយញ្ញបូជា” (ហេ ៩:២៦) ។

## លទ្ធផលនៃដង្វាយធួននឹងបាប

ព្រះគ្រីស្ទបានរស់នៅក្នុងជីវិតដ៏គ្រប់លក្ខណ៍ គ្មានបាបមួយ ហើយទ្រង់បានសុគតតាមរបៀបរបស់មនុស្សមានបាបដ៏គួរឲ្យរន្ធត់មួយ ដើម្បី “ជួយសង្គ្រោះរាស្ត្រទ្រង់ឲ្យរួចពីបាប” (ម៉ាថ ១:២១) ។ ទ្រង់បានសងថ្លៃទោស ដែលយើងគួរសងសំរាប់អំពើបាបរបស់យើង ។ ទ្រង់បានផ្ទុកសេចក្តីក្រោធដែលយើងសមទទួល ។ ទ្រង់បានយកឈ្នះអំពើបាបដែលបំបែកយើងចេញពីព្រះ ។ ទ្រង់បានដោះលែងយើងឲ្យរួចពីចំណងដែលបណ្តាលមកពីអំពើបាប ។ ដោយព្រោះកិច្ចការព្រះគ្រីស្ទក្នុងនាមយើង នោះព្រះអាច “ប្រោសយើងឲ្យរួចពីអំណាចនៃសេចក្តីងងឹត” ហើយផ្លាស់ “យើងមកក្នុងនគររបស់ព្រះរាជបុត្រាស្ងួនភ្ងានៃព្រះ” (កូល ១:១៣) ។ នេះជាសេចក្តីសង្គ្រោះដ៏អស្ចារ្យណាស់ !

# បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១. ហេតុអ្វីបានចាំបាច់ម្ល៉េះ ដែលព្រះយេស៊ូវត្រូវយាងមក ហើយរស់នៅក្នុងជីវិតដ៏គ្រប់លក្ខណ៍មួយ នៅលើផែនដីនេះ ?

២. ហេតុអ្វីបានចាំបាច់ម្ល៉េះ ដែលព្រះយេស៊ូវត្រូវសុគត ? តើទ្រង់អាចសង្គ្រោះយើងតាមរបៀបផ្សេងៗទៀតបានដែរឬទេ ?

៣. តើការយល់ដឹងអំពីឯង្វាយធួននឹងបាប ធ្វើឲ្យអ្នកបានបន្ទាបខ្លួនយ៉ាងដូចម្តេច ? ហើយវាលើកទឹកចិត្តអ្នកយ៉ាងដូចម្តេច ?

# ជំពូក ១១

# តើអ្វីទៅជាសេចក្តីរស់ឡើងវិញ ?

កិច្ចការរបស់ព្រះយេស៊ូវនៅលើផែនដី មិនបានបញ្ចប់ដោយព្រះជន្ម និងការសុគតរបស់ទ្រង់ទេ ។ ប្រសិនបើវាបានបញ្ចប់នៅពេលនោះ “នោះដំណឹងដែលយើងខ្ញុំផ្សាយនេះ ជាការឥតប្រយោជន៍ទទេ ហើយសេចក្តីជំនឿរបស់អ្នករាល់គ្នា ក៏ឥតអំពើដែរ” ហើយ “យើងវេទនាលើសជាងមនុស្សទាំងអស់ទៅទៀត” (១ កូរិន ១៥:១៤-១៩) ។ ប៉ុន្តែព្រះយេស៊ូវបានរស់ពីការសុគតឡើងវិញ ហើយយាងទៅស្ថានសួគ៌ ក្នុងនាមជាស្តេចចំបាំងដ៏មានជ័យជំនះ ។

## ភាពពិស្តារនៃសេចក្តីរស់ឡើងវិញ

កណ្ឌគម្ពីរដំណឹងល្អទាំងបួន សុទ្ធតែមានកំណត់ត្រានៃការរស់ឡើងវិញរបស់ព្រះយេស៊ូវ (ម៉ាថ ២៨:១-២០; ម៉ាក ១៦:១-៨; លូ ២៤:១-៥៣; យ៉ូន ២០:១-២១:២៥) ។ នៅក្នុងព្រះគម្ពីរកិច្ចការទាំងមូល ពួកសាវក នៅតែបន្តការនិយាយអំពីការរស់ឡើងវិញរបស់ព្រះយេស៊ូវទៀត ដើម្បីលើកទឹកចិត្តមនុស្សឲ្យបានទុកចិត្តទ្រង់ ដែលទ្រង់ជាព្រះមានព្រះជន្មគង់នៅ ហើយកំពុងតែសោយរាជ្យនៅនគរស្ថានសួគ៌ ។ ផ្នែកឯទៀតនៃគម្ពីរសញ្ញាថ្មី ពឹងផ្អែកទាំងស្រុងលើការសន្និដ្ឋានថាព្រះយេស៊ូវជាព្រះសង្គ្រោះដែលកំពុងមានព្រះជន្មគង់នៅ និងកំពុងសោយ

រាជ្យ ដែលទ្រង់ជាព្រះសិរសានៃពួកជំនុំ ។ តាមពិតទៅ គេអាចរកបានភស្តុតាងគ្រប់គ្រាន់ អំពីសេចក្ដីរស់ឡើងវិញ នៅក្នុងគម្ពីរសញ្ញាថ្មីទាំងមូល ។

ការរស់ឡើងវិញរបស់ព្រះគ្រីស្ទ មិនមែនជាការវិលត្រឡប់ដ៏សាមញ្ញមួយមកពីការស្លាប់ ដូចជាអ្នកដទៃទៀតធ្លាប់មានបទពិសោធន៍នោះទេ (ដូចជា ឡាសារ នៅក្នុង យ៉ូហាន ១១:១-៤៤) ។ តែនៅពេលដែលព្រះយេស៊ូវមានព្រះជន្មរស់ពីសុគតឡើងវិញ ទ្រង់បានចាប់ផ្ដើមជីវិតមនុស្សបែបថ្មីនៅក្នុងរូបកាយដ៏គ្រប់លក្ខណ៍មួយ ដែលមិនធ្វើឲ្យមានសេចក្ដីកម្សោយ មិនធ្វើឲ្យមានវ័យចាស់ មិនធ្វើឲ្យមានសេចក្ដីស្លាប់ និងមិនធ្វើឲ្យមានសេចក្ដីពុករលួយវិញ ។ ពេលព្រះយេស៊ូវមានព្រះជន្មរស់ពីសុគតឡើងវិញ ទ្រង់បានមានរូបកាយមួយដែលនឹងរស់នៅរហូតអស់កល្ប ដ្បិតព្រះយេស៊ូវបាន “ប្រដាប់ដោយសេចក្ដីមិនពុករលួយ” ហើយទ្រង់ “បានប្រដាប់ដោយសេចក្ដីមិនចេះស្លាប់” (១ កូរិន ១៥:៥៣) ។

រូបអង្គថ្មីរបស់ព្រះយេស៊ូវ គឺជារូបអង្គខាងរូបកាយ ។ នៅពេលដែលពួកសិស្សបានឃើញទ្រង់ ពួកគេបាន “ចូលទៅអោបព្រះបាទ”ទ្រង់ (ម៉ាថ ២៨:៩) ។ សិស្សរបស់ទ្រង់ “បានទទួលទានជាមួយនឹងទ្រង់” (កិច្ច ១០:៤១) ។ នៅក្នុងរូបអង្គថ្មី ព្រះយេស៊ូវបាន “យកនំបុ័ងមកប្រទានពរ រួចកាច់ប្រទានទៅឲ្យគេ” (លូ ២៤:៣០) ។ ទ្រង់ក៏បានអញ្ជើញ ថូម៉ាស បានប៉ះពាល់ព្រះហស្ដ និងចំហៀងរបស់ទ្រង់ (យ៉ូន ២០:២៧) ។ ព្រះគម្ពីរបានបង្ហាញយ៉ាងច្បាស់ថា ព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញ ជាមួយនឹងរូបកាយដែលមាន “សាច់” និង “ឆ្អឹង” (លូ ២៤:៣៩) ។

## លទ្ធផលនៃសេចក្តីរស់ឡើងវិញ

ជា លទ្ធផល ពួកយើងដែលសំឡឹងមើលទៅឯព្រះយេស៊ូវ ដើម្បីឲ្យបានសេចក្តីសង្គ្រោះ នោះទ្រង់បាន “បង្កើតយើងឡើងជាថ្មី តាមសេចក្តីមេត្តាករុណាដ៏ធំរបស់ទ្រង់ ដើម្បីឲ្យយើងរាល់គ្នាបានសេចក្តីសង្ឃឹមដ៏រស់ ដោយសារព្រះយេស៊ូវគ្រីស្ទទ្រង់រស់ពីស្លាប់ឡើងវិញ” (១ ពេ ១:៣) ។ មានន័យថា ព្រះគ្រីស្ទបានរកបានជីវិតអនាគតថ្មីមួយសំរាប់យើងរាល់គ្នា ដូចជាជីវិតថ្មីរបស់ទ្រង់ផ្ទាល់ ។ ទោះបីជារូបកាយរបស់យើងមិនទាន់បានដូចជារូបកាយថ្មីរបស់ទ្រង់នៅឡើយក៏ដោយ តែវិញ្ញាណរបស់យើងត្រូវបានធ្វើឲ្យមានជីវិត ដោយអំណាចសេចក្តីរស់ឡើងវិញថ្មីហើយ ។

អំណាចសេចក្តីរស់ឡើងវិញនេះ ជួយយើងឲ្យរស់នៅក្នុងជីវិតមួយ ដែលព្រះបានបង្កើតមក ឲ្យយើងត្រូវរស់នៅ ។ ហើយវាផ្តល់អំណាចឲ្យយើង ដើម្បីនឹងទទួលជ័យជំនះលើអំពើបាប កាន់តែច្រើនថែមទៀតនៅក្នុងជីវិតរបស់យើង ។ ដោយព្រោះសេចក្តីរស់ឡើងវិញ យើងអាចរាប់ទុកខ្លួនរបស់យើងទុកជា “ស្លាប់ខាងឯបាប” (រ៉ូម ៦:១១) ។ ទោះបីជាយើងនឹងមិនទទួលបានភាពគ្រប់លក្ខណ៍ នៅក្នុងជីវិតនេះក៏ដោយ តែសាវក ប៉ុល នៅតែប្រាប់យើងថា “បាបមិនត្រូវមានអំណាច លើអ្នករាល់គ្នាទៀតឡើយ” (រ៉ូម ៦:១៤) ។ វានឹងមិនមានអំណាចលើយើង ឬគ្រប់គ្រងយើងឡើយ ។ អំណាចសេចក្តីរស់ឡើងវិញនេះ ក៏រួមបញ្ចូលទាំងអំណាចពីព្រះវិញ្ញាណបរិសុទ្ធផងដែរ ដែលអំណាចនេះ ជួយឲ្យយើងអាចធ្វើការដែលព្រះយេស៊ូវបានតាំងយើងឲ្យធ្វើ (កិច្ច ១:៨) ។

លើសពីនោះទៀត សេចក្ដីរស់ឡើងវិញរបស់ព្រះយេស៊ូវ ធានាឲ្យយើងអាចឈរបានយ៉ាងត្រឹមត្រូវនៅចំពោះព្រះ ។ នៅក្នុងបទគម្ពីររ៉ូម ៤:២៥ សាវកប៉ុល បានប្រាប់ថា ព្រះយេស៊ូវ "មានព្រះជន្មរស់ឡើងវិញ ប្រយោជន៍ឲ្យយើងរាល់គ្នាបានរាប់ជាសុចរិត" ។ នៅពេលដែលព្រះបានប្រោសព្រះយេស៊ូវឲ្យមានព្រះជន្មរស់ឡើងវិញ នោះទ្រង់កំពុងតែបញ្ជាក់ពីកិច្ចការរបស់ព្រះយេស៊ូវក្នុងនាមយើងរាល់គ្នា ។ ទ្រង់កំពុងតែបង្ហាញពីការគាំទ្ររបស់ទ្រង់ចំពោះកិច្ចការនៃការរងទុក្ខ និងការសុគតរបស់ព្រះយេស៊ូវ សំរាប់អំពើបាបរបស់យើង ។ ទ្រង់កំពុងបញ្ជាក់ថា កិច្ចការរបស់ព្រះយេស៊ូវក្នុងនាមយើងរាល់គ្នាបានចប់សព្វគ្រប់ហើយ ហើយទោសដោយព្រោះបាបត្រូវបានសងថ្លៃរួច ដូច្នេះ ព្រះយេស៊ូវមិនត្រូវការជាប់នៅក្នុងសេចក្ដីស្លាប់ទៀតទេ ។ បទគម្ពីរហេព្រើរ ១:៣ បានប្រាប់យើងថា "ក្រោយដែលបានសំអាតអំពើបាប របស់យើងរាល់គ្នាទាំងប៉ុន្មានហើយ នោះក៏គង់នៅខាងស្ដាំនៃឫទ្ធានុភាពនៅលើស្ថានដ៏ខ្ពស់" ។ ព្រះយេស៊ូវបានគង់នៅខាងស្ដាំនៃព្រះវរបិតា ដោយព្រោះកិច្ចការរបស់ទ្រង់បានបញ្ចប់ហើយ ។

ជាចុងក្រោយ ដោយព្រោះ "ព្រះទ្រង់បានទាំងប្រោសឲ្យព្រះអម្ចាស់រស់ឡើងវិញ" ហើយទ្រង់ "នឹងប្រោសឲ្យយើងរាល់គ្នារស់ឡើងដែរ" (១ កូរិន ៦:១៤) ។ ហើយ "ព្រះអង្គដែលប្រោសព្រះអម្ចាស់យេស៊ូវឲ្យមានព្រះជន្មរស់ឡើងវិញ ទ្រង់នឹងប្រោសឲ្យយើងខ្ញុំរស់ឡើងដែរ ដោយសារព្រះយេស៊ូវ ហើយនាំយើងខ្ញុំទៅនៅចំពោះទ្រង់ជាមួយនឹងអ្នករាល់គ្នាដែរ " (២ កូរិន ៤:១៤) ។ ការរស់ឡើងវិញរបស់ព្រះយេស៊ូវ មានន័យថា យើងនឹងមានបទពិសោធន៍នូវការរស់

ឡើងវិញរបស់យើងផ្ទាល់មួយដែរ ។ សាវក ប៉ុល បាននិយាយថា នៅក្នុងសេចក្តីរស់ឡើងវិញរបស់ព្រះយេស៊ូវ គឺជារូបភាពមួយ ដែលត្រូវមកសំរាប់យើងរាល់គ្នា (១ កូរិន ១៥:២០) ។ នៅពេលព្រះយេស៊ូវត្រឡប់មកវិញ យើង “ទាំងអស់គ្នានឹងបានផ្លាស់ប្រែ” (១ កូរិន ១៥:៥១) រូបកាយដែលតែងតែស្លាប់របស់យើងនឹងបានផ្លាស់ប្រែ ឲ្យបានរូបកាយដែលមិនចេះស្លាប់វិញ (១ កូរិន ១៥:៥៣) ។ នៅឯសេចក្តីរស់ឡើងវិញចុងក្រោយ ដែលជាសេចក្តីរស់ឡើងវិញរបស់យើង នោះយើងនឹងទទួលបានរូបកាយថ្មីមួយ ដែលដូចជារូបកាយព្រះយេស៊ូវ នៅបច្ចុប្បន្ននេះ ។

## ការយាងទៅស្ថានសួគ៌របស់ព្រះយេស៊ូវ

រយៈពេល៤០ថ្ងៃបន្ទាប់ពីការរស់ឡើងវិញរបស់ទ្រង់ (កិច្ច ១:៣) ព្រះយេស៊ូវបាននាំអ្នកដើរតាមទ្រង់ ទៅខាងក្រៅក្រុងយេរូសាឡឹម “ទ្រង់លើកព្រះហស្តឡើងប្រទានពរឲ្យ កំពុងដែលទ្រង់ប្រទានពរ នោះព្រះវរបិតាបានញែកទ្រង់ចេញពីគេលើកឡើងទៅស្ថានសួគ៌ទៅ” (លូ ២៤:៥០-៥១) ។ នៅពេលព្រះយេស៊ូវ បានចេញពីផែនដី ទ្រង់បានយាងទៅកន្លែងដ៏ពិតប្រាកដមួយ គឺនគរស្ថានសួគ៌ ។

នៅក្នុងនគរស្ថានសួគ៌ ព្រះយេស៊ូវត្រូវ “បានដំកើងឡើង ដោយសារព្រះហស្តស្តាំនៃព្រះ” (កិច្ច ២:៣៣) ។ ព្រះ “បានលើកទ្រង់យ៉ាងខ្ពស់ ហើយបានប្រទានឲ្យមាននាមដ៏ប្រសើរលើសជាងអស់ទាំងនាមផង” (ភី ២:៩) ។ បន្ទាប់ពីការយាងទៅស្ថានសួគ៌ ព្រះយេស៊ូវបានទទួលសិរីរុងរឿង កិត្តិយស និងអំណាច ដែលមិន

ដែលមានតាំងពីមុនមក ក្នុងនាមបុគ្គលម្នាក់ដែលជាព្រះផង និងជាមនុស្សផង ។ ឥឡូវនេះ ពួកក្រុមចំរៀងទេវតា កំពុងតែច្រៀងសរសើរដល់ទ្រង់ ដោយពាក្យថា "កូនចៀមដែលគេបានសំឡាប់ នោះគួរនឹងបានព្រះចេស្តា ទ្រព្យសម្បត្តិ ប្រាជ្ញា ឥទ្ធិឫទ្ធិ កិត្តិនាម សិរីល្អ និងព្រះពរ !" (វិវរ ៥:១២) ។ នៅខាងស្តាំព្រះហស្តនៃព្រះ ឥឡូវនេះ ព្រះគ្រីស្ទ "បានសោយរាជ្យ ទាល់តែដាក់អស់ទាំងខ្មាំងសត្រូវនៅក្រោមព្រះបាទទ្រង់" (១ កូរិន ១៥:២៥) ។

ព្រះជន្មរបស់ព្រះគ្រីស្ទផ្តល់ជាគំរូមួយ សំរាប់គំរូរបស់យើងរាល់គ្នា ។ ការរស់ឡើងវិញរបស់ទ្រង់ ធ្វើឲ្យយើងដឹងពីអ្វីដែលត្រូវកើតឡើងសំរាប់យើងរាល់គ្នា នៅពេលចុងក្រោយ ហើយការយាងទៅស្ថានសួគ៌របស់ទ្រង់ ធ្វើឲ្យយើងដឹងពីកន្លែងដែលយើងត្រូវទៅ ។ ដូច្នេះហើយ យើងត្រូវរង់ចាំការយាងត្រឡប់មកវិញរបស់ព្រះគ្រីស្ទដោយ "សេចក្តីទន្ទឹង" (រ៉ូម ៨:១៩) ។ ពេលនោះយើងរាល់គ្នានឹងត្រូវបានលើកឡើងពីលោកិយនេះ ចូលទៅក្នុងកន្លែងដ៏មានសិរីរុងរឿងថ្មីមួយ ជាមួយនឹងរូបកាយដ៏គ្រប់លក្ខណ៍ថ្មីរបស់យើង ហើយទៅរស់នៅក្នុងពិភពលោកដ៏គ្រប់លក្ខណ៍ថ្មីរបស់យើងរាល់គ្នា ។

# បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១. ហេតុអ្វីបានជាមានសារៈសំខាន់ម្ល៉េះ ដែលព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញ ? តើជីវិតយើងនឹងទៅជាយ៉ាងណា ប្រសិនបើព្រះគ្រីស្ទមិនបានមានព្រះជន្មរស់ឡើងវិញ ?

២. តើការរស់ឡើងវិញរបស់ព្រះយេស៊ូវ មានលទ្ធផលអ្វីខ្លះនៅក្នុងជីវិតរបស់អ្នក និងនៅក្នុងលោកិយទាំងមូល ?

៣. តើការរស់ឡើងវិញរបស់ព្រះយេស៊ូវ ធ្វើឲ្យអ្នកចង់បាន ការរស់ឡើងផ្ទាល់របស់អ្នក យ៉ាងណាដែរ ?

# ជំពូក ១២
# តើអ្វីទៅជាការជ្រើសរើស

មានការមិនយល់ព្រមជាច្រើននៅខាងក្នុង និងខាងក្រៅនៃពួកជំនុំ អំពីគោលលទ្ធិនៃការជ្រើសរើស (ជួនកាល គេហៅថា “ការតំរូវទុកជាមុន”) ។ យើងអាចនឹងឲ្យនិយមន័យ “ការជ្រើសរើស” ដូចខាងក្រោមនេះ៖ ការជ្រើសរើស គឺជាកិច្ចការរបស់ព្រះមុនការបង្កើតមួយ ដែលទ្រង់បានជ្រើសរើសមនុស្សមួយចំនួន ឲ្យបានទទួលសេចក្តីសង្គ្រោះ មិនដោយព្រោះការឃើញសេចក្តីល្អរបស់អ្នកណាម្នាក់ជាមុននោះទេ តែដោយព្រោះតែទ្រង់សព្វព្រះហឫទ័យប៉ុណ្ណោះ ។ មនុស្សជាច្រើនបានគិតថា ដែលគេឲ្យនិយមន័យតាមរបៀបនេះ គឺកំពុងធ្វើឲ្យមានបញ្ហា និងមិនយុត្តិធម៌ទេ ។ ទោះជាយ៉ាងណាក៏ដោយ មុននឹងឈានចូលទៅការសន្និដ្ឋាន ជាការសំខាន់ត្រូវពិនិត្យមើលថា តើនិយមន័យនៃគោលលទ្ធិនេះមកពីណា ។

## សេចក្តីបង្រៀនរបស់គម្ពីរសញ្ញាថ្មី អំពីការជ្រើសរើស

មានបទនៅក្នុងព្រះគម្ពីរសញ្ញាថ្មីជាច្រើន ហាក់ដូចជាបញ្ជាក់យ៉ាងច្បាស់លាស់ថាព្រះបានតំរូវពួកអ្នកដែលនឹងបានទទួលសេចក្តីសង្គ្រោះជាមុន ។ ឧទាហរណ៍៖ ពេលដែលសាវក ប៉ុល និងបាណាបាស បានចាប់ផ្តើមប្រកាសដំណឹងល្អដល់សាសន៍ដទៃនៅក្នុងក្រុងអាន់ទីយ៉ូក ស្រុកពីស៊ីឌា លោកលូកា បានសរសេរថា

“កាលពួកសាសន៍ដទៃបានឮដូច្នោះ នោះ គេមានសេចក្តីអំណរ ហើយក៏សរសើរព្រះបន្ទូលនៃព្រះអម្ចាស់ ចំណែកអស់អ្នកដែលត្រូវបានជីវិតអស់កល្បជានិច្ចនោះ ក៏បានជឿ” (កិច្ច ១៣:៤៨) ។

ហេតុផលមួយក្នុងហេតុផលជាច្រើន លោក លូកា បាននិយាយថា មនុស្សជាច្រើន “រើសតាំងឲ្យមានជីវិតអស់កល្បជានិច្ច” មានន័យថា គាត់បានយល់ពីសេចក្តីពិតដែល សាវក ប៉ុល បានបង្ហាញក្រោយមក នៅក្នុងគម្ពីរអេភេសូរ ១:៤-៦ ព្រះ “បានរើសយើងរាល់គ្នាក្នុងព្រះគ្រីស្ទ តាំងពីមុនកំណើតលោកិយមក ប្រយោជន៍ឲ្យយើងរាល់គ្នាបានបរិសុទ្ធ ហើយឥតកន្លែងបន្ទោសបាននៅចំពោះទ្រង់ ។ ដោយសេចក្តីស្រឡាញ់...ទ្រង់បានតំរូវយើងរាល់គ្នាទុកជាមុនសំរាប់ឲ្យទ្រង់បានទទួលយើងជាកូនចិញ្ចឹម ដោយសារព្រះគ្រីស្ទតាមបំណងព្រះហឫទ័យទ្រង់ ដើម្បីនឹងសរសើរដល់ព្រះគុណដ៏ឧត្តមរបស់ទ្រង់ ដែលបានផ្តល់មកយើងរាល់គ្នាទទេ ក្នុងព្រះរាជបុត្រាស្ងួនភ្ងារបស់ទ្រង់” ក្រោយមកសាវក ប៉ុល បានបន្ថែមថា “ប្រយោជន៍ឲ្យយើងខ្ញុំ ដែលបានទុកចិត្តជឿដល់ព្រះគ្រីស្ទជាមុន” ត្រូវរស់នៅ “សំរាប់និងសរសើរដល់សិរីល្អទ្រង់” (អេ ១:១២) ។

ព្រះបានសង្គ្រោះយើង ហើយត្រាស់ហៅយើងមកឯទ្រង់ មិនដោយព្រោះសេចក្តីល្អរបស់យើងទេ ប៉ុន្តែដោយព្រោះគោលបំណងផ្ទាល់របស់ទ្រង់ និងព្រះគុណដ៏មិនស័ក្កិសមទទួលរបស់ទ្រង់ តាំងពីអស់កល្បរៀងមកវិញ ។ សាវក ប៉ុល បាននិយាយថា ព្រះជាអ្នកដែល “បានជួយសង្គ្រោះយើង ហើយបានហៅយើងមកក្នុងការងារបរិសុទ្ធ មិនមែនដោយការដែលយើងធ្វើទេ គឺដោយដំរិះ និងព្រះ

គុណនៃទ្រង់វិញ ដែលបានផ្តល់មកយើងក្នុងព្រះគ្រីស្ទយេស៊ូវ មុនទាំងអស់កល្ប” (២ ធី ១:៩) ។

និមិត្តរបស់សាវក យ៉ូហាន នៅក្នុងព្រះគម្ពីរវិវរណៈ បានប្រាប់យើងថា សេចក្តីសង្រ្គោះរបស់បុគ្គលម្នាក់ (នៅក្នុងបទនេះបានចែងពីអ្នកដែលមានឈ្មោះកត់ទុកនៅក្នុងបញ្ជីជីវិត) ត្រូវបានកំណត់ទុក “តាំងពីកំណើតលោកិយមក” ម្ល៉េះ (វិវរ ១៧:៨) ។

## តើការនេះមានអត្ថន័យយ៉ាងដូចម្តេច ?

មានសារៈសំខាន់ខ្លាំងណាស់ ដែលសំគាល់ឃើញថា ជា ញឹកញាប់អ្នកនិពន្ធគម្ពីរសញ្ញាថ្មី បានបង្ហាញពីគោលលទ្ធិនៃការជ្រើសរើស ទុកជាសេចក្តីកំសាន្តចិត្តមួយដល់អស់អ្នកដែលជឿព្រះយេស៊ូវ ។ ឧទាហរណ៍៖ សាវក ប៉ុល បាននិយាយថា ព្រះបានធ្វើ ហើយតែងតែធ្វើ សំរាប់សេចក្តីល្អនៃអស់អ្នកដែលទ្រង់បានត្រាស់ហៅមកឯទ្រង់ “យើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នាសំរាប់សេចក្តីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ គឺដល់ពួកអ្នកដែលទ្រង់ហៅមកតាមព្រះដំរិះទ្រង់” (រ៉ូម ៨:២៨) ។

ប៉ុន្តែ តើសាវក ប៉ុល អាចដឹងការនេះបានដោយរបៀបណា ? គាត់ប្រាប់ពីហេតុផលនេះ នៅពីរខទៀត ។ គាត់អាចនិយាយយ៉ាងដូច្នេះបាន ដោយព្រោះគាត់ក្រឡេកមើលទៅអតីតកាលដ៏វែងឆ្ងាយតាំងពីមុនកំណើតលោកិយ គាត់បានឃើញថា ព្រះ “បានស្គាល់ជាមុន” ហើយ “តំរូវទុកជាមុន” ចំពោះរាស្ត្រទ្រង់ ដើម្បីឲ្យពួក

គេ “បានត្រឡប់ដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់” (រ៉ូម ៨:២៩)។ បន្ទាប់មក សាវ័ក ប៉ុល ក្រឡេកមើលអតីតកាលថ្មីៗ គាត់បានរកឃើញថា “ពួកអ្នកដែលទ្រង់(ព្រះ) បានតំរូវទុកជាមុន នោះទ្រង់ក៏ហៅ ហើយពួកអ្នកដែលទ្រង់បានហៅ នោះទ្រង់ក៏រាប់ទុកជាសុចរិត” (រ៉ូម ៨:៣០)។ ហើយនៅពេលសាវ័ក ប៉ុល ក្រឡេកមើលទៅអនាគត គាត់ឃើញថា “ពួកអ្នកដែលទ្រង់បានរាប់ជាសុចរិត នោះទ្រង់ក៏បានដំកើងឡើងដែរ” (រ៉ូម ៨:៣០) មានន័យថា ព្រះបានកំណត់ជាមុនហើយថា ថ្ងៃណាមួយទ្រង់នឹងប្រទានរូបកាយគ្រប់លក្ខណ៍ដ៏មានសិរីរុងរឿង ដល់អស់អ្នកដែលជឿព្រះគ្រីស្ទ។ តាំងពីអស់កល្បរហូតដល់អស់កល្ប ព្រះបានធ្វើហើយនឹងធ្វើការល្អសំរាប់រាស្ត្រទ្រង់រហូត ។ ដូច្នេះ គោលលទ្ធិនៃការជ្រើសរើស គឺជាបុព្វហេតុមួយសំរាប់ការកំសាន្តចិត្ត និងសំរាប់ការដឹងយ៉ាងច្បាស់ថា ព្រះនឹងធ្វើការសំរាប់សេចក្តីល្អរបស់យើងសព្វថ្ងៃនេះ។ ហើយការទាំងអស់នេះនឹងកើតឡើង “មិនមែនដោយការដែលយើងធ្វើទេ” ប៉ុន្តែដោយ “ដំរិះ និងព្រះគុណនៃទ្រង់វិញ ដែលបានផ្តល់មកយើងក្នុងព្រះគ្រីស្ទយេស៊ូវមុនទាំងអស់កល្ប” (២ ធី ១:៩)។

ការឆ្លើយតបធម្មតាមួយ ចំពោះកិច្ចការរបស់ព្រះក្នុងនាមយើងរាល់គ្នា គឺយើងនឹងរស់នៅដើម្បី “សរសើរដល់សិរីល្អទ្រង់” (អេ ១:១២)។ ដូចជាសាវ័ក ប៉ុលដែរ យើងអាចថ្វាយការអរព្រះគុណដល់ព្រះ សំរាប់ពួកអ្នកដែលទ្រង់បានជ្រើសរើស (១ ថែស ១:២-៤) ដោយដឹងថា ព្រះជាអ្នកដែលទទួលខុសត្រូវចំពោះសេចក្តីសង្គ្រោះរបស់ពួកគេ ព្រមទាំងការល្អនានាដែលមកជាមួយសេចក្តីសង្គ្រោះនោះផង។ តាមពិតទៅ សាវ័ក ប៉ុល បាននិយាយថា យើងត្រូវតែថ្វាយ

ការអរព្រះគុណដល់ព្រះ សំរាប់សេចក្ដីសង្គ្រោះដ៏ធំនោះ (១ ថែស ២:១៣) ។ ការច្រៀងសរសើរដល់ព្រះសំរាប់សេចក្ដីសង្គ្រោះ មិនធ្វើឲ្យយើងមានពេលចន្លោះដើម្បីនឹងច្រៀង សំរាប់ការសរសើរដល់ខ្លួនឯង ព្រោះសេចក្ដីសង្គ្រោះរបស់យើងមិនមែនជាកិច្ចការផ្ទាល់របស់យើងទេ តែជាអំណោយទានដែលមកពីព្រះវិញ (អេ ២:៨-៩) ។

ប៉ុន្តែសេចក្ដីពិតនេះមិនគួរធ្វើឲ្យយើងគិតថា ការងារប្រកាសដំណឹងល្អរបស់យើង មិនមានសារៈសំខាន់នោះទេ ! នៅពេលដែលព្រះជ្រើសរើសមនុស្សឲ្យបានទទួលសេចក្ដីសង្គ្រោះ នោះ ទ្រង់អនុវត្តការនេះតាមមធ្យោបាយមនុស្ស ។ មូលហេតុនេះហើយបានជាសាវក ប៉ុល ខិតខំប្រកាសដំណឹងល្អយ៉ាងខ្លាំង ។ គាត់បាននិយាយថា "ខ្ញុំទ្រាំទ្រនឹងគ្រប់ការទាំងអស់ ដើម្បីជាប្រយោជន៍ដល់ពួករើសតាំងឲ្យគេបានសេចក្ដីសង្គ្រោះ ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ ព្រមទាំងមានសិរីល្អដ៏នៅអស់កល្បជានិច្ចផង" (២ ធី ២:១០) ។ ប៉ុន្តែសាវក ប៉ុល បានដឹងថា ព្រះបានជ្រើសរើសមនុស្សមួយចំនួន ឲ្យបានទទួលសេចក្ដីសង្គ្រោះ ហើយគាត់បានឃើញការនេះថា ជាការលើកទឹកចិត្តមួយ ក្នុងការប្រកាសដំណឹងល្អ មិនមែនជាការបំបាក់ទឹកចិត្តទេ ទោះបីជាត្រូវទ្រាំទ្រនឹងការឈឺចាប់ដ៏ខ្លាំងក្លាដ៏ដោយ ។ ការជ្រើសរើស គឺជាការធានារបស់សាវក ប៉ុល ដែលថា នឹងមានការជោគជ័យខ្លះសំរាប់ការងារប្រកាសដំណឹងល្អរបស់គាត់ ដ្បិតគាត់បានដឹងថា មនុស្ស*មួយចំនួន*ដែលគាត់បាននិយាយទៅកាន់ អាចជាពួកជ្រើសតាំង ដែលពួកគេអាចនឹងជឿដំណឹងល្អ ហើយបានទទួលសេចក្ដីសង្គ្រោះ ។ វាប្រៀបដូចជា មានមនុស្សម្នាក់បានអញ្ជើញសាវក

ប៉ុល ឲ្យមកចាប់ត្រី ហើយបាននិយាយថា "ខ្ញុំសូមធានាថា អ្នកនឹងចាប់បានត្រីខ្លះជាមិនខាន ដ្បិតត្រីទាំងនោះកំពុងតែឃ្លាន ហើយរងចាំ ។

## អ្វីដែលការនេះមិននិយាយសំដៅលើ

គោលលទ្ធិនៃការជ្រើសរើស មិនមានន័យថា ជំរើសរបស់យើងមិនសំខាន់ ហើយសកម្មភាពរបស់យើងអត់មានលទ្ធផលនោះទេ ។ ហើយគោលលទ្ធិនៃការជ្រើសរើសក៏មិនមែនតំរូវឲ្យយើងជឿថា អ្វីៗគ្រប់យ៉ាងនៅក្នុងសាកលលោក គឺជាសាកលលោកដែលអបុគ្គលនិងមិនអាចបត់បែនបាន ដែលត្រូវបានគ្រប់គ្រងដោយអំណាចនៃអបុគ្គលដែលគ្មានការបត់បែនបាន នោះដែរ ។

ព្រះគម្ពីរសញ្ញាថ្មី បានបង្ហាញពីផែនការនៃសេចក្តីសង្គ្រោះថា ជា អ្វីមួយដែលព្រះមួយអង្គបាននាំមកឯមនុស្សផ្ទាល់ ដោយសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត ។ "ដោយសេចក្តីស្រឡាញ់... ទ្រង់បានតំរូវយើងរាល់គ្នាទុកជាមុន សំរាប់ឲ្យទ្រង់បានទទួលយើងជាកូនចិញ្ចឹម ដោយសារព្រះគ្រីស្ទ" (អេ ១:៥) ។ កិច្ចការនៃសេចក្តីសង្គ្រោះរបស់ព្រះ ពេញដោយសេចក្តីស្រឡាញ់ សំរាប់ពួកអ្នកដែលទ្រង់បានជ្រើសរើស (សូមមើល យ៉ូហាន ៣:១៦ និងរ៉ូម ៨:២៨ ផងដែរ) ។

លើសពីនោះទៅទៀត បទគម្ពីរនៅតែបង្ហាញថា យើងជា*មនុស្សផ្ទាល់*ដែលត្រូវធ្វើ*ការសំរេចដោយឆន្ទៈ* ថា ទទួល ឬបដិសេធ ដំណឹងល្អ ។ ឧទាហរណ៍៖ យើងបានឃើញយ៉ាងច្បាស់ក្នុងសេចក្តីអញ្ជើញ នៅឯខាងចុងនៃព្រះគម្ពីរវិវរណៈ: "ព្រះវិញ្ញាណ និងប្រពន្ធថ្មោងថ្មីពោលថា អញ្ជើញមក ហើយអ្នកណាដែលឮ ក៏ថា

អញ្ជើញមកដែរ។ អ្នកណាដែលស្រេក នោះមានតែមក ហើយអ្នកណាដែលចង់បាន មានតែយកទឹកជីវិតនោះចុះ ឥតចេញថ្លៃទេ” (វិវរ ២២:១៧)។ មានការអញ្ជើញផ្សេងទៀតដែលដូចគ្នានឹងការអញ្ជើញនេះដែរ (ឧ៖ ម៉ាថ ១១:២៨) គឺនិយាយទៅកាន់បុគ្គលពិតៗដែលអាចស្តាប់សេចក្តីអញ្ជើញនេះបាន ហើយឆ្លើយតបវិញបាន ដោយធ្វើការសំរេចចិត្តដោយខ្លួនពួកគេ។ សេចក្តីសំរេចចិត្តដ៏ពិតប្រាកដទាំងនេះ មានលទ្ធផលដ៏នៅអស់កល្បជានិច្ច ដូចជាបានបង្ហាញនៅក្នុងគម្ពីរយ៉ូហាន ៣:១៨ ថា “ឯអ្នកណាដែលជឿដល់ទ្រង់ នោះមិនជាប់មានទោសទេ តែអ្នកណាដែលមិនជឿវិញ នោះត្រូវមានទោសហើយ ពីព្រោះមិនបានជឿដល់ព្រះនាមនៃព្រះរាជបុត្រាតែមួយរបស់ព្រះ”។

ការយល់ដឹងត្រឹមត្រូវអំពីការជ្រើសរើស ពិតជាផ្តល់តំលៃដ៏ពិតប្រាកដចំពោះសេចក្តីសំរេច និងជំរើសរបស់យើង មិនមានន័យថា ការសំរេចព្រះហឫទ័យរបស់ព្រះ *ផ្អែកលើ*សេចក្តីសំរេចចិត្តរបស់យើងនោះទេ។ ព្រះបានជ្រើសរើសបុគ្គលម្នាក់ៗ “តាំងពីមុនកំណើតលោកិយមក” (អេ ១:៤) ទ្រង់មិនបានធ្វើដូច្នោះ ដោយព្រោះទ្រង់បានទតឃើញជាមុនពីសេចក្តីជំនឿ ឬផ្នែកខ្លះនៃសេចក្តីសំរេចចិត្ត ដែលពួកគេនឹងធ្វើនោះទេ។ សាវក ប៉ុល បានបញ្ជាក់ការនេះ នៅក្នុងបទគម្ពីររ៉ូម ៨:២៩ នៅពេលដែលគាត់សរសេរថា “ដ្បិតអ្នកណាដែលទ្រង់បានស្គាល់ជាមុន នោះទ្រង់ក៏តំរូវទុកជាមុន” ។ នៅពេលដែលសាវក ប៉ុល និយាយអំពីបុព្វញ្ញាណរបស់ព្រះ មានន័យថា គាត់កំពុងតែគិតពីព្រះថា ទ្រង់ស្គាល់*បុគ្គល*ម្នាក់ៗជាមុន (ពួកអ្នកដែលទ្រង់ស្គាល់)។ ព្រះ “បានស្គាល់បុគ្គលទាំងនេះជាមុន”

ក្នុងបរិបទនៃទំនាក់ទំនងដែលបានសង្គ្រោះមួយ ជាមួយពួកគេ ។ នេះគឺខុសគ្នាអំពីការនិយាយពីបុព្វញ្ញាណដែលព្រះស្គាល់ពី*សកម្មភាព ឬការសំរេចចិត្ត*របស់បុគ្គលណាម្នាក់ជាមុន ឧទាហរណ៍ដូចជាទ្រង់ជ្រាបពីការសំរេចចិត្តជឿរបស់គេ ។

ជាការពិតណាស់ ព្រះគម្ពីរមិនដែលនិយាយអំពីសេចក្តីជំនឿ (បច្ចុប្បន្ន ឬអតីតកាល) ថាជាហេតុផល ដែលព្រះបានជ្រើសរើសអ្នកណាម្នាក់នោះទេ ។ នៅក្នុងព្រះគម្ពីរអេភេសូរ ១:៤-៦ សាវក ប៉ុល បាននិយាយថា "ដោយសេចក្តីស្រឡាញ់...ទ្រង់បានតំរូវយើងរាល់គ្នាទុកជាមុន សំរាប់ឲ្យទ្រង់បានទទួលយើងជាកូនចិញ្ចឹម ដោយសារព្រះគ្រីស្ទ*តាមបំណងព្រះហឫទ័យទ្រង់* ដើម្បីនឹងសរសើរដល់ព្រះគុណដ៏ឧត្តមរបស់ទ្រង់" ។ ប្រសិនបើការជ្រើសរើស ផ្អែកទៅលើការសំរេចចិត្តរបស់យើងរាល់គ្នា នោះ វាហាក់ដូចជា ធ្វើឲ្យសេចក្តីស្រឡាញ់របស់ព្រះកាន់តែតិចទៅ ហើយធ្វើឲ្យព្រះគុណរបស់ទ្រង់មិនសូវមានតំលៃ (ដ្បិតយើងគិតថាយើងមានសេចក្តីល្អខ្លះដែលយើងអាចធ្វើការជាមួយព្រះគុណទ្រង់) ព្រមទាំងកាត់បន្ថយសិរីល្អដែលទ្រង់សមទទួលសំរាប់សេចក្តីសង្គ្រោះរបស់យើងឲ្យកាន់តែតិចដែរ ។

## តើយើងពិតជាមានសេរីភាពឬទេ ?

មនុស្សជាច្រើនជឿថា ប្រសិនបើគោលលទ្ធិនៃការជ្រើសតាំងគឺជាការពិតមែន នោះយើងពិតជាមិនមានសេរីភាពទេ ។ មានការពិបាកក្នុងការគិតបែបនេះ គឺថាមាននិយមន័យ និងការសន្និដ្ឋានផ្សេងៗគ្នាជាច្រើន ជុំវិញពាក្យថា "សេរីភាព" ហើយ

និយមន័យទាំងនេះនាំទៅរកការយល់ខុស និងទំនាស់ ។ នៅក្នុងករណីនេះ វាមានប្រយោជន៍ក្នុងការប្រើប្រាស់ពាក្យមួយ ក្រៅពីពាក្យថា “សេរីភាព” ដើម្បីធ្វើឲ្យមានការទាក់ទងគ្នា ប៉ុន្តែត្រូវប្រុងប្រយ័ត្នថែមទៀតនូវអ្វីដែលអ្នកនិយាយ ។ ឧទាហរណ៍៖ ព្រះគម្ពីរសំណូមពរឲ្យសមត្ថភាពរបស់យើង ធ្វើជំរើស*ដោយស្ម័គ្រចិត្ត* ឬជំរើស*ដោយឆន្ទៈ*រាប់រយឯង (សូមមើលខនានាខាងលើ អំពី “ជំរើសដោយឆន្ទៈ” ហើយគ្រប់ទាំងសេចក្តីបង្គាប់នៅក្នុងព្រះគម្ពីរ ក៏សូមឲ្យយើងឆ្លើយតប និងស្តាប់បង្គាប់តាមផងដែរ) ។ យើងមិនត្រូវបានបង្ខំឲ្យធ្វើអ្វីមួយឲ្យខុសពីឆន្ទៈផ្ទាល់របស់យើងនោះទេ ។ យើងធ្វើអ្វីដែលយើង*ចង់*ធ្វើដោយខ្លួនឯង ។ ការធ្វើជំរើស គឺជាផ្នែកដែលសំដៅថា ជាមនុស្សជាតិដែលនៅក្នុងរូបអង្គព្រះជាអ្នកធ្វើដ្បិតយើងត្រាប់តាមសកម្មភាពផ្ទាល់របស់ព្រះ ក្នុងការធ្វើការសំរេចចិត្ត ដើម្បីធ្វើអ្វីៗទៅតាមចរិកលក្ខណៈរបស់ទ្រង់ ។

ប៉ុន្តែ តើនោះមានន័យថា ព្រះមិនបានធ្វើអ្វីសោះជាមួយនឹងជំរើសរបស់យើងឬ ? តើយើងចង់ឲ្យព្រះ ដែលទ្រង់ជាព្រះអាទិករដ៏មានអំណាចនិងប្រាជ្ញាឥតព្រំខ័ណ្ឌ មិនអាចមានឥទ្ធិពល ហើយលុញលួងចិត្ត និងបំណងប្រាថ្នារបស់យើងទៅតាមផែនការរបស់ទ្រង់ទេឬ ? ជាការពិតណាស់ ប្រសិនបើព្រះធ្វើការតាមរយៈ*ជំរើស* និងបំណងប្រាថ្នារបស់យើងដើម្បីសំរេចផែនការរបស់ទ្រង់ ក្នុងពេលតែមួយដែលយើងធ្វើជំរើសដោយស្ម័គ្រចិត្ត នោះការនេះនឹងធានាសមត្ថភាពក្នុងការជ្រើសរើសរបស់យើង ឲ្យវាកើតឡើងទៅតាមអ្វីដែលព្រះបានសំរេចព្រះហឫទ័យ និងតាំងឡើង ។

ដូច្នេះ ប្រសិនបើយើងឆ្លើយតបចំពោះការអញ្ជើញរបស់ព្រះគ្រីស្ទ នៅក្នុងរបៀបវិជ្ជមានមួយ នោះយើងអាចនិយាយដោយស្មោះត្រង់ថា យើង*បានជ្រើសរើស*ដើម្បីឆ្លើយតបចំពោះព្រះគ្រីស្ទហើយ ព្រមទាំងនិយាយថា ព្រះបានតាំងរបៀបនោះឡើងផង (ក្នុងរបៀបនានាដែលយើងមិនអាចយល់ពេញលេញបាន) ។ ប្រសិនបើយើងមិនអាចយល់ទាំងស្រុង ពីរបៀបដែលការទាំងពីរនេះជាការពិតព្រមៗគ្នាទេ នោះយើងត្រូវទទួលស្គាល់ថា ត្រង់នេះមានសេចក្តីអាថ៌កំបាំង ។ នៅក្នុងសម័យនេះ យើងមិនអាចយល់ពីសេចក្តីអាថ៌កំបាំងនេះទាំងស្រុងបានទេ ។ ហើយទោះបីជាយើងមិនយល់ពីការនេះក៏ដោយ ក៏យ៉ាងហោចណាស់យើងគួរប្រាកដថា យើងនិយាយតាមរបៀបដែលព្រះគម្ពីរនិយាយអំពីការនេះ នៅគ្រប់ផ្នែកនៃសេចក្តីបង្រៀនរបស់វាដែរ ។

លើសពីនោះទៅទៀត ព្រះក៏បានបង្កើតយើងមក ប្រយោជន៍ឲ្យជំរើសរបស់យើងជា *ជំរើសដ៏ពិតប្រាកដ* ។ ទោះជាយ៉ាងណាក៏ដោយ ជំរើសរបស់យើងមិនត្រូវការមានសេរីភាពទាំងស្រុងពីការពាក់ព័ន្ធជាមួយព្រះ ដើម្បីឲ្យបានក្លាយជាជំរើសដ៏ស្ម័គ្រពីចិត្តហើយដ៏ពិតប្រាកដនោះទេ ។ ឧទាហរណ៍៖ ជាច្រើនដងរាល់ថ្ងៃនៅពេលដែលយើងធ្វើការសំរេចចិត្តក្នុងការដកដង្ហើម ព្រះដ៏ជាព្រះអាទិករនិងជាអ្នកទប់ទល់របស់យើង បានពាក់ព័ន្ធគ្រប់ជំហានជាមួយយើងនៅក្នុងសេចក្តីសំរេចចិត្តនោះ ដ្បិតព្រះ “ធ្វើគ្រប់ការទាំងអស់ តាមដែលគាប់ព្រះហឫទ័យទ្រង់” (អេ ១:១១) ហើយព្រះគ្រីស្ទនៅតែបន្ត “ទ្រទ្រង់គ្រប់របស់ទាំងអស់ ដោយសារព្រះបន្ទូលដ៏មានព្រះចេស្តានៃទ្រង់” (ហេ ១:៣) ។

ចុះចំណែកឯពួកអ្នកមិនជឿ គឺពួកអ្នកដែលព្រះមិនបានជ្រើសរើស យ៉ាងម៉េចដែរ ? ព្រះគម្ពីរមិនដែលទំលាក់កំហុសដល់ព្រះ ក្នុងការដែលអ្នកណាម្នាក់បដិសេធនឹងការប្រកាសរបស់ព្រះគ្រីស្ទទេ ។ ការសំខាន់នោះ គឺតែងតែទំលាក់ទៅលើជំរើសដ៏ស្ម័គ្រពីចិត្តរបស់ពួកគេ ក្នុងការដែលពួកគេបដិសេធមិនព្រមជឿ ហើយបន្ទោសចំពោះការមិនជឿរបស់ពួកគេវិញ ។ ដូចជាព្រះយេស៊ូវបានមានបន្ទូលនៅក្នុងគម្ពីរយ៉ូហាន ៨:៤៣-៤៤ ថា “ហេតុអ្វីបានជាអ្នករាល់គ្នាមិនយល់សំដីខ្ញុំ ? គឺមកតែពីស្ដាប់ពាក្យខ្ញុំមិនបានប៉ុណ្ណោះ អ្នករាល់គ្នាមានអារក្សសាតាំងជាឪពុក ហើយអ្នករាល់គ្នាចូលចិត្តធ្វើតាមតណ្ហា ដែលគាប់ចិត្តដល់ឪពុករបស់អ្នក” ។ អស់អ្នកដែលបានបដិសេធទ្រង់ ព្រះយេស៊ូវមានបន្ទូលថា “អ្នករាល់គ្នាមិនសុខចិត្តមកឯខ្ញុំ ឲ្យបានជីវិតទេ” (យ៉ូន ៥:៤០) ។ ហើយសាវក ប៉ុល នៅក្នុងគម្ពីររ៉ូម ១:២០ ចែងថា អស់អ្នកដែលបដិសេធការបើកសំដែងអោយឃើញច្បាស់របស់ព្រះដល់មនុស្សជាតិទាំងអស់ ដូច្នេះពួកគេ “ពុំអាចដោះសារខ្លួនបានឡើយ” ។ នេះគឺជាគំរូដែលមានលក្ខណ:ដូចគ្នានៅក្នុងបទគម្ពីរ៖ មនុស្សដែលជាប់នៅក្នុងការមិនជឿ នឹងធ្វើយ៉ាងដូច្នេះ ពីព្រោះពួកគេមិនចង់មកឯព្រះ ហើយរីឯកំហុសសំរាប់ការមិនជឿ គឺនៅជាប់នឹងអ្នកដែលមិនជឿនោះឯង មិនមែននៅជាប់នឹងព្រះទេ ។ ដូចដែលបាននិយាយខាងលើហើយថា នៅក្នុងសម័យនេះ ប្រហែលជាយើងមិនអាចយល់ទាំងស្រុងបានទេ ។

## តើព្រះពិតជាយុត្តិធម៌ឬទេ ?

នៅត្រង់ចំនុចនេះ មនុស្សមួយចំនួននឹងបដិសេធថា ប្រសិនបើគោលលទ្ធិនៃការរើសតាំងជាការពិត អញ្ចឹងព្រះទ្រង់មិនយុត្តិធម៌ទេ ដោយព្រះជ្រើសរើសមនុស្សមួយចំនួនឲ្យបានសង្គ្រោះ ហើយបែរជាសំរេចព្រះហឫទ័យរំលងអ្នកផ្សេងទៀតមិនឲ្យបានទទួលសេចក្ដីសង្គ្រោះទៅវិញ ដូច្នេះទ្រង់បានប្រទានព្រះគុណមក ដោយមិនយុត្តិធម៌សោះ ។

វាមានសារៈសំខាន់ណាស់ ក្នុងការយល់ថាអ្វីទៅជា "យុត្តិធម៌" ពិតប្រាកដចំពោះសេចក្ដីសង្គ្រោះ ។ ជាការពិតប្រាកដហើយ វា យុត្តិធម៌ណាស់ ដែលព្រះមិនត្រូវសង្គ្រោះ មនុស្ស*ណាម្នាក់*ដែលបានធ្វើបាប ហើយបះបោរប្រឆាំងនឹងទ្រង់នោះ ។ ដូចជាទ្រង់បានធ្វើចំពោះពួកទេវតា "ព្រះមិនបានប្រណីដល់ពួកទេវតា ដែលបានធ្វើអំពើបាប គឺទ្រង់បោះទំលាក់ទៅក្នុងជង្ហុកជ្រៅបំផុត ឲ្យជាប់ច្រវាក់នៃសេចក្ដីងងឹត ទាំងឃុំទុកសំរាប់នឹងជំនុំជំរះវិញ" (២ ពេ ២:៤) ។ ប៉ុន្តែ ប្រសិនបើពិតជាសង្គ្រោះមនុស្សណាម្នាក់ នោះមានន័យថា នេះគឺជាការបង្ហាញឲ្យឃើញមួយនៃព្រះគុណរបស់ទ្រង់ ដែលព្រះគុណនោះខ្ពស់លើសពីការទាមទារនៃភាពយុត្តិធម៌នេះ ។ ប្រសិនបើព្រះបានសង្គ្រោះមនុស្សតែប្រាំនាក់ចេញពីមនុស្សជាតិទាំងមូល នោះក៏ជាសេចក្ដីមេត្តាករុណា និងព្រះគុណដែរ ។ ប្រសិនបើទ្រង់សង្គ្រោះមនុស្សមួយរយនាក់ នោះក៏ជាសេចក្ដីមេត្តាករុណា និងព្រះគុណដ៏គួរឲ្យស្ញប់ស្ញែងទៅទៀត ។ ប៉ុន្តែតាមពិតទៅ ទ្រង់បានសំរេចព្រះហឫទ័យដើម្បីសង្គ្រោះ "មនុស្សមួយហ្វូងយ៉ាងធំ ដែលគ្មានអ្នកណាអាចនឹងរាប់បានឡើយ គេមកពីគ្រប់ទាំងសាសន៍

គ្រប់ទាំងពូជមនុស្ស គ្រប់ទាំងគ្រួសារ ហើយគ្រប់ទាំងភាសា” (វិវរ ៧:៩) ។ នេះគឺជាសេចក្តីមេត្តាករុណាដែលលើសពីការយល់ដឹងរបស់យើង ។

សាវក ប៉ុល បានលើកសំនួរនេះឡើង អំពីកំរិតដ៏ជ្រាលជ្រៅមួយនៅក្នុងព្រះគម្ពីររ៉ូម ជំពូក ៩ ។ បន្ទាប់ពីគាត់និយាយថា ព្រះ “តែងផ្សាយមេត្តាករុណាដល់អ្នកណាតាមព្រះហឫទ័យ ហើយទ្រង់ធ្វើឲ្យអ្នកណារឹងទទឹង ក៏តាមតែព្រះហឫទ័យដែរ” (រ៉ូម ៩:១៨) សាវក ប៉ុល បានសរសេរថា “ដូច្នេះ អ្នកនឹងសួរខ្ញុំថា ហេតុអ្វីបានជាទ្រង់នៅតែបន្ទោសទៀត ដ្បិតតើអ្នកណាបានទទឹងនឹងព្រះហឫទ័យទ្រង់ ?” (រ៉ូម ៩:១៩) ។ ត្រង់នេះ សាវក ប៉ុល កំពុងតែផ្តល់សម្លេងនៃសំនួរមួយដែលមនុស្សជាច្រើនបានចោទសួរថា៖ ប្រសិនបើវាសនារបស់មនុស្សម្នាក់ៗ ត្រូវបានកំណត់ឡើងដោយព្រះ តើការនេះអាចនឹងយុត្តិធម៌យ៉ាងដូចម្តេចបាន ? សូម្បីតែនៅពេលមនុស្សធ្វើជំរើសហើយកំណត់ថា ពួកគេនឹងត្រូវបានសង្គ្រោះ ឬអត់ មានព្រះនៅពីក្រោយខ្នងរួចទៅហើយ អញ្ចឹងតើការនេះអាចនឹងយុត្តិធម៌យ៉ាងដូចម្តេចបាន ?

នេះជាអ្វីដែលសាវក ប៉ុល បាននិយាយ៖

ប៉ុន្តែ ឱមនុស្សអើយ តើអ្នកជាអ្វីដែលហ៊ានឆ្លើយទាស់នឹងព្រះដូច្នេះ ? តើរបស់ដែលជាស្មូនបានសូនធ្វើហើយ នឹងនិយាយទៅជាងនោះថា “ហេតុអ្វីបានជាសូនធ្វើអញដូច្នេះឬអី ? តើជាងស្មូនគ្មានអំណាច លើដីឥដ្ឋ នឹងយកដុំដីដដែល ធ្វើជាវត្ថុ សំរាប់ការដ៏ប្រសើរ ហើយមួយទៀតសំរាប់ការមិនប្រសើរទេឬអី ? ចុះបើសិនជាព្រះទ្រង់ចង់សំដែងសេចក្តីក្រោធ ព្រម

ទាំងបើកឲ្យស្គាល់ព្រះចេស្ដា ដល់ប្រដាប់គួរនឹងក្រោធ ដែលរៀបចំឡើង សំរាប់តែត្រូវបំផ្លាញដូច្នេះ ដែលទ្រង់ទ្រាំទ្រដោយអំណត់ជាយូរមកហើយ ហើយបើទ្រង់ចង់បើកឲ្យពួកគ្រឿងប្រដាប់ ដែលគួរនឹងសេចក្ដីមេត្តាករុណាដែលទ្រង់បានរៀបចំជាមុន បានស្គាល់សេចក្ដីវិសេសនៃសិរីល្អដ៏បរិបូររបស់ទ្រង់វិញ គឺយើងរាល់គ្នាដែលទ្រង់បានហៅមក មិនមែនពីសាសន៍យូដាតែប៉ុណ្ណោះ គឺពីសាសន៍ដទៃផង នោះធ្វើដូចម្ដេចទៅ? (រ៉ូម ៩:២០-២៤) ។

សាវក ប៉ុល កំពុងតែនិយាយផ្ដោតជាសំខាន់ថា មានចំនុចមួយដែលលើសពីហ្នឹងទៀត ដែលយើងមិនអាចឆ្លើយតបទៅឯព្រះ ឬការទាមទារនៃភាពយុត្តិធម៌បាន ។ ព្រះបានធ្វើអ្វីៗ ទៅតាមបំណងព្រះហឫទ័យទ្រង់ ។ ទ្រង់ជាអ្នកបង្កើត យើងជាអ្វីដែលទ្រង់បានបង្កើត យ៉ាងនេះហើយយើងគ្មានមូលដ្ឋានណាមួយអំពីការនេះ ដើម្បីចោទថាទ្រង់អយុត្តិធម៌នោះទេ ។ ចំលើយរបស់យើងចំពោះចម្ងល់ទាំងនេះ នៅក្នុងគម្ពីររ៉ូម បានបើកសំដែងជាច្រើនអំពីចិត្តនិងឆន្ទៈរបស់យើង ដើម្បីឲ្យយើងចុះចូលចំពោះព្រះអាទិករដែលបង្កើតយើងមក ។

## តើព្រះសព្វព្រះហឫទ័យឲ្យមនុស្សទាំងអស់បានសង្គ្រោះដែរឬទេ ?

ប្រសិនបើការរើសតាំងជាការពិត អញ្ចឹងតើព្រះនៅតែសព្វព្រះហឫទ័យឲ្យមនុស្សទាំងអស់បានសេចក្ដីសង្គ្រោះឬ? បាទ ពិតមែនហើយ ដោយយោងទៅតាមបទ

គម្ពីរខ្លះ ។ នៅក្នុង ១ ធីម៉ូថេ ២:៤ សាវក ប៉ុល បានសរសេរអំពីព្រះ និងព្រះអង្គសង្គ្រោះរបស់យើងថា "ទ្រង់សព្វព្រះហឫទ័យ ឲ្យមនុស្សទាំងអស់បានសង្គ្រោះ ហើយឲ្យបានស្គាល់សេចក្តីពិត" ។ សាវក ពេត្រុស ក៏បាននិយាយដូចគ្នាដែរ នៅក្នុង ២ ពេត្រុស ៣:៩ ថាព្រះអម្ចាស់ "មានព្រះហឫទ័យអត់ធ្មត់នឹងយើងរាល់គ្នាវិញ ដោយមិនចង់ឲ្យអ្នកណាមួយវិនាសឡើយ គឺចង់ឲ្យមនុស្សទាំងអស់បានប្រែចិត្តវិញ" ។

មនុស្សនឹងមិនយល់ស្របនឹងការបកស្រាយ នៃខគម្ពីរទាំងអស់នេះ តែមនុស្សជាច្រើននឹងយល់ស្របវិញ ។ ការនេះឆ្លុះបញ្ចាំងឲ្យឃើញថា ព្រះសព្វព្រះទ័យនឹងការខ្លះ ជាជាងការផ្សេងទៀត ។ ជាញឹកញាប់ មនុស្សដែលមិនយល់ស្របនឹងគោលលទ្ធិនៃការជ្រើសតាំង នឹងនិយាយដោយសំអាងលើខទាំងនេះ និងខផ្សេងទៀតថា ព្រះសព្វព្រះទ័យចង់ថែរក្សាឆន្ទៈសេរីរបស់មនុស្សជាជាង ទ្រង់សព្វព្រះទ័យចង់សង្គ្រោះមនុស្សទាំងអស់ ។ ប៉ុន្តែមនុស្សដែលគាំទ្រចំពោះគោលលទ្ធិនៃការជ្រើសតាំង នឹងនិយាយថា ព្រះសព្វព្រះទ័យចង់ជួយឲ្យសិរីល្អរបស់ទ្រង់បានជោគជ័យ ជា ជាងទ្រង់សព្វព្រះទ័យចង់សង្គ្រោះមនុស្សទាំងអស់ ហើយថាដូចជាបទគម្ពីររ៉ូម ជំពូក ៩ បានបង្ហាញថា សិរីល្អរបស់ទ្រង់ត្រូវបានជួយឲ្យជោគជ័យ ដោយសារការសង្គ្រោះមនុស្សមួយចំនួន មិនមែនមនុស្សទាំងអស់ ។ (ពួកគ្រីស្ទានទាំងសងខាងនៃការរ៉ែកញែកនោះ យល់ស្របថា មនុស្សទាំងអស់មិនសុទ្ធតែបានទទួលសេចក្តីសង្គ្រោះនោះទេ) ។ អញ្ចឹង តើពួកគេទាំងសងខាង អាចនិយាយថា *ព្រះសព្វព្រះទ័យចង់*ឲ្យមនុស្សទាំងអស់បានទទួលសេចក្តីសង្គ្រោះ

ដោយរបៀបណា បើយោងតាមគម្ពីរ ១ ធីម៉ូថេ ២:៤ និង ២ ពេត្រុស ៣:៩ ? ខទាំងអស់នេះសុទ្ធតែប្រាប់យើងពីអ្វីដែលព្រះបង្គាប់មនុស្សឲ្យធ្វើ និងសកម្មភាពអ្វីដែលធ្វើឲ្យទ្រង់សព្វព្រះហឫទ័យ (ឧ៖ ការប្រែចិត្ត និងការជឿដល់ព្រះគ្រីស្ទ) ។ នៅក្នុងគំនិតនេះ ទ្រង់ពិតជា “សព្វព្រះទ័យ” និង “ប្រាថ្នា” ចង់ឲ្យមនុស្សទាំងអស់បានទទួលសេចក្ដីសង្គ្រោះគ្រប់ៗគ្នា ។ ជួនកាល គេហៅការនេះថា បំណងព្រះហឫទ័យ “បើកសំដែង” របស់ទ្រង់ គឺជាការដែលទ្រង់ប្រាប់មនុស្សគ្រប់គ្នានៅលើផែនដី ពីអ្វីដែលពួកគេគួរធ្វើ ។ ប៉ុន្តែ ខទាំងនេះមិនកំពុងតែនិយាយអំពី ផែនការដ៏លាក់កំបាំងរបស់ព្រះតាំងពីអស់កល្បរៀងមក ក្នុងការជ្រើសរើសមនុស្សមួយចំនួនឲ្យបានទទួលសេចក្ដីសង្គ្រោះនោះទេ ។

ដែលមនុស្សទាំងអស់មិនសុទ្ធតែបានសង្គ្រោះ គឺ ជាគោលលទ្ធិដ៏ពិបាកពិចារណាបំផុតមួយ នៅក្នុងព្រះគម្ពីរ ។ ព្រះគម្ពីរបានបង្ហាញថា សូម្បីតែព្រះក៏មានសេចក្ដីទុក្ខព្រួយដ៏ធំដែរ នៅពេលដែលទ្រង់គិតអំពីពួកអ្នកដែលមិនបានសង្គ្រោះ ។ “ព្រះអម្ចាស់យេហូវ៉ាស្បថថា ដូចជាអញរស់នៅ នោះប្រាកដជាអញមិនរីករាយចំពោះសេចក្ដីស្លាប់របស់មនុស្សអាក្រក់ឡើយ គឺចូលចិត្តឲ្យគេលះចោលផ្លូវរបស់ខ្លួន ហើយមានជីវិតរស់នៅវិញទេតើ ចូរឲ្យឯងរាល់គ្នាបែរមក ចូរបែរមកពីផ្លូវអាក្រក់របស់ខ្លួនចុះ ដ្បិតឱពួកវង្សអ៊ីស្រាអែលអើយ ហេតុអ្វីបានជាចង់ស្លាប់” (អេសេ ៣៣:១១) ។ នៅពេលដែលព្រះយេស៊ូវបានគិតពីពួកអ្នកដែលបានបដិសេធទ្រង់នៅក្រុងយេរូសាឡឹម “ទ្រង់ព្រះកន្សែងនឹងក្រុងនោះ” (លូ ១៩:៤១) ហើយទ្រង់បានមានបន្ទូលថា “ឱយេរូសាឡឹម ! ក្រុងយេរូសាឡឹម

អើយ ! ឯងដែលសំឡាប់ពួកហោរា ហើយយកថ្មចោលពួកអ្នកដែលបានចាត់មកឯឯង តើប៉ុន្មានដងហើយ ដែលអញចង់ប្រមូលកូនឯងទាំងប៉ុន្មាន ? ដូចជាមេមាន់ក្រុងកូនវាឲ្យជ្រកក្រោមស្លាប តែឯងមិនព្រមទេ ។ សាវក ប៉ុល បាននិយាយថា “ខ្ញុំមានសេចក្តីទុក្ខសោកជាខ្លាំង និងសេចក្តីព្រួយលំបាកក្នុងចិត្តជានិច្ច” (រ៉ូម ៩:២) នៅពេលដែលទ្រង់បានគិតអំពីបងប្អូនជនជាតិយូដាប្រុសស្រីរបស់ទ្រង់ ដែលបានបដិសេធព្រះគ្រីស្ទ ។ សេចក្តីស្រឡាញ់ដែលព្រះប្រទានមកយើង សំរាប់ភាពជាមនុស្សរបស់យើង ហើយនិងសេចក្តីស្រឡាញ់ដែលទ្រង់បង្គាប់ឲ្យយើងមាន សំរាប់អ្នកជិតខាងរបស់យើង ធ្វើឲ្យយើងមានសេចក្តីទុក្ខព្រួយយ៉ាងខ្លាំង នៅពេលដែលយើងដឹងថា មនុស្សទាំងអស់មិនសុទ្ធតែបានសង្គ្រោះគ្រប់ៗគ្នានោះ ។ ប៉ុន្តែ ទណ្ឌកម្មនៃមនុស្សមានបាប គឺជាផែនការដ៏សុចរិត នៃសេចក្តីយុត្តិធម៌របស់ព្រះ ហើយយើងមិនគួរគិតថាវាជារឿងខុសឆ្គងទេ ។

លើសពីនោះទៅទៀត ព្រះប្រទានព្រះពរដ៏រាប់មិនអស់ ដល់មនុស្សគ្រប់ៗរូបនៅក្នុងជីវិតនេះ តែនោះមិនមែនជាផ្នែកនៃសេចក្តីសង្គ្រោះទេ ។ ជួនកាល គេហៅគោលលទ្ធិនេះថា “ព្រះគុណទូទៅ” ពីព្រោះ វាសំដៅទៅការបង្ហាញនៃព្រះគុណរបស់ព្រះមួយ ដែលមនុស្សគ្រប់ៗគ្នាបានទទួល តែវាខុសពីព្រះគុណនៃសេចក្តីសង្គ្រោះរបស់ព្រះ ។

## ព្រះគុណទូទៅ

នៅពេលដែលពួកយើងណាម្នាក់ធ្វើបាប យើងសមតែទទួលការមួយ គឺការដាច់ចេញពីព្រះដ៏នៅអស់កល្បជានិច្ច ។ យើងគួរត្រូវបានកាត់ផ្តាច់ពីបទពិសោធន៍ក្នុងការល្អមកពីព្រះ ហើយរស់នៅអស់កល្បក្នុងស្ថាននរក ព្រមទាំងគួរទទួលតែសេចក្តីក្រោធរបស់ព្រះជារៀងរហូតប៉ុណ្ណោះ ។ បទគម្ពីររ៉ូម ៦:២៣ ចែងថា “ឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់” ។ ប៉ុន្តែទណ្ឌកម្មនៃអំពើបាបមិនទាន់ទទួលភ្លាមៗនោះទេ ។ យ៉ាងណាមិញ មនុស្សជាតិទាំងអស់ ដោយមិនគិតថាពួកគេនឹងទទួលព្រះគុណរបស់ព្រះ ឬការជំនុំជំរះរបស់ព្រះនោះទេ ពួកគេនឹងនៅតែបន្តទទួលព្រះគុណជាច្រើន នៅពេលដែលពួកគេកំពុងរស់នៅលើផែនដីនេះ ។

ជួនកាលព្រះពរទាំងនោះមានរូបរាង ។ ព្រះយេស៊ូវបានមានបន្ទូលនៅក្នុងគម្ពីរម៉ាថាយ ៥:៤៥ ថាព្រះ “ធ្វើឲ្យថ្ងៃរះឡើង បំភ្លឺទាំងមនុស្សអាក្រក់ និងមនុស្សល្អ ហើយបង្អុរឲ្យភ្លៀងធ្លាក់មកលើ ទាំងមនុស្សសុចរិត និងមនុស្សទុច្ចរិតផង” ។ ព្រះអាទិករនៃចក្រវាឡនេះ មើលថែមនុស្សទាំងអស់ ទោះជាអ្នកជឿងល់ព្រះយេស៊ូវក្តី ទោះជាអ្នកបដិសេធការប្រកាសរបស់ទ្រង់ក្តី សុទ្ធតែទទួលបានសេចក្តីបរិបូរណ៍មកពីផែនដីរបស់ទ្រង់ ។

ព្រះគុណរបស់ទ្រង់ ក៏គេអាចឃើញនៅក្នុងសមត្ថភាពយល់ដឹងដែរ ។ ទោះបីជា សាតាំងជា “អ្នកកំភូត ហើយជាឪពុកនៃសេចក្តីនោះ” ហើយ “គ្មានសេចក្តីពិតនៅក្នុងវា” (យ៉ូន ៨:៤៤) ប៉ុន្តែ សូម្បីតែអ្នកបដិសេធការប្រកាសពីព្រះយេស៊ូវ ក៏មិនត្រូវបានប្រគល់ទៅក្នុងសេចក្តីកុហក និងសេចក្តីខ្វះការពិចារណា

ទាំងស្រុងនោះដែរ ។ ជំនួសមកវិញ ព្រះបានធ្វើឲ្យមនុស្សដែលបដិសេធទ្រង់ជាច្រើន មានការរុករកឃើញ និងការច្នៃប្រឌិតដ៏មិនគួរឲ្យជឿ ។ ពួកគេមិនដឹងថា ការដែលពួកគេចេះនិងយល់ដឹងការទាំងអស់នេះ គឺដោយសារតែព្រះយេស៊ូវជាអ្នកបំភ្លឺពួកគេនោះទេ ។ “ពន្លឺដ៏ពិត នោះគឺជាពន្លឺដែលបំភ្លឺដល់មនុស្សទាំងអស់ ដែលកើតមកក្នុងលោកិយ” (យ៉ូន ១:៩) ។ នៅពេលយើងទទួលអត្ថប្រយោជន៍ពីភាពជឿនលឿនទាំងនេះ មានន័យថា ពួកយើងកំពុងតែទទួលអត្ថប្រយោជន៍ពីព្រះគុណទូទៅរបស់ព្រះ ។

ព្រះគុណទូទៅនេះ ត្រូវបានឃើញក្នុងផ្នែកដទៃទៀតនៃជីវិតដូចជា៖ គំនិតខាងសីលធម៌ (មនុស្សមិនអាក្រក់ប្លួសល្បត់ណាស់នោះទេ), គំនិតច្នៃប្រឌិត (យើងអាចបង្កើត និងឲ្យតំលៃលើរបស់ល្អ និងស្អាតផ្សេងៗ), គំនិតរៀបចំសង្គម (មានសហគមន៍ និងស្ថាប័នជាច្រើន ហើយរដ្ឋាភិបាល ការពារ និងផ្គត់ផ្គង់ សំរាប់សមាជិក និងអ្នកគាំទ្ររបស់ខ្លួន), និងគំនិតសាសនា (ព្រះយេស៊ូវបានប្រាប់អ្នកដើរតាមទ្រង់ នៅក្នុងគម្ពីរម៉ាថាយ ៥:៤៤ ថា ឲ្យអធិស្ឋានសំរាប់អ្នកដែលបៀតបៀន ដើម្បីបង្ហាញថា ព្រះឆ្លើយតបនឹងសេចក្តីអធិស្ឋានជាច្រើនរបស់ពួកគេដែលសំរាប់ជាអត្ថប្រយោជន៍ដល់ពួកអ្នកមិនជឿ ។

ទោះបីជាព្រះគុណទូទៅមិនសង្គ្រោះមនុស្សក៏ដោយ តែ ការពន្យារការជំនុំជំរះរបស់ទ្រង់ គឺដើម្បីធ្វើឲ្យមនុស្សជាច្រើនមកឯសេចក្តីសង្គ្រោះ ។ “ព្រះអម្ចាស់មិនផ្អាកសេចក្តីសន្យារបស់ទ្រង់ ដូចជាមានអ្នកខ្លះគិតស្មាននោះទេ គឺទ្រង់មានព្រះបាទ្ទ័យអត់ធ្មត់នឹងយើងរាល់គ្នាវិញ ដោយមិនចង់ឲ្យអ្នកណាមួយវិនាស

ឡើយ គឺចង់ឲ្យមនុស្សទាំងអស់បានប្រែចិត្តវិញ” (២ ពេ ៣:៩) ។ ដូច្នេះ ព្រះគុណទូទៅរបស់ព្រះបង្ហាញរួចស្រេចទៅហើយ ពីភាពធំធេងនៃសេចក្តីល្អ និងសេចក្តីមេត្តាករុណារបស់ព្រះ ចំពោះមនុស្សជាតិទាំងអស់ ។ ការចាក់ព្រះពរដ៏ឥតចេះដាច់របស់ទ្រង់មកលើមនុស្សទាំងអស់ នឹងបង្ហាញថា ទ្រង់យុត្តិធម៌នៅថ្ងៃជំនុំជំរះចុងក្រោយ នៅ ពេលដែលទ្រង់ដាក់ទណ្ឌកម្មចំពោះអ្នកដែលបានបដិសេធទ្រង់ ។ ជាចុងក្រោយ អ្វីៗទាំងអស់ដែលជាការប្រទានព្រះគុណទូទៅរបស់ព្រះដល់មនុស្សទាំងអស់ បង្ហាញឲ្យឃើញពីសិរីល្អរបស់ព្រះ តាមរយៈការដែលពួកគេបានត្រាប់តាមចរិកលក្ខណៈរបស់ទ្រង់ នៅក្នុងសកម្មភាពនានារបស់ពួកគេ ។ ដូច្នេះ យើងអាចឲ្យតំលៃ និងពេញចិត្ត ចំពោះការបង្ហាញឲ្យឃើញពីព្រះគុណរបស់ផងព្រះតាមរយៈមនុស្សទាំងអស់ ដោយដឹងជាប្រាកដថា ព្រះ សមទទួលការសរសើរ និងសិរីរុងរឿង សំរាប់ការប្រទានពរទាំងនេះ ។

## ដោយសារព្រះគុណតែមួយប៉ុណ្ណោះ

គោលលទ្ធិនៃការជ្រើសតាំង បង្ហាញឲ្យយើងឃើញថា ព្រះបានស្រឡាញ់យើងមិនមែនដោយព្រោះយើងជាអ្នកណា ឬបានធ្វើអ្វី ឬនឹងធ្វើអ្វីនោះទេ ប៉ុន្តែដោយព្រោះទ្រង់បានសំរេចព្រះហឫទ័យស្រឡាញ់យើងវិញ ។ ដូច្នេះ ការឆ្លើយតបដ៏ត្រឹមត្រូវរបស់យើងចំពោះព្រះ គឺជាការដែលយើងថ្វាយការសរសើរដល់ទ្រង់ ជា រៀងរបូតអស់កល្ប ។ ការឆ្លើយតបដ៏ត្រឹមត្រូវរបស់យើងចំពោះអ្នកដទៃ គឺជាការ

បន្ទាបខ្លួន ព្រោះគ្មានផ្នែកណាមួយនៃព្រះគុណរបស់ទ្រង់ ជា របស់ផងយើងម្នាក់ៗ ឡើយ តែវាជាព្រះគុណតែមួយដែលមកពីទ្រង់ប៉ុណ្ណោះ ។

## បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១. តើការយល់ដឹងពីគោលលទ្ធិនៃការរើសតាំង ធ្វើឲ្យអ្នកមានសេចក្ដីអំណរដោយរបៀបណា ? តើមានអ្វីខ្លះ ដែលធ្វើឲ្យអ្នកមានបញ្ហាអំពីគោលលទ្ធិនេះ ?

២. នៅក្នុងគោលលទ្ធិនៃការរើសតាំង តើជំរើសរបស់យើងមានន័យ នៅក្នុងរបៀបណាខ្លះ ?

៣. តើអ្នកអាចរៀបរាប់ពីការពិសេសមួយចំនួន ដែលអ្នកបានឃើញថ្មីៗនេះថា ព្រះបានប្រទានពរដល់ស្នាព្រះហស្តរបស់ទ្រង់តាមរយៈព្រះគុណទូទៅ បានដែរឬទេ ? សូមចំណាយពេលបន្តិចដើម្បីអធិស្ឋានអរព្រះគុណដល់ព្រះ សំរាប់គំរូពិសេសនៃព្រះគុណ ដែលទ្រង់បានផ្ដល់មកមនុស្សទាំងអស់ ។

# ជំពូក ១៣

# តើវាមានន័យយ៉ាងដូចម្តេច ដែលក្លាយជាគ្រីស្ទានម្នាក់ ?

នៅក្នុងគម្ពីររ៉ូម ៨:៣០ សាវក ប៉ុល បានសរសេរពីលំដាប់លំដោយមួយ ដែលព្រះពរនៃសេចក្តីសង្គ្រោះ បានប្រទានមកពួកគ្រីស្ទាន “ឯពួកអ្នកដែលទ្រង់បានដំរូវទុកជាមុន នោះទ្រង់ក៏ហៅ ហើយពួកអ្នកដែលទ្រង់បានហៅ នោះទ្រង់ក៏រាប់ទុកជាសុចរិត ហើយពួកអ្នកដែលទ្រង់បានរាប់ជាសុចរិត នោះទ្រង់ក៏បានដំកើងឡើងដែរ” ។ យើងបានពិភាក្សាអំពីការដំរូវទុកជាមុន នៅក្នុងជំពូកមុននេះហើយ ។ ឥឡូវនេះ នៅក្នុងបួនជំពូកក្រោយមកទៀត យើងនឹងពិភាក្សាផ្នែកផ្សេងៗឯទៃទៀតនៃខនេះ ។

## ការត្រាស់ហៅដ៏មានប្រសិទ្ធិភាព

ការត្រាស់ហៅ ដែលសាវក ប៉ុល បាននិយាយនៅក្នុងគម្ពីររ៉ូម ៨:៣០ មិនមែនជាប្រភេទនៃ “ការត្រាស់ហៅ” ដែលសំដៅថា នៅពេលដែលគេបានផ្តល់ហេតុផលមក អ្នកនោះក៏ជ្រើសរើសកិច្ចការមួយ ឬសំរេចចិត្តធ្វើជាសមាជិកម្នាក់នៃពួកជំនុំណាមួយនោះទេ ។ ផ្ទុយទៅវិញ ការត្រាស់ហៅនេះ ទាក់ទងទៅនឹងអស់អ្នកដែល

បាន “តំរូវទុកជាមុន” ហើយនិងអ្នកដែល “បានត្រឡប់ជាសុចរិត” ។ មានន័យថា វាជាការត្រាស់ហៅមួយដែលត្រាស់ហៅជាពិសេស ដល់អស់អ្នកដែលជាអ្នកជឿព្រះយេស៊ូវ ។

ការត្រាស់ហៅប្រភេទនេះ គឺជាការកោះហៅមួយដែលមកពីស្តេចនៃចក្រវាឡនេះ ។ វាគឺជាការកោះហៅមួយ ដែលមិនអាចប្រកែកបានឡើយ ហើយការកោះហៅនោះ ធ្វើឲ្យមានការឆ្លើយតបដោយចិត្តចង់បានមួយនៅក្នុងចិត្តរបស់មនុស្ស បានកើតឡើង ។ ការត្រាស់ហៅនេះ គឺជាកិច្ចការមួយរបស់ព្រះវរបិតាដែលទ្រង់មានបន្ទូល តាមរយៈការប្រកាសដំណឹងល្អរបស់មនុស្ស ដើម្បីអញ្ជើញមនុស្សមកឯទ្រង់ នៅក្នុងរបៀបមួយដែលពួកគេឆ្លើយតបដោយ សេចក្តីជំនឿនៃសេចក្តីសង្គ្រោះ ។ ដោយព្រោះការត្រាស់ហៅនេះមកពីព្រះ ហើយតែងមានលទ្ធផលជានិច្ចនៅក្នុងសេចក្តីជំនឿនៃសេចក្តីសង្គ្រោះ នោះបានជាជួនកាលគេហៅការត្រាស់ហៅនេះថា *ការត្រាស់ហៅដ៏មានប្រសិទ្ធភាព* ។

នៅពេលដែលព្រះបានត្រាស់ហៅមនុស្ស តាមរបៀបដ៏មានអំណាចនេះ មានន័យថាទ្រង់បានត្រាស់ហៅពួកគេ “ចេញពីសេចក្តីងងឹត មកក្នុងពន្លឺអស្ចារ្យរបស់ទ្រង់” (១ ពេ ២:៩), ទ្រង់ហៅពួកគេមក “ឲ្យមានសេចក្តីប្រកបនឹងព្រះរាជបុត្រាទ្រង់” (១ កូរិន ១:៩ និង កិច្ច ២:៣៩) និងឲ្យ “មកក្នុងនគរ ហើយក្នុងសិរីល្អរបស់ព្រះ” (១ ថែស ២:១២ និង ១ ពេ ៥:១០; ២ ពេ ១:៣) ។ ពួកអ្នកដែលព្រះបានត្រាស់ហៅគឺ “ជាពួកអ្នកដែលព្រះយេស៊ូវគ្រីស្ទទ្រង់បានហៅដែរ” (រ៉ូម ១:៦) ។ ពួកគេត្រូវបានគេហៅថា “ពួកបរិសុទ្ធ” (រ៉ូម ១:៦; ១ កូរិន ១:២) ហើយ

ពួកគេបានមកក្នុងសេចក្តីមេត្រី (១ កូរិន ៧:១៥; កូល ៣:១៥), សេរីភាព (កា ៥:១៣), សេចក្តីសង្ឃឹម (អេ ១:៨; ៤:៨), សេចក្តីបរិសុទ្ធ (១ ថែស ៤:៧), ការអត់ទ្រាំក្នុងការរងទុក្ខ (១ ពេ ២:២០-២១; ៣:៩), និងជីវិតអស់កល្បជានិច្ច (១ ធី ៦:១២) ។

## ការត្រាស់ហៅទូទៅ និងការត្រាស់ហៅរបស់ដំណឹងល្អ

ទោះជាយ៉ាងណាក៏ដោយ មានគំនិតនៃ "ការត្រាស់ហៅ" ដ៏ទូលំទូលាយជាងមួយ គឺជាការប្រកាសដំណឹងល្អដល់មនុស្សទាំងអស់ មិនថាពួកគេនឹងឆ្លើយតបក្តី ឬមិនឆ្លើយតបក្តី ។ ក្រៅពីការត្រាស់ហៅដ៏មានប្រសិទ្ធិភាពដែលតែងតែនាំឲ្យមានការឆ្លើយតបជានិច្ច នោះយើងអាចពិភាក្សាអំពី "ការត្រាស់ហៅរបស់ដំណឹងល្អ"ជាទូទៅ ដែលការត្រាស់ហៅនេះ ត្រូវបាននាំទៅដល់មនុស្សទាំងអស់ ហើយជួនកាលគេហៅការត្រាស់ហៅនេះថា *ការត្រាស់ហៅខាងក្រៅ* ឬ *ការត្រាស់ហៅទូទៅ*។

ការត្រាស់ហៅរបស់ដំណឹងល្អ ត្រូវបាននាំទៅដល់មនុស្ស តាមរយៈការប្រកាសដំណឹងល្អ ។ សាវក ប៉ុល បានបញ្ជាក់នៅក្នុង ២ ថែស្សាឡូនីច ២:១៤ យ៉ាងច្បាស់ នៅ ពេលដែលគាត់បានសរសេរសំបុត្រទៅកាន់ពួកអ្នកជឿថា ការត្រាស់ហៅរបស់ពួកគេ គឺមកពីព្រះ តាមរយៈ "ដំណឹងល្អនៃយើងខ្ញុំ" មានន័យថា សាវក ប៉ុល និងអ្នកផ្សេងទៀត បានប្រកាសដំណឹងល្អដល់ពួកគេ ។ មូលហេតុនេះហើយ វាមានសារៈសំខាន់ ដែលយើងប្រកាសដំណឹងល្អដោយចិត្តក្លាហាន ដោយទុកចិត្តថា តាមរយៈការត្រាស់ហៅដ៏មានប្រសិទ្ធិភាព ព្រះនឹងធ្វើអ្វីដែលទ្រង់បានធ្វើ

ជាមួយនឹងនាង លីឌា នៅក្នុងគម្ពីរកិច្ចការ ១៦:១៤ “ព្រះអម្ចាស់ទ្រង់បើកចិត្តនាងឲ្យយកចិត្តទុកដាក់តាមសេចក្តីដែលប៉ុលអធិប្បាយ” ។

ការត្រាស់ហៅរបស់ដំណឹងល្អ មិនមែនសុទ្ធតែមានប្រសិទ្ធិភាពទាំងអស់នោះទេ ។ ការងាររបស់ពួកអ្នកជឿ គឺត្រូវពន្យល់ពីព្រះរាជសារដំណឹងល្អ រីឯការធ្វើឲ្យព្រះរាជសារ ឬការត្រាស់ហៅនោះ មានប្រសិទ្ធិភាព គឺជាកិច្ចការរបស់ព្រះវិញ ។

## ធាតុផ្សំផ្សេងៗនៃការត្រាស់ហៅរបស់ដំណឹងល្អ

មានធាតុផ្សំគន្លឹះសំខាន់បី ដែលជាផ្នែកមួយនៃការត្រាស់ហៅរបស់ដំណឹងល្អគឺ ការពន្យល់នៃសេចក្តីពិតអំពីសេចក្តីសង្គ្រោះ, ការអញ្ជើញឲ្យមកឆ្លើយតបចំពោះព្រះគ្រីស្ទដោយផ្ទាល់ក្នុងការប្រែចិត្ត និងសេចក្តីសន្យានៃការអត់ទោស និងជីវិតអស់កល្បជានិច្ច ។

ជាទូទៅ សេចក្តីពិតអំពីសេចក្តីសង្គ្រោះ មានជាអាទិ៍ដូចខាងក្រោមៈ

១. មនុស្សទាំងអស់សុទ្ធតែធ្វើបាប (រ៉ូម ៣:២៣) ។

២. ទោសនៃអំពើបាបរបស់យើង ជាសេចក្តីស្លាប់ (រ៉ូម ៦:២៣) ។

៣. ព្រះយេស៊ូវបានសុគត ដើម្បីសងថ្លៃនៃអំពើបាបរបស់យើង (រ៉ូម ៥:៨) ។

ប៉ុន្តែចំនុចខាងលើនេះ មិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ ត្រូវតែមានការអញ្ជើញឲ្យប្រែចិត្ត និងឲ្យជឿដំណឹងល្អនេះដោយផ្ទាល់ម្នាក់ៗ ។ ការអញ្ជើញមួយ

ដែលព្រះយេស៊ូវបានមានបន្ទូលដោយផ្ទាល់ ច្រើនឆ្នាំកន្លងទៅហើយ នៅក្នុងព្រះគម្ពីរម៉ាថាយ ១១:២៨-៣០ គួរនៅតែត្រូវបានគេឮ ទុកដូចជាទ្រង់កំពុងតែមានបន្ទូលនៅសព្វថ្ងៃនេះដែរ គឺថា "អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឈប់សំរាក ចូរទទួលនឹមខ្ញុំ ហើយរៀននឹងខ្ញុំចុះ ដ្បិតខ្ញុំស្លូត ហើយមានចិត្តសុភាព នោះអ្នករាល់គ្នានឹងបានសេចក្តីសំរាកដល់ព្រលឹង ពីព្រោះនឹមខ្ញុំងាយទេ ហើយបន្ទុកខ្ញុំក៏ស្រាល" ។

ចំពោះអស់អ្នកដែលឆ្លើយតបដោយជំនឿ ចំពោះការត្រាស់ហៅរបស់ដំណឹងល្អ ព្រះសន្យាថា អំពើបាបរបស់ពួកគេនឹងត្រូវបានអត់ទោសឲ្យ ហើយថាពួកគេនឹងមានបទពិសោធន៍ជីវិតអស់កល្បជានិច្ចជាមួយនឹងទ្រង់ផ្ទាល់ ។ "ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះមិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ" (យ៉ូន ៣:១៦) ។ ដូចជាព្រះយេស៊ូវបានមានបន្ទូលនៅក្នុងគម្ពីរយ៉ូហាន ៦:៣៧ រួចមកហើយថា "អ្នកណាដែលមកឯខ្ញុំ ខ្ញុំក៏មិនដែលចោលទៅក្រៅឡើយ" ។

## របៀបទទួលការត្រាស់ហៅ

បន្ទាប់ពីការអញ្ជើញឲ្យឆ្លើយតបចំពោះដំណឹងល្អ ត្រូវបានផ្តល់ឲ្យ ព្រះនឹងនាំឲ្យមានការផ្លាស់ប្រែមួយ នៅក្នុងចិត្តរបស់បុគ្គលម្នាក់នោះជាមិនខាន មុនពេលដែលអ្នកនោះអាចឆ្លើយតបដោយជំនឿ ។ ការផ្លាស់ប្រែនោះ ជា កិច្ចការដ៏អាថ៌កំបាំង

មួយរបស់ព្រះ ដែលទ្រង់ផ្តល់ឲ្យជីវិតថ្មីខាងព្រលឹងវិញ្ញាណរបស់យើង ។ ជួនកាលគេហៅការផ្លាស់ប្រែនោះថា ការកើតជាថ្មី ។ យើងគ្មានតួនាទីធ្វើអ្វីទាំងអស់នៅក្នុងការកើតជាថ្មីនេះ តែវាជាកិច្ចការមួយរបស់ព្រះ ដែលទ្រង់ធ្វើទាំងស្រុងវិញ ។

ការផ្លាស់ប្រែរបស់ចិត្ត ត្រូវបានពិពណ៌នានៅក្នុងគម្ពីរ អេសេគាល ៣៦:២៦ ថា “អញនឹងឲ្យឯងមានចិត្តថ្មី ហើយនឹងដាក់វិញ្ញាណថ្មីនៅក្នុងឯងដែរ អញនឹងដកចិត្តដែលរឹងដូចថ្មពីរូបសាច់ឯងចេញ រួចនឹងឲ្យមានចិត្តជាសាច់វិញ” ។ ព្រឹត្តិការណ៍ដែលកើតឡើងដ៏លឿននេះ បានផ្លាស់ប្រែអ្វីៗគ្រប់យ៉ាង ។ នៅពេលមួយដែលការផ្លាស់ប្រែនេះកើតឡើង អ្នកទទួល “ឈ្មោះថាបានកើតជាថ្មីហើយ អស់ទាំងសេចក្តីចាស់បានកន្លងបាត់ទៅ មើលគ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញ” ( ២ កូរិន ៥:១៧) ។ ទោះបីជាមិនបានដឹងខ្លួនភ្លាមក៏ដោយ ការផ្លាស់ប្រែនេះ មានលទ្ធផលនៅក្នុងចិត្តដែលបានផ្លាស់ប្រែមួយ ដែលនាំទៅរកចរិតលក្ខណៈដែលផ្លាស់ប្រែ រួចបង្កើតឲ្យមានជីវិតដែលផ្លាស់ប្រែមួយ ។ គ្រប់ផ្នែកទាំងអស់នៃជីវិតត្រូវបានផ្លាស់ប្រែទាំងស្រុង ។ បុគ្គលដែលបានកើតជាថ្មីម្នាក់ គួរតែរំពឹងចង់បានសេចក្តីស្រឡាញ់មួយសំរាប់ព្រះ និងរាស្ត្ររបស់ទ្រង់ (ម៉ាថ ២២:៣៧-៤០), ការស្តាប់បង្គាប់ដ៏ស្មោះត្រង់មួយចំពោះសេចក្តីបង្គាប់របស់ទ្រង់ (យ៉ូន ១៤:១៥), ហើយនិងចរិកលក្ខណៈដូចព្រះគ្រីស្ទ ដែលសាវក ប៉ុល ហៅចរិតលក្ខណៈនោះថា ផលផ្លែខាងព្រលឹងវិញ្ញាណ (កា ៥:២២-២៣) ។

## របៀបឆ្លើយតបចំពោះការត្រាស់ហៅ

នៅពេលមួយព្រះបានកោះហៅ តាមរយៈការត្រាស់ហៅដ៏មានប្រសិទ្ធិភាពមួយ ហើយបានបំផ្លាស់បំប្រែចិត្តរបស់បុគ្គលម្នាក់តាមរយៈការកើតជាថ្មី នោះការឆ្លើយតបដ៏ចាំបាច់ គឺជាការប្រែចិត្ត និងសេចក្តីជំនឿ ។ ប៉ុន្តែ ដោយព្រោះ ការត្រាស់ហៅរបស់ដំណឹងល្អ គឺជាការត្រាស់ហៅដោយផ្ទាល់មួយ នោះវាក៏តំរូវឲ្យមានការឆ្លើយតបដោយផ្ទាល់មួយដែរ ។ ការផ្លាស់ប្រែ គឺជាការឆ្លើយតបដ៏ស្ម័គ្រពីចិត្តផ្ទាល់ខ្លួនចំពោះការត្រាស់ហៅរបស់ដំណឹងល្អ ដែលបុគ្គលម្នាក់បានប្រែចិត្តពីអំពើបាបរបស់គាត់ដោយស្មោះត្រង់ ហើយដោយទុកចិត្តព្រះគ្រីស្ទសំរាប់សេចក្តីសង្គ្រោះ ។

ការយល់ដឹង និងការអះអាងពីសេចក្តីពិតនៃសេចក្តីសង្គ្រោះដូចដែលបានចែងក្នុងការត្រាស់ហៅរបស់ដំណឹងល្អខាងលើនេះ មិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ សេចក្តីជំនឿនៃសេចក្តីសង្គ្រោះពិតប្រាកដ ក៏តំរូវឲ្យមានការទុកចិត្តផងដែរ គឺរួមទាំងចំណេះដឹង (ការយល់ដឹងពីសេចក្តីពិតនៃសេចក្តីសង្គ្រោះ) ហើយនិងការគាំទ្រ (ការយល់ព្រមថា សេចក្តីទាំងនោះគឺជាការពិត) ។ ដូច្នេះ អ្នកដែលមានសេចក្តីជំនឿនៃសេចក្តីសង្គ្រោះពិតប្រាកដ បានផ្លាស់ប្តូរពីការស្វែងយល់ពីការប្រកាសរបស់ព្រះយេស៊ូវ មកឯការជឿថា ការប្រកាសទាំងនេះសុទ្ធតែពិតត្រង់ ហើយពីការជឿថា ការប្រកាសទាំងនេះសុទ្ធតែពិត មកឯការទុកចិត្តដល់ព្រះគ្រីស្ទសំរាប់ការអត់ទោសបាប និងជីវិតអស់កល្បជានិច្ចជាមួយនឹងព្រះវិញ ។ ប្រសិនបើខ្ញុំមានសេចក្តីជំនឿនៃសេចក្តីសង្គ្រោះពិត នោះខ្ញុំមិនគ្រាន់តែជឿសេចក្តីពិតអំពីព្រះយេស៊ូវតែប៉ុណ្ណោះទេ តែខ្ញុំទុកចិត្តព្រះយេស៊ូវដោយផ្ទាល់វិញថា ទ្រង់នឹង

សង្គ្រោះខ្ញុំ ។ ព្រះគម្ពីរបានប្រើភាសាខ្លាំងៗធ្ងន់ៗ ដើម្បីពិពណ៌នាពីការទុកចិត្តដោយផ្ទាល់នេះថា យើងមិនគ្រាន់តែត្រូវ “ជឿព្រះយេស៊ូវ” ទេ (មានន័យថា ត្រូវជឿអំពីអ្វីដែលទ្រង់បានមានបន្ទូល ថាជាការពិត) ប៉ុន្តែ យើងត្រូវតែ “ជឿដល់ទ្រង់” ថា “ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ ដើម្បី*ឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ*មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ” (យ៉ូហាន ៣:១៦) (មានន័យថា ត្រូវដាក់សេចក្តីទុកចិត្តផ្ទាល់ក្នុងទ្រង់ ហើយពឹងដល់ទ្រង់) ។

ការទុកចិត្តនេះមានការពាក់ព័ន្ធពីរផ្នែកគឺ ការប្រែចិត្ត និងសេចក្តីជំនឿ ។ សាវក ប៉ុល បានប្រកាសដំណឹងល្អមួយ “ពីការប្រែចិត្តទៅឯព្រះ ហើយ ពីសេចក្តីជំនឿជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើងរាល់គ្នា” (កិច្ច ២០:២១) ។ អ្នកនិពន្ធនៃព្រះគម្ពីរហេព្រើរបាននិយាយថា ធាតុផ្សំពីរដំបូងនៃសេចក្តីបង្រៀនគ្រឹះរបស់គ្រីស្ទានគឺជា “សេចក្តីប្រែចិត្តចេញពីការស្លាប់” និង “សេចក្តីជំនឿជឿដល់ព្រះ” (ហេ ៦:១) ។ ការប្រែចិត្តមានន័យថា ការសំរេចចិត្តដ៏មានមនសិកាមួយដើម្បីបែរចេញពីអំពើបាបរបស់យើង ហើយសេចក្តីជំនឿមានន័យថា ការបែរទៅរកព្រះគ្រីស្ទ ដើម្បីឲ្យទ្រង់បានអត់ទោសអំពើបាបទាំងនោះ ។ សេចក្តីជំនឿប្រភេទនេះ មានន័យថា អ្នកកំពុងតែសារភាពថា អ្នកមិនអាចសង្គ្រោះខ្លួនឯងបានទេ ហើយនៅពេលដំណាលគ្នានោះ អ្នកកំពុងតែជឿថា មានតែព្រះគ្រីស្ទប៉ុណ្ណោះដែលអាចសង្គ្រោះអ្នកបាន ។

ការប្រែចិត្ត និងសេចក្តីជំនឿ គឺជាផ្នែកទាំងពីរសងខាងនៃកាក់តែមួយ ។ ដ្បិតនៅពេលណាដែលខ្ញុំពិតជាលះចោល ហើយបោះបង់ចោលអំពើបាបរបស់ខ្ញុំ នោះខ្ញុំនឹងត្រឡប់ទៅឯព្រះគ្រីស្ទដោយសេចក្តីជំនឿ ហើយទុកចិត្តទ្រង់តែមួយអង្គប៉ុណ្ណោះ សំរាប់សេចក្តីសង្គ្រោះរបស់ខ្ញុំ ។ ហើយការប្រែចិត្ត និងសេចក្តីជំនឿដំបូងនេះ នឹងផ្តល់ជាគំរូមួយសំរាប់ចិត្តគំនិតនៃការប្រែចិត្ត និងសេចក្តីជំនឿដែលនឹងបន្តក្នុងមួយជីវិតរបស់គ្រីស្ទាន ។ ដូចដែលសាវក ប៉ុល បានសរសេរនៅក្នុងព្រះគម្ពីរកូល៉ុស ២:៦ ហើយថា “ដូច្នេះ ដែលអ្នករាល់គ្នាបានទទួលព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់បែបយ៉ាងណា នោះចូរដើរក្នុងទ្រង់តាមបែបយ៉ាងនោះចុះ” ។

## បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១. តើមនុស្សម្នាក់ ក្លាយជាគ្រីស្ទានម្នាក់ដោយរបៀបណា ?

២. តើអ្នកអាចពន្យល់បានទេថា តើការជឿលើព្រះយេស៊ូវដោយពិតប្រាកដមានន័យថាយ៉ាងដូចម្តេច ? តើការប្រែចិត្តពីអំពើបាប មានន័យថាយ៉ាងដូចម្តេច ?

៣. តើតាមរបៀបណាខ្លះ ដែលគ្រីស្ទានអាចផ្តល់ភស្តុតាងពីជំនឿរបស់ពួកគេលើព្រះយេស៊ូវ ?

# ជំពូក ១៩
# អ្វីទៅជាការរាប់ជាសុចរិត និងការរាប់ជាកូនចិញ្ចឹម

សាវក ប៉ុល បានសរសេរនៅក្នុងព្រះគម្ពីររ៉ូម ៨:៣០ ថា ពួកអ្នកដែលព្រះបានត្រាស់ហៅ "នោះទ្រង់ក៏រាប់ទុកជាសុចរិត" ។ យើងបានពិភាក្សាអំពី "ការត្រាស់ហៅ" នៅក្នុងជំពូកមុនរួចមកហើយ ។ នៅក្នុងជំពូកនេះ យើងនឹងពិភាក្សាអំពីអ្វីដែលព្រះនឹងធ្វើ បន្ទាប់ពីទ្រង់បានត្រាស់ហៅអ្នកណាម្នាក់មកយ៉ាងមានប្រសិទ្ធិភាព ហើយនិងបន្ទាប់ពីមនុស្សម្នាក់បានឆ្លើយតបយ៉ាងវិជ្ជមាន ចំពោះការត្រាស់ហៅរបស់ព្រះ ដោយការប្រែចិត្ត និងសេចក្ដីជំនឿនៃសេចក្ដីសង្គ្រោះ ។

## ការរាប់ជាសុចរិត គឺជាការប្រកាសដ៏ស្របច្បាប់មួយ ដោយព្រះជាម្ចាស់

នៅពេលអ្នកណាម្នាក់បានឆ្លើយតបនឹងការត្រាស់ហៅរបស់ព្រះ ដោយការប្រែចិត្ត និងសេចក្ដីជំនឿ ព្រះបានឆ្លើយតបនឹងសេចក្ដីជំនឿនោះ ដោយគិតអំពីអំពើបាបរបស់បុគ្គលនោះ ទុកជាការអត់ទោស ហើយដោយគិតពីសេចក្ដីសុចរិតរបស់ព្រះគ្រីស្ទ ទុកជារបស់ផងអ្នកនោះ ។ ភ្លាមនោះ ព្រះក៏ប្រកាសថា អ្នកនោះបានក្លាយជាសុចរិតនៅចំពោះទ្រង់ហើយ ។ កិច្ចការនៃព្រះនេះ គេហៅថា "ការរាប់ជា

សុចរិត" ។ ការរាប់ជាសុចរិត គឺជាកិច្ចការដ៏ស្របច្បាប់ហើយភ្លាមៗមួយរបស់ព្រះ ដែលទ្រង់ (១) គិតអំពីអំពើបាបរបស់យើង ទុកជាការអត់ទោស ហើយគិតអំពីសេចក្ដីសុចរិតរបស់ព្រះគ្រីស្ទ ទុកជារបស់ផងយើង ហើយទ្រង់ (២)ក៏បានប្រកាសថាយើងរាល់គ្នាត្រឡប់ជា "សុចរិត" នៅចំពោះទ្រង់ហើយ ។

សាវក ប៉ុល បានប្រាប់យ៉ាងច្បាស់ថា ការរាប់ជាសុចរិតនេះបានកើតឡើង *បន្ទាប់ពី*យើងបានឆ្លើយតបនឹងការត្រាស់ហៅរបស់ដំណឹងល្អ ដោយជំនឿ ហើយការរាប់ជាសុចរិតនោះ គឺជាការឆ្លើយតបរបស់ព្រះចំពោះសេចក្ដីជំនឿរបស់យើងរាល់គ្នា ។ នៅក្នុងព្រះគម្ពីររ៉ូម ៣:២៦ សាវក ប៉ុល បានសរសេរថា ព្រះគឺជាអ្នក "រាប់ពួកអ្នកដែលមានសេចក្ដីជំនឿជឿដល់ព្រះយេស៊ូវ ថាជាសុចរិត" ហើយនៅក្នុងគម្ពីររ៉ូម ៥:១ ថា យើង "បានរាប់ជាសុចរិតដោយការជឿ" ។ នៅក្នុងកាឡាទី ២:១៦ គាត់បានសរសេរថា "យើងដឹងថា មនុស្សមិនបានរាប់ជាសុចរិតដោយប្រព្រឹត្តិតាមក្រិត្យវិន័យនោះឡើយ គឺដោយសេចក្ដីជំនឿជឿដល់ព្រះយេស៊ូវគ្រីស្ទវិញ" ។ ខទាំងនេះបានបញ្ជាក់យ៉ាងច្បាស់ថា ការរាប់ជាសុចរិតគឺដោយសារសេចក្ដីជំនឿ ។

(នៅពេលដែល លោក យ៉ាកុប បាននិយាយថា មនុស្សម្នាក់ "បានរាប់ជាសុចរិតដោយសារការប្រព្រឹត្តិ" នៅក្នុងយ៉ាកុប ២:២១, ២៤, និង ២៥ គឺគាត់មិនកំពុងតែជំទាស់នឹងសាវក ប៉ុលនោះទេ ប៉ុន្តែ គាត់កំពុងតែប្រើពាក្យ "រាប់ជាសុចរិត" ក្នុងន័យផ្សេងទៀត មិនមែនសំដៅលើពាក្យថា "រាប់ជាសុចរិតដោយសារព្រះ" នោះទេ ប៉ុន្តែសំដៅពីការ "បង្ហាញពីសេចក្ដីសុចរិតនៅចំពោះមនុស្ស

ដទៃ” វិញ ដូចជាបានបង្ហាញយ៉ាងច្បាស់នៅក្នុងបរិបទនៃព្រះគម្ពីរយ៉ាកុប ២:១៨-២៦ ហើយ ថាវាជាកន្លែងដែលគាត់និយាយពីភស្តុតាងខាងក្រៅ ដែលមនុស្សម្នាក់មានជំនឿ) ។

## សេចក្តីប្រកាសមួយថាយើងសុចរិត នៅចំពោះព្រះ

ការរាប់ជាសុចរិត គឺជាការប្រកាសដ៏ស្របច្បាប់មួយ ដោយព្រះជាម្ចាស់ ។ ព្រះធ្វើជាចៅក្រម ហើយទ្រង់ប្រកាស ពីបុគ្គលណាមួយដែលសុចរិតនៅចំពោះទ្រង់ ។ ប្រសិនបើ ព្រះបានប្រកាសថា អ្នកសុចរិតនៅចំពោះទ្រង់ នោះអ្នកនឹងមិនត្រូវសងថ្លៃទោសសំរាប់អំពើបាបនៅអតីតកាល បច្ចុប្បន្ន និងអនាគតរបស់អ្នកទេ ។ ដូចជាសាវក ប៉ុល បានសរសេរនៅក្នុងព្រះគម្ពីររ៉ូម ៨:១ ថា “នៅជាន់នេះ អ្នកណាដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ នោះគ្មានទោសសោះ” ។ ហើយក្រោយមកនៅក្នុងគម្ពីររ៉ូមដដែល ៨:៣៣ សាវក ប៉ុល បង្ហាញយ៉ាងច្បាស់ថា គ្មានអ្នកណាម្នាក់អាចនាំមកនូវការប្រឆាំង ឬការផ្តន្ទាទោស ដល់រាស្ត្ររើសតាំងរបស់ផងព្រះបានឡើយ ។ អស់អ្នកដែលព្រះបានរាប់ជាសុចរិត សុទ្ធតែមានសេចក្តីអត់ទោសពេញលេញនៃអំពើបាបរបស់ពួកគេ ។

អំពើបាបរបស់ពួកអ្នកដែលត្រូវបានរាប់ជាសុចរិត ត្រូវបានអត់ទោសឲ្យពីព្រោះព្រះបានចាត់ទុកបាបរបស់ពួកគេ ជារបស់ផងព្រះគ្រីស្ទ ហើយព្រះគ្រីស្ទបានសងថ្លៃទោសសំរាប់អំពើបាបនោះរួចរាល់ហើយ ។ ប៉ុន្តែ ព្រះមិនត្រឹមតែចាត់ទុកអំពើបាបទាំងនោះជារបស់ផងព្រះគ្រីស្ទទេ ទ្រង់ថែមទាំងចាត់ទុកសេចក្តី

សុចរិតរបស់ព្រះគ្រីស្ទជារបស់យើងផងដែរ ។ ព្រះគ្រីស្ទបានទទួលទោសដែលយើងទាំងអស់គ្នាសមទទួល យ៉ាងនោះហើយបានជាយើងអាចទទួលបាននូវការទទួលយករបស់ព្រះ ដែលយើងរាល់គ្នាចង់បាន ។ ដូចជាបានចែងនៅក្នុង ២ កូរិនថូស ៥:២១ ថា “ដ្បិតឯព្រះអង្គដែលមិនបានស្គាល់បាបសោះ នោះព្រះទ្រង់បានធ្វើឲ្យត្រឡប់ជាតួបាបជំនួសយើងរាល់គ្នាវិញ ដើម្បីឲ្យយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្តីសុចរិតរបស់ព្រះ ដោយនូវព្រះអង្គនោះឯង” ។ ដោយព្រោះតែការងាររបស់ព្រះគ្រីស្ទក្នុងនាមយើង ហើយតាមរយៈការរាប់ជាសុចរិតរបស់ព្រះ នោះព្រះអាចចាត់ទុកអំពើបាបរបស់យើងជាការអត់ទោសដ៏ពេញលេញ ហើយចាត់ទុកថាយើងអាចឲ្យទ្រង់ទទួលយកបាន ព្រមទាំងទទួលបានសេចក្តីសុចរិតយ៉ាងពេញលេញនៅចំពោះទ្រង់ទៀតផង ។

## ការរាប់ជាសុចរិតដោយសារតែជំនឿប៉ុណ្ណោះ

សាវក ប៉ុល បានពន្យល់ថា មនុស្សត្រូវ “បានរាប់ជាសុចរិត” ដោយសារព្រះគុណរបស់ព្រះ “ដោយពឹងដល់ព្រះគុណទ្រង់ នោះបានរាប់ជាសុចរិតទទេ ដោយសារសេចក្តីប្រោសលោះដ៏ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ” (រ៉ូម ៣:២៤) ។ នៅក្នុងព្រះគម្ពីរអេភេសូរ ២:៨-៩ សាវក ប៉ុល បានបង្ហាញយ៉ាងច្បាស់ នៅ ពេលគាត់បានសរសេរថា “ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ *ដោយសារសេចក្តីជំនឿ*។ ហើយសេចក្តីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយការប្រព្រឹត្តិដែរ ក្រែងអ្នកណាអួតខ្លួន” ។ ការ

រាប់ជាសុចរិតកើតឡើង ជាលទ្ធផលមួយនៃព្រះគុណរបស់ព្រះ (មានន័យថា យើងមិនសមទទួលបានព្រះគុណនោះទេ) ហើយព្រះគុណនោះ គឺជាការឆ្លើយតបរបស់ព្រះចំពោះសេចក្តីជំនឿរបស់យើង (ដែលផ្ទុយពីការពឹងខ្លួនឯង ឬការប្រព្រឹត្តិល្អរបស់យើងរាល់គ្នា) ។

ទោះបីជាការរាប់ជាសុចរិតកើតឡើងជាកិច្ចការរបស់ព្រះ ក្នុងការឆ្លើយតបចំពោះសេចក្តីជំនឿរបស់យើងក៏ដោយ នោះមិនមានន័យថា សេចក្តីជំនឿរបស់យើងមានសេចក្តីល្អណាមួយ នៅចំពោះព្រះនោះទេ ។ មិនមែនជាសេចក្តីជំនឿរបស់យើង ដែលធ្វើឲ្យយើងបានគាប់គួរនៅចំពោះព្រះទេ ។ បទគម្ពីរបានចែងយ៉ាងច្បាស់ថា ការរាប់ជាសុចរិតពឹងលើតែសេចក្តីល្អនៃកិច្ចការរបស់ព្រះគ្រីស្ទប៉ុណ្ណោះ (សូមមើលរ៉ូម ៣:២៩ ខាងលើ) ការរាប់ជាសុចរិតមិនដែលពឹងលើសេចក្តីល្អណាមួយ ដោយសេចក្តីជំនឿរបស់យើងទេ ។ នេះពិតជាដំណឹងដ៏អស្ចារ្យមួយ ពីព្រោះវាមានន័យថា យើងមិនបាច់បង្កើតតំលៃ ឬ បង្កើតការបង់ថ្លៃនៃអំពើបាប សំរាប់ខ្លួនរបស់យើងទេ ។ តាមរយៈព្រះគ្រីស្ទ យើងអាចសំឡឹងមើលទៅឯព្រះ ដើម្បីសូមឲ្យទ្រង់ប្រទាននូវអ្វីដែលយើងដឹងថា យើងមិនអាចផ្តល់ឲ្យខ្លួនឯងបាន ។

គោលលទ្ធិនៃការរាប់ជាសុចរិត គឺជាភាពខុសគ្នាដ៏សំខាន់មួយរវាង ពួកប្រូតេស្តស្តង់ និងពួករ៉ូម៉ាំងកាតូលិក នៅសម័យកែទំរង់ ដែលវាចាប់ផ្តើមដោយ Martin Luther នៅទីក្រុង Wittenberg, ប្រទេសអាឡឺម៉ង់ នៅឆ្នាំ១៥១៧ ។ លោក Luther និងពួកប្រូតេស្តស្តង់ឯទៀតដែលដើរតាមគាត់ បានទាមទារថា

ការរាប់ជាសុចរិត គឺដោយសារតែ "សេចក្តីជំនឿ*តែមួយប៉ុណ្ណោះ*" ក្នុងខណៈដែលពួករ៉ូមម៉ាំងកាតូលិក បានឆ្លើយតបថា ការរាប់ជាសុចរិតគឺដោយសារសេចក្តីជំនឿបូកនឹងការប្រើប្រាស់នៃ "មធ្យោបាយនៃព្រះគុណ" ដែលបានរកឃើញនៅក្នុងពិធីសំខាន់ៗរបស់គ្រីស្ទាន (ដូចជា ពិធីជ្រមុជទឹក, ពិធីលៀងព្រះអម្ចាស់ជាបទពិសោធន៍នៅក្នុងពិធីបុណ្យម៉ាស និងការធ្វើល្អស្តងកំហុស)។ គោលលទ្ធិនៃការរាប់ជាសុចរិតរបស់ពួកប្រូតេស្តស្តង់និយាយថា ព្រះបានរាប់ជាសុចរិតយ៉ាងពេញលេញភ្លាម នៅពេលដែលយើងជឿ ដ្បិត "នៅជាន់នេះ អ្នកណាដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ នោះគ្មានទោសសោះ" (រ៉ូម ៨:១)។ គោលលទ្ធិនៃការរាប់ជាសុចរិតរបស់ពួករ៉ូម៉ាំងកាតូលិកនិយាយថា យើងមិនត្រូវបានរាប់ជាសុចរិតពេញលេញទេ ទាល់តែជីវិតរបស់យើងត្រូវបានសំអាតពីអំពើបាបទាំងស្រុង ដែលការនោះមិនអាចកើតឡើងបាន ទាល់តែបន្ទាប់ពីស្លាប់រួច ហើយយើងនឹងបានជាបរិសុទ្ធ នៅក្នុងកន្លែងរងទុក្ខមួយ (ពួកប្រូតេស្តស្តង់និយាយថា មិនមានកន្លែងយ៉ាងនោះទេ មានតែស្ថានសួគ៌ និងស្ថាននរកប៉ុណ្ណោះ)។ ភាពខុសគ្នារវាងពួកប្រូតេស្តស្តង់ និងពួករ៉ូម៉ាំងកាតូលិក អំពីការរាប់ជាសុចរិតទាំងនេះ នៅតែបន្តរហូតដល់សព្វថ្ងៃនេះ។

## ការទទួលជាកូនចិញ្ចឹម: សមាជិកភាពនៅក្នុងគ្រួសារថ្មីមួយ

ក្រៅពីការរាប់ជាសុចរិត មានអភ័យឯកសិទ្ធិមួយផ្សេងទៀត ដែលប្រទានមកពួកអ្នកដែលសំឡឹងមើលព្រះដើម្បីឲ្យបានសេចក្តីសង្គ្រោះ គឺព្រះធ្វើឲ្យយើងរាល់គ្នា

ក្លាយជាសមាជិកនៃគ្រួសាររបស់ទ្រង់ ។ គេហៅកិច្ចការនៃព្រះនេះថា ការរាប់ជាកូនចិញ្ចឹម ។

នៅក្នុងគម្ពីរយ៉ូហាន ១:១២ បានប្រាប់យើងថា ចំពោះអស់អ្នកដែលទទួលព្រះគ្រីស្ទ គឺពួកអ្នក "ជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាចឲ្យបានត្រឡប់ជាកូនព្រះ" ។ នេះមិនមែនជាអភ័យឯកសិទ្ធិសំរាប់មនុស្សទាំងអស់នោះទេ ។ សាវក ប៉ុល បាននិយាយនៅក្នុងគម្ពីរអេភេសូរ ២:២-៣ ថា អស់អ្នកដែលមិនជឿលើព្រះគ្រីស្ទជាកូននៃសេចក្តី "រឹងចចេស" និងជាកូននៃ "សេចក្តីខ្ញាល់" ។

ដោយព្រោះអ្នកជឿត្រូវបានចាត់ទុកថាជាកូនរបស់ព្រះ នោះយើងមានបទពិសោធន៍នឹងអត្ថប្រយោជន៍ជាច្រើន ពីការរាប់ជាកូនចិញ្ចឹម នៅបច្ចុប្បន្ននេះ ។ ជាកូនរបស់ព្រះ យើងមានអភ័យឯកសិទ្ធិនៃទំនាក់ទំនងដ៏ជិតស្និតមួយជាមួយព្រះដែលយើងអាចហៅទ្រង់ថា ព្រះវរបិតារបស់យើង (រ៉ូម ៨:១៥) ។ យើងមិនបាច់រស់នៅក្នុងជីវិតភ័យខ្លាចដូចជាបាវបំរើនោះទេ ។ តែយើងមានសេរីភាព ក្នុងការទទួលបទពិសោធន៍សេចក្តីអំណារ នៅក្នុងការរស់នៅក្នុងនាមជាអ្នកគ្រងមរតកគ្រប់ទាំងព្រះពរ ដែលព្រះសព្វព្រះហឫទ័យប្រទានដល់កូនៗរបស់ទ្រង់វិញ (រ៉ូម ៨:១៥, ១៧) ។

ពួកយើងដែលព្រះបានរាប់ជាកូនចិញ្ចឹម បច្ចុប្បន្ននេះ មានបទពិសោធន៍នឹងព្រះពរ និងអត្ថប្រយោជន៍ខ្លះក្នុងនាមជាកូនរបស់ទ្រង់ ។ ប៉ុន្តែ យើងនឹងមិនមានបទពិសោធន៍នឹងព្រះពរទាំងនេះពេញលេញនោះទេ ទាល់តែព្រះយេស៊ូវយាង

ត្រឡប់មកវិញទើបបានពេញលេញ ។ ម្យ៉ាង "ឥឡូវនេះយើងរាល់គ្នាជាកូនរបស់ព្រះហើយ" (១ យ៉ូន ៣:២) តែម្យ៉ាងវិញទៀត យើង "ក៏ថ្ងូរក្នុងខ្លួន" រង់ចាំទម្រាំដល់ថ្ងៃដែលយើង នឹងមានបទពិសោធន៍នឹងព្រះពរនៃការរាប់ជាកូនចិញ្ចឹមដ៏ពេញលេញដែរ (រ៉ូម ៨:២៣) ។

នៅចន្លោះពេលនោះ ជីវិតកូនព្រះនឹងត្រូវបានសំគាល់ដោយព្រះពរជាច្រើន ប៉ុន្តែក៏ត្រូវបានសំគាល់ដោយការឈឺចាប់ផងដែរ (រ៉ូម ៨:១៧) ។ ការឈឺចាប់ទាំងនេះ សាវក ប៉ុល បានសន្យាថា "ខ្ញុំរាប់អស់ទាំងសេចក្តីទុក្ខលំបាកនៅជាន់នេះ ថា ជាសេចក្តីមិនគួរប្រៀបផ្ទឹមនឹងសិរីល្អ ដែលបើកសំដែងមកឲ្យយើងរាល់គ្នាឃើញ" នៅពេលដែលព្រះគ្រីស្ទយាងត្រឡប់មកវិញនោះទេ (រ៉ូម ៨:១៨) ។ ថ្ងៃនោះនឹងជាថ្ងៃ ដែលព្រះផ្ទាល់នឹងជូត "អស់ទាំងទឹកភ្នែក" ពីភ្នែករបស់ពួកកូនទ្រង់ ហើយសេចក្តីស្លាប់ សេចក្តីសោកសង្រេង សេចក្តីយំទួញ និងសេចក្តីលំបាក "បានកន្លងបាត់ទៅ" (វិវរ ២១:៤) ។

# បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១.	ការរាប់ជាសុចរិតមានន័យយ៉ាងដូចម្ដេច ?

២.	តើគ្រីស្ទានត្រូវបានរាប់ជាសុចរិតដោយរបៀបណា ?  តើអ្នកពិតជាជឿថាអ្នកត្រូវបានរាប់ជាសុចរិតម្ដងជាសំរេចឬទេ ?

៣.	ប្រសិនបើអ្នកជាគ្រីស្ទានម្នាក់ តើអ្នកមានអារម្មណ៍យ៉ាងណា ដែលអ្នកជាផ្នែកនៃគ្រួសាររបស់ព្រះ ?  ហេតុអ្វីបានជាវាធ្វើឲ្យអ្នកមានអារម្មណ៍បែបនេះ ?  តើអ្នកអាចរៀបរាប់ពីការប្រទានពរជាក់លាក់នានា ដែលមកពីការរាប់ជាកូនចិញ្ចឹមបានដែរឬទេ ?

# ជំពូក ១៥

# តើការញែកចេញជាបរិសុទ្ធ និងសេចក្តីខ្ជាប់ខ្ជួន ជាអ្វី ?

ដូចជាបាននិយាយនៅជំពូក ១៣ រួចមកហើយថា ការផ្លាស់ប្រែ គឺជាការប្រែចិត្តពីអំពើបាបរបស់យើង ហើយទុកចិត្តព្រះសំរាប់សេចក្តីសង្គ្រោះ ។ ការផ្លាស់ប្រែបង្កើតឲ្យមានគំរូនៃការសំរាកក្នុងជីវិតជាគ្រីស្ទាន ។ ការប្រែចិត្ត និងសេចក្តីជំនឿមានលទ្ធផលនៅក្នុងការរាប់ជាសុចរិត ប៉ុន្តែការប្រែចិត្ត និងសេចក្តីជំនឿ ក៏ជួយកិច្ចការមួយទៀតផងដែរ ដែលជួនកាលគេហៅកិច្ចការនោះថា *ការញែកចេញជាបរិសុទ្ធ* ។ ការញែកចេញជាបរិសុទ្ធ គឺជាកិច្ចការកំពុងបន្តមួយរបស់ព្រះ និងមនុស្សដែលធ្វើឲ្យពួកគ្រីស្ទានកាន់តែមានសេរីភាពពីអំពើបាប ហើយកាន់តែដូចព្រះគ្រីស្ទឡើងៗ នៅ ក្នុងជីវិតជាក់ស្តែងរបស់ពួកគេ ។ ព្រះ និងពួកកូនៗរបស់ព្រះសហការណ៍គ្នា ក្នុងតួនាទីផ្សេងគ្នា នៅក្នុងការងារនេះ ។ ទោះបីជាពួកគ្រីស្ទានរំពឹងថា នឹងបានរីកចំរើននៅក្នុងការញែកចេញជាបរិសុទ្ធរបស់ពួកគេក៏ដោយ ប៉ុន្តែពួកគេនឹងមិនដែលទទួលបានសេចក្តីគ្រប់លក្ខណ៍ទេ ទាល់តែព្រះគ្រីស្ទយាងត្រឡប់មកវិញទើបបាន ។

## ការញែកចេញជាបរិសុទ្ធ គឺជាដំណើរការមួយ

ការញែកជាបរិសុទ្ធ ចាប់ផ្ដើមពីចំនុចនៃការកើតជាថ្មី (អំណោយទាននៃជីវិតថ្មីខាងព្រលឹងវិញ្ញាណរបស់ព្រះ) ហើយចំរើនឡើងនៅក្នុងជីវិតទាំងមូល ។ នៅឯចំនុចការកើតជាថ្មី សាវក ប៉ុល បាននិយាយថា ពួកគ្រីស្ទាន "ទ្រង់បានប្រោសឲ្យរួចពីអំពើបាបហើយ" (រ៉ូម ៦:១៨) ហើយពួកគេក៏ត្រូវរាប់ថា "ស្លាប់ខាងអំពើបាប... តែរស់ខាងឯព្រះ... ដោយនូវព្រះគ្រីស្ទយេស៊ូវ... ដ្បិតបាបមិនត្រូវមានអំណាច" លើអ្នករាល់គ្នាទៀតឡើយ (រ៉ូម ៦:១១, ១៤) ។ ការបាក់បែកដំបូងពីអំណាចនៃអំពើបាបនេះ មានន័យថា អំពើបាបមិនគ្រប់គ្រង ឬមានអំណាចលើពួកគ្រីស្ទានទេ ហើយពួកគ្រីស្ទានក៏មិនស្រឡាញ់អំពើបាបទៀតដែរ ។

ប៉ុន្តែ ដោយព្រោះការញែកចេញជាបរិសុទ្ធ ជាដំណើរការមួយ នោះយើងនឹងមិនដែលមានសេរីភាពពីអំពើបាបទាំងស្រុង នៅក្នុងជីវិតនេះទេ ។ ដូចជាគម្ពីរ ១ យ៉ូហាន ១:៨ ចែងថា "បើសិនជាយើងថា យើងគ្មានបាបសោះ នោះឈ្មោះថាយើងបញ្ឆោតដល់ខ្លួន ហើយសេចក្ដីពិតមិនស្ថិតនៅក្នុងយើងទេ" ។ ឬក៏ដូចជានៅក្នុងព្រះគម្ពីរសាស្ដា ៧:២០ ចែងថា "ពិតប្រាកដ ជាគ្មានមនុស្សសុចរិតណានៅផែនដី ដែលប្រព្រឹត្តិសុទ្ធតែល្អឥតធ្វើបាបឡើយនោះទេ" ។ ដោយជ្រាបពីការនេះ ព្រះយេស៊ូវបានបង្គាប់សិស្សរបស់ទ្រង់ឲ្យអធិស្ឋាន (អំពីអ្វីដែលជារបៀបនៃការប្រព្រឹត្តិប្រចាំថ្ងៃ) ថា "សូមអត់ទោសបាបយើងខ្ញុំ" (លូ ១១:៤) ។

ពេលមួយដែលពួកគ្រីស្ទានស្លាប់ ហើយទៅនៅជាមួយនឹងព្រះ ការញែកចេញជាបរិសុទ្ធរបស់ពួកគេ នឹងបានពេញលេញ ពីព្រោះព្រលឹងរបស់ពួកគេត្រូវ

បានញែកពីអំពើបាប ហើយត្រឡប់ជាគ្រប់លក្ខណ៍ ។ អ្នកនិពន្ធព្រះគម្ពីរហេព្រើរបាននិយាយថា នៅ ពេលដែលយើងចូលមកក្នុងវត្តមានរបស់ព្រះដើម្បីគោរពថ្វាយបង្គំ យើងមកឯ "វិញ្ញាណនៃពួកសុចរិតដែលបានគ្រប់លក្ខណ៍ហើយ" (ហេ ១២:២៣) ។ មានតែការនេះប៉ុណ្ណោះដែលសមរម្យ ពីព្រោះវាស្ថិតនៅក្នុងការរំពឹងទុកនៃសេចក្តីពិតដែលថែងថា "គ្មានអ្វីដែលស្មោកគ្រោក ឬអ្នកណាដែលប្រព្រឹត្តិបែបគួរខ្ពើម ឬសេចក្តីកំភូតណា ចូលទៅក្នុងទីក្រុងនោះបានឡើយ" (វិវរ ២១:២៧) ។ ប៉ុន្តែនៅក្នុងន័យមួយទៀត ដោយព្រោះវាពាក់ព័ន្ធនឹងបុគ្គលទាំងមូល (រូបកាយ និងព្រលឹងវិញ្ញាណ) នោះការញែកចេញជាបរិសុទ្ធនឹងមិនពេញលេញទេ ទាល់តែព្រះអម្ចាស់យាងត្រឡប់មកវិញ ហើយទ្រង់បំផ្លាស់បំប្រែ "រូបកាយថោកទាបរបស់យើង ឲ្យត្រឡប់ដូចជារូបអង្គឧត្តមរបស់ទ្រង់" (ភី ៣:២១) ។ បន្ទាប់មក រូបកាយរបស់យើងនឹងបានត្រឡប់ជាគ្រប់លក្ខណ៍ ហើយនឹងមានសេរីភាពពីឥទ្ធិពលនានានៃអំពើបាបដែរ ។

ទោះបីជា យើងនឹងមិនដែលមានសេរីភាពពីអំពើបាបពេញលេញនៅក្នុងជីវិតនេះក៏ដោយ យើងគួរនៅតែរំពឹងមើលការរីកចំរើនដ៏ទៀងទាត់មួយនៅក្នុងការញែកចេញជាបរិសុទ្ធរបស់យើង ។ សាវក ប៉ុល បាននិយាយថា យើង "កំពុងតែផ្លាស់ប្រែទៅ...ពីសិរីល្អទៅឯលស់សិរីល្អ" (២ កូរិន ៣:១៨) ។ គាត់ក៏បាននិយាយផងដែរថា "ខ្ញុំភ្លេចសេចក្តីទាំងប៉ុន្មានដែលកន្លងទៅ ហើយក៏ខំមមុលឈោងទៅសេចក្តីខាងមុខទៀត ទាំងរត់តំរង់ទៅឯទី ដើម្បីឲ្យបានរង្វាន់នៃការងារដ៏ខ្ពស់របស់ព្រះក្នុងព្រះគ្រីស្ទយេស៊ូវ" (ភី ៣:១៣-១៤) ។ នេះគឺជារូបភាពនៃដំណើរការដែល

កំពុងបន្តនៅក្នុងជីវិតមួយ ។ ព្រះគម្ពីរមិនបាននិយាយជាក់លាក់ពីទំហំនៃការរីកចំរើននៅក្នុងការញែកចេញជាបរិសុទ្ធ ដែលយើងគួររំពឹងទុកនៅក្នុងជីវិតនេះទេ ។ ព្រះគម្ពីរ ក៏មិនបានប្រាប់យើងឲ្យចំៗពីការរីកចំរើននោះថានឹងមានលក្ខណៈយ៉ាងដូចម្ដេច ឬអំពើបាបជាក់លាក់ណាខ្លះ ដែលយើងនឹងមិនតស៊ូជាមួយទៀត នោះទេ ។ ជាការពិតណាស់ ជួនកាល យើងនឹងមានបទពិសោធន៍មានសេរីភាពពីអំពើបាបមួយ ហើយតស៊ូដឹស្វិតស្វាញជាមួយនឹងអំពើបាបមួយផ្សេងទៀត ។

ប៉ុន្តែនៅក្នុងការទាំងអស់នេះ ពួកគ្រីស្ទានមិនគួរបោះបង់ការតស៊ូរបស់ពួកគេនោះទេ ។ ពួកគេមិនគួរនិយាយថា អំពើបាបណាមួយបានយកឈ្នះលើពួកគេនោះទេ ។ ពួកគេមិនគួរនិយាយថា ពួកគេមិនអាចផ្លាស់ប្រែបាននោះទេ ។ ប៉ុន្តែនៅក្នុងការតស៊ូ ពួកគេគួរតោងសេចក្ដីសន្យារបស់ព្រះឲ្យជាប់ ដូចជាសេចក្ដីសន្យាមួយដែលនៅក្នុងគម្ពីររ៉ូម ៦:១៤ ថា “ដ្បិតបាបមិនត្រូវមានអំណាចលើអ្នករាល់គ្នាទៀតឡើយ” ។

## តួនាទីរបស់ព្រះនៅក្នុងការញែកចេញជាបរិសុទ្ធ

ការញែកចេញជាបរិសុទ្ធ គឺជាកិច្ចការដ៏ចំបងរបស់ព្រះ ។ សាវក ប៉ុល បានបង្ហាញការនេះ នៅពេលដែលគាត់អធិស្ឋាននៅក្នុង ១ ថែស្សាឡូនីច ៥:២៣ ថា “សូមឲ្យព្រះនៃសេចក្ដីសុខសាន្ត ញែកអ្នករាល់គ្នាចេញជាបរិសុទ្ធសព្វគ្រប់” ។ អ្នកនិពន្ធគម្ពីរហេព្រើរ បានបញ្ជាក់ការនេះថែមទៀត នៅពេលដែលគាត់សរសេរថា “សូមឲ្យ ព្រះនៃសេចក្ដីសុខសាន្ត...ប្រោសអ្នករាល់គ្នាបានគ្រប់លក្ខណ៍ក្នុងការល្អគ្រប់

ជំពូក ដោយសារព្រះលោហិតនៃសញ្ញាដ៏នៅអស់កល្បជានិច្ច ប្រយោជន៍ឲ្យអ្នករាល់គ្នាបានធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះ ដោយទ្រង់ធ្វើការក្នុងអ្នករាល់គ្នា ដែលគាប់ដល់ព្រះហឫទ័យនៃទ្រង់ ដោយសារព្រះយេស៊ូវគ្រីស្ទ សូមឲ្យទ្រង់បានសិរីល្អនៅអស់កល្បជានិច្ចរៀងរាបតទៅ” (ហេ ១៣:២០-២១) ។

ព្រះប្រោសកូនរបស់ទ្រង់ តាមរយៈអំណាចព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ។ ព្រះវិញ្ញាណបរិសុទ្ធ ជា អ្នកធ្វើការនៅក្នុងយើង ដើម្បីបំផ្លាស់បំប្រែ និងញែកយើងចេញជាបរិសុទ្ធ ដើម្បីឲ្យយើងកាន់តែបរិសុទ្ធខ្លាំងឡើងៗនៅក្នុងជីវិតនេះ ។ នោះជាមូលហេតុដែល សាវក ពេត្រុស និយាយពី “ព្រះវិញ្ញាណទ្រង់ញែកជាបរិសុទ្ធ” នៅក្នុង ១ ពេត្រុស ១:២ ហើយក៏ជាមូលហេតុដែលសាវក ប៉ុល និយាយពី “ព្រះវិញ្ញាណទ្រង់ញែកចេញជាបរិសុទ្ធ” នៅក្នុង ២ ថែស្សាឡូនីច ២:១៣ ។ ព្រះវិញ្ញាណបរិសុទ្ធដែលបង្កើត “ផលផ្លែនៃព្រះវិញ្ញាណ” នៅក្នុងយើងរាល់គ្នា (កា ៥:២២-២៣) និង ចរិតលក្ខណៈទាំងឡាយណាដែលជាផ្នែកនៃការញែកចេញជាបរិសុទ្ធកាន់តែខ្លាំងឡើង ។ នៅពេលយើងចំរើនឡើងនៅក្នុងការញែកចេញជាបរិសុទ្ធ យើង “ដើរក្នុងព្រះវិញ្ញាណ” ហើយយើងត្រូវបានដឹកនាំដោយ “វិញ្ញាណ” (កា ៥:១៦-១៨) មានន័យថា យើងកាន់តែឆ្លើយតបច្រើនឡើង ចំពោះបំណងប្រាថ្នា និងការរំលឹកប្រាប់ នៃ ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិត និងចរិតលក្ខណៈរបស់យើង ។ ព្រះវិញ្ញាណបរិសុទ្ធ គឺជាវិញ្ញាណនៃភាពបរិសុទ្ធ ។ ដូច្នេះ ទ្រង់បង្កើតភាពបរិសុទ្ធនៅក្នុងយើងរាល់គ្នា ។

## តួនាទីរបស់យើងនៅក្នុងការញែកចេញជាបរិសុទ្ធ

យើងបានចូលរួមពាក់ព័ន្ធយ៉ាងសកម្ម និងយ៉ាងអសកម្ម នៅក្នុងការញែកចេញជាបរិសុទ្ធ ។ តាមរយៈការប្រែចិត្ត និងសេចក្តីជំនឿ យើងត្រូវថ្វាយខ្លួនរបស់យើង "ទៅព្រះដូចជាបានរស់ពីស្លាប់នោះឡើងវិញ" (រ៉ូម ៦:១៣) ។ នេះហើយដែលជាការចូលរួមយ៉ាងសកម្មរបស់យើង ។ នៅក្នុងគម្ពីររ៉ូម ៨:១៣ បានប្រាប់យើងថា "សំឡាប់អំពើរូបសាច់" (មានន័យថា អំពើបាប) ដែលការនោះបង្ហាញពីតួនាទីដ៏សកម្មមួយនៅក្នុងផ្នែករបស់យើង ។ ទោះបីជា សាវក ប៉ុល បាននិយាយយ៉ាងច្បាស់ថា យើងអាចធ្វើដូច្នេះបាន ដោយសារតែអំណាចនៃ "ព្រះវិញ្ញាណ" ក៏ដោយ (រ៉ូម ៨:១៣) ប៉ុន្តែ យើងត្រូវបានប្រាប់ថា យើងក៏មានតួនាទីដ៏សកម្មមួយដែរ ។

តួនាទីសកម្ម និងអសកម្មដ៏ដែលនេះ ត្រូវបានរកឃើញនៅក្នុងព្រះគម្ពីរភីលីព ២:១២-១៣ ថា "ចូរបង្ហើយសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នា ដោយកោតខ្លាច ហើយញាប់ញ័រចុះ ទុកដូចជាបានស្តាប់បង្គាប់ខ្ញុំជាដរាបរៀងមកដែរ...ដ្បិត គឺជាព្រះហើយដែលបណ្តាលចិត្តអ្នករាល់គ្នា ឲ្យមាន ទាំងចំណង់ចង់ធ្វើ ហើយឲ្យបានប្រព្រឹត្តិតាមបំណងព្រះហឫទ័យទ្រង់ដែរ" ។ ការលើកទឹកចិត្តឲ្យបង្ហើយសេចក្តីសង្គ្រោះរបស់យើង គឺផ្អែកលើសេចក្តីសន្យាដែលព្រះនឹងធ្វើការក្នុងយើង គឺព្រះនឹងប្រទានអំណាចដល់កិច្ចការរបស់យើងជាមិនខាន ! សំរាប់ហេតុផលនេះ អ្នកដែលជឿព្រះយេស៊ូវអាច "ដេញតាម...ឲ្យបានសេចក្តីបរិសុទ្ធដែរ បើអ្នកណាគ្មានសេចក្តីបរិសុទ្ធ នោះមិនដែលឃើញព្រះអម្ចាស់ឡើយ" (ហេ ១២:១៤) ។

ការដែលក្លាយជាគ្រីស្ទានម្នាក់ គឺជាអំណោយមួយពីព្រះដែលតំរូវឲ្យមានការចូលរួមរបស់យើង ហើយសំរាប់ការញែកចេញជាបរិសុទ្ធវិញក៏យ៉ាងដូច្នេះដែរ ។ ការរីកចំរើននៅក្នុងការញែកចេញជាបរិសុទ្ធ គឺជាអំណោយមួយនៃព្រះគុណ ប៉ុន្តែវាគឺជាអំណោយមួយ ដែលយើងអាចរំពឹងថានឹងបានទទួល ។ នៅពេលដែលព្រះសព្វព្រះហឫទ័យនឹងជំនឿគ្រាដំបូងរបស់យើង (ជំនឿដែលទ្រង់បានប្រទានមកយើង) ទ្រង់ក៏សព្វព្រះហឫទ័យនិងកិច្ចការបន្តនៃសេចក្តីជំនឿ និងការស្តាប់បង្គាប់របស់យើងផងដែរ ដូចជាយើងបានឃើញតាមរយៈការអានព្រះគម្ពីរ និងការសញ្ជឹងគិត (ទំនុក ១:២; ម៉ាថ ៤:៤; យ៉ូន ១៧:១៧) ការអធិស្ឋាន (អេ ៦:១៨; ភី ៤:៦) ការថ្វាយបង្គំ (អេ ៥:១៨-២០) ការធ្វើបន្ទាល់ (ម៉ាថ ២៨:១៩-២០) កិច្ចការនៃសេចក្តីមេត្តាករុណា និងសេចក្តីយុត្តិធម៌ (ម៉ាថ ២៣:២៣; យ៉ា ១:២៧) ការប្រកបគ្នារបស់គ្រីស្ទាន (ហេ ១០:២៤-២៥) វិន័យផ្ទាល់ខ្លួន និងការដឹងខ្នាត (កា ៥:២៣; ទីត ១:៨) ។

វាមានសារៈសំខាន់ណាស់ ដែលយើងនៅតែបន្តធំចំរើនឡើង ទាំងនៅក្នុងការទុកចិត្តដ៏អសកម្មដល់ព្រះរបស់យើង ដើម្បីឲ្យទ្រង់បានញែកយើងចេញជាបរិសុទ្ធ ហើយទាំងនៅក្នុងការដេញតាមដ៏សកម្មសំរាប់សេចក្តីបរិសុទ្ធ និងការស្តាប់បង្គាប់នៅក្នុងជីវិតរបស់យើង ។ ប្រសិនបើ យើងធ្វេសប្រហែសក្នុងការខិតខំស្តាប់បង្គាប់ព្រះឲ្យបានសកម្ម នោះយើងនឹងក្លាយជាគ្រីស្ទានកម្ជិល ។ ប្រសិនបើ យើងធ្វេសប្រហែសនឹងតួនាទីអសកម្មនៃការទុកចិត្តព្រះ និងការចុះចូលចំពោះព្រះ នោះយើងនឹងមានអំនួត និងមានទំនុកចិត្តខ្លាំងពេក ចំពោះខ្លួនឯង ។

នៅក្នុងករណីទាំងពីរនេះ ការញែកចេញជាបរិសុទ្ធរបស់យើង នឹងមិនបានគ្រប់គ្រាន់ទេ ។ ហើយប្រសិនបើការញែកចេញជាបរិសុទ្ធរបស់យើង មិនបានគ្រប់គ្រាន់ នោះយើងនឹងមិនមានបទពិសោធន៍នឹងសេចក្តីអំណរ និងសេចក្តីសុខសាន្ត ដែលព្រះបានសន្យាចំពោះយើងទេ (កា ៥:២២, រ៉ូម ១៤:១៧) ។

## បើយើងបញ្ឈប់ដំណើរការការញែកជាបរិសុទ្ធ នោះនឹងទៅជាយ៉ាងណា ?

គ្រីស្ទានពិតប្រាកដទាំងអស់ គួរតែរំពឹងពីការលូតលាស់ធំធំរីកចំរើនឡើងនៅក្នុងការញែកចេញជាបរិសុទ្ធ នៅក្នុងជីវិតរបស់ពួកគេ ។ ប៉ុន្តែ ចុះបើដំណើរការនោះហាក់ដូចជាឈប់ដំណើរការ វានឹងយ៉ាងម៉េចវិញ? ហើយប្រសិនបើវាឈប់ដំណើរការ តើវាមានន័យយ៉ាងដូចម្តេច ? តើវាមានន័យថា ពីមុនយើងជាគ្រីស្ទាន ហើយឥឡូវនេះមិនមែនជាគ្រីស្ទានទៀតឬ ? មានសំនួរមួយដែលជាឫសគល់នៃសំនួរទាំងនេះគឺ៖ តើយើងអាចបាត់បង់ព្រះពរនៃសេចក្តីសង្គ្រោះរបស់យើងបានដែរឬទេ ?

ចំលើយចំពោះសំនួរនេះគឺ ទេ ។ ពួកគ្រីស្ទានទាំងអស់ ពិតជាបានទទួលការថែរក្សាដោយអំណាចព្រះចេស្តារបស់ព្រះ ហើយពួកគេនឹងខ្ជាប់ខ្ជួនជាគ្រីស្ទានរហូតដល់ទីបញ្ចប់នៃជីវិតរបស់ពួកគេ ។ ប៉ុន្តែ តើយើងដឹងថា យើងជាគ្រីស្ទានពិតប្រាកដដោយរបៀបណា ? ចុះវានឹងដូចម្តេច ប្រសិនបើមានអ្នកខ្លះដាច់ចេញពីការអះអាងនៃសេចក្តីជំនឿ ហើយរស់នៅក្នុងជីវិតបះបោរដ៏សកម្មមួយប្រឆាំងនឹងព្រះវិញនោះ ? ចំពោះករណីទាំងអស់នេះ យើងត្រូវតែនិយាយថា មានតែពួកអ្នកដែល

បានខ្ជាប់ខ្ជួនរហូតដល់ទីបញ្ចប់ប៉ុណ្ណោះ ទើបជាគ្រីស្ទានពិតប្រាកដ ។ ជួនកាល គេសំដៅការបង្រៀនដែលមានពីរផ្នែកនេះ (គ្រីស្ទានពិតប្រាកដទាំងអស់នឹងបានខ្ជាប់ខ្ជួន ហើយមានតែពួកអ្នកដែលបានខ្ជាប់ខ្ជួនប៉ុណ្ណោះ ទើបជាគ្រីស្ទានពិត) ថា ជា *សេចក្តីខ្ជាប់ខ្ជួននៃពួកបរិសុទ្ធ* ។

## សេចក្តីសន្យានៃព្រះយេស៊ូវ

ទីមួយ មានភស្តុតាងនៃព្រះគម្ពីរដែលថា គ្រីស្ទានពិតប្រាកដទាំងអស់នឹងបានខ្ជាប់ខ្ជួន ។ នៅក្នុងយ៉ូហាន ៦:៣៨-៤០ ព្រះយេស៊ូវមានបន្ទូលថា “ខ្ញុំបានចុះពីស្ថានសួគ៌មក មិនមែនធ្វើតាមចិត្តខ្ញុំទេ គឺតាមបំណងព្រះហឫទ័យនៃព្រះវិញ ដែលទ្រង់ចាត់ឲ្យខ្ញុំមក ។ ឯបំណងព្រះហឫទ័យនៃព្រះវរបិតាដែលចាត់ឲ្យខ្ញុំមក នោះគឺមិនចង់ឲ្យខ្ញុំបាត់អ្នកណា ក្នុងគ្រប់អស់ទាំងមនុស្ស ដែលទ្រង់ប្រទានមកខ្ញុំ នោះឡើយ គឺទ្រង់ចង់ឲ្យខ្ញុំប្រោសទាំងអស់ឲ្យរស់ឡើងនៅថ្ងៃចុងបំផុតវិញ នេះហើយជាបំណងព្រះហឫទ័យនៃព្រះវរបិតាខ្ញុំ គឺឲ្យអស់អ្នកណាដែលឃើញព្រះរាជបុត្រា ហើយក៏ជឿដល់ទ្រង់ បានជីវិតដ៏នៅអស់កល្បជានិច្ច ហើយខ្ញុំនឹងឲ្យអ្នកនោះរស់ឡើងវិញ នៅថ្ងៃចុងបំផុត” ។

នៅត្រង់នេះ ព្រះយេស៊ូវបានមានបន្ទូលថា អ្នកដែលជឿទ្រង់ នឹងមានជីវិតអស់កល្បជានិច្ច ។ ទ្រង់បានមានបន្ទូលថា ទ្រង់នឹងប្រោសឲ្យអ្នកនោះបានរស់ឡើងវិញ នៅថ្ងៃចុងបំផុត ដោយប្រទានឲ្យអ្នកនោះមានជីវិតអស់កល្បជាមួយទ្រង់ ។ លើសពីនោះទៅទៀត ព្រះយេស៊ូវមានបន្ទូលពីបំណងព្រះហឫទ័យរបស់

ទ្រង់ថា ទ្រង់ “មិនចង់ឲ្យ...បាត់” អ្នកណាក្នុងមនុស្សទាំងអស់ដែលព្រះបានប្រទានមកទ្រង់ឡើយ ។

ព្រះយេស៊ូវបានធ្វើសេចក្តីសន្យាដែលស្រដៀងគ្នានេះ នៅក្នុងព្រះគម្ពីរយ៉ូហាន ១០:២៧-២៩ ថា “ចៀមខ្ញុំទាំងប៉ុន្មានវាស្តាប់ខ្ញុំ ហើយមកតាម ខ្ញុំក៏ស្គាល់វាដែរ ។ ខ្ញុំឲ្យជីវិតអស់កល្បដល់វា វាមិនត្រូវវិនាសនៅអស់កល្បរៀងទៅ ក៏គ្មានអ្នកណាឆក់យកវាពីដៃខ្ញុំបានទេ ។ ព្រះវរបិតានៃខ្ញុំ ដែលប្រទានវាមកខ្ញុំ ទ្រង់ធំលើសជាងទាំងអស់ គ្មានអ្នកណាអាចនឹងឆក់យកវាចេញពីព្រះហស្តរបស់ព្រះវរបិតាខ្ញុំបានឡើយ” ។

នៅក្នុងព្រះគម្ពីរយ៉ូហាន ១០:២៨ ព្រះយេស៊ូវបានមានបន្ទូលចំៗពីការពីរយ៉ាង អំពីអ្នកដើរតាមទ្រង់ ។ ទីមួយ ទ្រង់បានមានបន្ទូលថា “គ្មានអ្នកណាឆក់យកវាពីដៃខ្ញុំបានទេ” ។ ទីពីរ ទ្រង់បានមានបន្ទូលថា “វានឹងមិនត្រូវវិនាស” ។ យកឃ្លាទាំងនេះដាក់បញ្ចូលគ្នា នោះ វានឹងបង្កើតជាសេចក្តីសន្យាដ៏អស្ចារ្យមួយដែលថា អ្នកណាដែលព្រះយេស៊ូវប្រទានជីវិតអស់កល្បឲ្យ នឹងមិនដែលបាត់ជីវិតនោះទេ ។

ទាំងនេះគ្រាន់តែជាសេចក្តីសន្យាពីរ ដែលព្រះយេស៊ូវបានប្រទានមក អំពីសេចក្តីខ្ជាប់ខ្ជួនរបស់ពួកបរិសុទ្ធប៉ុណ្ណោះ ។ បទទាំងពីរនេះ ហាក់ដូចជានិយាយយ៉ាងច្បាស់ថា ព្រះយេស៊ូវបានជ្រាបថា ពួកអ្នកដែលបានទទួលជីវិតអស់កល្បជានិច្ចពីទ្រង់ នឹងរក្សាជីវិតដ៏អស់កល្បនោះជារៀងរហូតទៅ ។

## សេចក្តីសន្យានៃព្រះវិញ្ញាណបរិសុទ្ធ

មានភស្តុតាងច្រើនជាងនេះទៀតគឺថា ព្រះរក្សាពួកគ្រីស្ទានឲ្យមានសុវត្ថិភាពជារៀងរហូត គឺជាត្រាដែលដៅចំណាំលើយើងរាល់គ្នា ។ ត្រានោះគឺជាព្រះវិញ្ញាណបរិសុទ្ធដែលនៅក្នុងយើង ។ នៅក្នុងព្រះគម្ពីរអេភេសូរ ១:១៣-១៤ សាវក ប៉ុល បានសរសេរថា នៅពេលដំបូងដែលយើងបានជឿព្រះយេស៊ូវ យើងត្រូវបាន "ដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធ ដែលបានសន្យា ។ ព្រះវិញ្ញាណនោះទ្រង់ជាទីបញ្ចាំចិត្តពីដំណើរកេរ្តិ៍អាកររបស់យើងរាល់គ្នាទាល់តែបានលោះរបស់កំណាន់ ដែលទ្រង់បានទិញទុកឲ្យយើងនោះ សំរាប់ជាសេចក្តីសរសើរដល់សិរីល្អនៃទ្រង់" ។ កេរ្តិ៍អាករដែលព្រះបានសន្យា ក៏រួមបញ្ចូលទាំងព្រះពរនៃជីវិតអស់កល្បជានិច្ច និងរង្វាន់ដ៏ធំមួយ នៅក្នុងនគរស្ថានសួគ៌ជាមួយទ្រង់ ផងដែរ ។ ត្រា ឬការធានានៃសេចក្តីសន្យានោះ គឺជាព្រះវត្តមានរបស់ព្រះ ដែលជាព្រះវិញ្ញាណបរិសុទ្ធនៅក្នុងគ្រីស្ទានគ្រប់រូប ។

## សេចក្តីសន្យានៅក្នុងសេចក្តីខ្ជាប់ខ្ជួន

ពួកអ្នកដែលជាពួកគ្រីស្ទានពិតប្រាកដ នឹងខ្ជាប់ខ្ជួនដល់ទីបញ្ចប់ ហើយមានតែពួកអ្នកដែលខ្ជាប់ខ្ជួនដល់ទីបញ្ចប់ប៉ុណ្ណោះ ទើបជាគ្រីស្ទានពិតប្រាកដ ។ នៅក្នុងព្រះគម្ពីរយ៉ូហាន ៨:៣១ ព្រះយេស៊ូវមានបន្ទូលថា "បើអ្នករាល់គ្នានៅជាប់ក្នុងពាក្យខ្ញុំនោះអ្នករាល់គ្នាជាសិស្សខ្ញុំមែន" ។ មានន័យថា ភស្តុតាងមួយនៃសេចក្តីជំនឿដ៏ពិត

គឺជាការដែលនៅតែបន្តជឿ និងស្តាប់បង្គាប់នូវអ្វីដែលព្រះយេស៊ូវបានមានបន្ទូល និងបានបង្គាប់មក ។

នៅក្នុងព្រះគម្ពីរកូល៉ុស ១:២២-២៣ សាវក ប៉ុល បានសរសេរទៅកាន់ពួកគ្រីស្ទានដែលនៅទីនោះថា ព្រះគ្រីស្ទបានផ្សះផ្សាពួកគេជាមួយនឹងព្រះ “ដើម្បីថ្វាយអ្នករាល់គ្នាជាជង្វាយបរិសុទ្ធ ឥតសៅហ្មង ហើយឥតកន្លែងបន្ទោសបាន នៅចំពោះទ្រង់ នោះគឺបើតិចណាស់ អ្នករាល់គ្នាបានតាំងនៅជាប់លាប់ហើយមាំមួនក្នុងសេចក្តីជំនឿដែរ ឥតងាកបែរចេញពីសេចក្តីសង្ឃឹមរបស់ដំណឹងល្អដែលអ្នករាល់គ្នាបានឮ” ។ សាវក ប៉ុល បានដាក់លក្ខខ័ណ្ឌនៃសេចក្តីខ្ជាប់ខ្ជួនមួយនៅក្នុងសេចក្តីសន្យា ដែលគាត់កំពុងតែផ្តល់មក ដោយគាត់មិនចង់ឲ្យសេចក្តីខ្ជាប់ខ្ជួនក្លែងក្លាយ ដល់ពួកអ្នកដែលមិនមែនជាពួកគ្រីស្ទានពិតប្រាកដ ។ ដោយនិយាយថា “តាំងនៅជាប់លាប់ហើយមាំមួនក្នុងសេចក្តីជំនឿ” សាវក ប៉ុល មិនកំពុងតែព្យាយាមគំរាមកំហែង ឬបន្លាចពួកអ្នកជឿពិតប្រាកដនោះទេ តែគាត់កំពុងតែនិយាយថា ពួកអ្នកដែលមិនជឿពិតប្រាកដ នឹងដាច់ចេញពីសេចក្តីជំនឿដែលពួកគេប្រកាសថាខ្លួនមាន នៅទីបំផុតវិញ ។

សេចក្តីសន្យានៅក្នុងសេចក្តីខ្ជាប់ខ្ជួន គឺថា អ្នកណានៅតែបន្តសេចក្តីជំនឿរហូតដល់ទីបំផុតនៃជីវិតរបស់ពួកគេ ទើបជាគ្រីស្ទានពិតប្រាកដ ។ ដូចជាយើងបាននិយាយខាងដើមរួចមកហើយ នេះមិនមានន័យថា មនុស្សទាំងអស់នេះរស់នៅក្នុងជីវិតដ៏គ្រប់លក្ខណ៍នោះទេ ។ គ្រីស្ទានពិតប្រាកដអាចនឹងមានការតស៊ូដ៏ជ្រាលជ្រៅជាមួយអំពើបាប នៅពេលផ្សេងៗក្នុងជីវិតរបស់ពួកគេ ។ ប៉ុន្តែ អ្វីដែល

វាចង់សំដៅ គឺថា ការតស៊ូទាំងនោះនឹងជាការងឺលំបាកណាស់ ។ គ្រីស្ទានពិតប្រាកដ នឹងប្រយុទ្ធនឹងអំពើបាប តាមរយៈការប្រែចិត្ត និងសេចក្តីជំនឿ ។ សេចក្តីសន្យានៅក្នុងសេចក្តីខ្ជាប់ខ្ជួនបំរើជាការរំលឹកដាស់តឿនមួយ ចំពោះអ្នកដែលមិនមែនជាគ្រីស្ទានពិតប្រាកដ ពីព្រោះវាផ្តល់ហេតុផលឲ្យពួកគេជឿថា បើពួកគេបានដាច់ចេញពីសេចក្តីជំនឿ វា នឹងជាសញ្ញាមួយដែលថា ពួកគេមិនដែលជាគ្រីស្ទានពិតប្រាកដតាំងពីដំបូងមកម្ល៉េះ ។

## ការដឹងប្រាកដនៃសេចក្តីខ្ជាប់ខ្ជួន

អ្នកនិពន្ធព្រះគម្ពីរហេព្រើរប្រាប់ផ្លូវមួយដល់យើង ដើម្បីឲ្យដឹងថា សេចក្តីជំនឿរបស់យើងនៅក្នុងព្រះគ្រីស្ទគឺពិតប្រាកដដោយសារការកាន់ "ខ្ជាប់តាមសេចក្តីជំនឿដើមដរាបដល់ចុងបំផុតមែន" (ហេ ៣:១៤) ។ ប៉ុន្តែប្រសិនបើយើង*គ្រាន់តែ*មានទំនុកចិត្តថា សេចក្តីជំនឿរបស់យើងនឹងបានពិតប្រាកដរហូតមកដល់ចុងបញ្ចប់នៃជីវិត នោះយើងមានសេចក្តីសង្ឃឹមតិចតួចសំរាប់បច្ចុប្បន្ននេះវិញ ។ យើងអាចនឹងតែងតែឆ្ងល់ថា ប្រហែលជាយើងអាចនឹងដាច់ចេញនៅទីបញ្ចប់នៃជីវិតរបស់យើង ហើយប្រហែលជា យើងពិតជាមិនបានសង្គ្រោះយ៉ាងពិតប្រាកដទេមើលទៅ ។ ការព្រួយបារម្ភបែបនេះ នឹងមិនស្របជាមួយនឹងរបៀបដែលព្រះគម្ពីរសញ្ញាចាស់បង្ហាញឲ្យឃើញពីការដឹងប្រាកដរបស់យើងទេ ។

ជាការពិតណាស់ គ្រីស្ទានពិតប្រាកដអាចទទួលបានការដឹងប្រាកដច្បាស់នៃសេចក្តីសង្គ្រោះដ៏ពិត ពីកត្តាផ្សេងៗ ហើយជាពិសេស ពីការទុកចិត្តលើព្រះគ្រីស្ទ

នៅបច្ចុប្បន្ននេះ ហើយនិងកិច្ចការដែលទ្រង់កំពុងធ្វើនៅក្នុងជីវិតរបស់ពួកគេ ។ ការទុកចិត្តលើព្រះគ្រីស្ទនាពេលបច្ចុប្បន្នរបស់យើងសំរាប់សេចក្តីសង្គ្រោះ គឺ ជាការដឹងប្រាកដច្បាស់មួយនៃការផ្លាស់ប្រែដ៏ពិត ។ នេះគឺជាការបង្រៀននៃខគម្ពីរដ៏ល្បីបំផុត នៅក្នុងព្រះគម្ពីរ៖ "ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ ដើម្បីឲ្យ*អ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ*មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ" (យ៉ូន ៣:១៦) ។ ប្រសិនបើអ្នកជឿទ្រង់ នោះអ្នកមានជីវិតអស់កល្បជានិច្ច ។ ប្រសិនបើអ្នករាល់គ្នាមាន ទំនុកចិត្តលើកិច្ចការរបស់ព្រះគ្រីស្ទក្នុងនាមអ្នករាល់គ្នា, ទំនុកចិត្តលើសមត្ថភាពទទួលទោសរបស់ព្រះគ្រីស្ទសំរាប់អំពើបាបរបស់យើង និង ទំនុកចិត្តដែលព្រះគ្រីស្ទគួរអនុញ្ញាតឲ្យអ្នកចូលទៅក្នុងនគរស្ថានសួគ៌ ដោយពឹងលើកិច្ចការរបស់ទ្រង់ដែលមិនមែនជាកិច្ចការរបស់អ្នករាល់គ្នា ហើយប្រសិនបើ ទំនុកចិត្តនោះនៅតែមាននៅក្នុងជីវិតរបស់អ្នកសព្វថ្ងៃនេះនៅឡើយ នោះមានន័យថា ទំនុកចិត្តនោះ គឺជាការដឹងប្រាកដច្បាស់នៃសេចក្តីជំនឿពិតរបស់អ្នកហើយ ។

ប៉ុន្តែ ការទុកចិត្តលើព្រះគ្រីស្ទសំរាប់សេចក្តីសង្គ្រោះ មិនមែនជាការតែម្យ៉ាងដែលផ្តល់នូវការដឹងប្រាកដច្បាស់នោះទេ ។ ភស្តុតាងនៃកិច្ចការកំពុងបន្តរបស់ព្រះដែលនៅក្នុងជីវិតរបស់អ្នក ក៏ផ្តល់នូវការដឹងប្រាកដច្បាស់ផងដែរ ។ កិច្ចការដែលកំពុងតែបន្តនេះ នឹងរួមបញ្ចូលទាំងទីបន្ទាល់របស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងចិត្តរបស់អ្នកផង ដែលទីបន្ទាល់នោះ ឲ្យយើងបានដឹងថា អ្នកជាមនុស្សម្នាក់នៃកូនរបស់ព្រះ (១ យ៉ូន ៤:១៣) ។ កិច្ចការដែលកំពុងតែបន្តនោះ នឹងរួម

បញ្ចូលទាំងកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ ដែលនាំឲ្យអ្នកស្ដាប់បង្គាប់តាមបំណងព្រះហឫទ័យរបស់ព្រះ (រ៉ូម ៨:១៤)។ ហើយវានឹងបង្ហាញតាមរយៈជីវិតមួយនៃ "សេចក្ដីស្រឡាញ់ អំណរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ហើយដឹងខ្នាត" (កា ៥:២២-២៣)។ ខណៈពេលដែលការទាំងនេះមិនតែងតែជាភស្ដុតាងគ្រប់លក្ខណ៍ នោះការស្ទាបស្ទង់នៃជីវិតរបស់អ្នក គួរបង្ហាញពីភស្ដុតាងនៃការការរីកចំរើនក្នុងផ្នែកទាំងអស់នេះ។ លើសពីនោះទៀត គួរតែមានភស្ដុតាងនៃទំនាក់ទំនងឥតដាច់មួយជាមួយនឹងព្រះយេស៊ូវគ្រីស្ទ។ ដ្បិត "អ្នកណាដែលថាបានស្គាល់ទ្រង់ តែ មិនកាន់តាមបញ្ញត្តិទ្រង់ទេ អ្នកនោះឈ្មោះថាជាអ្នកកុហក ហើយសេចក្ដីពិតមិននៅក្នុងអ្នកនោះឡើយ តែអស់អ្នកណាដែលកាន់តាមព្រះបន្ទូលទ្រង់វិញ នោះប្រាកដជាសេចក្ដីស្រឡាញ់នៃព្រះបានពេញខ្នាត នៅ ក្នុងអ្នកនោះហើយ គឺដោយសេចក្ដីនោះឯង ដែលយើងដឹងថា យើងនៅក្នុងទ្រង់ អ្នកណាដែលថាខ្លួននៅក្នុងទ្រង់ នោះត្រូវតែប្រព្រឹត្តិដូចជាទ្រង់ដែរ" (១ យ៉ូន ២:៤-៦)។ ជីវិតគ្រប់លក្ខណ៍មួយ គឺមិនចាំបាច់នោះទេ ប៉ុន្តែជីវិតនៃគ្រីស្ទានពិតប្រាកដ នឹងនៅតែបន្តបង្ហាញ ជាគំរូទូទៅមួយនៃការស្ដាប់បង្គាប់ចំពោះការបង្គាប់របស់ព្រះគ្រីស្ទ និងការត្រាប់តាមពីព្រះជន្មរបស់ទ្រង់។

កិច្ចការដែលកំពុងបន្តរបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងយើងនេះ នឹងត្រូវបានគេឃើញនៅកំឡុងពេលក្នុងជីវិតរបស់យើង។ មានន័យថា គ្រីស្ទានពិតប្រាកដ នឹងធំចំរើនឡើងនៅក្នុងការញែកចេញជាបរិសុទ្ធរបស់ពួកគេ។ សាវ័កពេត្រុស បានប្រាប់យើងពីរបៀបមួយ "ដើម្បីនឹងធ្វើឲ្យដំណើរដែលទ្រង់ហៅ

ហើយរើសតាំងអ្នករាល់គ្នា បានពិតប្រាកដ” (២ ពេ ១:១០) គឺត្រូវបង្កើនគុណតំលៃ ចំណេះដឹង ការដឹងខ្នាត សេចក្តីខ្ជាប់ខ្ជួន ការកោតខ្លាចព្រះ ការចេះស្រឡាញ់គ្នាជាបងប្អូន ហើយនិងសេចក្តីស្រឡាញ់ (២ ពេ ១:៥-៨) ។ សាវក ពេត្រុស បាននិយាយថា ប្រសិនបើគុណតំលៃទាំងនេះ បានរីកចំរើនឡើងនៅក្នុងជីវិតរបស់យើង នោះយើង “មិនដែលជំពប់ឡើយ” (២ ពេ ១:១០) ។ ប្រសិនបើអ្នកដឹងពីការខ្វះខាតនៃគុណតំលៃទាំងនេះ នោះអ្នកមិនត្រូវព្យាយាមធ្វើម្តងទៀតនៅក្នុងជីវិតអ្នក ដើម្បីធ្វើឲ្យការដឹងប្រាកដច្បាស់របស់អ្នករឹតតែខ្លាំងឡើងនោះឡើយ ។ ប៉ុន្តែជំនួសមកវិញ អ្នកត្រូវប្រែចិត្តពីការខ្វះខាតទាំងនោះនៅក្នុងជីវិតរបស់អ្នក ហើយសូមឲ្យព្រះប្រទានការរីកចំរើននៃផ្នែកទាំងអស់នោះវិញ ។

## ការខ្ជាប់ខ្ជួន តាមរយៈដំណើរការនៃការញែកចេញជាបរិសុទ្ធ

ការញែកចេញជាបរិសុទ្ធ គឺជាដំណើរការមួយពេញមួយជីវិត ។ ប្រសិនបើយើងជាអ្នកជឿព្រះគ្រីស្ទម្នាក់ នោះ ជួនកាលវានឹងបាក់ដូចជា ដំណើរការនេះកំពុងតែដើរលឿនជាង ដែលអ្នកធ្លាប់គិត ។ នៅពេលនោះ អ្នកនឹងត្រូវការការការពារប្រឆាំងនឹងសេចក្តីអំនួត និងសេចក្តីសុចរិតផ្ទាល់ខ្លួន (ការដែលគិតថា ខ្លួនជាអ្នកប្រសើរជាងគេ ហើយយកមុខមាត់សំរាប់ជាសេចក្តីល្អរបស់អ្នក តែតាមពិតការទាំងនោះជាអំណោយទានមួយនៃព្រះគុណវិញទេ) ។

នៅពេលខ្លះទៀត អ្នកនឹងឆ្ងល់ថា តើនឹងមានជីវិតណាមួយនៅក្នុងអ្នកដែរឬទេ ។ នៅពេលនោះ អ្នកនឹងអាចងឿងឆ្ងល់ថា តើអ្នកជាគ្រីស្ទានពិតប្រាកដដែរឬ

ទេ ។ នៅពេលដែលការសង្ស័យទាំងនេះបានចាប់ផ្តើមមាននៅពាសពេញក្នុងគំនិតរបស់អ្នក នោះសូមអ្នកបានអធិស្ឋាននូវសេចក្តីអធិស្ឋាន ដែលបានរកឃើញនៅក្នុងព្រះគម្ពីរម៉ាកុស ៩:២៤ ថា “ខ្ញុំជឿហើយលោកម្ចាស់អើយ សូមជួយចំពោះសេចក្តីណាដែលខ្ញុំមិនជឿផង !” ។

ហើយនៅក្នុងចំណោមការទាំងអស់នេះ ចូរកាន់ឲ្យជាប់ចំពោះសេចក្តីសន្យាដែលថា ដោយសារ “ព្រះចេស្តានៃព្រះ” អ្នក “កំពុងតែថែរក្សា ដោយសារសេចក្តីជំនឿសំរាប់ឲ្យបានសេចក្តីសង្គ្រោះ ដែលប្រុងប្រៀបនឹងសំដែងមកនៅជាន់ក្រោយបង្អស់នោះ” (១ ពេ ១:៥) ។ ហើយចូរទុកចិត្តលើព្រះបន្ទូលរបស់ព្រះយេស៊ូវដែលថា “នេះហើយជាបំណងព្រះហឫទ័យនៃព្រះវរបិតាខ្ញុំ គឺឲ្យអស់អ្នកណាដែលឃើញព្រះរាជបុត្រា ហើយក៏ជឿដល់ទ្រង់ បានជីវិតដ៏នៅអស់កល្បជានិច្ច ហើយខ្ញុំនឹងឲ្យអ្នកនោះរស់ឡើងវិញ នៅថ្ងៃចុងបំផុត” (យ៉ូន ៦:៤០) ។

# បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១.	តើការញែកចេញជាបរិសុទ្ធ ខុសពីការរាប់ជាសុចរិតដោយរបៀបណា ?

២.	តើអ្វីទៅជាតួនាទីរបស់យើង នៅក្នុងការញែកចេញជាបរិសុទ្ធ ? តើអ្វីទៅជាតួនាទីរបស់ព្រះ នៅក្នុងការញែកចេញជាបរិសុទ្ធ ? តើរបៀបពិសេសអ្វីខ្លះ ដែលអ្នកអាចជួយកាន់តែច្រើនឡើង ចំពោះការញែកចេញជាបរិសុទ្ធរបស់អ្នកនៅក្នុងសប្តាហ៍ក្រោយ ?

៣.	ចូររៀបរាប់ពីបទគម្ពីរខ្លះ ដែលគាំទ្រដល់គោលលទ្ធិនៃសេចក្តីខ្ជាប់ខ្ជួន ។ នៅពេលដែលអ្នកឆ្លុះបញ្ចាំងពីបទគម្ពីរទាំងនោះ តើពួកវាធ្វើឲ្យអ្នកមានអារម្មណ៍យ៉ាងដូចម្តេច ? ហេតុអ្វីបានជាពួកវាធ្វើឲ្យអ្នកមានអារម្មណ៍បែបនោះ ?

# ជំពូក ១៦

# តើសេចក្ដីស្លាប់ជាអ្វី ?

ដូចជាបាននិយាយនៅជំពូកមុនរួចមកហើយ សេចក្ដីស្លាប់នាំមកនូវការបញ្ចប់ផ្នែកមួយនៃការញែកចេញជាបរិសុទ្ធរបស់គ្រីស្ទាន ។ នៅពេលស្លាប់ ព្រលឹងវិញ្ញាណរបស់គ្រីស្ទានត្រឡប់ជាគ្រប់លក្ខណ៍ភ្លាម ហើយចូលទៅក្នុងវត្តមានរបស់ព្រះ ។ ប៉ុន្តែ វា មិនរហូតទាល់តែព្រះគ្រីស្ទយាងត្រឡប់មកវិញ ទើបគ្រីស្ទានទទួលបទពិសោធន៍ភាពគ្រប់លក្ខណ៍ពេញលេញសំរាប់រូបកាយ និងព្រលឹងវិញ្ញាណនោះទេ ដ្បិតនៅពេលនោះ រូបកាយរបស់ពួកគេ នឹងត្រូវបានរស់ឡើងវិញ ហើយក៏ត្រឡប់ជាគ្រប់លក្ខណ៍ដែរ ។ នៅក្នុងជំពូកនេះ យើងនឹងសង្កេតមើលពីអ្វីដែលកើតឡើងនៅឯព្រឹត្តិការណ៍ទាំងពីរនោះ និងអ្វីដែលកើតឡើងនៅចន្លោះពេលស្លាប់ និងពេលដែលព្រះគ្រីស្ទយាងត្រឡប់មកវិញ ។

## ហេតុអ្វីបានជាគ្រីស្ទានស្លាប់ ?

សេចក្ដីស្លាប់មិនមែនជាទណ្ឌកម្មមួយសំរាប់គ្រីស្ទាននោះទេ ។ ដូចជាយើងបានបង្ហាញយ៉ាងច្បាស់នៅបួនជំពូកមុនរួចមកហើយថា “អ្នកណាដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ នោះគ្មានទោសសោះ” (រ៉ូម ៨:១) ។ ទោសទាំងអស់របស់គ្រីស្ទាន ត្រូវបានសងដោយព្រះគ្រីស្ទយេស៊ូវរួចហើយ ។

ប៉ុន្តែនៅក្នុងប្រាជ្ញាញាណរបស់ទ្រង់ ព្រះបានសំរេចព្រះហឫទ័យដ៏ប្រសើរបំផុត ដែលគ្រីស្ទានមិនទទួលបទពិសោធន៍នឹងអត្ថប្រយោជន៍ទាំងអស់នៃសេចក្តីសង្គ្រោះក្នុងពេលតែមួយ ។ ឧទាហរណ៍៖ គ្រីស្ទាននៅតែធ្វើបាប នៅតែមានជំងឺ នៅតែឈឺចាប់ពីគ្រោះធម្មជាតិ ហើយទទួលការប៉ះពាល់ដោយសកម្មភាពនៃការអាក្រក់និងភាពអយុត្តិធម៌ ។ ហើយគ្រីស្ទាននៅតែស្លាប់ ។ ទាំងអស់នេះសុទ្ធតែជាលទ្ធផលនៃការរស់នៅក្នុងលោកិយមួយដែលមិនសូវត្រឹមត្រូវ ជា លោកិយមួយដែលមិនមានសេរីភាពពេញលេញពីបណ្តាសានៃអំពើបាប ។

សាវក ប៉ុល ប្រាប់យើងថា ទោះជាព្រះគ្រីស្ទបានយកឈ្នះលើសេចក្តីស្លាប់ នៅ ពេលដែលទ្រង់មានព្រះជន្មរស់ឡើងវិញហើយក៏ដោយ ប៉ុន្តែ សេចក្តីស្លាប់ នៅតែជាលទ្ធផលចុងក្រោយនៃអំពើបាបដែលត្រូវយកចេញពីលោកិយដ៏ដុនដាបនេះ ព្រោះ គ្រីស្ទត្រូវ “បានសោយរាជ្យ ទាល់តែដាក់អស់ទាំងខ្មាំងសត្រូវនៅក្រោមព្រះបាទទ្រង់ ។ឯខ្មាំងសត្រូវក្រោយបង្អស់ដែលត្រូវបំផ្លាញ គឺជាសេចក្តីស្លាប់” (១ កូរិន ១៥:២៥-២៦) ។

ព្រះប្រើបទពិសោធន៍នៃសេចក្តីស្លាប់ ដើម្បីបញ្ចប់ការញែកចេញជាបរិសុទ្ធរបស់យើង ។ ព្រះប្រើសេចក្តីស្លាប់ជាមធ្យោបាយមួយ ធ្វើឲ្យយើងកាន់តែមានលក្ខណៈដូចព្រះគ្រីស្ទឡើង ។ ជាការពិតណាស់ នៅ ក្នុងជីវិតរបស់គ្រីស្ទានជាទូទៅវាមិនចំឡែកទេ ដែលព្រះប្រើប្រាស់សេចក្តីលំបាក និងការឈឺចាប់ ដើម្បីនាំមកនូវសេចក្តីល្អនោះ ។ សាវក ប៉ុល ប្រាប់យើងនៅក្នុងគម្ពីររ៉ូម ៨:២៨ ថា “យើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នាសំរាប់សេចក្តីល្អដល់ពួកអ្នកដែលស្រឡាញ់

ព្រះ គឺដល់ពួកអ្នកដែលទ្រង់ហៅមកតាមព្រះដំរិះទ្រង់” ។ ជាញឹកញាប់ ការឈឺចាប់ និងសេចក្តីលំបាក ជា លទ្ធផលនៃការវាយផ្ចាលកូនរបស់ទ្រង់ “ដ្បិតព្រះអម្ចាស់ទ្រង់ផ្ចាញ់ផ្ចាល ចំពោះអស់អ្នកណាដែលទ្រង់ស្រឡាញ់...ទ្រង់វាយផ្ចាលនោះសំរាប់ជាប្រយោជន៍ដល់យើងវិញ ដើម្បីឲ្យយើងបានសេចក្តីបរិសុទ្ធរបស់ទ្រង់ កាលណាយើងត្រូវសេចក្តីផ្ចាញ់ផ្ចាល នោះមើលទៅដូចជាព្រួយណាស់ មិនមែនសប្បាយទេ តែក្រោយមក នោះទើបបង្កើតផលដ៏សុខសាន្តនៃសេចក្តីសុចរិតដល់អ្នកណាដែលត្រូវរងទ្រាំនោះវិញ” (ហេ ១២:៦, ១០-១១) ។

មិនមែនការវាយផ្ចាលទាំងអស់សុទ្ធតែបំរើដើម្បីកែតំរូវយើង នៅពេលដែលយើងធ្វើខុសនោះទេ ។ ជាញឹកញាប់ ការវាយផ្ចាលរបស់ព្រះនៅក្នុងជីវិតរបស់យើង គឺជាផ្លូវមួយនៃការចំរើនកំលាំងដល់យើង ។ វាគឺជាមធ្យោបាយមួយនៃការញែកចេញជាបរិសុទ្ធ ។ ទោះបីព្រះយេស៊ូវមិនដែលធ្វើបាបក៏ដោយ ទ្រង់នៅតែ “រៀនស្តាប់បង្គាប់ ដោយសារការដែលទ្រង់រងទុក្ខលំបាកទាំងប៉ុន្មាននោះដែរ” (ហេ ៥:៨) ហើយទ្រង់ “បានគ្រប់លក្ខណ៍ដោយរងទុក្ខលំបាក” (ហេ ២:១០) ។ នៅពេលដែលទ្រង់បានធំចំរើនឡើងពីវ័យកុមារទៅជាវ័យមនុស្សធំ ហើយនៅតែបន្តចំរើនឡើងតាមរយៈព្រះជន្មរបស់ទ្រង់នៅលើផែនដី ។ កិច្ចការនៃការស្តាប់បង្គាប់ចំពោះព្រះរបស់ទ្រង់ កាន់តែមានការលំបាកឡើងៗ ហើយរាប់បញ្ចូលទាំងការរងទុក្ខទៀតផង ។ តាមរយៈការទាំងអស់នេះ ព្រះយេស៊ូវកាន់តែមានកំលាំងឡើង ដើម្បីការស្តាប់បង្គាប់ព្រះ ។

ដោយព្រះធ្វើការ សូម្បីតែតាមរយៈបទពិសោធន៍នៃសេចក្តីស្លាប់របស់យើង ដើម្បីបង្កើយការញែកចេញជាបរិសុទ្ធរបស់យើង ការថែរក្សាជីវិតរបស់យើង ហើយសេចក្តីកំសាន្តទូទៅ គឺមិនមែនជាគោលដៅខ្ពស់បំផុតរបស់យើងទេ ។ ការស្តាប់បង្គាប់ចំពោះព្រះ និងសេចក្តីស្មោះត្រង់នៅគ្រប់កាលៈទេសៈ គឺមានសារៈសំខាន់ជាង ។ មូលហេតុនេះហើយបានជាសាវក ប៉ុល អាចប្រាប់ពួកចាស់ទុំនៅក្រុងអេភេសូរថា "ខ្ញុំក៏មិនរាប់ជីវិតនេះទុកជារបស់វិសេសដល់ខ្ញុំដែរ ឲ្យតែខ្ញុំបានបង្ហើយការរត់ប្រណាំងរបស់ខ្ញុំដោយអំណរចុះ ព្រមទាំងការងារដែលខ្ញុំបានទទួល អំពីព្រះអម្ចាស់យេស៊ូវ គឺឲ្យខ្ញុំបានធ្វើបន្ទាល់សព្វគ្រប់ ពីដំណឹងល្អនៃព្រះគុណវិញ" (កិច្ច ២០:២៤) ។

ទោះបីជា ព្រះប្រើប្រាស់សេចក្តីលំបាកមួយដូចជាសេចក្តីស្លាប់សំរាប់ជាមធ្យោបាយវិជ្ជមានមួយក៏ដោយ ប៉ុន្តែវាមានសារៈសំខាន់ណាស់ដែលចងចាំថា សេចក្តីស្លាប់មិនមែន "តាមធម្មជាតិ" ទេ គឺដូចជាមនុស្សគ្មានព្រះបន្ទូលព្រះបានគិតជាញឹកញាប់អញ្ចឹង ។ រីឯជំងឺ និងការអាក្រក់ឬសេចក្តីអយុត្តិធម៌ ក៏មិនមែនជាធម្មជាតិដែរ ។ ការទាំងអស់នេះមិនត្រឹមត្រូវតាមសភាពដើម ហើយពួកវាមិនគួរនឹងមាននៅក្នុងផែនដីរបស់ព្រះទេ ។ ទោះជាយើងរស់នៅជាមួយនឹងសេចក្តីទាំងអស់នេះនៅពេលបច្ចុប្បន្នក៏ដោយ តែ ថ្ងៃមួយសេចក្តីទាំងអស់នេះ សូម្បីតែសេចក្តីស្លាប់ផងដែរ នឹងត្រូវបានបំផ្លាញនៅចុងបញ្ចប់ជាមិនខាន ។ (១ កូរិន ១៥:២៤-២៦) ។

## នៅពេលគ្រីស្ទានស្លាប់

ប្រសិនបើយើងជាអ្នកជឿដល់ព្រះយេស៊ូវម្នាក់ នោះព្រះគម្ពីរបានលើកទឹកចិត្តដល់អ្នកថា មិនឲ្យមើលទៅកាន់សេចក្តីស្លាប់របស់អ្នកផ្ទាល់ដោយសេចក្តីភ័យខ្លាចនោះទេ ។ ព្រះយេស៊ូវបានសុគតដើម្បី “ប្រោសដល់ពួកអ្នកនោះ ដែលជាប់ជាបាវបំរើគ្រប់មួយជីវិត ដោយខ្លាចស្លាប់ឲ្យបានរួចចេញវិញ” (ហេ ២:១៥) ។ ជំនួសមកវិញអ្នកត្រូវមើលមកឯសេចក្តីស្លាប់ផ្ទាល់ខ្លួនរបស់អ្នកដោយសេចក្តីអំណរវិញ ដោយដឹងថា បន្ទាប់ពីសេចក្តីស្លាប់នេះទៅ អ្នកនឹងនៅជាមួយព្រះគ្រីស្ទ ។ សាវក ប៉ុលបានបង្ហាញពីការយល់ដឹងយ៉ាងច្បាស់មួយនៃការនេះនៅក្នុង ២ កូរិនថូស ៥:៨ នៅពេលដែលគាត់បានសរសេរថា “យើងខ្ញុំមានចិត្តជឿជាក់ ហើយក៏សុខចិត្តស៊ូចេញពីរូបកាយនេះ ទៅនៅជាមួយនឹងព្រះអម្ចាស់ជាជាង” ។ គាត់ក៏បានសរសេរស្រដៀងគ្នានេះដែរ នៅក្នុងព្រះគម្ពីរភីលីព ១:២៣ ថា “ខ្ញុំមានសេចក្តីបណ្តាលទាំងសងខាង ក៏មានចិត្តចង់ចេញទៅនៅជាមួយនឹងព្រះគ្រីស្ទ ដែលល្អជាជាងនោះផង” ។

ប្រសិនបើអ្នកខ្លាចសេចក្តីស្លាប់ ហើយមិនជឿពាក្យរបស់សាវកប៉ុលទេ នោះអ្នកគួរលន់តួការនោះចំពោះព្រះអម្ចាស់ ដែលវាអាចនឹងមានប្រយោជន៍សំរាប់អ្នក ។ ដោយសូមទ្រង់បង្កើនការយល់ដឹងរបស់យើងអំពីអ្វីដែលនឹងកើតឡើងនៅពេលដែលអ្នកស្លាប់ ព្រមទាំងសូមទ្រង់បង្កើនសេចក្តីជំនឿនៅក្នុងសេចក្តីល្អរបស់ទ្រង់ ។

នៅពេលដែលគ្រីស្ទានស្លាប់ វិញ្ញាណរបស់ពួកគេចូលទៅក្នុងព្រះវត្តមានរបស់ព្រះភ្លាម ។ ទោះបីជារូបកាយរបស់ពួកគេនៅក្នុងដីក៏ដោយ តែវិញ្ញាណរបស់ពួកគេ ចូលទៅក្នុងព្រះវត្តមាននៃព្រះអាទិកររបស់ពួកគេ ។ មូលហេតុនេះហើយបានជាសាវក ប៉ុល សរសេរពីស្ថានភាពជីវិត ដែលចេញពីរូបកាយ តាមរយៈសេចក្តីស្លាប់ (២ កូរិន ៥:៨) ហើយចេញពីសេចក្តីស្លាប់ទៅនៅជាមួយព្រះគ្រីស្ទ (ភី ១:២៣) ។ ដោយព្រោះព្រលឹងវិញ្ញាណនៃពួកគ្រីស្ទានមានសេចក្តីអំណរដ៏អស់កល្ប នៅក្នុងព្រះវត្តមាននៃព្រះ នោះមិនត្រូវឲ្យអធិស្ឋានសំរាប់មនុស្សដែលបានស្លាប់ឡើយ ។ (នេះគឺជាផ្នែកមួយ ដែលពួករ៉ូម៉ាំងកាតូលិក ប្រកាន់ទស្សនៈផ្សេងមួយទៅវិញ ដោយព្រោះតែគេជឿថា គ្រីស្ទានដែលបានស្លាប់ទៅ បានទៅឯកន្លែងរងទុក្ខ ហើយសេចក្តីអធិស្ឋានរបស់យើងអាចជួយពួកគេឲ្យចេញពីកន្លែងរងទុក្ខនោះបានឆាប់ជាង) ។

ទោះបីជាយើងដឹងថា ព្រលឹងវិញ្ញាណរបស់ពួកអ្នកជឿបានមានសេចក្តីអំណរដ៏អស់កល្ប នៅក្នុងព្រះវត្តមានរបស់ព្រះក៏ដោយ វា នៅតែត្រឹមត្រូវដែលយើងមានអារម្មណ៍សោកសង្រេងចំពោះបងប្អូន ឬសាច់ញាតិគ្រីស្ទានម្នាក់ដែលបានស្លាប់ ។ នៅពេលដែលសាវក ស្ទេផាន ត្រូវបានគេចោលនឹងដុំថ្ម “មនុស្សខ្លះដែលកោតខ្លាចដល់ព្រះ បាននាំយកទៅកប់ ព្រមទាំងយំសោកនឹងគាត់ជាខ្លាំង” (កិច្ច ៨:២) ។ ព្រះយេស៊ូវផ្ទាល់ បានព្រះកន្សែងនៅឯផ្នូររបស់មិត្តភ័ក្តិរបស់ទ្រង់ម្នាក់ឈ្មោះឡាសារ (យ៉ូន ១១:៣៥) ដោយព្រោះតែ សេចក្តីសោកសង្រេងដែលមិត្តរបស់ទ្រង់បានស្លាប់ផង និងដោយព្រោះតែ សេចក្តីសោកសង្រេងសំរាប់

អស់អ្នកដែលនឹងបានទទួលបទពិសោធន៍ការឈឺចាប់នៃសេចក្តីស្លាប់ រហូតដល់ការយាងត្រឡប់មកវិញរបស់ទ្រង់ ។

ប៉ុន្តែ សេចក្តីទុក្ខសោកចំពោះសេចក្តីស្លាប់របស់គ្រីស្ទានម្នាក់ មិនមែនជាសេចក្តីទុក្ខសោកដែលអស់សង្ឃឹមមួយនោះទេ ព្រោះយើងដឹងថា អ្នកជឿម្នាក់បានទៅនៅជាមួយនឹងព្រះអម្ចាស់ហើយ ។ សាវក ប៉ុល បានសរសេរនៅក្នុង ១ ថែស្សាឡូនីច ៤:១៣ ថា កុំឲ្យយើង "កើតទុក្ខព្រួយ ដូចជាអ្នកឯទៀតដែលគ្មានសង្ឃឹម" ។

## នៅពេលដែលអ្នកមិនជឿស្លាប់ទៅ

នៅពេលមនុស្សដែលបានបដិសេធពីការប្រកាសពីព្រះគ្រីស្ទ បានស្លាប់ទៅ នោះព្រលឹងរបស់ពួកគេនឹងទៅឯទណ្ឌកម្មដ៏នៅអស់កល្បជានិច្ចភ្លាម ។ ប៉ុន្តែ រូបកាយរបស់ពួកគេនៅក្នុងដី រហូតទាល់ដល់ការយាងមករបស់ព្រះគ្រីស្ទ ជា ពេលដែលរូបកាយទាំងនោះ នឹងចូលមករួមជាមួយនឹងវិញ្ញាណរបស់ពួកគេវិញ សំរាប់ថ្ងៃជំនុំជំរះចុងក្រោយ (សូមមើល ម៉ាថ ២៥:៣១-៤៦; យ៉ូន ៥:២៨-២៩; កិច្ច ២៤:១៥ ហើយនិង វិវរ ២០:១២) ។ ព្រះគម្ពីរមិនដែលលើកទឹកចិត្តយើងថា មនុស្សនឹងមានឱកាសទីពីរដើម្បីទុកចិត្តដល់ព្រះគ្រីស្ទបន្ទាប់ពីស្លាប់ហើយនោះទេ ។ ជាការពិតណាស់ ស្ថានភាពនេះគឺពិតជាការផ្ទុយគ្នាស្រឡះវិញ ដូចដែលបានបង្ហាញនៅក្នុងព្រះបន្ទូលប្រៀបប្រដូចនៃរឿងបុរសអ្នកមាន និងឡាសារ (សូមមើល លូក ១៦:២៤-២៦) ហើយនិងនៅក្នុងសេចក្តីថ្លែងការណ៍ទូទៅនានា អំពីសេចក្តីស្លាប់

និងការជំនុំជំរះ (សូមមើល ហេ ៩:២៧ ថា “ដោយព្រោះបានដំរូវ ត្រូវឲ្យមនុស្ស ទាំងអស់ស្លាប់មួយដង រួចសឹមជាប់សេចក្ដីជំនុំជំរះ”) ។

ដូច្នេះ សេចក្ដីទុក្ខសោកនៅពេលអ្នកដែលបដិសេធព្រះគ្រីស្ទម្នាក់បាន ស្លាប់ គឺមិនមែនជាសេចក្ដីទុក្ខសោកមួយដែលប្រកបទៅដោយសេចក្ដីសង្ឃឹមនោះ ទេ ។ សាវក ប៉ុល បានគិតអំពីពួកជនរួមជាតិយូដាខ្លះដែលបានបដិសេធព្រះគ្រីស្ទ ថា “ខ្ញុំមានសេចក្ដីទុក្ខសោកជាខ្លាំង និងសេចក្ដីព្រួយលំបាកក្នុងចិត្តជានិច្ច” (រ៉ូម ៩:២) ។ ទោះជាយ៉ាងណាក៏ដោយ ជា ញឹកញាប់យើងមិនមានភាពប្រាកដច្បាស់ ពេញលេញថា មិត្តម្នាក់ ឬអ្នកជាទីស្រឡាញ់ម្នាក់ នៅ តែបន្តបដិសេធព្រះគ្រីស្ទ រហូតដល់ទីបញ្ចប់នោះទេ ។ ចំណេះដឹងនៃសេចក្ដីស្លាប់ដែលទំនងនឹងកើតឡើង ឆាប់ៗ អាចនឹងនាំមកនូវ ចិត្តនៃការស្វែងរកដ៏ពិតប្រាកដ ហើយមនុស្សម្នាក់អាច នឹងមកឯការប្រែចិត្ត និងសេចក្ដីជំនឿដ៏ពិត ។ នៅក្នុងករណីខ្លះ យើងមិនបានដឹង ទេ ។ ប៉ុន្តែ បន្ទាប់ពីអ្នកដែលមិនមែនជាគ្រីស្ទានម្នាក់បានស្លាប់ទៅ វាអាចនឹងខុស ដែលប្រាប់អ្នកដទៃទៀតថា យើងគិតថាបុគ្គលនោះបានទៅស្ថានសួគ៌ហើយ ហើយ ការនេះអាចនឹងកាត់បន្ថយការយល់ដឹងពីការសំខាន់ដែលត្រូវដោះស្រាយ សំរាប់ពួកអ្នកដែលកំពុងរស់នៅដើម្បីទុកចិត្តដល់ព្រះគ្រីស្ទ ។ នៅពេល អ្នកដែល មិនមែនជាគ្រីស្ទានម្នាក់បានស្លាប់ទៅ ជា ញឹកញាប់វាមានប្រយោជន៍ ដែល និយាយពីអំណរគុណដ៏ស្មោះត្រង់ អំពីគុណប្រយោជន៍ដែលយើងបានកត់សំគាល់ ឃើញនៅក្នុងជីវិតនៃបុគ្គលនោះ ដូចជាស្ដេច ដាវីឌ បានធ្វើនៅពេលដែលគាត់ដឹង ថា ស្ដេច សូល បានស្លាប់ (២ សាំ ១:១៩-២៥) ។

## តើនៅពេលណាពួកគ្រីស្ទានរស់ពីស្លាប់ឡើងវិញ ?

ម្តងទៀត ប្រសិនបើអ្នកជាអ្នកជឿព្រះយេស៊ូវម្នាក់ នៅពេលអ្នកស្លាប់ទៅ រូបកាយរបស់អ្នកនឹងនៅក្នុងដី ហើយព្រលឹងរបស់អ្នកនឹងទៅឯព្រះវត្តមានរបស់ព្រះភ្លាម ។ ហើយនៅយ៉ាងដូច្នេះ ទាល់តែព្រះគ្រីស្ទយាងត្រឡប់មក ។ យើងរង់ចាំ "សេចក្តីប្រោសលោះដល់រូបកាយយើងផង ដ្បិតយើងបានសង្គ្រោះរួច ដោយសេចក្តីសង្ឃឹម" (រ៉ូម ៨:២៣-២៤) ។ សាវក ប៉ុល បាននិយាយថា ពេលនោះនឹងជាថ្ងៃ ដែលយើងរាល់គ្នា "បានដំកើងឡើងជាមួយ" ព្រះគ្រីស្ទ (រ៉ូម ៨:១៧) ។

ចំពោះគ្រីស្ទានដែលបានស្លាប់ហើយ ថ្ងៃដែលព្រះគ្រីស្ទយាងមក នឹងជាជំហានចុងក្រោយ នៅក្នុងការប្រើប្រាស់ជាប្រយោជន៏នៃសេចក្តីប្រោសលោះ ។ នៅថ្ងៃនោះរូបកាយថ្មីដ៏គ្រប់លក្ខណ៍របស់ពួកគេ នឹងរួមមកជាមួយនឹងព្រលឹងរបស់ពួកគេវិញ ។ ព្រះគ្រីស្ទគឺជាមនុស្សដំបូងដែលមានព្រះជន្មរស់ពីស្លាប់ជាមួយនឹងរូបកាយរស់ឡើងវិញបែបនោះ ប៉ុន្តែ សាវក ប៉ុល បាននិយាយថា "កាលដែលទ្រង់យាងមក" ពួកអ្នកជឿនឹងត្រូវបានប្រោសឲ្យរស់ឡើងវិញតាមរបៀបនេះដែរ (១ កូរិន ១៥:២២-២៣) ។ រីឯពួកគ្រីស្ទានដែលនៅមានជីវិតនៅពេលព្រះគ្រីស្ទយាងមក រូបកាយដ៏មិនគ្រប់លក្ខណ៍របស់ពួកគេ នឹងត្រូវបានផ្លាស់ប្តូរទៅជារូបកាយដ៏គ្រប់លក្ខណ៍ភ្លាម ។ សាវក ប៉ុល បាននិយាយថា "យើងទាំងអស់គ្នានឹងមិនដេកលក់ទៅទេ [មានន័យថា ស្លាប់] តែទាំងអស់គ្នានឹងបានផ្លាស់ប្រែទៅ ក្នុងមួយរំពេចវិញ គឺក្នុងមួយប៉ប្រិចភ្នែកប៉ុណ្ណោះ ក្នុងកាលដែលឮសូរត្រែក្រោយបង្អស់ ដ្បិតត្រែនឹងឮឡើងមែន នោះពួកស្លាប់នឹងរស់ឡើងវិញ មិនពុករលួយទៀតឡើយ

រួចយើងរាល់គ្នានឹងបានផ្លាស់ប្រែទៅ” (១ កូរិន ១៥:៥១-៥២) ។ ដូច្នេះ ពួកអ្នកជឿព្រះយេស៊ូវទាំងអស់ នឹងបានទទួលរូបកាយដែលរស់ឡើងវិញហើយកែជាថ្មីមួយដូចដែលព្រះអង្គសង្គ្រោះរបស់ពួកគេបានទទួលដែរ (១ កូរិន ១៥:២០, ២៣, ៤៩; ភី ៣:២១) ។ ដំណើរការនេះត្រូវគេបានហៅថា “ការដំកើងឡើង” ពីព្រោះរូបកាយរបស់ពួកគេទទួលបានសិរីល្អនៃស្ថានសួគ៌ថ្មីមួយ ។

រូបកាយថ្មីទាំងនេះ នឹង “មិនពុករលួយ” (១ កូរិន ១៥:៥២) មានន័យថាពួកគេនឹងមិនចេះអស់កំលាំង មិនចេះចាស់ ឬមានជំងឺទេ ។ ពួកគេនឹងមិនមានបង្ហាញសញ្ញាណាមួយនៃការវិវឌ្ឍន៍ទៅជាវ័យចាស់ទេ ប៉ុន្តែជំនួសមកវិញ ពួកគេនឹងមានសុខភាពល្អ និងមានកំលាំងខ្លាំងក្លាជាដរាបរហូតទៅ ។ រូបកាយថ្មីគឺជាអ្វីដែលព្រះបានរៀបចំឡើងតាំងពីដើមដំបូងឲ្យបានជារូបកាយ ដ៏មានសោភ័ណភាព និងភាពទាក់ទាញជាងអ្វីៗដែលយើងអាចស្រមើស្រមៃនៅក្នុងសម័យនេះ ឆ្ងាយណាស់ ។ ពួកអ្នកដែលបានរស់ឡើងវិញជាមួយព្រះគ្រីស្ទ នឹងរស់នៅជារៀងរហូតក្នុងរូបកាយដែលមានគ្រប់គុណលក្ខណៈដ៏ល្អបំផុត ដែលព្រះបានបង្កើតយើងមកដើម្បីឲ្យមានរូបកាយនោះ ។ រូបកាយទាំងនោះនឹងជាភស្តុតាងដ៏រស់រហូតនៃប្រាជ្ញាញាណរបស់ព្រះក្នុងការបង្កើត គឺជាការបង្កើតមួយដែលទ្រង់បានហៅថា “ការល្អប្រពៃ” (លោក ១:៣១) ។

# បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១. ហេតុអ្វីបានជាគ្រីស្ទានស្លាប់ ? តើការនោះប៉ះពាល់ដល់របៀបដែលអ្នកគិតអំពីសេចក្ដីស្លាប់របស់អ្នកនៅពេលអនាគត ដោយរបៀបណា ?

២. តើអ្វីនឹងកើតឡើងចំពោះរូបកាយ និងព្រលឹងរបស់ពួកគ្រីស្ទាន នៅ ពេលដែលពួកគេស្លាប់ទៅ ? តើការនេះធ្វើឲ្យអ្នកមានអារម្មណ៍យ៉ាងដូចម្ដេច ? ហេតុអ្វីបានជាវាធ្វើឲ្យអ្នកមានអារម្មណ៍បែបនេះ ?

៣. តើអ្វីនឹងកើតឡើងចំពោះរូបកាយរបស់ពួកគ្រីស្ទាន នៅ ពេលដែលព្រះយេស៊ូវយាងត្រឡប់មកផែនដីវិញ ? តើផ្នែកពិសេសអ្វីខ្លះនៃរូបកាយដែលរស់ឡើងវិញរបស់យើង ដែលអ្នកសង្ឃឹមទុកជាពិសេស ?

# ជំពូក ១៧

# តើពួកជំនុំជាអ្វី ?

ពួកជំនុំ គឺជាសហគមន៍នៃពួកអ្នកជឿទាំងអស់គ្រប់ពេលវេលា ។ មានន័យថា ពួកជំនុំ ត្រូវបានបង្កើតឡើងពីពួកបុរស និងស្ត្រីដែលជាអ្នកជឿលើព្រះយេស៊ូវពិតប្រាកដ ។ នៅពេលដែលសាវក ប៉ុល បានសរសេរនៅក្នុងគម្ពីរអេភេសូរ ៥:២៥ ថា “ព្រះគ្រីស្ទបានស្រឡាញ់ដល់ពួកជំនុំ ហើយបានប្រគល់ព្រះអង្គជំនួសផង” គាត់កំពុងតែនិយាយសំដៅលើ ពួកអ្នកដែលព្រះគ្រីស្ទបានសុគតដើម្បីប្រោសលោះ ។ គាត់មិនគ្រាន់តែចង់សំដៅលើ ពួកអ្នកដែលមានជីវិតរស់នៅក្រោយពេលដែលព្រះគ្រីស្ទបានសុគតនោះទេ ប៉ុន្តែក៏សំដៅលើពួកដែលសំឡឹងមើលទៅឯព្រះសំរាប់សេចក្តីសង្គ្រោះ នៅសម័យមុនពេលដែលព្រះគ្រីស្ទបានយាងមកផែនដីនេះផងដែរ ។ ដោយមិនគិតពីសម័យកាលរស់នៅ អ្នកជឿទាំងអស់បង្កើតបានជាពួកជំនុំ ។

ព្រះយេស៊ូវបានមានបន្ទូលថា ទ្រង់នឹងបង្កើតពួកជំនុំរបស់ទ្រង់ (ម៉ាថ ១៦:១៨) ដោយការហៅរាស្ត្ររបស់ទ្រង់មកឯទ្រង់ ។ គំរូនៃការបង្កើតពួកជំនុំនេះ គឺជាការបន្តមួយនៃដំណើរការបង្កើតពួកជំនុំ តាំងពីមុនពេលព្រះគ្រីស្ទយាងមកផែនដីទៅទៀត ដ្បិតនៅក្នុងសម័យសញ្ញាចាស់ ព្រះនៅតែបានបន្តការត្រាស់ហៅរាស្ត្ររបស់ទ្រង់មកឯទ្រង់ ដើម្បីធ្វើជាក្រុមប្រជុំសំរាប់ការថ្វាយបង្គំមួយនៅចំពោះ

ទ្រង់ ។ ប្រជាជននៃសាសន៍អ៊ីស្រាអែលទាំងមូលនៅក្នុងសម័យសញ្ញាចាស់ គឺត្រូវប្រជុំគ្នា ដើម្បីថ្វាយបង្គំព្រះ ដូច្នេះគ្រីស្ទាននៅសម័យបច្ចុប្បន្ននេះ ក៏ត្រូវបានត្រាស់ហៅឲ្យធ្វើយ៉ាងដូច្នេះដែរ ។

## ពួកជំនុំដ៏មើលពុំឃើញ តែជាពួកជំនុំដ៏មើលឃើញវិញ

ដោយព្រោះ យើងមិនអាចមើលឃើញស្ថានភាពខាងព្រលឹងវិញ្ញាណនៃចិត្តរបស់មនុស្សបាន នោះពួកជំនុំពិតប្រាកដ គឺមិនត្រូវបានមើលឃើញ នៅក្នុងភាពពិតខាងព្រលឹងវិញ្ញាណ ដែលជាការប្រកបនៃអ្នកជឿពិតប្រាកដនោះទេ ។ មានតែព្រះប៉ុណ្ណោះដែលអាចមើលឃើញស្ថានភាពនៃចិត្តរបស់មនុស្សបាន ។ ដូចជាសាវ័កប៉ុល បាននិយាយនៅក្នុង ២ ធីម៉ូថេ ២:១៩ ថា “ព្រះអម្ចាស់ទ្រង់ស្គាល់អស់អ្នកដែលជារបស់ផងទ្រង់” ។ ដូច្នេះ “ពួកជំនុំដ៏មើលពុំឃើញ” គឺជាពួកជំនុំ ដែលព្រះទតឃើញ ។

ប៉ុន្តែពួកជំនុំនេះក៏គេអាចមើលឃើញផងដែរ ។ ពួកជំនុំដ៏មើលពុំឃើញ គឺជាពួកជំនុំដែលព្រះទតឃើញ រីឯ “ពួកជំនុំដ៏មើលឃើញ” គឺជាពួកជំនុំ ដែលពួកគ្រីស្ទាននៅលើផែនដីនេះមើលឃើញ ។ ដូច្នេះ ពួកជំនុំដ៏មើលឃើញ នឹងមានអ្នកជឿពិតប្រាកដ និងអ្នកមិនជឿ ឬធ្វើតាមការប្រកាសរបស់ព្រះយេស៊ូវពិតប្រាកដ ។ ប៉ុន្តែក្នុងការញែកភាពផ្សេងគ្នានេះ យើងមិនគួរមានការសង្ស័យច្រើនពេក អំពីស្ថានភាពនៃពួកអ្នកដែលហាក់ដូចជាអ្នកជឿពិតប្រាកដនោះទេ ។ ជំនួសមកវិញដោយសុភវិនិច្ឆ័យដ៏សប្បុរស យើងគួរចាត់ទុកពួកគេទាំងអស់គ្នាជាសមាជិកនៃ

ពួកជំនុំសាកល ដែលហាក់ដូចជាអ្នកជឿ ដោយសារការអះអាងនៃសេចក្តីជំនឿរបស់ពួកគេ និងគំរូនៃជីវិតរបស់ពួកគេ ។

## ការពិពណ៌នាផ្សេងៗនៃពួកជំនុំ

នៅក្នុងសញ្ញាថ្មី ពាក្យថា “ពួកជំនុំ” ត្រូវបានគេប្រើដើម្បីពិពណ៌នាពីប្រភេទផ្សេងៗនៃក្រុមអ្នកជឿ ដូចជា៖ ពួកជំនុំដែលប្រជុំនៅតាមផ្ទះតូចៗ (រ៉ូម ១៦:៥; ១ កូរិន ១៦:១៩), ពួកជំនុំនៅក្នុងទូទាំងទីក្រុងមួយ (១ កូរិន ១:២; ២ កូរិន ១:១; ១ ថែស ១:១), ពួកជំនុំនៅក្នុងទូទាំងតំបន់មួយ (កិច្ច ៩:៣១), ហើយពួកជំនុំទូទាំងលោកិយមួយ (អេ ៥:២៥; ១ កូរិន ១២:២៨) ។ ដូច្នេះ សហគមន៍មួយនៃរាស្ត្ររបស់ព្រះនៅក្នុងលំដាប់ណាក៏ដោយ គឺគេហៅដោយសមរម្យថា ជាពួកជំនុំមួយ ។

មានពាក្យប្រៀបប្រដូចជាច្រើន ក៏ត្រូវបានគេប្រើដើម្បីពិពណ៌នាពីពួកជំនុំដែរ ។ មានពាក្យប្រៀបប្រដូចមួយ ដែលលើកឡើងថា ពួកជំនុំគឺជាគ្រួសារមួយ ហើយជាសមាជិកនៃពួកជំនុំដែលមានទំនាក់ទំនងទៅវិញទៅមក ដូចជាសមាជិកគ្រួសារធំមួយមានទំនាក់ទំនងគ្នាយ៉ាងដូច្នោះដែរ ។ នេះជាមូលហេតុដែលសាវក ប៉ុល បានសរសេរនៅក្នុង ១ ធីម៉ូថេ ៥:១-២ ថា “កុំឲ្យស្តីបន្ទោសដល់មនុស្សចាស់ៗឡើយ ចូរទូន្មានគាត់ទុកដូចជាឪពុកចុះ ហើយមនុស្សដែលក្មេងជាងអ្នកនោះទុកដូចជាប្អូនវិញ ឯស្ត្រីចាស់ៗទុកដូចជាម្តាយ ហើយពួកស្រីដែលក្មេងជាងអ្នក ទុកដូចជាប្អូនដែរ ដោយសេចក្តីបរិសុទ្ធសព្វគ្រប់” ។ ទំនាក់ទំនងរវាងព្រះគ្រីស្ទ

និងពួកជំនុំ ក៏ត្រូវបានឃើញនៅក្នុងពាក្យដែលទាក់ទងនឹងគ្រួសារ ដោយព្រះគ្រីស្ទជាប្ដី ហើយពួកជំនុំជាប្រពន្ធរបស់ទ្រង់ (អេ ៥:៣២; ២ កូរិន ១១:២) ។

រូបភាពមួយទៀតដែលបង្ហាញពីពួកជំនុំ គឺជារូបកាយមួយ ។ នៅក្នុង ១ កូរិនថូស ១២ សាវក ប៉ុល បានសំដៅថា សមាជិកនៃពួកជំនុំ ជាសមាជិកនៃរូបកាយមួយ ។ សមាជិកនិមួយៗមានតួនាទី និងទំនួលខុសត្រូវពិសេសផ្ទាល់របស់ពួកគេ ដូចជាអវយវៈនៃរូបកាយយ៉ាងដូច្នោះដែរ ។ នៅក្នុងគម្ពីរអេភេសូរ ១:២២-២៣; ៤:១៥-១៦ និងគម្ពីរកូលុស ២:១៩ ពួកជំនុំត្រូវគេសំដៅថាជា រូបកាយមួយដែលមានព្រះគ្រីស្ទជាសិរសា ដែលរួបរួមគ្នាជារូបកាយទាំងមូល ហើយប្រដាប់គ្រប់ទាំងអវយវៈដើម្បីធ្វើការ ដែលវាគួរធ្វើ ។

មានពាក្យប្រៀបប្រដូចជាច្រើនទៀត ដែលគេប្រើសំដៅលើពួកជំនុំ ដូចជាព្រះវិហារថ្មី (១ ពេ ២:៤-៨), ជាសង្ឃបរិសុទ្ធ (១ ពេ ២:៥), ជាខ្នែងទំពាំងបាយជូរ (យ៉ូន ១៥:៥), ជាដើមអូលីវ (រ៉ូម ១១:១៧-២៤), ហើយជាចំការដំណាំមួយ (១ កូរិន ៣:៦-៩) ។ ពាក្យប្រៀបប្រដូចដែលប្រើសំរាប់ពួកជំនុំទាំងអស់នេះ គួររំលឹកយើង មិនឲ្យផ្ដោតទៅលើអ្នកណាម្នាក់ខ្លាំងពេកឡើយ ។ ការផ្ដោតដែលថ្លឹងមិនស្មើមួយលើពាក្យប្រៀបប្រដូចមួយ ចំពោះការមិនរាប់បញ្ចូលពាក្យប្រៀបប្រដូចផ្សេងទៀត នឹងមានលទ្ធផលនៅក្នុងគំនិតដែលថ្លឹងមិនស្មើមួយនៃពួកជំនុំ ។ ជំនួសវិញ យើងគួរពិចារណាពាក្យប្រៀបប្រដូចនិមួយៗថា ជា គំនិតផ្សេងៗគ្នាមួយអំពីពួកជំនុំ ជាអ្វីមួយដែលប្រាប់យើងបន្ថែមទៀត អំពីសហគមន៍ដែលព្រះបានអនុញ្ញាតឲ្យយើងធ្វើជាផ្នែកមួយ ។

## តើអ្វីទៅដែលធ្វើឲ្យពួកជំនុំ ជាពួកជំនុំ ?

ប្រសិនបើមនុស្សមួយក្រុមប្រជុំគ្នា ដើម្បីពិភាក្សាសេចក្តីខាងឯព្រលឹងវិញ្ញាណ តើការនោះធ្វើឲ្យពួកគេ ជាពួកជំនុំមួយឬទេ ? ចុះប្រសិនបើពួកគេធ្វើដូច្នេះ នៅក្នុងអាគារព្រះវិហារដែលមិនមែនជាបាងកាហ្វេវិញ តើឥឡូវនេះ ពួកគេក្លាយជាពួកជំនុំដែរឬទេ ? ក្រៅពីការពិភាក្សា ចុះ ប្រសិនបើពួកគេច្រៀង ហើយនិងអធិស្ឋានជាមួយគ្នាទៀតនោះ នឹងយ៉ាងម៉េចដែរ ? ចុះប្រសិនបើ ពួកគេបន្ថែមការអានព្រះគម្ពីរនៅក្នុងក្រុមរបស់ពួកគេទៀត តើឥឡូវនេះវាជាពួកជំនុំឬ ? តើសកម្មភាពអ្វីខ្លះដែលធ្វើឲ្យពួកគេក្លាយជាពួកជំនុំ ?

ជាទំនៀមទម្លាប់ អ្នកនិពន្ធគ្រីស្ទានជាច្រើន បានយល់ព្រមថា មានសកម្មភាព (ឬ "ចំនុចសំគាល់") ដ៏ចំបងពីរ ដែលពួកជំនុំទាំងអស់ត្រូវតែបង្ហាញ ដើម្បីឲ្យឃើញថាជាពួកជំនុំពិតប្រាកដមួយ ។ ទីមួយ គឺជាការអធិប្បាយដ៏ត្រឹមត្រូវតាមព្រះគម្ពីរ ។ ចំនុចសំគាល់នេះ មិនរាប់បញ្ចូលទាំងទំរង់នៃការអធិប្បាយទេ តែជាមាតិកាដែលនៅក្នុងសេចក្តីអធិប្បាយនោះវិញ ។ ប្រសិនបើសេចក្តីអធិប្បាយនៅក្នុងពួកជំនុំមួយនៅតែបន្តមានគោលលទ្ធិខុសឆ្គង ឬពួកគេលាក់បាំងសេចក្តីពិតនៃដំណឹងល្អពីការសង្គ្រោះដោយសេចក្តីជំនឿ ដូច្នេះពួកជំនុំដែលអធិប្បាយសេចក្តីទាំងនោះ មិនមែនជាពួកជំនុំពិតប្រាកដទេ ។

ចំនុចសំគាល់ទីពីរនៃពួកជំនុំដ៏ពិតប្រាកដ គឺជាការគ្រប់គ្រងដ៏ត្រឹមត្រូវនៃពិធី (ឬ "ច្បាប់") ពីររបស់គ្រីស្ទាន គឺពិធីជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់ ។ នៅពេលក្រុមមួយ ចាប់ផ្តើមអនុវត្តពិធីជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់ទៅតាម

របៀបព្រះគម្ពីរ មានន័យថាក្រុមនេះកំពុងតែដើរតួ ជាពួកជំនុំពិតប្រាកដមួយហើយ ។ ការអនុវត្តន៍នៃពិធីទាំងពីរនេះ ត្រូវបានគេចាត់ទុកថា ជាសញ្ញាមួយនៃពួកជំនុំពិតប្រាកដ ពីព្រោះពិធីទាំងនេះ អាចបំរើជា ការគ្រប់គ្រងសមាជិកភាពសំរាប់ពួកជំនុំ មានន័យថា ពិធីជ្រមុជទឹកគឺជាមធ្យោបាយមួយសំរាប់អនុញ្ញាតឲ្យបុគ្គលម្នាក់ៗ ចូលមកក្នុងពួកជំនុំ ។ ហើយការចូលរួមនៅក្នុងពិធីលៀងព្រះអម្ចាស់ គឺជារបៀបមួយដែលសមាជិកទាំងនោះនៅតែបន្ត ដើម្បីបង្ហាញពីជំហរល្អរបស់ពួកគេនៅក្នុងរូបកាយពួកជំនុំ ។ ដូច្នេះ នៅក្នុងប្រវត្តិសាស្ត្រ អ្នកនិពន្ធជាច្រើនបាននិយាយថា មានតែពួកជំនុំដែលអនុវត្តពិធីទាំងនោះបានត្រឹមត្រូវប៉ុណ្ណោះ ដែលត្រូវបានចាត់ទុកថា ជាពួកជំនុំពិតប្រាកដ ។

ប៉ុន្តែជាមួយអង្គការពួកជំនុំពិសេសៗជាច្រើននៅបច្ចុប្បន្ននេះ (មានន័យថាព័ន្ធកិច្ចពិសេស ដូចជាភ្នាក់ងារបេសកកម្ម សកលវិទ្យាល័យគ្រីស្ទាន និងមហាវិទ្យាល័យគ្រីស្ទាន) វាមានប្រយោជន៍ដើម្បីបន្ថែម “ចំនុចសំគាល់” មួយផ្សេងទៀត ដល់ពួកជំនុំដ៏ពិតប្រាកដមួយ ។ ដើម្បីធ្វើឲ្យជាពួកជំនុំពិតប្រាកដមួយ អង្គការមួយគួរព្យាយាមបំពេញមុខងារជាពួកជំនុំមួយ ជាជាងគ្រាន់តែការលើកទឹកមនុស្សឲ្យក្លាយជាសមាជិកនៃពួកជំនុំក្នុងតំបន់មួយ ។

ក្នុងចំណោមពួកជំនុំពិតប្រាកដ ភាពខុសគ្នាពីរផ្សេងទៀតក៏អាចត្រូវបានធ្វើឡើងដែរ ដូចជាគេបានផ្តោតសំខាន់នៅក្នុងសញ្ញាថ្មី ។ ពួកជំនុំមួយអាចមានភាពបរិសុទ្ធច្រើនជាង ឬតិចជាង ហើយការរួបរួមគ្នាល្អជាង ឬមិនសូវល្អជាង ។ ទីមួយ ភាពបរិសុទ្ធនៃពួកជំនុំ ត្រូវបានកំណត់ឡើងដោយកំរិតនៃការរួចផុតពីគោលលទ្ធិ

និងការអនុវត្តន៍ខុសឆ្គង ហើយនិងកំរិតនៃការធ្វើតាមព្រះហឫទ័យបើកសំដែងរបស់ព្រះសំរាប់ពួកជំនុំ ។ គោលដៅរបស់ព្រះគ្រីស្ទសំរាប់ពួកជំនុំគឺ “ដើម្បីឲ្យទ្រង់បានញែកពួកជំនុំជាបរិសុទ្ធ ដោយបានលាងសំអាតនឹងទឹក គឺជាព្រះបន្ទូលប្រយោជន៍នឹងថ្វាយពួកជំនុំនេះដល់ព្រះអង្គទុកជាពួកជំនុំដ៏ឧត្តម ឥតប្រឡាក់ ឥតជ្រួញ ឬមានអ្វីឲ្យដូចឡើយ គឺឲ្យបានបរិសុទ្ធហើយឥតកន្លែងបន្ទោសបានវិញ” (អេ ៥:២៦-២៧) ។ ដូច្នេះ ជាសមាជិកនៃពួកជំនុំ យើងគួរប្រដេញតាមភាពបរិសុទ្ធរបស់ពួកជំនុំគ្រប់ផ្នែកទាំងអស់ ឲ្យអស់ពីសមត្ថភាពរបស់ពួកយើង ។

ទីពីរ យើងគួរប្រដេញតាមការរួបរួមគ្នាផងដែរ មានន័យថា ការរួចផុតពីការការបាក់បែកគ្នាក្នុងចំណោមពួកគ្រីស្ទានពិតប្រាកដ តាមដែលយើងអាចធ្វើបាន ។ នៅពេលដែលយើងធ្វើការនេះ យើងកំពុងតែធ្វើតាមសេចក្តីអធិស្ឋានរបស់ព្រះយេស៊ូវ នៅក្នុងគម្ពីរយ៉ូហាន ១៧:២១ សំរាប់អ្នកជឿនៅអនាគត “ឲ្យទាំងអស់រួមមកតែមួយ” ។ នេះមិនមានន័យថា ត្រូវតែមានរដ្ឋាភិបាលពួកជំនុំទូទាំងពិភពលោកមួយគ្រប់គ្រងពួកគ្រីស្ទានទាំងអស់នោះទេ ដ្បិតការរួបរួមគ្នា អាចបង្ហាញឲ្យឃើញ តាមរបៀបផ្សេងៗទៀត ។ ប៉ុន្តែ វាពិតជាមានន័យថា គ្រប់ពួកជំនុំពិតត្រង់គួរព្យាយាមសហការណ៍ និងបង្កើតទំនាក់ទំនងជិតស្និត ជា មួយនឹងពួកជំនុំ និងក្រុមគ្រីស្ទានពិតត្រង់ដទៃទៀត តាមរបៀបសមរម្យនានា គ្រប់ពេលវេលា ។ ពួកជំនុំទាំងឡាយណាដែលតែងតែមិនចុះសំរុងនឹងក្រុមជំនុំផ្សេងទៀត គួរតែពិចារណាដោយសេចក្តីអធិស្ឋានថា តើ ខ្លួនកំពុងតែធ្វើការបានល្អយ៉ាងណា ចំពោះគោលបំណងរបស់ព្រះអំពីការរួបរួមគ្នាក្នុងចំណោមអ្នកជឿ ។

## តើពួកជំនុំគួរធ្វើអ្វី ?

ពួកជំនុំគួរបំរើដល់ព្រះ ដល់សមាជិករបស់ពួកជំនុំនោះ ហើយដល់លោកិយទាំងមូល ។ ព័ន្ធកិច្ចចំពោះព្រះ ត្រូវបានសំរេចឡើង តាមរយៈការថ្វាយបង្គំទ្រង់ ។ នៅក្នុងគម្ពីរកូល៉ុស ៣:១៦ សាវក ប៉ុល បានលើកទឹកចិត្តពួកជំនុំឲ្យច្រៀង "ទំនុកដំកើង ទំនុកបរិសុទ្ធ និងចំរៀងខាងឯវិញ្ញាណ ទាំងច្រៀងក្នុងចិត្តថ្វាយព្រះដោយអរព្រះគុណ" ។ ការថ្វាយបង្គំនៅក្នុងពួកជំនុំ មិនគ្រាន់តែជាការរៀបចំមួយសំរាប់អ្វីមួយផ្សេងទៀតនោះទេ តែនៅក្នុងការថ្វាយបង្គំនោះផ្ទាល់ គឺជាការសំរេចបាននូវគោលបំណងមួយដ៏សំខាន់របស់ពួកជំនុំ ដែលសមាជិករបស់វាត្រូវបានបង្កើតឡើងដើម្បីរស់នៅ សំរាប់ការសរសើរដល់សិរីល្អរបស់ព្រះ (អេ ១:១២) ។

ព័ន្ធកិច្ចរបស់ពួកជំនុំ ចំពោះសមាជិករបស់វា ត្រូវបានសំរេចឡើងតាមរយៈការបង្ហាត់បង្រៀន និងការស្អាងគ្នាឡើង យ៉ាងនោះពួកជំនុំអាច "ថ្វាយគ្រប់មនុស្ស ជាឯង្វាយគ្រប់លក្ខណ៍ក្នុងព្រះគ្រីស្ទ" (កូល ១:២៨) ។ ដូចជាសាវក ប៉ុល បាននិយាយនៅក្នុងគម្ពីរអេភេសូរ ៤:១២-១៣ ថា អ្នកដឹកនាំដ៏មានអំណោយទានរបស់ពួកជំនុំ ត្រូវបានផ្តល់មកដើម្បី "នឹងនាំឲ្យពួកបរិសុទ្ធបានគ្រប់លក្ខណ៍ឡើង សំរាប់ធ្វើការជំនួយ ហើយនឹងស្អាងរូបកាយព្រះគ្រីស្ទឡើង ទាល់តែយើងរាល់គ្នាបានរួបរួមខាងឯសេចក្តីជំនឿរួចជាស្រេច ហើយបានស្គាល់ព្រះរាជបុត្រានៃព្រះដូចគ្នាទាំងអស់ គឺដល់បានពេញជាមនុស្ស ហើយដល់ខ្នាតកំពស់នៃសេចក្តីពោរពេញផងព្រះគ្រីស្ទ" ។

ព័ន្ធកិច្ចរបស់ពួកជំនុំចំពោះលោកិយ ត្រូវសំរេចឡើងតាមរយៈការប្រកាសដំណឹងល្អដល់មនុស្សទាំងអស់ជាព្រះបន្ទូល និងជាទង្វើ នៅក្នុងពិភពលោកនេះតែម្តង ។ នៅក្នុងគម្ពីរម៉ាថាយ ២៨:១៩ ព្រះយេស៊ូវបានបង្គាប់ដល់ពួកសិស្សរបស់ទ្រង់ថា "ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍" ។ នៅក្នុងគម្ពីរកិច្ចការ ១:៨ ពួកសិស្សត្រូវបានប្រាប់ឲ្យផ្សាយព្រះរាជសារដំណឹងល្អ "រហូតដល់ចុងផែនដីបំផុត" ។ គំរូនៃការប្រកាសដំណឹងល្អនៅក្នុងព្រះគម្ពីរ គឺបង្ហាញយ៉ាងច្បាស់ថា៖ ព្រះ រាជសារនោះត្រូវបានផ្តល់មកទាំងជាព្រះបន្ទូល (តាមរយៈការប្រកាសដំណឹងល្អ) និងទាំងជាទង្វើ (តាមរយៈព័ន្ធកិច្ចនៃសេចក្តីមេត្តាករុណា) ។

ពួកជំនុំនិមួយៗ គួរត្រូវបានពាក់ព័ន្ធនៅក្នុងព័ន្ធកិច្ចផ្សេងៗនៃព្រះបន្ទូល និងទង្វើ គឺមិនត្រឹមតែការប្រកាសដំណឹងល្អប៉ុណ្ណោះទេ ប៉ុន្តែរួមទាំងព័ន្ធកិច្ចចំពោះអ្នកទាល់ក្រ និងអ្នកត្រូវគេជិះជាន់ផងដែរ (កា ២:១០; យ៉ា ១:២៧) ។ ហើយនៅខណៈពេលដែលហាក់ដូចជាមានភាពចាំបាច់ សំរាប់តំរូវការខាងរូបកាយនៃអ្នកជឿដូចគ្នា (កិច្ច ១១:២៩; ២ កូរិន ៨:៤; ១ យ៉ូន ៣:១៧) នោះសមាជិកទាំងអស់នៃពួកជំនុំ ត្រូវ "ធ្វើល្អដល់មនុស្សទាំងអស់" នៅពេលដែលពួកគេមានឱកាស (កា ៦:១០) ។

ពួកជំនុំទាំងអស់គួរព្យាយាមសំរេចគោលបំណងទាំងបីនេះ ដ្បិតព្រះបង្កើតពួកជំនុំទាំងអស់នោះមកសំរាប់ (ការថ្វាយបង្គំ ការស្អាងចិត្តគ្នា និងការផ្សាយដំណឹងល្អនិងសេចក្តីមេត្តាករុណា) ។ គោលបំណងមួយ មិនមានសារៈសំខាន់ជាងគោលបំណងដទៃផ្សេងទៀតទេ ហើយពួកជំនុំមិនគួរធ្វើឲ្យគោល

បំណងមួយសំខាន់ជាងគេ ហើយធ្វេសប្រហែសចំពោះគោលបំណងឯទៃទៀត នោះដែរ ។ ជំនួសមកវិញ ដោយការទុកចិត្តពេញលេញនៅក្នុងសេចក្ដីសន្យារបស់ព្រះគ្រីស្ទ ដែលថា ទ្រង់នឹងស្អាងពួកជំនុំរបស់ទ្រង់ (ម៉ាថ ១៦:១៨) គ្រប់ពួកជំនុំទាំងអស់គួរតែស្វែងរកការថ្វាយបង្គំព្រះដោយអស់ពីចិត្ត ហើយស្អាងសមាជិកនៃពួកជំនុំឲ្យបានពេញវ័យឡើង ព្រមទាំងប្រកាសដំណឹងល្អដល់លោកិយនេះ តាមរយៈព្រះបន្ទូល និងទង្វើ ។

## អំណាចរបស់ពួកជំនុំ ក្នុងការបំពេញបេសកកម្មរបស់ខ្លួន

នៅពេលដែលព្រះគ្រីស្ទបានសន្យាថា នឹងស្អាងពួកជំនុំរបស់ទ្រង់ នោះទ្រង់បានប្រទានអំណាចដល់ពួកសិស្សរបស់ទ្រង់ ដើម្បីធ្វើការងារនេះ ។ ហើយនៅពេលដែលទ្រង់បានចាកចេញពីពួកគេ ទ្រង់បានចាត់ព្រះវិញ្ញាណបរិសុទ្ធឲ្យមកឯពួកគេ ដើម្បីឲ្យពួកគេមានអំណាចក្នុងការស្អាងពួកជំនុំ (យ៉ូន ១៤:២៦; កិច្ច ១:៨) ។ ព្រះវិញ្ញាណបរិសុទ្ធបានប្រទានអំណាចដល់អ្នកដើរតាមព្រះយេស៊ូវ ជាមួយនឹងអំណោយទាននានា (“អំណោយទានខាងវិញ្ញាណ”) ដែលតំរូវឲ្យមានក្នុងការអនុវត្តន៍ព័ន្ធកិច្ចរបស់ពួកជំនុំ ហើយព្រះវិញ្ញាណបរិសុទ្ធ ប្រទានអំណាចដល់យើង ឲ្យប្រើអំណោយទានទាំងនេះ ដើម្បីបន្តព័ន្ធកិច្ចនៃពួកជំនុំនាសម័យបច្ចុប្បន្ននេះ ។

អំណោយទានខាងវិញ្ញាណ គឺរួមទាំងអំណោយទានដែលទាក់ទងនឹងសមត្ថភាពពីធម្មជាតិ (ការបង្រៀន ការបង្ហាញសេចក្ដីមេត្តាករុណា ការគ្រប់គ្រង) និងទាំងអំណោយទានដែលហាក់ដូចជាអស្ចារ្យ (ការទាយទំនាយ ការប្រោសជំងឺ

ការស្គាល់វិញ្ញាណនានា)។ ទោះបីជា អ្នកខ្លះអាចធ្វើការបែងចែកមួយ រវាងអំណោយទានពីធម្មជាតិ និងអំណោយទានធ្វើការអស្ចារ្យក៏ដោយ ប៉ុន្តែនៅពេលសាវក ប៉ុល រៀបរាប់ពីអំណោយទានខាងឯវិញ្ញាណ គាត់ហាក់ដូចជាមិនធ្វើការបែងចែកយ៉ាងដូច្នេះទេ (រ៉ូម ១២:៦-៨; ១ កូរិន ៧:៧; ១២:៨-១០, ២៨; អេ ៤:១១)។ ហើយគាត់ក៏ហាក់ដូចជាមិននិយាយថា អំណោយទានអស្ចារ្យខ្លះត្រូវបានផ្តល់មកសំរាប់តែពួកសាវក ទុកជាទីសំគាល់ដើម្បីបង្ហាញភស្តុតាងពីព័ន្ធកិច្ចរបស់ពួកគេនៅសម័យមុននោះដែរ ដ្បិតអំណោយទានទាំងនេះ ត្រូវបានផ្តល់មកយ៉ាងទូលំទំលាយនៅក្នុងចំណោមអ្នកជឿ នៅក្នុងពួកជំនុំនានានាសម័យរបស់សាវក ប៉ុល។ ប៉ុន្តែសាវក ប៉ុល បាននិយាយនៅក្នុង ១ កូរិនថូស ១៣:១២ ថា អំណោយទានអស្ចារ្យទាំងនេះ នឹងបាត់ទៅ (សូមមើលខ ១០) នៅពេលដែលយើងឃើញព្រះគ្រីស្ទ “មុខទល់នឹងមុខ” ហើយនៅពេលយើងស្គាល់ទ្រង់ច្បាស់វិញ។ នៅពេលដែលព្រះគ្រីស្ទយាងត្រឡប់មកវិញ អំណោយទានខាងឯវិញ្ញាណនឹងបាត់ទៅ ដ្បិតយើងនឹងមិនត្រូវការអំណោយទានទាំងអស់នេះទៀតទេ (១ កូរិន ១៣:៨)។

អំណោយទានខាងវិញ្ញាណទាំងអស់ សាវក ប៉ុល បាននិយាយនៅក្នុង ១ កូរិនថូស ១២:១១ ថា “គឺជាវិញ្ញាណតែមួយដដែលនោះឯង ដែលធ្វើគ្រប់ការទាំងនោះ ទាំងចែកដល់គ្រប់គ្នាដោយមុខៗផង តាមដែលទ្រង់សព្វព្រះហឫទ័យ”។ អំណោយទានទាំងអស់នេះ ត្រូវបានប្រទានមក “ដើម្បីឲ្យបានកើតផល” (១ កូរិន ១២:៧) ហើយដើម្បីប្រើសំរាប់នឹង “ស្អាងចិត្ត” ពួកជំនុំឡើង (១ កូរិន ១៤:២៦)។

អំណោយទានខាងវិញ្ញាណ មិនគ្រាន់តែប្រដាប់ពួកជំនុំសំរាប់ព័ន្ធកិច្ចដែលទ្រង់ត្រាស់ហៅឲ្យធ្វើនោះទេ ប៉ុន្តែអំណោយទានទាំងនោះក៏ផ្តល់ឲ្យលោកិយនូវសញ្ញាមួយនៃសម័យកាលដែលត្រូវមកផងដែរ ។ នៅពេលដែលព្រះគ្រីស្ទយាងត្រឡប់មកវិញ ការគ្រប់គ្រង និងរាជ្យរបស់ទ្រង់នឹងត្រូវបានគេស្គាល់ និងមានបទពិសោធន៍យ៉ាងច្បាស់ មិនត្រឹមតែនៅក្នុងតែជីវិតនៃបុគ្គលដែលអត់មានបាបប៉ុណ្ណោះទេ (១ យ៉ូន ៣:២) ប៉ុន្តែក៏នៅក្នុងរូបកាយដ៏រុងរឿងនៃពួកអ្នកជឿផងដែរ (១ កូរិន ១៥:៥៣) ។ តាមរយៈអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ពួកជំនុំធ្វើឲ្យសេចក្តីសន្យានៅអនាគតនេះ ក្លាយជាការពិតនៅបច្ចុប្បន្នវិញ (ឧ៖ តាយរយៈការផ្លាស់ប្រែនៃអ្នកមិនជឿម្នាក់ ឬក៏ការប្រោសជំងឺឲ្យជា) សេចក្តីសន្យានេះកំពុងតែផ្តល់មកដល់ពួកអ្នក ដែលនឹងបានឃើញពីសញ្ញានៃអ្វីដែលត្រូវមក ហើយនិងការសំរេចជោគជ័យនូវព័ន្ធកិច្ចដែលព្រះគ្រីស្ទបានបង្គាប់ និងបានប្រទានអំណាចឲ្យសំរេចបាន ។

# បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១. តើពួកជំនុំមួយខុសគ្នាពីថ្នាក់សិក្សាព្រះគម្ពីរមួយ ឬខុសពីកន្លែងសន្និបាតរបស់គ្រីស្ទានដោយរបៀបណា ?

២. ហេតុអ្វីបានជាពួកគ្រីស្ទានត្រូវក្លាយជាសមាជិកនៃពួកជំនុំមួយ ? តើអ្វីខ្លះជាការគ្រោះថ្នាក់នៃការមិនធ្វើជាសមាជិកនៃពួកជំនុំក្នុងតំបន់មួយ ?

៣. តើអ្នកអាចរៀបរាប់ពីការអ្វីខ្លះ ដែលពួកជំនុំមួយគួរធ្វើ ? តើអ្នកអាចប្រាប់ពីឧទាហរណ៍ចំៗនានា ដែលកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធកំពុងតែប្រទានអំណាច និងប្រទានពរចំពោះការទាំងអស់នោះ នៅក្នុងពួកជំនុំផ្ទាល់របស់អ្នកបានឬទេ ?

# ជំពូក ១៨

# តើនឹងមានអ្វីកើតឡើងនៅពេលដែលព្រះគ្រីស្ទយាងមកវិញ ?

មានការវែកញែកជាច្រើន នៅក្នុងប្រវត្តិសាស្ត្រនៃពួកជំនុំ អំពីសំនួរស្តីពីអនាគត ។ ជាពិសេស ការវែកញែកពីការយាងមកវិញរបស់ព្រះគ្រីស្ទ សហស្សវត្ស (ឬ រាជ្យមួយពាន់ឆ្នាំ) គឺជាការជំនុំជំរះចុងក្រោយ ជា ពេលដាក់ទណ្ឌកម្មអស់កល្បជានិច្ចដល់អ្នកមិនជឿ ហើយក៏ជាពេលប្រទានរង្វាន់ដល់ពួកអ្នកជឿ ព្រមទាំងជីវិតជាមួយនឹងព្រះនៅក្នុងស្ថានសួគ៌និងផែនដីថ្មី ។ ការសិក្សានៃព្រឹត្តិការណ៍ទាំងនេះគេហៅថា ការសិក្សានៃ “សេចក្តីចុងក្រោយ” ឬ “Eschatology” (ពីភាសាក្រិក *eschatos* មានន័យថា “ចុងក្រោយ”) ។

## ការយាងមកវិញរបស់ព្រះគ្រីស្ទ

ព្រះយេស៊ូវបានប្រាប់ពួកសិស្សរបស់ទ្រង់ថា ទ្រង់នឹងយាងមកផែនដីក្នុងពេលមួយរំពេច “ខ្ញុំនឹងត្រឡប់មកវិញ និងទទួលអ្នករាល់គ្នាទៅឯខ្ញុំ ប្រយោជន៍ឲ្យអ្នករាល់គ្នា បាននៅកន្លែងដែលខ្ញុំនៅនោះដែរ” (យ៉ូន ១៤:៣) ។ ខណៈពេលដែលបទនេះ និងបទដទៃទៀត (ដូចជា កិច្ច ១:១១; ១ ថែស ៤:១៦; ហេ ៩:២៨; ២ ពេ

៣:១០; ១ យ៉ូន ៣:២) បានបង្ហាញយ៉ាងច្បាស់ថា ព្រះគ្រីស្ទនឹងយាងមកវិញ បទទាំងនេះក៏បង្ហាញយ៉ាងច្បាស់ថា “គ្មានអ្នកណាដឹងបាន” (ម៉ាក ១៣:៣២) ពីពេលកំណត់នៃការយាងមកវិញរបស់ព្រះគ្រីស្ទបានទេ ដ្បិត “កូនមនុស្សនឹងមកនៅវេលាដែលអ្នករាល់គ្នាមិនគិត” (ម៉ាថ ២៤:៤៤) ។

ទោះបីជា គ្មានអ្នកណាម្នាក់ដឹងពីពេលវេលានៃការយាងត្រឡប់មកវិញរបស់ព្រះគ្រីស្ទក៏ដោយ តែ អ្នកជឿទាំងអស់គួរឆ្លើយតប ដូចជាលោក យ៉ូហាន បានឆ្លើយតបនៅក្នុងព្រះគម្ពីរវិវរណៈ ២២:២០ នៅពេលដែលគាត់បានឮព្រះគ្រីស្ទមានបន្ទូលថា “អើអញមកជាឆាប់” សាវក យ៉ូហាន ក៏តបថា “អាម៉ែន ព្រះអម្ចាស់យេស៊ូវអើយ សូមយាងមក !” ។

## ថ្ងៃកំណត់នៃការយាងមកវិញ

ខណៈពេលខគម្ពីរបានលើកឡើងខាងលើ ពិតជាបង្ហាញយ៉ាងច្បាស់ថា ការយាងត្រឡប់មកវិញរបស់ព្រះគ្រីស្ទ នឹងមកនៅពេលមួយដែលគ្មានអ្នកណាម្នាក់ដឹង បទគម្ពីរដទៃទៀតហាក់ដូចជាលើកឡើងថា ទីសំគាល់ជាក់លាក់នឹងមកមុនពេលនៃការយាងមកវិញរបស់ព្រះគ្រីស្ទ ។ ទីសំគាល់ទាំងនេះ ត្រូវបានបង្ហាញតាមរយៈខនានាដូចខាងក្រោមនេះ

- “ដំណឹងល្អនឹងត្រូវផ្សាយដល់គ្រប់សាសន៍ជាមុនសិន” (ម៉ាក ១៣:១០; សូមមើល ម៉ាថ ២៤:៤៤) ។

- “ដ្បិតនៅគ្រានោះនឹងមានសេចក្តីវេទនាខ្លាំងណាស់ ដល់ម៉្លេះបានជា តាំងពីកំណើតលោកិយដែលព្រះទ្រង់បានបង្កើតឯរាបដល់សព្វថ្ងៃនេះ មិនដែលមានយ៉ាងដូច្នេះទេ ហើយទៅមុខក៏មិនដែលមានផង បើព្រះអម្ចាស់មិនបានបន្ថយថ្ងៃទាំងនោះឲ្យខ្លី នោះគ្មានមនុស្សណាបានសង្គ្រោះទេ ប៉ុន្តែទ្រង់បានបន្ថយថ្ងៃទាំងនោះ ដោយព្រោះពួកអ្នកដែលទ្រង់បានរើសតាំង” (ម៉ាក ១៣:១៩-២០) ។
- “ដ្បិតនឹងមានព្រះគ្រីស្ទក្លែងក្លាយ ហើយហោរាក្លែងកើតឡើង គេនឹងធ្វើទីសំគាល់យ៉ាងធំ ហើយនិងការអស្ចារ្យ ដើម្បីនឹងនាំទាំងពួកអ្នករើសតាំងឲ្យវង្វេងផង បើសិនជាបាន” (ម៉ាថ ២៤:២៣-២៤) ។
- នៅគ្រាក្រោយសេចក្តីវេទនានោះ ថ្ងៃនឹងទៅជាងងឹត ខែនឹងលែងភ្លឺ អស់ទាំងផ្កាយនៅលើមេឃនឹងធ្លាក់ ហើយអស់ទាំងអំណាចនៅលើមេឃនឹងត្រូវកក្រើករំពើក” (ម៉ាក ១៣:២៤-២៥; ហើយសូមមើល ម៉ាថ ២៤:២៩-៣០ និងលូក ២១:២៥-២៧ ផងដែរ) ។
- អំពី “ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើងទ្រង់ត្រូវយាងមក ដ្បិតថ្ងៃនោះមិនមកឡើយ ទាល់តែមានសេចក្តីក្បត់សាសនាមកជាមុន ហើយមនុស្សដែលជាតួបាបនោះបានលេចមក គឺជាមនុស្សដែលត្រូវហិនវិនាស ដែលទាស់ទទឹង ហើយលើកខ្លួនឡើងខ្ពស់លើសជាងអស់ទាំងអ្វីដែលហៅថាព្រះ ឬរបស់អ្វីដែលគោរពប្រតិបត្តិផង ដល់ម៉្លេះបានជាវានឹងអង្គុយនៅ ដូចជាព្រះក្នុងវិហារនៃព្រះ ទាំងសំដែងខ្លួនថាជាព្រះផង” (២ ថែស ២:១; ៣-៤) ។

- “ចង់ឲ្យដឹងថា...សាសន៍អ៊ីស្រាអែលទាំងអស់គ្នា នឹងបានសង្គ្រោះ” (រ៉ូម ១១:២៥-២៦) ។

ព្រះយេស៊ូវមិនបាននិយាយថា ទីសំគាល់ទាំងនេះត្រូវបានប្រទានមក ដើម្បីឲ្យមនុស្សនឹងអាចគិតថា ដោយព្រោះពួកគេមិនបានឃើញទីសំគាល់ទាំងនោះ អញ្ចឹងព្រះគ្រីស្ទនឹងមិនយាងត្រឡប់មកវិញនោះទេ ។ ជំនួសមកវិញ ទីសំគាល់ទាំងនោះត្រូវបានប្រទានមក ដើម្បីធ្វើឲ្យការរំពឹងទុកមួយនៃការយាងត្រឡប់មករបស់ព្រះគ្រីស្ទ កាន់តែមានកំលាំងឡើង វិញ ។ “កាលណាការទាំងនេះចាប់តាំងកើតមក នោះឲ្យអ្នករាល់គ្នាងើបមើលទៅលើ ពីព្រោះសេចក្តីប្រោសលោះរបស់អ្នករាល់គ្នាជិតដល់ហើយ” (លូក ២១:២៨) ។

ប៉ុន្តែការថែងពីទីសំគាល់ទាំងនេះ លើកឡើងសំនួរដ៏សមហេតុផលពីរគឺៈ តើទីសំគាល់ណាខ្លះក្នុងចំណោមទីសំគាល់ទាំងនេះ បានកើតឡើងរួចហើយ ? ហើយប្រសិនបើទីសំគាល់ទាំងអស់នេះមិនបានកើតឡើងទេ តើព្រះគ្រីស្ទអាចនឹងយាងត្រឡប់មកនៅពេលណាមួយឆាប់ៗនេះឬ ? ចំលើយចំពោះសំនួរទាំងនេះមានខុសៗពីគ្នា នៅក្នុងពួកជំនុំទាំងអស់ ។

អ្នកខ្លះជឿថា ទីសំគាល់ទាំងនេះមិនបានកើតឡើងទេ ហើយដូច្នេះព្រះគ្រីស្ទ នឹងមិនយាងត្រឡប់មកវិញឆាប់ៗទេ ។ ប៉ុន្តែព្រះគ្រីស្ទបានលើកទឹកចិត្តដល់ពួកសិស្សរបស់ទ្រង់ថា “ចូរប្រុងប្រយ័ត្ន ឲ្យចាំយាមហើយអធិស្ឋានផង ដ្បិតអ្នករាល់គ្នាមិនដឹងពេលកំណត់នោះទេ” (ម៉ាក ១៣:៣៣) ។ ទស្សនៈមួយដែលប្រាប់

ពួកគ្រីស្ទានថា ព្រោះ គ្រីស្ទមិនអាចត្រឡប់មកវិញឆាប់ៗ ហាក់ដូចជាធ្វើឲ្យបាត់បង់កំលាំងនៃការលើកទឹកចិត្តរបស់ព្រះគ្រីស្ទ ។

អ្នកខ្លះទៀតជឿថា ព្រះគ្រីស្ទនឹងពិតជាមកក្នុងពេលណាមួយ ហើយ ពួកគេដោះស្រាយការសំរេចនៃទីសំគាល់តាមរបៀបផ្សេងៗគ្នាបីយ៉ាងគឺ៖ (១) អ្នកខ្លះវែកញែកថា នឹងមានការយាងមកពីរដោយឡែកពីគ្នារបស់ព្រះគ្រីស្ទគឺ ការយាងមកជាសំងាត់មួយ និងការយាងមកជាសាធារណៈមួយ ។ ប៉ុន្តែបទគម្ពីរដែលបានចែងពីការយាងមកវិញរបស់ទ្រង់ ហាក់ដូចជាមិនគាំទ្រដល់ការយាងមកពីរដោយឡែកពីគ្នានោះទេ (សូមមើលការពិភាក្សាខាងក្រោម) ។ (២) អ្នកផ្សេងទៀតបានវែកញែកថា គ្រប់ទាំងទីសំគាល់បានសំរេចរួចរាល់ហើយ កាលពីនៅប្រវត្តិសាស្រ្តនៃពួកជំនុំជំនាន់មុន ដូច្នេះព្រះគ្រីស្ទអាចនឹងមកនៅពេលណាមួយឆាប់ៗនេះ ។ ប៉ុន្តែទីសំគាល់មួយចំនួនដូចជា (ឧ៖ សេចក្តីទុក្ខវេទនាខ្លាំង, សេចក្តីសង្គ្រោះនៃពួកអ៊ីស្រាអែល, លក្ខណៈនៃ "មនុស្សដែលត្រូវហិនវិនាស ដែលទាស់ទទឹង", អស់ទាំងផ្កាយនៅលើមេឃនឹងធ្លាក់) ហាក់ដូចជាមិនបានសំរេចនៅក្នុងរបៀបច្បាស់លាស់ ឬមានភស្តុតាង នៅសម័យនៃពួកជំនុំជំនាន់មុននៅឡើយទេ ។ (៣) ហើយអ្នកខ្លះទៀតនៅតែវែកញែកថា វា *មិនទំនងតែអាចទៅរួច*ដែលទីសំគាល់បានសំរេចរួចហើយ ហើយថា ដូច្នេះព្រះគ្រីស្ទអាចនឹងយាងមកនៅពេលឆាប់ៗនេះ ។

នៅក្នុងអត្ថន័យលើសពីមួយ ដែលមានការទាក់ទងទៅនឹងសេចក្តីសំរេចនៃទីសំគាល់ទាំងនេះ វា ហាក់ដូចជាទស្សនៈចុងក្រោយសមហេតុផលជាងគេ ។ ទស្សនៈនេះធ្វើឲ្យយើងរំពឹងថា ទីសំគាល់ដែលមកមុនការយាងមកវិញរបស់

ព្រះគ្រីស្ទ នឹងប្រហែលជានៅតែកើតឡើងនៅពេលអនាគត ប៉ុន្តែដោយព្រោះយើងមិនដឹងច្បាស់អំពីការនោះ យើងអាចនៅតែត្រៀមខ្លួនជាស្រេច សំរាប់ការយាងមកវិញមួយរំពេចរបស់ព្រះគ្រីស្ទនៅថ្ងៃណាមួយ ។ (លើទស្សនៈនេះ ការត្រៀមខ្លួនជាស្រេចសំរាប់ការយាងមកវិញរបស់ព្រះគ្រីស្ទ គឺស្រដៀងគ្នានឹង ការពាក់ខ្សែក្រវាត់សុវត្ថិភាពនៅក្នុងឡានយ៉ាងដូច្នោះដែរ គឺអ្នកមិនគិតថាអ្នកនឹងមានគ្រោះថ្នាក់នោះទេ តែអ្នកពាក់ខ្សែក្រវាត់សុវត្ថិភាពដោយព្រោះអ្នកអាចនឹងមានបញ្ហាដោយប្រការណាមួយ ។

## ព្រឹត្តិការណ៍នៅពេលការយាងមករបស់ព្រះគ្រីស្ទ

មានការមិនយល់ស្របគ្នាជាច្រើននៅក្នុងពួកជំនុំ អំពីការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវ ដែលទាក់ទងផ្ទាល់ជាមួយនឹងការបកស្រាយនៃបទគម្ពីរមួយគឺ វិវរណៈ ២០:១-៦ ។ ជាពិសេស ការមិនយល់ស្របនេះ ពាក់ព័ន្ធនឹងរាជ្យមួយពាន់ឆ្នាំ ដែលសាវក យ៉ូហាន បាននិយាយនៅក្នុងគម្ពីរវិវរណៈ ២០:៤-៥ នៅពេលដែលគាត់បានសរសេរថា មនុស្សមួយក្រុម “បានរស់ឡើងវិញ ហើយក៏សោយរាជ្យជាមួយនឹងព្រះគ្រីស្ទនៅមួយពាន់ឆ្នាំ តែមនុស្សស្លាប់ឯទៀតមិនបានរស់វិញទេ ទាល់តែផុតពីមួយពាន់ឆ្នាំនោះទៅ” ។ ពួកគ្រីស្ទានជាច្រើន បានហៅដំណាក់កាលមួយពាន់ឆ្នាំនេះ ថា “រាជ្យមួយពាន់ឆ្នាំ” ហើយជាធម្មតា ពួកគេយកទស្សនៈមួយក្នុងចំណោមទស្សនៈបី អំពីសម័យកាល និងនិស្ស័យនៃកំឡុងពេលមួយពាន់ឆ្នាំនេះ ។

*ទស្សនៈទី១ - អសហាសវត្ស: រាជ្យមួយពាន់ឆ្នាំគឺឥឡូវនេះ ហើយនៅពេលដែលវាបញ្ចប់ ព្រះយេស៊ូវនឹងយាងមកវិញ*

ទស្សនៈដ៏សាមញ្ញបំផុតនៃរាជ្យមួយពាន់ឆ្នាំគឺថា ព្រះគម្ពីរវិវរណៈ ២០:១-៦ បានពិពណ៌នាថា មិនមែនជាពេលវេលាអនាគតនោះទេ ប៉ុន្តែនៅសម័យពួកជំនុំបច្ចុប្បន្ននេះវិញ ។ ពួកគ្រីស្ទានដែលប្រកាន់ទស្សនៈនេះ ជឿថា ទីសំគាល់ជាច្រើន ឬទីសំគាល់ទាំងអស់ដែលបានលើកមកនិយាយនៅពេលមុននេះ បានកើតឡើងនៅសម័យមុនក្នុងប្រវត្តិសាស្ត្រពួកជំនុំរួចហើយ ហើយថា ព្រះគ្រីស្ទពិតជាអាចនឹងយាងមកនៅពេលណាមួយឆាប់ៗនេះ ។ តាមទស្សនៈនេះ នៅពេលសាវក យ៉ូហានបានសរសេរថា “ពួកទាំងនោះបានរស់ឡើងវិញ ហើយក៏សោយរាជ្យជាមួយនឹងព្រះគ្រីស្ទនៅមួយពាន់ឆ្នាំ” (វិវរ ២០:៤) គាត់ចង់សំដៅថា ពួកគ្រីស្ទានដែលបានស្លាប់រួចហើយ កំពុងតែសោយរាជ្យខាងព្រលឹងវិញ្ញាណជាមួយព្រះគ្រីស្ទ នៅសព្វថ្ងៃនេះ (សូមមើលនៅម៉ាថាយ ២៨:១៨ កន្លែងដែលព្រះយេស៊ូវបានមានបន្ទូលថា “គ្រប់ទាំងអំណាចបានប្រគល់មកខ្ញុំនៅលើស្ថានសួគ៌ ហើយលើផែនដីផង”) ហើយនៅគម្ពីរអេភេសូរ ២:៦ បានចែងថា ឲ្យយើងអង្គុយជាមួយព្រះគ្រីស្ទ “នៅស្ថានដ៏ខ្ពស់” ។ ដោយព្រោះព្រឹត្តិការណ៍នៅក្នុងគម្ពីរវិវរណៈ ២០ ត្រូវបានកំពុងតែសំរេចនៅក្នុងពួកជំនុំ នោះរាជ្យមួយពាន់ឆ្នាំដែលសាវក យ៉ូហាន បានលើកឡើងនៅក្នុងគម្ពីរវិវរណៈ ២០:៤-៥ គឺជារូបភាពមួយនៃសំដី សំរាប់ពេលវេលាដ៏យូរ

មួយ- ជាពិសេសទៅទៀត សម័យកាលនៃពួកជំនុំទាំងមូល តាំងពីថ្ងៃបុណ្យទី៥០ រហូតដល់ការយាងមកវិញរបស់ព្រះគ្រីស្ទ ។

ទស្សនៈនេះនឹងអាចនិយាយថា សាតាំងដែលក្នុងគម្ពីរវិវរណៈ បានចែងថា ត្រូវបាន "ចង" ហើយបោះវាចោលទៅក្នុងជង្ហុកធំ ទាំងខ្ទប់ ហើយបិទត្រាពីលើ "ដើម្បីកុំឲ្យវានាំអស់ទាំងសាសន៍ ឲ្យវង្វេងទៀត" ហើយធ្វើឲ្យអំណាចរបស់វាថយចុះមួយចំនួនធំ កំឡុងពេលព័ន្ធកិច្ចរបស់ព្រះគ្រីស្ទនៅលើផែនដីនេះ (ម៉ាថ ១២:២៨-២៩; លូក ១០:១៨) ។ ការដែលសាវក ប៉ុល អាចនឹងបង្រៀនដល់ពួកសាសន៍ដទៃទាំងអស់អំពី "ព្រះអម្ចាស់យេស៊ូវគ្រីស្ទ តាមចិត្ត ឥតមានអ្នកណាឃាត់ឃាំងឡើយ" (កិច្ច ២៨:៣១) គឺជាការមួយដែលបង្ហាញថា សាតាំងត្រូវបាន "ចង" ហើយ ដូច្នេះវានឹងមិន "នាំអស់ទាំងសាសន៍ ឲ្យវង្វេងទៀត" ទេ ។

ជាញឹកញាប់ ទស្សនៈនេះគេហៅថា ទស្សនៈអសហាសវត្ស ពីព្រោះអស់អ្នកដែលប្រកាន់នូវទស្សនៈនេះ មិនជឿថាគម្ពីរវិវរណៈ ២០:៤-៥ បង្រៀនពីរាជ្យមួយពាន់ឆ្នាំនៅពេលអនាគត មុនពេលការយាងមកវិញរបស់ព្រះយេស៊ូវទេ ។ ជំនួសមកវិញ ពួកគេជឿថា នៅពេលព្រះគ្រីស្ទយាងត្រឡប់មកវិញ នឹងមានការរស់ឡើងវិញមួយនៃពួកអ្នកជឿ និងទាំងពួកមិនជឿ ។ ពួកអ្នកដែលជឿព្រះយេស៊ូវនឹងទៅស្ថានសួគ៌ ជា ពួកអ្នកដែលនឹងមិនប្រឈមមុខនឹងការជំនុំជំរះចុងក្រោយ និងការផ្តន្ទាទោសអស់កល្បជានិច្ច ។ នៅពេលនៅ ស្ថានសួគ៌ថ្មី និងផែនដីថ្មី នឹងចាប់ផ្តើម ហើយស្ថិតស្ថេរនៅអស់កល្បជានិច្ចទេ ។ ការវែកញែកមួយដែលគាំទ្រដល់ទស្សនៈនេះ គឺថាវាសាមញ្ញណាស់ ហើយមិនស្មុកស្មាញទេ គឺព្រះគ្រីស្ទយាង

ត្រឡប់មកវិញ បន្ទាប់មកមានការជំនុំជំរះ ហើយបន្ទាប់មកយើងរស់នៅក្នុងស្ថានសួគ៌ថ្មី និងផែនដីថ្មីជារៀងរហូត ។

*ទស្សនៈទី២- បុច្ឆសហាសវត្ស: រាជ្យមួយពាន់ឆ្នាំនឹងមកបន្តិចម្តងៗ ហើយព្រះយេស៊ូវនឹងយាងមកបន្ទាប់ពីមួយពាន់ឆ្នាំនោះ*

ពួកគ្រីស្ទានផ្សេងទៀតជឿថា ព្រះយេស៊ូវនឹងត្រឡប់មកវិញបន្ទាប់ពីមួយពាន់ឆ្នាំដែលបានចែងនៅក្នុងគម្ពីរវិវរណៈ ២០:៤-៥ ។ នៅខណៈពេលដែលពួកជំនុំរីកចំរើន ពួកគ្រីស្ទានកាន់តែបន្តមានឥទ្ធិពលកាន់តែខ្លាំងឡើងៗ នោះសង្គមនឹងចាប់ផ្តើមធ្វើតួនាទីកាន់តែច្រើននៅក្នុងខ្នាតរបស់ព្រះ ។ បន្តិចម្តងៗ "សម័យសហាស្សវត្ស" មួយ នៃសេចក្តីសុខសាន្ត និងសេចក្តីសុចរិតដ៏ធំ (មិនចាំបាច់មួយពាន់ឆ្នាំពិតប្រាកដនោះទេ) នឹងកើតឡើងនៅលើផែនដីនេះ ។ ព្រះគ្រីស្ទនឹងមិនសោយរាជ្យខាងរូបកាយ នៅលើផែនដីនេះ នៅក្នុងកំឡុងនេះ ។ ជំនួសមកវិញពួកគ្រីស្ទាននឹងមានឥទ្ធិពលដ៏ខ្លាំងមួយនៅក្នុងសង្គម ហើយរាជ្យរបស់ពួកគ្រីស្ទាននឹងកើតឡើងតាមរយៈឥទ្ធិពលនៃគ្រីស្ទាននេះឯង ។ ពួកអ្នកដែលគាំទ្រដល់ទស្សនៈនេះ ផ្តោតទៅលើខគម្ពីរដែលបង្ហាញពី របៀបដែលនគរព្រះរីកចំរើនឡើងដោយស្ងាត់ៗតែទៀតទាត់ ពីការចាប់ផ្តើមដ៏តូចមួយ ទៅដល់ចុងបញ្ចប់ដ៏ធំមួយ ។ ឧទាហរណ៍៖ មានរឿងប្រៀបប្រដូចនឹងគ្រាប់ពូជដ៏តូចល្អិត ដែលក្លាយជាដើមឈើដ៏ធំ (ម៉ាថ ១៣:៣១-៣២) ហើយនិងព្រះបន្ទូលរបស់ព្រះយេស៊ូវថា "នគរស្ថានសួគ៌

ប្រៀបដូចជាដំបែ ដែលស្ត្រីម្នាក់បានយកមកលាយនឹងម្សៅ៣រង្វាល់ ទាល់តែម្សៅនោះបានដោរឡើងគ្រប់ទាំងអស់” (ម៉ាថ ១៣:៣៣) ។ អ្នកបុច្ឆសបាសវត្សនិយម ក៏ផ្តោតសំខាន់លើព្រះបន្ទូលរបស់ព្រះយេស៊ូវដែលថា “គ្រប់ទាំងអំណាចបានប្រគល់មកខ្ញុំនៅលើស្ថានសួគ៌ ហើយលើផែនដីផង” ផងដែរ (ម៉ាថ ២៨:១៨) ហើយពួកគេរំពឹងថា លទ្ធផលមួយនៃនគរព្រះ នឹងនៅតែបន្តរីកចំរើនជាមួយនឹងអំណាចព្រះចេស្តាដ៏ធំទូទាំងផែនដីទាំងមូល រហូតទាល់តែមានរាជ្យមួយពាន់ឆ្នាំមួយនៅលើផែនដីនេះ ។

យោងតាមទស្សនៈនេះ ព្រះយេស៊ូវនឹងយាងត្រឡប់មកវិញ នៅខាងចុងនៃរាជ្យមួយពាន់ឆ្នាំនេះ ។ ពេលនោះនឹងមានសេចក្តីរស់ឡើងវិញមួយនៃពួកអ្នកជឿ និងពួកអ្នកមិនជឿ ។ ពួកអ្នកដែលជឿដល់ទ្រង់ នឹងទៅស្ថានសួគ៌ ជា ពួកអ្នកដែលនឹងមិនប្រឈមមុខនឹងសេចក្តីជំនុំជំរះចុងក្រោយ និងការផ្តន្ទាទោសអស់កល្បជានិច្ច ។ នៅពេលនោះ ស្ថានសួគ៌ថ្មី និងផែនដីថ្មី នឹងចាប់ផ្តើម ហើយស្ថិតស្ថេរនៅជារៀងរហូត ហើយព្រះគ្រីស្ទនឹងមានវត្តមាននៅលើផែនដី ដើម្បីសោយរាជ្យខាងឯរូបកាយ ។ ទស្សនៈនេះគេហៅថា *ទស្សនៈបុច្ឆសបាសវត្ស* ពីព្រោះការយាងត្រឡប់មកវិញរបស់ព្រះគ្រីស្ទ ហើយនិងរាជ្យរបស់ទ្រង់ នឹងកើតឡើង *បន្ទាប់ពី*មួយពាន់ឆ្នាំនៅពេលអនាគតមួយ ។

*ទស្សនៈទី៣- បុរេសហស្សវត្ស: រាជ្យមួយពាន់ឆ្នាំនឹងមកភ្លាម ហើយព្រះយេស៊ូវនឹងយាងត្រឡប់មកមុនរាជ្យមួយពាន់ឆ្នាំនោះ*

ជាទីបញ្ចប់ មានពួកគ្រីស្ទានដែលជឿថា ព្រះយេស៊ូវនឹងយាងមកវិញមុនព្រឹត្តិការណ៍នានានៃគម្ពីរវិវរណៈ ២០:១-១០ ។ ការនេះគេហៅថាទស្សនៈបុរេសហស្សវត្ស ពីព្រោះវាប្រកាន់ថា ព្រះគ្រីស្ទនឹងយាងមកវិញមុនរាជ្យមួយពាន់ឆ្នាំ ។ ទស្សនៈនេះក៏ប្រកាន់ផងដែរថា មុនការយាងមកវិញរបស់ព្រះគ្រីស្ទ នឹងមានគ្រាទុក្ខលំបាកធំមួយនៅលើផែនដីនេះ ជួនកាលគេហៅវាថា សេចក្តីវេទនាដ៏ធំ (សូមមើល ម៉ាថ ២៤:២១-៣១) ។

យោងតាមទស្សនៈបុរេសហស្សវត្ស ព្រះគ្រីស្ទនឹងយាងត្រឡប់មកវិញ ហើយសោយរាជ្យខាងរូបកាយលើផែនដីនេះអស់រយៈពេលមួយពាន់ឆ្នាំ ដែលបានចែងនៅក្នុងវិវរណៈ ២០:៤-៥ (មិនចាំបាច់សំដៅថាមួយពាន់ឆ្នាំពិតៗនោះទេ) ។ នៅពេលដែលព្រះគ្រីស្ទយាងមកវិញដើម្បីចាប់ផ្តើមរាជ្យមួយពាន់ឆ្នាំរបស់ទ្រង់ អស់អ្នកដែលជឿទ្រង់នឹងត្រូវបានប្រោសឲ្យរស់ពីស្លាប់ ដើម្បីសោយរាជ្យជាមួយទ្រង់ ។ នេះគឺជាអត្ថន័យនៃគម្ពីរវិវរណៈ ២០:៤ "អ្នកទាំងនោះបានរស់វិញ ហើយក៏សោយរាជ្យជាមួយនឹងព្រះគ្រីស្ទនៅមួយពាន់ឆ្នាំ" ។

នៅកំឡុងពេលមួយពាន់ឆ្នាំនោះ សាតាំង និងពួកអារក្សរបស់វា នឹងត្រូវដកចេញទាំងអស់ពីគ្រប់ទាំងឥទ្ធិពលនៅលើផែនដីនេះ ដូចដែលពិពណ៌នានៅក្នុងគម្ពីរវិវរណៈ ២០:១-៣ ហើយថា៖

ខ្ញុំក៏ឃើញទេវតាមួយ ចុះពីស្ថានសួគ៌មក ទាំងកាន់កូនសោជង្ហុកធំ និង ច្រវាក់មួយយ៉ាងធំនៅដៃ ទេវតានោះក៏ចាប់នាគចងវាទុកមួយពាន់ឆ្នាំ គឺជា ពស់ពីបុរាណដែលជាអារក្សឈ្មោះថា សាតាំង ក៏បោះវាចោលទៅក្នុង ជង្ហុកធំ ទាំងខ្ទប់ ហើយបិទត្រាពីលើ ដើម្បីកុំឲ្យវានាំអស់ទាំងសាសន៍ឲ្យ វង្វេងទៀត ទាល់តែផុតពីមួយពាន់ឆ្នាំនោះទៅ ក្រោយនោះត្រូវតែស្រាយ វាលែងបន្តិច ។

ដោយព្រោះព្រះយេស៊ូវនឹងសោយរាជ្យនៅក្នុងសេចក្តីសុខសាន្ត និង សេចក្តីសុចរិតលើផែនដីនេះ នោះមនុស្សជាច្រើននៅលើផែនដីនឹងបែរមកឯទ្រង់ សំរាប់សេចក្តីសង្គ្រោះរបស់ពួកគេ ។ ប៉ុន្តែ នឹងនៅតែមានអ្នកមិនជឿនៅលើផែនដី នេះ ដូចជាមានពួកអ្នកខ្លះមាន “សេចក្តីសង្ស័យ” ក្រោយពីគេបានឃើញ ព្រះយេស៊ូវនៅក្នុងរូបកាយដែលរស់ឡើងវិញរបស់ទ្រង់ (ម៉ាថ ២៨:១៧) ។ អ្នកខ្លះ នឹងមិនជឿទេ ដោយព្រោះ សេចក្តីជំនឿពិតប្រាកដ គឺជាអ្វីមួយដែលត្រូវតែមកពី ចិត្តមួយដែលផ្លាស់ប្រែពីខាងក្នុង ហើយជាអ្វីមួយដែលមិនអាចបង្ខំបាន សូម្បីតែ ដោយភស្តុតាង និងការរំភើបខាងក្រៅដ៏គួរឲ្យចាប់អារម្មណ៍ក៏ដោយ ។ សូម្បីតែ ពុំមានឥទ្ធិពលពីសាតាំង ឬអារក្ស នៅ លើផែនដីនេះក៏ដោយ ក៏នៅតែមានមនុស្ស ធ្វើអាក្រក់ដដែរ នោះបង្ហាញឲ្យឃើញថា អំពើបាបរបស់យើងពិតជាមិនត្រូវ បណ្តាលមកដោយសារសាតាំងទេ ប៉ុន្តែជាទំនួលខុសត្រូវរបស់មនុស្សជាតិវិញ ដែលពួកគេជាអ្នកធ្វើបាបនោះ ។

នៅក្នុងទស្សនៈបុរេសហស្សវត្សនេះ បន្ទាប់ពីរាជ្យមួយពាន់ឆ្នាំរបស់ព្រះគ្រីស្ទនៅលើផែនដីនេះ ការជំនុំជំរះចុងក្រោយនឹងមក ហើយពួកអ្នកដែលជឿព្រះយេស៊ូវ នឹងនៅតែបន្តសោយរាជ្យជាមួយទ្រង់ជារៀងរហូតអស់កល្ប រីឯពួកអ្នកដែលបដិសេធទ្រង់វិញនឹងត្រូវជាប់មានទោសអស់កល្បជានិច្ច ។

ព្រះគម្ពីរហាក់ដូចជាគាំទ្រចំពោះគោលជំហរនេះ លើសជាងជំហរផ្សេងៗទៀត ។ បទគម្ពីរវិវរណៈ ២០:១-៦ ជាអំណានងាយស្រួល ហើយធម្មតាមួយ ហើយមនុស្សជាច្រើនបានយល់អំពីវានៅក្នុងរបៀប តាំងពីពួកជំនុំដំបូងមកម្ល៉េះ ។ លើសពីនោះទៀត បទគម្ពីរសញ្ញាចាស់ដូចជានៅក្នុងគម្ពីរអេសាយ ៦៥:២០ បានចង្អុលបង្ហាញពីគ្រាមួយនៅពេលអនាគត ដែលមានលក្ខណៈផ្សេងគ្នាពីសម័យនេះ គឺនៅពេលដែលអំពើបាប និងសេចក្តីស្លាប់មិនត្រូវបានដោះចេញ នោះ “នឹងលែងមានកូនតូចដែលរស់នៅតែប៉ុន្មានថ្ងៃ ឬមនុស្សចាស់ដែលមិនបានរស់នៅឲ្យពេញកំណត់អាយុតទៅទៀត ដ្បិតអ្នកណាដែលស្លាប់ក្នុងអាយុ ១០០ឆ្នាំ នោះគេនឹងរាប់ថា ជា ក្មេងទេ ហើយមនុស្សបាបណាដែលរស់ដល់ត្រឹម ១០០ឆ្នាំ នោះត្រូវបណ្តាសាវិញ” ។ បទគម្ពីរផ្សេងទៀត ដូចជាគម្ពីរទំនុកដំកើង ៧២:៨-១៤; អេសាយ ១១:២-៩; សាការី ១៤:៦-២១; ១ កូរិនថូស ១៥:២៤ និង វិវរណៈ ២:២៧; ១២:៥ ហើយនិង ១៩:១៥ ហាក់ដូចជាចង្អុលបង្ហាញពីកំឡុងនៃគ្រាមួយនៅពេលដែលរាជ្យរបស់ព្រះគ្រីស្ទលើគ្រប់ទាំងអស់ ត្រូវបានឃើញនៅក្នុងរបៀបដ៏អស្ចារ្យជាងនេះមួយ ប៉ុន្តែអំពើបាប និងសេចក្តីអាក្រក់នៅតែមាននៅលើផែនដី

នេះនៅឡើយ ។ ចំនុចនេះ ស័ក្តិសមនឹងរូបភាពមួយនៃរាជ្យមួយពាន់ឆ្នាំនៅពេលអនាគតរបស់ព្រះគ្រីស្ទ ។

លើសពីនោះ រាជ្យអនាគតមួយ តែមិនមែនជារាជ្យចុងក្រោយរបស់ព្រះគ្រីស្ទ ត្រូវបានគាំទ្រដោយបទគម្ពីរដូចជា វិវរណៈ ២:២៦-២៧ ដែលចង្អុលបង្ហាញពីការគ្រប់គ្រងមួយដោយ "ដំបងដែក" លើមនុស្សបះបោរមួយពួក ។ ប្រភេទនៃការគ្រប់គ្រងនេះ គឺជាការចង្អុលបង្ហាញឲ្យឃើញអំពីបុរេរាជ្យមួយពាន់ឆ្នាំមួយរបស់ព្រះគ្រីស្ទ ។ រាជ្យនេះហាក់ដូចជាត្រូវបានទទួលការគាំទ្រយ៉ាងខ្លាំង ពីបទគម្ពីរសញ្ញាថ្មីដទៃទៀត ដែលបញ្ជាក់ថា អ្នកជឿព្រះយេស៊ូវ នឹងបានសោយរាជ្យលើផែនដីនេះជាមួយនឹងទ្រង់ នៅពេលមួយនាថ្ងៃអនាគត (លូក ១៩:១៧, ១៩; ១ កូរិន ៦:៣; វិវរ ២:២៦-២៧; ៣:២១) ។

មានភាពខុសគ្នាមួយលើទស្សនៈបុរេសបាសវត្ស ដែលមានអ្នកជឿតាមជាច្រើននៅក្នុងសហរដ្ឋអាមេរិក ។ ដោយព្រោះទស្សនៈប្រកាន់ថា ព្រះគ្រីស្ទនឹងយាងមកវិញមុន "សេចក្តីវេទនា" ដ៏ធំដែលបានចែងនៅក្នុងគម្ពីរម៉ាថាយ ២៤:២១-៣១ ។ គេហៅទស្សនៈនេះថា *ទស្សនៈបុរេសបាសវត្សមុនសេចក្តីវេទនា* ។ ពួកអ្នកដែលប្រកាន់ទស្សនៈនេះ ជឿថាព្រះគ្រីស្ទនឹងយាងមកវិញពីរដង គឺការយាងមកវិញជាសំងាត់មួយ ដើម្បីយកពួកគ្រីស្ទានពីលោកិយនេះ ហើយប្រាំពីរឆ្នាំក្រោយមក ទ្រង់យាងមកវិញជាសាធារណៈ ជា ពេលដែលទ្រង់នឹងនាំយកពួកគ្រីស្ទានមកឯផែនដីវិញ ដើម្បីសោយរាជ្យជាមួយទ្រង់ក្នុងរយៈពេលមួយពាន់ឆ្នាំដូចដែលបានចែងនៅក្នុងគម្ពីរវិវរណៈ ២០:៤-៥ ។ កំឡុងប្រាំពីរឆ្នាំដែលព្រះគ្រីស្ទ និងពួក

គ្រីស្ទាន បានអវត្តមានពីផែនដីនេះ នោះនឹងមានគ្រានៃសេចក្តីវេទនាដ៏ធំមួយ នៅពេលដែលសាសន៍យូដាដ៏ច្រើនសន្ធឹកសន្ធាប់ នឹងទុកចិត្តលើព្រះគ្រីស្ទ ជា ព្រះម៉ែស៊ីរបស់ពួកគេ ហើយប្រកាសដំណឹងល្អដល់ពួកអ្នកដែលនៅសល់លើផែនដីនេះ ។

ការលំបាកជាមួយនឹងគោលជំហរនេះ គឺថា វា ពិបាករកបទគម្ពីរដែលនិយាយអំពីការយាងមកវិញជាសំងាត់របស់ព្រះគ្រីស្ទ ។ បទគម្ពីរដែលនិយាយអំពីការយាងមកវិញរបស់ព្រះគ្រីស្ទ តែងតែនិយាយនៅក្នុងភាពដែលមើលឃើញហើយជាសាធារណៈ ដូចជានៅក្នុង ១ ថែស្សាឡូនីច ៤:១៦ “ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់មួយព្រះឱស្ឋទាំងមានឮសំឡេងមហាទេវតា និងត្រែរបស់ព្រះផង” ។

## ស្តេចដ៏មានជ័យជំនះ

ប្រហែលមិនមែនជាការគួរឲ្យភ្ញាក់ផ្អើលទេ ដែលពួកគ្រីស្ទានមានទស្សនៈផ្សេងគ្នាអំពីអនាគតនោះ ។ ពីព្រោះនេះជាប្រធានបទដែលពិបាកយល់ យើងមិនអាចដឹងច្បាស់ពីអនាគតនោះទេ ព្រោះវាមិនទាន់កើតឡើងនៅឡើយ! ប៉ុន្តែដោយការមិនគិតពីពេលកំណត់នៃការយាងមកវិញរបស់ព្រះគ្រីស្ទ ពួកគ្រីស្ទានទាំងអស់គ្នាជឿថាជ័យជំនះចុងក្រោយរបស់ព្រះគ្រីស្ទលើសាតាំង (បានពិពណ៌នានៅក្នុងគម្ពីរវិវរណៈ ២០:៧-១០) នឹងកើតឡើងនៅពេលអនាគតជាមិនខាន ។ ពួកគេជឿថាសាតាំងនឹងត្រូវបាន “លែងពីគុក” (វិវរ ២០:៧) ដើម្បីប្រមូលពួកអ្នកដែលវានាំឲ្យវង្វេងមកធ្វើចំបាំង ។ នៅចុងបញ្ចប់នៃចំបាំង ព្រះយេស៊ូវនឹងយកឈ្នះសាតាំង និងកងទ័ព

របស់វានៅពេលតែមួយ ហើយសំរាប់ការទាំងអស់គ្រប់យ៉ាង ។ នៅចុងបញ្ចប់នៃចំបាំង សាតាំង “បានត្រូវបោះទៅក្នុងបឹងដែលឆេះជាភ្លើង និងស្ពាន់ធ័រ” ជាកន្លែងដែលវា “ត្រូវរងទុក្ខវេទនាទាំងយប់ទាំងថ្ងៃ នៅអស់កល្បជានិច្ច” (វិវរ ២០:១០) ។ នៅចុងបញ្ចប់នៃចំបាំង ព្រះយេស៊ូវ ជាស្តេចដ៏មានជ័យជំនះ នឹងអនុវត្តការជំនុំជំរះចុងក្រោយរបស់ទ្រង់ ។ ហើយបន្ទាប់មក ទ្រង់នឹងសោយរាជ្យជាដរាបតទៅ ។

ខណៈដែលព្រះយេស៊ូវបានមានបន្ទូលប្រាប់សាវក យ៉ូហាន នេះ គឺជាអ្វីមួយដែលពួកគ្រីស្ទានមានសេចក្តីសង្ឃឹមដ៏ធំ ដោយព្រោះទ្រង់បានមានបន្ទូលថាពាក្យទាំងនេះ “ពិតប្រាកដ ហើយគួរជឿ” (វិវរ ២២:៦) ។ ព្រះយេស៊ូវបានមានបន្ទូលថា “មើល អញមកជាឆាប់ ទាំងនាំយកដង្វាយមកជាមួយ ដើម្បីនឹងចែកឲ្យគ្រប់គ្នា តាមការដែលខ្លួនបានធ្វើ” (វិវរ ២២:១២) ។ ការឆ្លើយតបនៃពួកអ្នកជឿព្រះយេស៊ូវ គឺមិនគិតពីការបកស្រាយនៃបទគម្ពីរវិវរណៈ ២០:១-៦ គួរដូចជាការឆ្លើយតបរបស់សាវក យ៉ូហានដែរគឺថា “អាម៉ែន ព្រះអម្ចាស់យេស៊ូវអើយ សូមយាងមក !” (វិវរ ២២:២០) ។

# បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១. តើការអ្វីខ្លះអំពី Eschatology ដែលពួកគ្រីស្ទានទាំងអស់គួរយល់ស្រប តាម ? តើការមួយណាក្នុងចំណោមនោះ ដែលធ្វើឲ្យអ្នកមានសេចក្ដីអំណរបំផុត ?

២. តើមានបញ្ហាអ្វីខ្លះដែលទាក់ទងនឹង Eschatology ដែលផ្សេងពីគំនិត របស់ពួកគ្រីស្ទាន ? តើពួកគ្រីស្ទានគួរដោះស្រាយជាមួយភាពខុសគ្នាទាំងនេះ ដោយរបៀបណា ?

៣. សូមចំណាយពេលមួយភ្លែត អានគម្ពីរវិវរណៈ ២២:១២ ។ ដើម្បីឆ្លើយតប ចំពោះអំណាននោះ សូមចំណាយពេលមួយភ្លែតដើម្បីអធិស្ឋាន សេចក្ដីអធិស្ឋាន របស់សាវក យ៉ូហាន ដូចដែលឃើញនៅក្នុងគម្ពីរវិវរណៈ ២២:២០ ។

# ជំពូក ១៩

# តើអ្វីទៅជាការជំនុំជំរះចុងក្រោយ ?

បន្ទាប់ពីរាជ្យមួយពាន់ឆ្នាំនៃព្រះគ្រីស្ទ (យោងតាម ទស្សនៈនានា ដែលបានពិភាក្សា នៅក្នុងជំពូកមុន) ហើយបន្ទាប់ពីជ័យជំនះលើសាតាំង និងកងទ័ពរបស់វា ព្រះយេស៊ូវគ្រីស្ទនឹងជំនុំជំរះមនុស្សជាតិទាំងអស់ពី “បល្ល័ង្កសមួយយ៉ាងធំ” របស់ទ្រង់ (វិវរ ២០:១១-១៥) ។

ការជំនុំជំរះចុងក្រោយនេះ គឺជាកំពូលព្រឹត្តិការណ៍មួយនៃកំពូលព្រឹត្តិការណ៍ជាច្រើនទូទាំងប្រវត្តិសាស្ត្រ ដែលព្រះបានប្រទានរង្វាន់ដល់សេចក្តីសុចរិត ឬដាក់ទណ្ឌកម្មដល់សេចក្តីទុច្ចរិត (ឧះ ទឹកជំនន់នៅគម្ពីរលោកុប្បត្តិ ៦-៨ ឬការវិនាសអន្តរាយដ៏យោរយៅនៃក្រុងសូដុំម និងក្រុងកូម៉ូរ៉ា នៅ ក្នុងលោកុប្បត្តិ ១៩:១-២៦) ។ ការជំនុំជំរះចុងក្រោយគឺជា “ថ្ងៃនៃសេចក្តីក្រោធ...ជាថ្ងៃដែលសេចក្តីជំនុំជំរះដ៏សុចរិតរបស់ព្រះ នឹងសំដែងមក” (រ៉ូម ២:៥) ។ វាជាថ្ងៃដែលព្រះបានកំណត់ថ្ងៃដែល “ទ្រង់នឹងជំនុំជំរះលោកិយដោយយុត្តិធម៌” តាមរយៈព្រះគ្រីស្ទ (កិច្ច ១៧:៣១) ។

## តើមានអ្វីកើតឡើងនៅពេលការជំនុំជំរះចុងក្រោយ ?

ព្រះយេស៊ូវ "ព្រះអង្គនេះហើយដែលព្រះបានតាំងឡើងឲ្យជំនុំជំរះដល់ទាំងមនុស្សរស់ និងមនុស្សស្លាប់ផង" (កិច្ច ១០:៤២; សូមមើល ២ ធី ៤:១ និងម៉ាថ ២៥:៣១-៣៣ ផងដែរ) ។ "អំណាចមកទ្រង់ឲ្យជំនុំជំរះ" គឺត្រូវបានផ្តល់មកដោយព្រះ (យ៉ូហាន ៥:២៧) ។ "ពេលកំណត់ដែលត្រូវជំនុំជំរះពួកមនុស្សស្លាប់" នេះ នឹងជាពេលមួយសំរាប់ការ "ប្រទានរង្វាន់" ដល់អ្នកបំរើរបស់ព្រះ ហើយក៏ជាពេលមួយសំរាប់ការ "បំផ្លាញពួកអ្នកដែលបង្ខូចផែនដីផង" (វិវរ ១១:១៨) ។ ដូច្នេះ នៅពេលនោះ ទាំងពួកអ្នកជឿ និងទាំងពួកអ្នកមិនជឿព្រះយេស៊ូវ នឹងទទួលការជំនុំជំរះ ។

សំរាប់អ្នកមិនជឿ សាវក ប៉ុល បាននិយាយថា "ពួកអ្នកដែលទាស់ទទឹង មិនព្រមស្តាប់តាមសេចក្តីពិត គឺស្តាប់តាមតែសេចក្តីទុច្ចរិតវិញ នោះនឹងបានសេចក្តីក្រោធ និងសេចក្តីឃោរឃៅ" (រ៉ូម ២:៨) ។ នៅក្នុងគម្ពីរសញ្ញាចាស់ មានការដឹងប្រាកដច្បាស់មួយថា "ព្រះទ្រង់នឹងនាំគ្រប់ការទាំងអស់មក ដើម្បីជំនុំជំរះ ព្រមទាំងអ្វីៗដែលលាក់កំបាំងផង ទោះល្អ ឬអាក្រក់ក្តី" (សាស ១២:១៤) ។ អស់អ្នកណាដែលមិនសំឡឹងមើលព្រះយេស៊ូវសំរាប់សេចក្តីសង្គ្រោះរបស់ខ្លួន នឹងទទួលការជំនុំជំរះ ទៅតាមអ្វីដែលពួកគេបានធ្វើ (វិវរ ២០:១២) ។ ព្រះនឹងយុត្តិធម៌ជាមិនខាន ។ កំរិតនៃទណ្ឌកម្ម នឹងមានភាពខុសគ្នា ទៅ តាមអ្វីដែលបុគ្គលម្នាក់ៗបានធ្វើ ដ្បិតអ្នកខ្លះ "នឹងត្រូវទោសធ្ងន់ជាងទៅទៀត" (លូក ២០:៤៧) ។ យោងទៅតាមសេចក្តីបង្រៀនរបស់ព្រះយេស៊ូវ អំពីភាពខុសគ្នារវាងបាវបំរើដែលបានស្គាល់ចិត្ត

របស់ចៅហ្វាយ ហើយនិងបាវបំរើដែលមិនបានស្គាល់ចិត្តរបស់ចៅហ្វាយ (លូក ១២:៤៧-៤៨) វាហាក់ដូចជាការដាក់ទណ្ឌកម្មនោះ នឹងមានភាពខុសគ្នាទៅតាមចំណេះដឹងដែលមនុស្សមាន អំពីការតំរូវរបស់ព្រះផងដែរ ។

ពួកយើងដែលជាអ្នកជឿព្រះយេស៊ូវ ក៏នឹង "ត្រូវឈរនៅមុខទីជំនុំជំរះរបស់ផងព្រះ" ដើម្បី "នឹងត្រូវរៀបរាប់ទូលថ្វាយព្រះ" (រ៉ូម ១៤:១០-១២) ។ ប៉ុន្តែការជំនុំជំរះចុងក្រោយសំរាប់អ្នកជឿ នឹងមិនទទួលបាននូវការដាក់ទោសនោះទេ តែនឹងបានទទួលរង្វាន់វិញ ។ ព្រះយេស៊ូវបានសន្យានៅក្នុងគម្ពីរយ៉ូហាន ៥:២៤ "អ្នកណាដែលស្តាប់ពាក្យខ្ញុំ ហើយជឿដល់ព្រះអង្គដែលចាត់ខ្ញុំឲ្យមក អ្នកនោះមានជីវិតដ៏នៅអស់កល្បជានិច្ច *ហើយមិនដែលត្រូវជំនុំជំរះឡើយ* គឺបានកន្លងហួសពីសេចក្តីស្លាប់ទៅដល់ជីវិតវិញ" ។ សាវក ប៉ុល ក៏បញ្ជាក់ការនេះផងដែរ នៅពេលដែលគាត់បានសរសេរនៅក្នុងគម្ពីររ៉ូម ៨:១ "អ្នកណាដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវនោះគ្មានទោសសោះ" ។

ដូច្នេះការជំនុំជំរះចុងក្រោយ គួរតែមិនមែនជាប្រភពនៃការភ័យខ្លាចសំរាប់អ្នកជឿនោះទេ ប៉ុន្តែវាជាការលើកទឹកចិត្តសំរាប់ពួកគេវិញ ដើម្បីធ្វើឲ្យគោលបំណងរបស់ពួកគេខំសង្វាត "ឲ្យបានគាប់ព្រះហឫទ័យទ្រង់" (២ កូរិន ៥:៩) ។ គ្រប់អំពើបាបដែលយើងបានធ្វើ ត្រូវបានសងរួចអស់ដោយសារព្រះគ្រីស្ទ ហើយព្រះជាម្ចាស់ក៏បានអត់ទោសឲ្យជារៀងរហូតផងដែរ ។ នៅពេលជំនុំជំរះ យើងនឹងទទួលបានរង្វាន់ដែលយើងសមទទួលតាមការដែលយើង "បានធ្វើពីកាលនៅក្នុង

រូបកាយរៀងខ្លួន ទោះល្អ ឬអាក្រក់ក្តី” (២ កូរិន ៥:១០) ។ មនុស្សអាក្រក់នឹងបាត់ទៅ ហើយមនុស្សល្អនឹងបានទទួលរង្វាន់ (១ កូរិន ៣:១២-១៥) ។

ទោះបីជា មានកំរិតនានានៃការទទួលរង្វាន់នៅនគរស្ថានសួគ៌ក៏ដោយ ក៏សេចក្តីអំណររបស់ពួកគេទាំងអស់ នឹងបានពេញលេញដែរ ។ នេះដោយព្រោះតែសេចក្តីអំណររបស់យើង នឹងមិនមកពីអ្វីមួយ ឬឋានៈដែលយើងមាននោះទេ ប៉ុន្តែមកពីទំនាក់ទំនងរបស់យើងជាមួយព្រះវិញ ។ នៅនគរស្ថានសួគ៌ សេចក្តីអំណររបស់យើងនឹងបានស្កប់ចិត្តយ៉ាងពេញលេញនៅក្នុងព្រះជាម្ចាស់ ជា សេចក្តីអំណរដែលយើងអាចនៅក្នុងព្រះវត្តមានរបស់ទ្រង់ ហើយលុតចុះនៅចំពោះបល្ល័ង្ករបស់ទ្រង់ដើម្បីថ្វាយបង្គំ វា នឹងជាសេចក្តីអំណរដែលធំលើសជាងសេចក្តីអំណរដែលមាននៅក្នុងរង្វាន់ណាទាំងអស់ (វិវរ ៤:១០-១១) ។

ជំនួសពីការជំរុញឲ្យមានវិញ្ញាណនៃការប្រកួតប្រជែង ការពិតដែលថាយើងនឹងទទួលបានរង្វាន់មួយសំរាប់អ្វីដែលយើងបានធ្វើ គួរតែលើកទឹកចិត្តយើងឲ្យខិតខំកាន់តែខ្លាំងឡើងដើម្បី “ពិចារណាមើលគ្នាទៅវិញទៅមកដែរ ដើម្បីនឹងបណ្តាលឲ្យមានសេចក្តីស្រឡាញ់ ហើយឲ្យប្រព្រឹត្តិការល្អផង ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ ត្រូវឲ្យកំឡាចិត្តគ្នាវិញ” ឲ្យកាន់តែខ្លាំងឡើងផង ដ្បិតថ្ងៃនៃការជំនុំជំរះចុងក្រោយហាក់ដូចជាជិតមកដល់ហើយ (ហេ ១០:២៤-២៥) ។

មិនត្រឹមតែអ្នកជឿ និងអ្នកមិនជឿ ដែលនឹងត្រូវទទួលការជំនុំជំរះប៉ុណ្ណោះទេ គម្ពីរយូដាស ៦ និង ២ ពេត្រុស ២:៤ បានប្រាប់យើងថា ទេវតាដែលបះបោរក៏

នឹងត្រូវទទួលការជំនុំជំរះដែរ ។ ហើយ ១ កូរិនថូស ៦:៣ បានប្រាប់ឲ្យដឹងថា ទេវតាល្អ នឹងត្រូវបានវាយតំលៃចំពោះការងារ និងការបំរើរបស់ពួកគេ ។

## គោលបំណងនៃការជំនុំជំរះចុងក្រោយ

ការជំនុំជំរះចុងក្រោយនឹងមិនកើតឡើង ដើម្បីឲ្យព្រះអាចកំណត់លក្ខខណ្ឌនៃចិត្ត របស់បុគ្គលម្នាក់ៗបាននោះទេ ដ្បិតទ្រង់ជ្រាបលក្ខខណ្ឌចុងក្រោយនៃចិត្តមនុស្ស គ្រប់រូបមុនពេលបានចាប់ផ្តើមទៅទៀត ។ ជំនួសមកវិញ ការជំនុំជំរះចុងក្រោយនឹង កើតឡើង នោះទើបព្រះអាចបង្ហាញសិរីល្អរបស់ទ្រង់ដល់មនុស្សជាតិទាំងអស់ ដោយការបង្ហាញឲ្យឃើញពីសេចក្តីយុត្តិធម៌ ព្រមទាំងសេចក្តីមេត្តាករុណារបស់ ទ្រង់ក្នុងពេលតែមួយ ។

ការជំនុំជំរះចុងក្រោយនឹងមានភាពយុត្តិធម៌ទាំងស្រុង ។ មនុស្សម្នាក់ៗ មិនថាមនុស្សដែលតំរូវសំរាប់សិរីរុងរឿងអស់កល្ប ឬក៏អ្នកដែលតំរូវឲ្យមានទោស អស់កល្បនោះទេ នឹងត្រូវបានដោះស្រាយដោយយុត្តិធម៌ នៅពេលការជំនុំជំរះចុង ក្រោយជាជាងពេលដ៏វិសេសណាទាំងអស់ ។ ព្រះនឹងជំនុំជំរះ “តាមការដែលគេ ប្រព្រឹត្តិរៀងខ្លួន” (១ ពេ ១:១៧) ដ្បិតព្រះ “មិនយោគយល់ខាងអ្នកណាសោះ” (រ៉ូម ២:១១) ។ ការជំនុំជំរះរបស់ទ្រង់នឹងពោរពេញដោយសិរីល្អនៅក្នុងការជំនុំជំរះ ចុងក្រោយរបស់ទ្រង់ ដែលយើងរាល់គ្នានឹងស្រែកឡើងថា “ហាលេលូយ៉ា សេចក្តីសង្គ្រោះ សិរីល្អ និងព្រះចេស្តា នោះជារបស់ផងព្រះនៃយើងរាល់គ្នា

ហើយ ដ្បិតសេចក្តីជំនុំជំុំរះរបស់ទ្រង់សុទ្ធតែពិតត្រង់ ហើយសុចរិតទាំងអស់” (វិវរ ១៩:១-២) ។

## ការប្រើប្រាស់ជាប្រយោជន៏នៃការជំនុំជំរះចុងក្រោយ

ដោយព្រោះមានការជំនុំជំរះចុងក្រោយមួយ នោះបានដឹងយ៉ាងប្រាកដច្បាស់ថា ចក្រវាឡរបស់ព្រះគឺយុត្តិធម៌ ។ ការជំនុំជំរះនេះធ្វើឲ្យវិញ្ញាណខាងក្នុងរបស់យើង ដែលត្រូវការសេចក្តីយុត្តិធម៌ នៅក្នុងលោកិយនេះ បានស្កប់ចិត្ត ។ ការជំនុំជំរះចុងក្រោយ ធ្វើឲ្យយើងដឹងច្បាស់ដោយមិនគិតពីអ្វីដែលកើតឡើងនោះទេ ថាព្រះទ្រង់គ្រប់គ្រង ហើយទីបំផុតទ្រង់នាំមកនូវទីបញ្ចប់ដ៏យុត្តិធម៌មួយចំពោះស្ថានភាពទាំងអស់ ។ សាវក ប៉ុល បានសរសេរនៅក្នុងគម្ពីរកូល៉ុស ៣:២៥ ថា “ឯអ្នកណាដែលប្រព្រឹត្តិខុសឆ្គង នោះនឹងទទួលតាមការកំហុសរបស់ខ្លួន ហើយទ្រង់មិនរើសមុខអ្នកណាឡើយ” ។

ដូច្នេះនៅក្នុងពន្លឺនៃការជំនុំជំរះចុងក្រោយរបស់ទ្រង់ ពួកគ្រីស្ទានគួរតែអាចអត់ទោសឲ្យគ្នា ដ្បិតយើងដឹងថា គ្រប់ទាំងបញ្ជីនឹងត្រូវបានជំរះនៅថ្ងៃនោះ ហើយគ្រប់ទាំងកំហុសនឹងធ្វើឲ្យបានត្រឹមត្រូវវិញ ។ ដោយព្រោះមានការជំនុំជំរះចុងក្រោយមួយ ពួកគ្រីស្ទានមិនគួរសងសឹកដោយខ្លួនឯងទេ ប៉ុន្តែជំនួសមកវិញ “ចូរថយចេញពីសេចក្តីកំហឹងទៅ ដ្បិតមានសេចក្តីចែងទុកមកថា ព្រះអម្ចាស់ទ្រង់មានបន្ទូលថា ការសងសឹកនោះស្រេចនឹងអញ អញនឹងសងដល់គេ” (រ៉ូម ១២:១៩) ។ នៅពេលដែលគេធ្វើខុសចំពោះយើង យើងចង់ឲ្យការនេះមានសេចក្តី

យុត្តិធម៌នៅចំពោះព្រះ ដោយសូមឲ្យទ្រង់បានរកសេចក្តីយុត្តិធម៌នោះនៅក្នុងនាមយើង ។ យើងមានទំនុកចិត្តថានឹងមានថ្ងៃការដាក់ទោសដល់មនុស្សដែលមានទោស ហើយទោសនោះនឹងធ្លាក់លើស្មារបស់ព្រះគ្រីស្ទ ឬក៏ស្មារបស់មនុស្សមានទោស ជារៀងរហូតអស់កល្បជានិច្ច ។ នៅពេលយើងប្រព្រឹត្តិក្នុងរបៀបនេះ មានន័យថាយើងកំពុងធ្វើតាមគំរូរបស់ព្រះគ្រីស្ទ ដ្បិត "កាលគេបានជេរប្រមាថដល់ទ្រង់ នោះទ្រង់ក៏មិនបានតំហកកំហែងដល់គេដែរ គឺបានប្រគល់ព្រះអង្គទ្រង់ទៅព្រះដែលជំនុំជំរះដោយសុចរិតវិញ" (១ ពេ ២:២៣) ។

ការជំនុំជំរះចុងក្រោយ ក៏ផ្តល់ឲ្យយើងនូវការជំរុញទឹកចិត្ត ដើម្បីរស់នៅក្នុងការស្តាប់បង្គាប់ព្រះដែរ ដូច្នេះដើម្បីឲ្យយើង "ប្រមូលទ្រព្យសម្បត្តិទុកសំរាប់ខ្លួននៅឯស្ថានសួគ៌" (ម៉ាថ ៦:២០) ។ ទោះបីជា ទ្រព្យសម្បត្តិទាំងនេះមិនធ្វើឲ្យយើងរកបាននូវសេចក្តីសង្គ្រោះរបស់យើងក៏ដោយ ក៏ទ្រព្យសម្បត្តិទាំងនោះជារង្វាន់ដល់យើងសំរាប់ការល្អដែលយើងបានធ្វើដែរ ។

ការជំនុំជំរះចុងក្រោយ ក៏ផ្តល់ឲ្យយើងនូវការលើកទឹកចិត្តមួយ ដើម្បីប្រាប់អ្នកដទៃទៀត អំពីដំណឹងល្អពីព្រះយេស៊ូវ ។ ការពន្យារនៃការយាងត្រឡប់មកវិញ និងការជំនុំជំរះចុងក្រោយរបស់ព្រះអម្ចាស់ គឺពីព្រោះតែព្រះមានព្រះហឫទ័យ "មិនចង់ឲ្យអ្នកណាមួយវិនាសឡើយ គឺចង់ឲ្យមនុស្សទាំងអស់បានប្រែចិត្តវិញ" (២ ពេ ៣:៩) ។ ដូច្នេះពួកអ្នកដែលជឿព្រះយេស៊ូវ គួរចែកចាយដំណឹងល្អនៃអ្វីដែលពួកគេជឿនេះជាមួយនឹងអ្នកដទៃទៀត ។ ការដាស់តឿនដ៏ច្បាស់លាស់ពីការជំនុំជំរះចុងក្រោយរបស់ព្រះគម្ពីរ គួរលើកទឹកចិត្តដល់អ្នកដែលមិនជឿ ឲ្យបែរពីអំពើបាប

របស់ពួកគេ ហើយសំឡឹងមើលមកឯព្រះយេស៊ូវសំរាប់សេចក្តីសង្គ្រោះរបស់ពួកគេវិញ ។

## តើស្ថាននរកជាអ្វី ?

នៅពេលជំនុំជំរះចុងក្រោយ ពួកអ្នកដែលបានបដិសេធចំពោះការប្រកាសអំពីព្រះយេស៊ូវ នឹងទៅកន្លែងទណ្ឌកម្មដ៏នៅអស់កល្បជានិច្ចមួយ ។ ព្រះគម្ពីរប្រាប់យើងអំពីកន្លែងទណ្ឌកម្មដ៏នៅអស់កល្បជានិច្ចនោះថា ជាស្ថាននរក ។

ការពិពណ៌នានានាអំពីស្ថាននរកនៅក្នុងព្រះគម្ពីរ វា ពិបាកអានណាស់ ហើយការពិពណ៌នាទាំងនោះ គួរតែជាការដែលគួរធ្វើឲ្យយើងព្រួយចិត្ត ។ ព្រះយេស៊ូវមានបន្ទូលអំពីស្ថាននរកថាជា “ភ្លើងដែលឆេះអស់កល្បជានិច្ច ដែលបានរៀបចំទុកសំរាប់អារក្ស ហើយនិងពួកទេវតារបស់វា” ហើយទ្រង់បានមានបន្ទូលទៀតថា ពួកអ្នកដែលបានបដិសេធទ្រង់ក៏នឹងទៅទីនោះដែរ (ម៉ាថ ២៥:៤១) ។ វាជាកន្លែងដែល “មានដង្កូវមិនដែលស្លាប់ ហើយភ្លើងមិនដែលរលត់” (ម៉ាក ៩:៤៨) ។ វាជា “ស្ថានវេទនា” មួយ (លូ ១៦:២៨) ។ សាវកយ៉ូហាន បានប្រាប់យើងថា វា ជាកន្លែងដែលពួកអ្នកដែលបានបដិសេធទ្រង់ នឹង “ផឹកស្រាផងសេចក្តីឃោរឃៅរបស់ព្រះ ជា ស្រាឥតលាយដែលចាក់ទៅក្នុងពែងនៃសេចក្តីក្រោធរបស់ទ្រង់” ហើយ “ត្រូវរងទុក្ខវេទនានៅក្នុងភ្លើង និងស្ពាន់ធ័រចំពោះមុខនៃពួកទេវតាបរិសុទ្ធ និងកូនចៀម” ជាមួយនឹងពួកអារក្ស និងទេវតារបស់វា (វិវរ ១៤:១០) ។ “ផ្សែងនៃសេចក្តីទុក្ខលំបាករបស់គេ” នឹងហុយឡើង

“អស់កល្បជានិច្ចរៀងរាបតទៅ គេ នឹងឥតមានសេចក្ដីស្រាកស្រាន្ត...ទាំងយប់ទាំងថ្ងៃ” (វិវរ ១៤:១១) ។ ពួកយើងដែលជាពួកអ្នកបានជឿព្រះគ្រីស្ទហើយ មិនគួរភ័យខ្លាចចំពោះស្ថាននរកទេ ។ យើងគួរគិតអំពីវា ដោយក្ដីម៉ឹងម៉ាត់ និងក្ដីសោកសង្រេង ។ សូម្បីតែព្រះផ្ទាល់ទ្រង់មានបន្ទូលថា “អញមិនរីករាយចំពោះសេចក្ដីស្លាប់របស់មនុស្សអាក្រក់ឡើយ” (អេសេ ៣៣:១១) ។ ទោះបីជាពិបាកគិតពីវាក៏ដោយ គោលលទ្ធិនៃស្ថាននរក ត្រូវបានបង្រៀនយ៉ាងច្បាស់នៅក្នុងបទគម្ពីរ ដែលហាក់ដូចជាមិនអាចបដិសេធបាន ហើយវានៅតែជាប្រធានបទនៃព្រះបន្ទូលរបស់ព្រះ ។ លើសពីនេះទៀត នៅក្នុងចក្រវាឡជាកន្លែងមួយដែលមានសេចក្ដីអាក្រក់ដ៏ជ្រាលជ្រៅ ហើយមានឥទ្ធិពលខ្លាំង ដែលហៅរកសេចក្ដីក្រោធដ៏យុត្តិធម៌នៃព្រះដ៏សុចរិត និងបរិសុទ្ធមួយអង្គ ។ យើងគួរដឹងផងដែរថា សេចក្ដីអាក្រក់មិនអាចរួចខ្លួនពីការដាក់ទោសបានទេ ។ គ្រប់ការជំនុំជំរះរបស់ព្រះសុទ្ធតែយុត្តិធម៌ និងសុចរិត ពីព្រោះ “ព្រះយេហូវ៉ាទ្រង់ទៀងត្រង់... គ្មានសេចក្ដីទុច្ចរិតណានៅក្នុងទ្រង់ឡើយ” (ទំនុក ៩២:១៥) ។

# បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១. តើមានអ្វីកើតឡើងចំពោះគ្រីស្ទាន នៅពេលជំនុំជំរះចុងក្រោយ? តើមានអ្វីនឹងកើតឡើង ចំពោះពួកអ្នកដែលបានបដិសេធការប្រកាសរបស់ព្រះយេស៊ូវ?

២. តើការយល់ដឹងរបស់អ្នកអំពីការជំនុំជំរះចុងក្រោយ ធ្វើឲ្យមានឥទ្ធិពលដល់ជីវិតយើងសព្វថ្ងៃយ៉ាងដូចម្ដេច? តើវាមានឥទ្ធិពលយ៉ាងដូចម្ដេច ចំពោះរបៀបដែលអ្នកមានទំនាក់ទំនងជាមួយអ្នកដទៃទៀត?

៣. តើព្រះគម្ពីរប្រាប់យើងអ្វីខ្លះអំពីស្ថាននរក? តើការយល់ដឹងរបស់អ្នកអំពីស្ថាននរក ធ្វើឲ្យអ្នកមានអារម្មណ៍យ៉ាងដូចម្ដេច? ហេតុអ្វីបានជាវាធ្វើឲ្យអ្នកមានអារម្មណ៍បែបនោះ?

# ជំពូក ២០

# តើនគរស្ថានសួគ៌ជាអ្វី ?

បន្ទាប់ពីការជំនុំជំរះចុងក្រោយ ពួកអ្នកដែលជឿលើព្រះយេស៊ូវ នឹងចូលទៅក្នុងសេចក្ដីអំណរដ៏ពេញលេញ នៃជីវិតដែលពួកគេមាន ។ ពួកគេនឹងឮព្រះយេស៊ូវមានបន្ទូលពីអ្វីមួយដូចជា “ចូរមកទទួលមរតកចុះ គឺជានគរដែលបានរៀបចំទុកសំរាប់អ្នករាល់គ្នា តាំងពីកំណើតលោកិយមក” (ម៉ាថ ២៥:៣៤) ហើយពួកគេនឹងរស់នៅអស់កល្បជានិច្ច នៅក្នុងព្រះវត្តមានរបស់ព្រះ ។ ជាញឹកញាប់មនុស្សនិយាយពីនគរនេះថាជា “ស្ថានសួគ៌” រីឯព្រះគម្ពីរវិញ បានផាត់ពណ៌កាន់តែស្អាតឡើងលើស្ថានសួគ៌ថ្មី និងផែនដីថ្មីមួយវិញ ។

ព្រះគម្ពីរបានសន្យាពីការបង្កើតថ្មីទាំងស្រុងមួយ ។ វានឹងជា “ផ្ទៃមេឃថ្មី និងផែនដីថ្មី” ដែលព្រះនឹងបង្កើតឡើង (អេសា ៦៦:២២) ។ វាជាកន្លែងមួយដែលមានភាពសំបូរបែប ហើយល្អ ហើយថ្មី ដែល “របស់ពីមុនៗ” ដូចជាសេចក្ដីស្លាប់ ការឈឺចាប់ ការសោកសង្រេង សេចក្ដីលំបាក “នោះនឹងគ្មានអ្នកណានឹកចាំទៀត ក៏មិនដែលចូលក្នុងគំនិតឡើយ” (អេសា ៦៥:១៧) ។ វាជាកន្លែងមួយដែលស្ថានសួគ៌ និងផែនដីនឹងរួមគ្នា (វិវរ ២១:២) ហើយជាព្រះសូរសៀងមួយពីបល្ល័ង្ករបស់ព្រះ ដែលនឹងប្រកាសថា “មើល រោងឧបោសថរបស់ព្រះ បាននៅជាមួយ

នឹងមនុស្សហើយទ្រង់នឹងគង់នៅជាមួយនឹងគេ គេនឹងធ្វើជារាស្ត្ររបស់ទ្រង់ ហើយព្រះអង្គទ្រង់ក៏នឹងធ្វើជាព្រះដល់គេ” (វិវរ ២១:៣) ។

## ស្ថានសួគ៌ថ្មី ផែនដីថ្មី និងការបង្កើតថ្មី

ជាញឹកញាប់ ព្រះគម្ពីរនិយាយពីកន្លែងដែលព្រះគង់នៅសព្វថ្ងៃថាជា “នគរស្ថានសួគ៌” ។ ឧទាហរណ៍៖ ព្រះយេស៊ូវបានបង្រៀនសិស្សរបស់ទ្រង់ឲ្យអធិស្ឋានថា “ឱព្រះវរបិតានៃយើងខ្ញុំដែលគង់នៅស្ថានសួគ៌អើយ” (ម៉ាថ ៦:៩) ។ សាវក ពេត្រុស បាននិយាយថា ព្រះយេស៊ូវ “បានយាងចូលទៅក្នុងស្ថានសួគ៌ គង់នៅខាងស្តាំនៃព្រះ” (១ ពេ ៣:២២) ។ ស្ថានសួគ៌ជាកន្លែងដែលព្រះធ្វើឲ្យគេស្គាល់យ៉ាងពេញលេញបំផុត ពីព្រះវត្តមានដើម្បីនឹងប្រទានពររបស់ទ្រង់ ។ ទោះបីព្រះគង់នៅគ្រប់ទីកន្លែង តែវត្តមានដើម្បីនឹងប្រទានពររបស់ទ្រង់ គឺត្រូវបានមើលឃើញច្បាស់បំផុត នៅក្នុងស្ថានសួគ៌ ។ ស្ថានសួគ៌ គឺជាកន្លែងមួយដែលមនុស្សទាំងអស់ថ្វាយបង្គំទ្រង់ ។ ក្រៅពីបង្កើតស្ថានសួគ៌ថ្មី ព្រះនឹងបង្កើតការបង្កើតដែលនៅផែនដីជាថ្មីផងដែរ គឺផែនដី និងពួកអ្នកដែលនៅក្នុងផែនដី (២ ពេ ៣:១៣; វិវរ ២១:១) ។ សាវក ប៉ុល បានសរសេរនៅក្នុងគម្ពីររ៉ូម ៨:២១ ថា “ជីវិតទាំងនោះឯងនឹងបានរួចពីចំណងនៃសេចក្តីពុករលួយ ឲ្យបានសេរីភាពនៃសិរីល្អរបស់ពួកកូនព្រះវិញ” ។ នឹងមិនមាន “បន្លាហើយនិងអញ្ចាញ” (លោក ៣:១៨) ដែលព្រះបាននាំមកនៅក្នុងការជំនុំជំរះអំពើបាបទៀតទេ ហើយក៏នឹងមិនមានភាពមិនប្រក្រតីនៃធម្មជាតិ ដែលនាំឲ្យមានសេចក្តីវិនាសទៀតដែរ ដូចជាខ្យល់ព្យុះ ខ្យល់ព្យុះ

កំបុតត្បូង ទឹកជំនន់ គ្រោះរាំងស្ងួត ការរញ្ជួយផែនដី ។ កន្លែងដ៏ស្អាតសោភា នឹងត្រូវកែឡើងជាថ្មី ។

ពួកអ្នកដែលរស់នៅលើផែនដីថ្មី នឹងមានរូបកាយដ៏ប្រកបដោយសិរីល្អថ្មី ដែលនឹងមិនដែលចាស់ ឬចុះខ្សោយ ឬមានជំងឺទេ ។ ដោយបណ្ដាសាត្រូវបានដកចេញហើយនោះ ការបង្កើតទាំងអស់នឹងត្រឡប់ទៅជាសភាពដើមរបស់វាវិញ គឺជាសភាពមួយដែល “ល្អប្រពៃ” (លោក ១:៣១) ។

ជីវិតនៅក្នុងស្ថានសួគ៌ និងផែនដីថ្មី នឹងរួមបញ្ចូលទាំងការល្អជាច្រើន អំពីជីវិតនៅលើផែនដីនេះផងដែរ ។ ប៉ុន្តែការល្អនោះនឹងប្រសើរជាងគេ គឺពួកគេទាំងអស់គ្នា នឹងបរិភោគ ហើយផឹកនៅឯពិធីជប់លៀងអាពាហ៍ពិពាហ៍របស់កូនចៀម (វិវរ ១៩:៩) ។ នៅពេលមួយ ព្រះយេស៊ូវផឹកស្រាទំពាំងបាយជូរជាមួយពួកសិស្សរបស់ទ្រង់ (លូ ២២:១៨) ។ “ទន្លេទឹកជីវិត” នឹងហូរ “នៅកណ្ដាលផ្លូវក្រុងនោះ” ហើយ “ដើមជីវិត” នឹងបង្កើតផ្លែ១២ប្រភេទ គឺប្រភេទមួយៗសំរាប់ខែមួយៗ (វិវរ ២២:១-៣) ។

តន្ត្រី ពិតជាសំខាន់ណាស់នៅក្នុងការពិពណ៌នាពីនគរស្ថានសួគ៌នៅក្នុងគម្ពីរវិវរណៈ ។ វាហាក់ដូចជា តន្ត្រី និងសកម្មភាពសិល្បៈត្រូវបានប្រគំឡើងយ៉ាងល្អឥតខ្ចោះ ថ្វាយដល់សិរីល្អនៃព្រះ ។ មនុស្សនឹងប្រហែលជានៅតែបន្តមានអំណាចលើផែនដីនេះ ។ តាមរយៈមធ្យោបាយបច្ចេកវិទ្យា ច្នៃ ប្រឌិត និងបង្កើតថ្មី ធនធានដែលមាននៅផែនដីនេះ នឹងឆ្លុះបញ្ចាំងទាំងស្រុងពីការបង្កើតរបស់ពួកគេនៅក្នុងរូបអង្គទ្រង់ ។ ហើយទោះបីជាមនុស្សដែលមានរូបកាយថ្មី នឹងបានដូចជាព្រះក៏ដោយ

តែពួកគេនឹងមិនមែនជាព្រះទេ ។ ឧទាហរណ៍៖ យើងមិនមានចំណេះដឹងដែលឥតព្រំខណ្ឌទេ ប៉ុន្តែយើងនឹងបន្តរីកចំរើនពីចំណេះដឹងនៃព្រះរបូត ។ មានតែព្រះប៉ុណ្ណោះដែលឥតព្រំខណ្ឌ (កូល ១:១០) ។

នៅទីបញ្ចប់ ស្ថានសួគ៌ថ្មី និងផែនដីថ្មី នឹងជាកន្លែងមួយដែលយើងអាចពេញចិត្តទាំងស្រុងនឹង ទ្រព្យសម្បត្តិនៅឯស្ថានសួគ៌ (ម៉ាថ ៦:២០) ជាទ្រព្យសម្បត្តិដែលយើងបានប្រមូលទុកសំរាប់ខ្លួនយើង កំឡុងពេលដែលយើងមានជីវិតនៅលើផែនដី ។ នេះគឺជាការលើកទឹកចិត្តដ៏អស្ចារ្យមួយសំរាប់យើង ដើម្បី "ធ្វើការល្អដល់មនុស្សទាំងអស់ ហើយគិតដល់ពួកអ្នកជឿជាដើម" (កា ៦:១០) ។ ដូច្នេះ ក្នុងនាមជាអ្នកជឿព្រះយេស៊ូវ យើងគួរតែរស់នៅ "ក្នុងកិរិយាបរិសុទ្ធ និងសេចក្តីគោរពប្រតិបត្តិ" នៅខណៈពេលដែលយើងកំពុង "ទន្ទឹងចាំផ្ទៃមេឃថ្មី និងផែនដីថ្មី ដែលមានសុទ្ធតែសេចក្តីសុចរិត" (២ ពេ ៣:១១, ១៣) ។

## សិរីល្អដ៏ពិតប្រាកដនៃព្រះ

ស្ថានសួគ៌មិនគ្រាន់តែជាកន្លែងដ៏ស្អាតរកថ្លែងពុំបានប៉ុណ្ណោះទេ តែក៏ជាកន្លែងមួយដែលសិរីល្អពិតៗរបស់ព្រះត្រូវបានឃើញច្បាស់ ដែលការបង្កើតទាំងអស់នឹងបំពេញមុខងារនៅក្នុងរបៀបមួយ ដែលសហការយ៉ាងពេញលេញជាមួយនឹងបំណងព្រះហឫទ័យរបស់ទ្រង់ ។ ដូច្នេះលោកិយនឹងមិន "បាក់បែក" ទៀតទេ វានឹងដំណើរការ តាមការដែលវាគួរដំណើរការ ។ ហើយមនុស្សទាំងអស់នឹងមិនត្រូវបាន "បាក់បែក" ទៀតទេ ដ្បិតពួកគេនឹងធ្វើការ ហើយប្រព្រឹត្តិ ព្រមទាក់ទងគ្នា

តាមដែលពួកគេគួរធ្វើ ។ នឹងមិនមានការឈឺចាប់ ឬការសោកសង្រេង ការទុក្ខសោក ឬសោកនាដកម្មទៀតទេ ដ្បិតព្រះផ្ទាល់ទ្រង់នឹងគង់នៅក្នុងរាស្ត្ររបស់ទ្រង់ ។ "ព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែក ពីភ្នែកគេចេញ និងគ្មានសេចក្តីស្លាប់ ឬសេចក្តីសោកសង្រេង ឬសេចក្តីទួញយំ ឬទុក្ខលំបាកណាទៀតឡើយ ដ្បិតសេចក្តីមុនទាំងប៉ុន្មានបានកន្លងបាត់ទៅហើយ" (វិវរ ២១:៤) ។

ប៉ុន្តែកាន់តែគួរឲ្យរំភើបថែមទៀត ដែលការប្រកបរបស់ព្រះជាមួយនឹងយើងរាល់គ្នា នឹងមិនមានកំណត់ ។ យើងនឹងអាចមានទំនាក់ទំនងគ្នាទៅវិញទៅមកជាមួយទ្រង់ ហើយថ្វាយបង្គំទ្រង់ជារៀងរហូត ដ្បិតទ្រង់បានសូនយើងមកដើម្បីធ្វើយ៉ាងដូច្នោះ ។ ទីក្រុងនោះនឹងមិនត្រូវការពន្លឺ "ដ្បិតសិរីល្អនៃព្រះបានបំភ្លឺហើយ ឯកូនចៀមក៏ជាចង្កៀងនៃក្រុងនោះដែរ" (វិវរ ២១:២៣) ។ ការនេះនឹងជាការសំរេចជោគជ័យនៃបំណងព្រះហឫទ័យនៃព្រះ ដែលទ្រង់ត្រាស់ហៅយើងមក "ដោយសារសិរីល្អ និងសគុណរបស់ទ្រង់" (២ ពេ ១:៣) ។ យើងនឹងរស់នៅក្នុងវត្តមាននៃសិរីល្អរបស់ទ្រង់ជាមួយសេចក្តីអំណរដ៏អស្ចារ្យ (យូដ ២៤; ហើយសូមមើលគម្ពីររ៉ូម ៨:១៨; ១ កូរិន ១៥:៤៣; ២ កូរិន ៤:១៧; ១ ថែស ២:១២; ១ ពេ ៥:៤, ១០) ។

សេចក្តីដ៏អស្ចារ្យបំផុតរបស់យើង នឹងជាការដែលយើង "ឃើញព្រះភក្ត្រទ្រង់" (វិវរ ២២:៤) ។ ការឃើញព្រះភក្ត្ររបស់ព្រះ នឹងជាការសំរេចបាននូវអ្វីៗគ្រប់យ៉ាង ដែលយើងស្គាល់ថាល្អ ត្រឹមត្រូវ គួរឲ្យចង់បាននៅក្នុងចក្រវាឡនេះ ។ នៅក្នុងព្រះភក្ត្ររបស់ព្រះ យើងនឹងឃើញ ហើយមានបទពិសោធន៍នឹងការសំរេច

បាននូវគ្រប់ទាំងសេចក្ដីប្រាថ្នា ដែលយើងធ្លាប់មាន ដូចជា ការចង់ស្គាល់សេចក្ដីស្រឡាញ់ដ៏គ្រប់លក្ខណ៍ សេចក្ដីសុខសាន្តដ៏គ្រប់លក្ខណ៍ និងសេចក្ដីអំណរដ៏គ្រប់លក្ខណ៍ ដើម្បីឲ្យស្គាល់ពីសេចក្ដីពិត និងសេចក្ដីយុត្តិធម៌ ភាពបរិសុទ្ធ និងប្រាជ្ញា សេចក្ដីល្អ និងអំណាចព្រះចេស្ដា សិរីល្អ និងភាពលំអ ។ យើងនឹងរកឃើញថា នៅក្នុងព្រះវត្តមានរបស់ព្រះ "មានសេចក្ដីអំណរដ៏ពោរពេញ" នៅព្រះហស្តស្តាំទ្រង់ "មានសេចក្ដីអរសប្បាយជាដរាបតទៅ" (ទំនុក ១៦:១១) ។

## បញ្ជីសំនួររំលឹកសារឡើងវិញ និង ការប្រើប្រាស់ជាប្រយោជន៍

១. ចូររៀបរាប់អំពីការខ្លះ ដែលព្រះគម្ពីរបាននិយាយពីស្ថានសួគ៌ ។

២. តើការពិពណ៌នារបស់ព្រះគម្ពីរពីស្ថានសួគ៌ តាមរបៀបណាខ្លះដែលធ្វើឲ្យអ្នកភ្ញាក់ផ្អើល ? លើកទឹកចិត្តអ្នក ? ហើយធ្វើឲ្យអ្នកកាន់តែចង់បានស្ថានសួគ៌ថែមទៀត ?

៣. ចំណាយពេលបន្តិចដើម្បីអធិស្ឋាន និងអរព្រះគុណដល់ព្រះសំរាប់លក្ខណៈនានាអំពីនគរស្ថានសួគ៌ ។